គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ

សៀវភៅបណ្តុះបណ្តាល

ការកាត់បន្ថយគ្រោះថ្នាក់ដោយគ្រោះមហន្តរាយ

Training Manual on Disaster Risk Reduction

ឆ្នាំ២០១០

Copyright © NCDM 2010

ផ្តល់បច្ចេកទេសនិងរៀបចំដោយ : ឯកឧត្តម ប៉ុន ណារិទ្ធិ

អគ្គលេខាធិការរង គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ

ចូលរួមសហការប្រមូលឯកសារ : លោក ជុំ រ៉ុន្ធី, ប្រធានគ្រប់គ្រងគំរោងប្រចាំតំបន់ (ADPC)

លោក អុល សែន, អ្នកសំរបសំរួលកម្មវិធី (ADPC)

លោក ប៊ី ច័ន្ទតុលា, ជំនួយការគំរោង (ADPC)

លោក ហាក់ មិនា, អ្នកសំរបសំរួលការបណ្តុះបណ្តាល (NCDM)

ផ្តល់បច្ចេកទេសដោយ : សមាជិកវេទិកាកាត់បន្ថយគ្រោះภัយនៃគ្រោះមហន្តរាយ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ

សៀវភៅបណ្តុះបណ្តាល

ឆ្នាំ២០១០

អារម្ភកថា

គ្រោះមហន្តរាយកើតមានឡើង គឺវាធ្វើឱ្យសមិទ្ធិផលទាំងឡាយនៃការអភិវឌ្ឍ ត្រូវរលាយបាត់បង់ ហើយមនុស្ស និងប្រទេសជាតិ ត្រូវធ្លាក់ក្នុងភាពក្រីក្រ ដូច្នេះហើយបានជាក្របខ័ណ្ឌសកម្មភាពយោហ្គូ (HFA) បានបញ្ជាក់ថា ការកាត់បន្ថយគ្រោះภัយនៃគ្រោះមហន្តរាយ គឺជាបញ្ហាចំបងសម្រាប់នយោបាយអភិវឌ្ឍន៍ ហើយវាលើសពីនេះទៅទៀត វាក៏ជាផលប្រយោជន៍ដល់ផ្នែកវិទ្យាសាស្ត្រ មនុស្សធម៌ និងបរិស្ថានផងដែរ ។

រាជរដ្ឋាភិបាលកម្ពុជាដែលមាន **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ជាប្រមុខ និងជាប្រធានគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ បានដាក់ចេញនូវផែនការសកម្មភាពជាតិនៃយុទ្ធសាស្ត្រសម្រាប់ ការកាត់បន្ថយគ្រោះภัយនៃគ្រោះមហន្តរាយ ដើម្បីធ្វើជាផែនទីបង្ហាញផ្លូវ ឬជាគោលការណ៍ណែនាំសម្រាប់ពង្រឹង និងទទួលអនុវត្ត ការកាត់បន្ថយគ្រោះภัយនៃគ្រោះ មហន្តរាយនៅកម្ពុជា ។

សៀវភៅបណ្តុះបណ្តាលអំពី ការកាត់បន្ថយគ្រោះภัយនៃគ្រោះមហន្តរាយ ពិតជាបានរួមចំណែកមួយយ៉ាងសំខាន់ទៅនឹងផែនការសកម្មភាពជាតិ ដើម្បីផ្តល់ចំណេះដឹង និងការយល់ដឹងជាទូទៅ សំដៅកាត់បន្ថយភាពងាយរងគ្រោះរបស់ប្រជាជន ជាពិសេសប្រជាជនក្រីក្រ ដែលទទួលរងផលប៉ះពាល់ពីមុខសញ្ញាគ្រោះថ្នាក់ ដោយធម្មជាតិ ដោយបរិស្ថាន និងដោយមនុស្ស ។ មេរៀនទាំងឡាយដែលចងក្រងឡើង គឺបានបំពេញនូវតម្រូវការខ្វះខាតសម្រាប់ការបណ្តុះបណ្តាល ផ្តល់នូវចំណេះដឹងជាមូលដ្ឋាន សម្រាប់អ្នកពាក់ព័ន្ធអនុវត្តការងារគ្រប់គ្រងគ្រោះមហន្តរាយ អាចដកស្រង់យកទៅអនុវត្ត ស្របតាមតួនាទី ភារកិច្ច របស់ខ្លួន ។ លើសពីនេះផងដែរ ក៏ជាជំនួយបច្ចេកទេសសម្រាប់ ពង្រឹងសមត្ថភាព របស់សហគមន៍ និងបុគ្គលិក ដើម្បីយល់ដឹងពី ការកាត់បន្ថយគ្រោះภัយនៃគ្រោះមហន្តរាយ របស់ពួកគេ ។ ការពង្រឹងសមត្ថភាពមានប្រសិទ្ធភាពទៅបាន ក៏អាស្រ័យលើការទ្រទ្រង់ និងជ្រោមជ្រែងពីគ្រប់អ្នកពាក់ព័ន្ធលើការងារគ្រប់គ្រងគ្រោះ មហន្តរាយនោះដែរ ។

ខ្ញុំមានសេចក្តីរីករាយ ដើម្បីបង្ហាញនូវសៀវភៅបណ្តុះបណ្តាលអំពី ការកាត់បន្ថយគ្រោះภัយនៃគ្រោះមហន្តរាយ ជាមួយក្តីសង្ឃឹមថា មន្ត្រីពាក់ព័ន្ធការងារគ្រប់គ្រងគ្រោះមហន្តរាយ និងសហគមន៍មូលដ្ឋាន នឹងបង្កើនសមត្ថភាពបច្ចេកទេសដើម្បីកាត់បន្ថយគ្រោះภัយនៃគ្រោះមហន្តរាយ និងជួយដល់សហគមន៍ប្រឈមគ្រោះภัយ មានសមត្ថភាពទប់ទល់បានទៅនឹងមុខសញ្ញាគ្រោះថ្នាក់ដោយធម្មជាតិ ដើម្បីបង្កើតវប្បធម៌សុវត្ថិភាព និងការអភិវឌ្ឍប្រកបដោយចីរភាព ។

ខ្ញុំមានសុទិដ្ឋិនិយម ចំពោះកម្មវិធីកសាងសមត្ថភាពមន្ត្រីគ្រប់គ្រងគ្រោះមហន្តរាយ នឹងធ្វើឱ្យស្ថាប័នគ្រប់គ្រងគ្រោះមហន្តរាយមានការប្រែប្រួលថ្មី លើការគ្រប់គ្រងគ្រោះภัយនៃគ្រោះមហន្តរាយជាក់ជាមិនខាន ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០១០

បណ្ឌិត ញ៉ឹម ឌណ្ណា
ទេសរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេស
អនុប្រធានទី១ គ.ជ.គ.ម

តើការប្រើប្រាស់សៀវភៅបណ្តុះបណ្តាលដើម្បីអ្វី?

សៀវភៅនេះសម្រាប់ផ្តល់នូវចំណេះដឹងជាមូលដ្ឋាន ដល់មន្ត្រីគ្រប់អ្នកពាក់ព័ន្ធទាំងអស់លើការអនុវត្ត ការកាត់បន្ថយគ្រោះภัយ នៃគ្រោះមហន្តរាយ ហើយក៏សម្រាប់យកទៅដំណើរការ សិក្ខាសាលាបណ្តុះបណ្តាល លើការគ្រប់គ្រងគ្រោះภัយនៃគ្រោះមហន្តរាយ ដែលមានរចនាសម្ព័ន្ធនៃសៀវភៅដូចខាងក្រោម:

ជាប់ជាមួយនូវសកម្មភាពទៅនឹងការបើកសិក្ខាសាលាបណ្តុះបណ្តាលជាផ្លូវការ ដែលរួមបញ្ចូលកម្មវិធីបើកវគ្គ, ការណែនាំឱ្យស្គាល់នៃសិក្ខាកាមម្នាក់ៗ, សេចក្តីរំពឹងទុករបស់សិក្ខាកាមម្នាក់ៗ, ការពិភាក្សាលើគម្រោងការបណ្តុះបណ្តាល, កម្មវិធី និងគោលបំណងវគ្គ, កាលវិភាគ និងការសម្រុះសម្រួលមានរបៀបនៃបច្ចេកទេស ។

ផ្នែកទី ១: បរិយាយអំពីបទពិសោធន៍ ការគ្រប់គ្រងគ្រោះមហន្តរាយក្នុងប្រទេសកម្ពុជា ដែលទាក់ទងទៅនឹងស្ថានការណ៍គ្រោះមហន្តរាយជាតិ ព្រមជាមួយនោះក៏មានការពន្យល់យ៉ាងច្បាស់ផងដែរពី ទស្សនាទាន និងមធ្យោបាយ ក្នុងការគ្រប់គ្រងគ្រោះภัយនៃគ្រោះមហន្តរាយ ។

ផ្នែកទី ២: ពន្យល់ច្បាស់អំពីប្រព័ន្ធរដ្ឋាភិបាលថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ រចនាសម្ព័ន្ធ និងតួនាទី ការទទួលខុសត្រូវរបស់អ្នកពាក់ព័ន្ធក្នុងការគ្រប់គ្រងគ្រោះภัយនៃគ្រោះមហន្តរាយ ។

ផ្នែកទី ៣: ណែនាំបង្ហាញឧទាហរណ៍ និងដំណើរការក្នុងការដឹកនាំ ការចូលរួមប៉ាន់ប្រមាណគ្រោះภัយ ដែលរួមបញ្ចូលការប៉ាន់ប្រមាណមុខសញ្ញាគ្រោះថ្នាក់, ការប៉ាន់ប្រមាណភាពងាយរងគ្រោះ, ការប៉ាន់ប្រមាណសមត្ថភាព និងការយល់ដឹងរបស់ប្រជាជនអំពីគ្រោះภัយនៃគ្រោះមហន្តរាយ និងការចុះធ្វើការជាក់ស្តែងនៅមូលដ្ឋាន លើការប៉ាន់ប្រមាណគ្រោះภัយនៅសហគមន៍ ទាក់ទងទៅនឹងមេរៀននេះ ។

ផ្នែកទី ៤: ការនាំឱ្យស្គាល់ទៅនឹងវិធានការកាត់បន្ថយគ្រោះภัយនៃគ្រោះមហន្តរាយ និងពន្យល់អំពីវិធានការកាត់បន្ថយគ្រោះថ្នាក់ និងការត្រៀមរៀបចំ ដ៏មានសារៈសំខាន់នៃការកាត់បន្ថយគ្រោះภัយទឹកជំនន់, រាំងស្ងួត, ខ្យល់ព្យុះ និងសកម្មភាពគ្រប់គ្រងគ្រោះภัយនៃគ្រោះ មហន្តរាយ នៅថ្នាក់ខេត្ត-ស្រុក ។

ផ្នែកទី ៥: ពិភាក្សាអំពីសារៈសំខាន់ និងដំណើរការទាក់ទងទៅនឹងការបង្កើតផែនការកាត់បន្ថយគ្រោះภัយនៃគ្រោះមហន្តរាយ និងការញ្ជាបការកាត់បន្ថយគ្រោះภัយនៃគ្រោះមហន្តរាយ នៅក្នុងផែនការអភិវឌ្ឍ ។

ផ្នែកទី ៦: ណែនាំបង្ហាញនូវដំណើរការក្នុងការដឹកនាំ ការចូលរួមប៉ាន់ប្រមាណការខូចខាត និងសេចក្តីត្រូវការ ព្រមទាំងពន្យល់ច្បាស់អំពីទម្រង់ ដែលត្រូវបំពេញក្នុងការធ្វើសេចក្តីរាយការណ៍ ។

គម្រោងការបណ្តុះបណ្តាល

I. គោលដៅទូទៅ

ការបណ្តុះបណ្តាលគឺ មានបំណងដើម្បីឱ្យសិក្ខាកាម ដែលជាមន្ត្រីពាក់ព័ន្ធលើការងារគ្រប់គ្រងគ្រោះមហន្តរាយ មានចំណេះដឹង ជំនាញ ក្នុងការគ្រប់គ្រងគ្រោះภัយនៃគ្រោះមហន្តរាយ ។

II. គោលដៅជាក់លាក់

ពីការចាប់ផ្តើមរហូតដល់បញ្ចប់ការបណ្តុះបណ្តាលចំនួន ៥ថ្ងៃ សិក្ខាកាមនឹងអាចមានសមត្ថភាពដើម្បី :

១. កំណត់ច្បាស់នូវគ្រោះមហន្តរាយ មុខសញ្ញាគ្រោះថ្នាក់ ภาពងាយរងគ្រោះ សមត្ថภาព ការកាត់បន្ថយគ្រោះภัយនៃគ្រោះមហន្តរាយ និងចំណុចសំខាន់ៗនៃគ្រោះภัย

២. ពន្យល់បានអំពីការកាត់បន្ថយគ្រោះภัយនៃគ្រោះមហន្តរាយ និងដំណោះស្រាយការកាត់បន្ថយគ្រោះภัយនៃគ្រោះមហន្តរាយ

៣. ពន្យល់បាននូវប្រព័ន្ធគ្រប់គ្រងគ្រោះមហន្តរាយនៅគ្រប់ថ្នាក់ និងការទទួលខុសត្រូវរបស់ គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយ និងអ្នកពាក់ព័ន្ធ

៤. យល់ដឹងគោលការណ៍ជាមូលដ្ឋានត្រឹមត្រូវសម្រាប់ថ្នាក់ជាតិ ខេត្ត និងស្រុក លើការគ្រប់គ្រងគ្រោះภัយនៃគ្រោះមហន្តរាយ ក្រោមក្របខ័ណ្ឌការងារគ្រប់គ្រងគ្រោះภัយនៃគ្រោះមហន្តរាយ

៥. ស្រាយបំភ្លឺជំនាញក្នុងការត្រៀមរៀបចំសម្រាប់គ្រោះមហន្តរាយ និងការកាត់បន្ថយគ្រោះថ្នាក់

៦. ស្រាយបំភ្លឺជំនាញក្នុងការឆ្លើយតបគ្រោះអាសន្ន

៧. ស្រាយបំភ្លឺជំនាញក្នុងការរៀបចំជាក់លាក់នៃផែនការកាត់បន្ថយគ្រោះภัយនៃគ្រោះមហន្តរាយ ។

កាលវិភាគ និងគម្រោងការ

ថ្ងៃ.ខែ.ឆ្នាំ /	ប្រធានបទ / សកម្មភាព	វិធីសាស្ត្រ	បុគ្គលសំខាន់
ថ្ងៃទី ១	**សកម្មភាពបើកវគ្គ** -ចុះឈ្មោះសិក្ខាកាម -មតិស្វាគមន៍ -សន្ទរកថាបើក -ការពិនិត្យមើលសេចក្ដីរំពឹងមុន ការនាំខ្លួន -ការរៀបចំនៃបច្ចេកទេស **ផ្នែកទី ១** ១. ទស្សនាទានជាមូលដ្ឋាន ២. ការគ្រប់គ្រងគ្រោះមហន្តរាយ ៣. ស្ថានការណ៍គ្រោះមហន្តរាយ និង ការគ្រប់គ្រងគ្រោះមហន្តរាយនៅកម្ពុជា	**បទបង្ហាញ** **<u>ការបង្រៀន</u>** -សិក្ខាសាលាធ្វើការជាក្រុម និងធ្វើរបាយការណ៍	គ្រូសម្របសម្រួល
ថ្ងៃទី ២	**ផ្នែកទី ២** ១. គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ ២. គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយ រាជធានី-ខេត្ត ៣. គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយ ក្រុង-ស្រុក-ខ័ណ្ឌ ៤. គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយ ឃុំ-សង្កាត់	**<u>ការបង្រៀន</u>** -សិក្ខាសាលាធ្វើការជាក្រុម និងធ្វើរបាយការណ៍	គ្រូសម្របសម្រួល
ថ្ងៃទី ៣	**ផ្នែកទី ៣** ១. ការនាំឱ្យស្គាល់ទៅនឹងការប៉ាន់ប្រមាណគ្រោះภัយ ២. ការប៉ាន់ប្រមាណមុខសញ្ញាគ្រោះថ្នាក់ ៣. ការប៉ាន់ប្រមាណภาពងាយរងគ្រោះ និងសមត្ថภาព ៤. ការណែនាំការចុះធ្វើការងារជាក់ស្តែងអំពីការប៉ាន់ប្រមាណគ្រោះภัយ	**<u>ការបង្រៀន</u>** -សិក្ខាសាលាធ្វើការជាក្រុម និងធ្វើរបាយការណ៍	គ្រូសម្របសម្រួល

ថ្ងៃទី ៤	**ផ្នែកទី ៤** ១. ការនាំឱ្យស្គាល់ទៅនឹងវិធានការកាត់បន្ថយគ្រោះภัយនៃគ្រោះមហន្តរាយ ២. ការកាត់បន្ថយគ្រោះថ្នាក់ និងការត្រៀមរៀបចំសម្រាប់គ្រោះមហន្តរាយ ទឹកជំនន់ រាំងស្ងួត ខ្យល់ព្យុះ ៣. ការយល់ដឹងជាសាធារណៈ ៤. ប្រព័ន្ធប្រកាសឱ្យដឹងមុន ៥. ការឆ្លើយតបគ្រោះអាសន្ន និងការស្តារឡើងវិញ	**<u>ការបង្រៀន</u>** -សិក្ខាសាលាធ្វើការជាក្រុម និងធ្វើរបាយការណ៍	គ្រូសម្របសម្រួល
ថ្ងៃទី ៥	**ផ្នែកទី ៥** ១. សេចក្តីណែនាំស្តីពីការរៀបចំផែនការកាត់បន្ថយគ្រោះภัយនៃគ្រោះមហន្តរាយ ២. ទម្រង់គំរូ និងផែនការកាត់បន្ថយគ្រោះภัយនៃគ្រោះមហន្តរាយថ្នាក់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ៣. ការធ្វើសមាហរណកម្ម ផែនការកាត់បន្ថយគ្រោះภัយនៃគ្រោះមហន្តរាយ ទៅក្នុងផែនការអភិវឌ្ឍ ថ្នាក់ជាតិ រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ **ផ្នែកទី ៦** ១. ដំណើរការនៃការប៉ាន់ប្រមាណការខូចខាត និងសេចក្តីត្រូវការ	**<u>ការបង្រៀន</u>** -សិក្ខាសាលាធ្វើការជាក្រុម និងធ្វើរបាយការណ៍	គ្រូសម្របសម្រួល

មាតិកា

ផ្នែកទី ១: ស្ថានការណ៍គ្រោះមហន្តរាយ និង ការគ្រប់គ្រងគ្រោះមហន្តរាយនៅកម្ពុជា

មេរៀនទី ១: ទស្សនាទានជាមូលដ្ឋាន 01

I. **មុខសញ្ញាគ្រោះថ្នាក់** 01

II. **ភាពងាយរងគ្រោះ** 01

III. **គ្រោះមហន្តរាយ** 02

IV. **ទំនាក់ទំនងរវាងមុខសញ្ញាគ្រោះថ្នាក់ ភាពងាយរងគ្រោះ និង គ្រោះមហន្តរាយ** 02

១. ភាពងាយរងគ្រោះផ្នែកសំភារៈ និង រូបវន្ត 03

២. ភាពងាយរងគ្រោះផ្នែកសង្គម និង ស្ថាប័ន 04

៣. ភាពងាយរងគ្រោះផ្នែកចិត្តសាស្ត្រសង្គម 04

មេរៀនទី ២: ការគ្រប់គ្រងគ្រោះមហន្តរាយ 05

I. **អ្វីទៅការគ្រប់គ្រងគ្រោះមហន្តរាយ** 05

១. ការត្រៀមបង្ការគ្រោះមហន្តរាយ 05

២. ការកាត់បន្ថយគ្រោះថ្នាក់គ្រោះមហន្តរាយ 06

៣. ការត្រៀមរៀបចំសម្រាប់គ្រោះមហន្តរាយ 06

៤. ការឆ្លើយតប សង្គ្រោះបន្ទាន់ 06

៥. ការស្តារឡើងវិញ និងកសាងឡើងវិញ 07

មេរៀនទី ៣: ស្ថានការណ៍គ្រោះមហន្តរាយ និងការគ្រប់គ្រងគ្រោះមហន្តរាយនៅកម្ពុជា 08

I. **គោលបំណងរួម** 08

II. **ស្ថានការណ៍គ្រោះមហន្តរាយ និង ការគ្រប់គ្រងគ្រោះមហន្តរាយនៅកម្ពុជា** 08

១. ប្រវត្តិគ្រោះមហន្តរាយ និង មុខសញ្ញាគ្រោះថ្នាក់នៅកម្ពុជា 08

១.១ គ្រោះទឹកជំនន់ 09

១.២ គ្រោះរាំងស្ងួត 11

១.៣ ជម្ងឺរាតត្បាត 14

១.៤ ខ្យល់ព្យុះ 15

១.៥ ភ្លើងឆេះព្រៃ និងអគ្គីភ័យ 22

១.៦ ការប្រែប្រួលអាកាសធាតុ 23

១.៧ មុខសញ្ញាគ្រោះថ្នាក់ដោយបច្ចេកវិទ្យា និង មនុស្ស 23
១.៨ ភាពងាយរងគ្រោះ 25
III. **ឯកសារយោង** 26

ផ្នែកទី ២: ក្របខ័ណ្ឌការងារគ្រប់គ្រងគ្រោះមហន្តរាយនៅកម្ពុជា

មេរៀនទី ១: គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ 27
I. **គោលបំណងរួម** 27
II. **ខ្លឹមសារមេរៀន** 27
១. សមាសភាពនៃគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ 27
២. បេសកកម្ម 28
៣. មុខងារ ភារកិច្ច និង ការទទួលខុសត្រូវ 28
៤. រចនាសម្ព័ន្ធគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ 29
៤.១ ខុទ្ទកាល័យប្រធានគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ 29
៤.២ អគ្គលេខាធិការដ្ឋាន 29

មេរៀនទី ២: គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយរាជធានី-ខេត្ត 32
I. **គោលបំណងរួម** 32
II. **ខ្លឹមសារមេរៀន** 32
១. សមាសភាព 32
២. បេសកកម្ម 32
៣. រចនាសម្ព័ន្ធ 32
៣.១ លេខាធិការដ្ឋាន 33
៣.២ ក្រុមប្រតិបត្តិការគណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយរាជធានី-ខេត្ត 33
៤. មុខងារ និងការកិច្ចរួម របស់គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយរាយរាជធានី-ខេត្ត 36
III. **ឯកសារយោង** 36

មេរៀនទី ៣: គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយក្រុង-ស្រុក-ខ័ណ្ឌ 37
I. **គោលបំណងរួម** 37
II. **ខ្លឹមសារមេរៀន** 37
១. សមាសភាព 37

២. លេសកកម្ម 37

៣. រចនាសម្ព័ន្ធ 37

៣.១ លេខាធិការដ្ឋាន 38

៣.២ ក្រុមប្រតិបត្តិការ គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយ ស្រុក-ខ័ណ្ឌ 38

៤. មុខងារ និង ភារកិច្ចរួមរបស់គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយក្រុង-ស្រុក-ខ័ណ្ឌ 41

III. **ឯកសារយោង** 42

មេរៀនទី ៤: គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយ ឃុំ-សង្កាត់ 43

I. **គោលបំណងរួម** 43

II. **ខ្លឹមសារមេរៀន** 43

១. សមាសភាព 43

២. លេសកកម្ម 43

៣. រចនាសម្ព័ន្ធ 44

៤. តួនាទី ការទទួលខុសត្រូវរបស់ប្រធាន អនុប្រធាន លេខាធិការដ្ឋាន និងក្រុមប្រតិបត្តិការ 44

៤.១ ប្រធាន 44

៤.២ អនុប្រធាន 45

៤.៣ លេខាធិការដ្ឋាន 45

៤.៤ ក្រុមសន្តិសុខ និងរុករកសង្គ្រោះ 45

៤.៥ ក្រុមសុខភាព និង អនាម័យ 46

៤.៦ ក្រុមឆ្លើយតប និងព័ត៌មាន 47

៤.៧ មុខងារ និង ភារកិច្ចរបស់គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយឃុំ-សង្កាត់ 47

III. **ឯកសារយោង** 48

ផ្នែកទី ៣: ការចាត់ប្រមាណគ្រោះภัយបែបចូលរួម

មេរៀនទី ១: ការនាំឱ្យស្គាល់ទៅនឹងការចាត់ប្រមាណគ្រោះภัយ 49

I. **គោលបំណងរួម** 49

II. **តើការចាត់ប្រមាណគ្រោះภัយ (RA) ជាអ្វី?** 49

III. **តើការចាត់ប្រមាណគ្រោះภัយដោយមានការចូលរួមនៅតាមសហគមន៍ជាអ្វី?** 49

IV. **ជំហាននៃការចាត់ប្រមាណគ្រោះภัយដោយមានការចូលរួមនៅតាមសហគមន៍** 50

១. ការជ្រើសរើសសហគមន៍ 50

១.១ លក្ខខ័ណ្ឌនៅក្នុងការជ្រើសរើសសហគមន៍ 50
១.២ លក្ខខ័ណ្ឌយេនឌ័រនៅក្នុងការជ្រើសរើសសហគមន៍ 50
២. ដំណើរកាត់ទទឹង 51
២.១ តើគំនូសកាត់ទទឹងជាអ្វី? 51
២.២ ការរៀបចំផែនទីសង្គមកិច្ច 53
៣. ការប្រមូលព័ត៌មាន និងការបញ្ជាក់ពីកាលបរិច្ឆេទបន្ទាប់ 54
៣.១ វិធីសាស្ត្របញ្ជាក់ពីព័ត៌មានបន្ទាប់ដែលពាក់ព័ន្ធ 55
៣.២ វិធីសាស្ត្រ 55
៣.៣ ដំណើរការ 55

មេរៀនទី ២: ការចាំ១ប្រមាណពីមុខសញ្ញាគ្រោះថ្នាក់ 57
I. **តើការចាំ១ប្រមាណពីមុខសញ្ញាគ្រោះថ្នាក់ គឺជាអ្វី?** 57
II. **ការគូសផែនទីមុខសញ្ញាគ្រោះថ្នាក់** 58
១. គោលបំណង 58
២. វិធីសាស្ត្រ 58
៣. ជំហាននៅក្នុងការគូសផែនទីមុខសញ្ញាគ្រោះថ្នាក់ 58
៤. កិច្ចការក្រុម 59
III. **កំនត់ចំណាំលើបញ្ហាយេនឌ័រ** 60
IV. **ទំរង់មុខសញ្ញាគ្រោះថ្នាក់** 61
V. **តារាងម៉ាទ្រិច ស្តីពីការខូចខាត និង វិសាលភាព** 62

មេរៀនទី ៣: ការចាំ១ប្រមាណភាពងាយរងគ្រោះ និងសមត្ថភាព 63
I. **ការចាំ១ប្រមាណពីភាពងាយរងគ្រោះ** 63
១. សមាសភាគគ្រោះថ្នាក់ 64
២. តើសមាសភាគគ្រោះថ្នាក់ ជាអ្វី? 64
៣. ប្រភេទនៃភាពងាយរងគ្រោះ 64
៣.១ ការគូរផែនទីភាពងាយរងគ្រោះ 65
៤. ជំហានក្នុងការកំណត់ពីភាពងាយរងគ្រោះដែលពាក់ព័ន្ធនឹងទំរង់សំពាធ និងបញ្ជ្រៀស (PAR model) 65
៤.១ ដំណាក់កាលទី ១: សមាសភាគគ្រោះថ្នាក់ 66
៤.២ ដំណាក់កាលទី ២: លក្ខខ័ណ្ឌគ្មានសុវត្ថិភាព 66
៤.៣ ដំណាក់កាលទី ៣: អានុភាពចម្បងៗ 67

៤.៤ ដំណាក់កាលទី ៤: មូលហេតុគ្រឹះនៃភាពងាយរងគ្រោះ 67
៥. ការផ្តល់អាទិភាពលើភាពងាយរងគ្រោះ 67
II. **ការប៉ាន់ប្រមាណពីសមត្ថភាព** 68
១. តើអ្វីជាសមត្ថភាព? 69
២. ការប៉ាន់ប្រមាណពីសមត្ថភាព: ប្រភេទនៃការវិភាគ 69
៣. ជំហានក្នុងការកំណត់ពីភាពងាយរងគ្រោះដែលពាក់ព័ន្ធនឹងទំរង់សំពាធ និងបញ្ជ្រៀស (PAR model) 69
៣.១ ដំណាក់កាលទី ១: សមាសភាគដែលត្រូវការពារ 70
៣.២ ដំណាក់កាលទី ២: ការកំនត់ពីលក្ខខ័ណ្ឌសុវត្ថិភាព 70
៣.៣ ដំណាក់កាលទី ៣: អានុភាពចំបងៗដែលបានបញ្ជ្រៀស 70
៣.៤ ដំណាក់កាលទី ៤: ការកំនត់ពីមូលហេតុគ្រឹះជាវិជ្ជមាន 71
៤. ការផ្តល់អាទិភាពលើសមត្ថភាព 71

មេរៀនទី ៤: ការណែនាំការចុះធ្វើការងារជាក់ស្តែងអំពីការចាន់ប្រមាណគ្រោះภัយ 72
I. **ជំរើសការងារលើការកាត់បន្ថយគ្រោះภัយ** 73
១. ប្រតិទិនរដូវកាល 73
២. ប្រតិទិនរដូវកាលនៃការចិញ្ចឹមជីវិត 74
២.១ គោលបំណង 74
២.២ វិធីសាស្ត្រ 74
២.៣ ដំណើរការ 74
៣. ប្រតិទិនរដូវកាលនៃមុខសញ្ញាគ្រោះថ្នាក់ 75
៣.១ គោលបំណង 75
៣.២ វិធីសាស្ត្រ 75
៣.៣ ដំណើរការ 75
៤. ការវិភាគរកហេតុផល 76
៤.១ គោលបំណង 76
៤.២ វិធីសាស្ត្រ 76
៤.៣ ដំណើរការ 76
II. **ភាពជាក់លាក់នៃជំរើសការងារលើការកាត់បន្ថយគ្រោះภัយ** 77
១. ផ្នែកនៃជំរើសលើការកាត់បន្ថយគ្រោះภัយ និងអាទិភាពគ្រប់គ្រង 77
១.១ គោលបំណង 77

១.២ វិធីសាស្ត្រ 77

១.៣ ដំណើរការ 77

២. ជំរើសការងារលើការកាត់បន្ថយគ្រោះภัย 78

៣. ការវិភាគពីផលប៉ះពាល់នៃជំរើសលើការកាត់បន្ថយគ្រោះภัย 79

៣.១ គោលបំណង 79

៣.២ វិធីសាស្ត្រ 79

៣.៣ ដំណើរការ 79

៤. យុទ្ធសាស្ត្រអនុវត្តជំរើសការងារ 80

៤.១ គោលបំណង 80

៤.២ វិធីសាស្ត្រ 80

៤.៣ ដំណើការ 80

III. **កិច្ចប្រជុំនៅតាមសហគមន៍ : មតិទូទៅលើជំរើស** 81

១. មតិទូទៅរវាងដៃគូអនុវត្តបឋម និងបន្ទាប់ លើជំរើសការងារដែលបានលើកឡើង 81

១.១ គោលបំណង 81

១.២ វិធីសាស្ត្រ 81

១.៣ ដំណើរការ 81

បញ្ជីសំរង់ព័ត៌មានពីគ្រោះภัយនៃគ្រោះមហន្តរាយ 82

IV. **ប្រភពឯកសារ** 94

ផ្នែកទី ៤: វិធានការកាត់បន្ថយគ្រោះภัយនៃគ្រោះមហន្តរាយ

មេរៀនទី ១: ការនាំឱ្យស្គាល់ទៅនឹងវិធានការកាត់បន្ថយគ្រោះภัយនៃគ្រោះមហន្តរាយ 95

ក. មុខសញ្ញាគ្រោះថ្នាក់ (Hazard) 95

ខ. សមត្ថភាព 95

I. **ការត្រៀមបង្ការគ្រោះមហន្តរាយ** 98

II. **ការកាត់បន្ថយគ្រោះថ្នាក់** 98

១. វិធីសាស្ត្រកាត់បន្ថយគ្រោះថ្នាក់ទឹកជំនន់ 99

២. ការកាត់បន្ថយគ្រោះថ្នាក់ទឹកជំនន់របស់អាគារ ឬអង្គភាពនីមួយៗ 99

៣. វិធីសាស្ត្រកាត់បន្ថយគ្រោះថ្នាក់កន្លែងផ្សេងទៀត 101

III. **ការត្រៀមរៀបចំសម្រាប់គ្រោះមហន្តរាយ** 101

១. ការកំនត់ទំនាបទឹកលិច 101

២. ការកសាងសមត្ថភាព និងការលើកកំពស់ចំណេះដឹង និងការអនុវត្តន៏ក្នុងស្រុក 102

៣. ការលើកកំពស់ការយល់ដឹងជាសាធារណៈ 103

មេរៀនទី ២: ការកាត់បន្ថយគ្រោះថ្នាក់ និងការត្រៀមរៀបចំសម្រាប់គ្រោះមហន្តរាយ ទឹកជំនន់ រាំងស្ងួត ខ្យល់ព្យុះ 104

I. **ការលើកកំពស់ការយល់ដឹងជាសាធារណៈ** 104

II. **វិធីសាស្ត្រលើកកំពស់ការយល់ដឹងជាសាធារណៈ** 104

III. **ការបង្កើតប្រព័ន្ធសំរាប់ការផ្សព្វផ្សាយការព្យាករណ៏ និងការប្រកាសអាសន្ន** 106

IV. **ផែនការជំលៀស និងគ្រប់គ្រងទីជំរកបណ្តោះអាសន្ន** 109

V. **ការធ្វើផែនការស្វែងរក និងសង្គ្រោះ** 110

VI. **ការធ្វើផែនការទឹកស្អាត អនាម័យ និងការថែទាំសុខភាព** 110

VII. **ការធ្វើផែនការជីវភាពរស់នៅ** 112

VIII. **លំហាត់ "ហ្វឹកហ្វឺន Drills" និងសមយុទ្ធ "ធ្វើត្រាប់ Mock"** 113

មេរៀនទី ៣: ការយល់ដឹងជាសាធារណៈ 114

I. **គោលបំណង** 114

II. **ខ្លឹមសារមេរៀន** 114

១. និយមន័យ 114

២. គោលបំណងនៃការផ្សព្វផ្សាយការយល់ដឹងជាសាធារណៈ 115

៣. លក្ខណៈនៃការផ្សព្វផ្សាយការយល់ដឹងជាសាធារណៈ 115

៤. កត្តាសំខាន់ៗ សំរាប់ទំនាក់ទំនងប្រកបដោយប្រសិទ្ធភាព 115

៥. មធ្យោបាយសំរាប់ផ្សព្វផ្សាយលើកកំពស់ការយល់ដឹងជាសាធារណៈ 116

៦. តួនាទី និងការទទួលខុសត្រូវសំខាន់ៗក្នុងការផ្សព្វផ្សាយលើកកំពស់ការយល់ដឹងជាសាធារណៈ 117

មេរៀនទី ៤: ប្រព័ន្ធប្រកាសឱ្យដឹងមុន (Early Warning System) 119

I. **គោលបំណង** 119

II. **ខ្លឹមសារមេរៀន** 119

១. និយមន័យ 119

២. សារៈសំខាន់នៃប្រព័ន្ធប្រកាសឱ្យដឹងមុន 119

៣. ផ្នែកផ្សេងៗនៃប្រព័ន្ធប្រកាសឱ្យដឹងមុន 119

៣.១ ការកំនត់ និងការព្យាករណ៍ពីមុខសញ្ញាគ្រោះថ្នាក់ 120
៣.២ ការគណនា ឬរៀបចំពត៌មានសំរាប់ធ្វើការប្រកាសឱ្យដឹងមុន 120
៣.៣ ការផ្សព្វផ្សាយព័ត៌មានព្យាករណ៍ និងព័ត៌មានប្រកាសឱ្យដឹងមុន 121
៣.៤ ការឆ្លើយតបរបស់សហគមន៍ 122
៣.៥ តួនាទី និងការទទួលខុសត្រូវរបស់ស្ថាប័ន និងភ្នាក់ងារពាក់ព័ន្ធនៅក្នុងប្រព័ន្ធប្រកាសឱ្យដឹងមុន ... 122
៤. ទម្រង់បញ្ជូនការប្រកាសឱ្យដឹងមុន 126
៥. ចំណុចសំខាន់ៗ មុនចេញផ្សព្វផ្សាយពត៌មានព្យាករណ៍ និងពត៌មានប្រកាសភាពអាសន្ន 126

មេរៀនទី ៥: ការឆ្លើយតបគ្រោះអាសន្ន និងការស្តារឡើងវិញ 128
I. **ការឆ្លើយតប សង្គ្រោះបន្ទាន់** 128
១. ការតាមដានមុខសញ្ញាគ្រោះថ្នាក់ 129
២. ការព្យាករណ៍ និងការប្រកាសឱ្យដឹងមុន 130
៣. ប្រតិបត្តិការជំលៀស 130
៤. តំបន់សុវត្ថិភាព និងការគ្រប់គ្រងជំរកបណ្តោះអាសន្ន 130
៥. ប្រតិបត្តិការស្វែងរក និង សង្គ្រោះ 131
៦. ការថែទាំសុខភាព និង ប្រតិបត្តិការផ្នែកសុខាភិបាល 131
៧. ការប៉ាន់ប្រមាណរហ័សអំពីការខូចខាត និងតំរូវការ 132
៨. ការសំរបសំរួល និងការគ្រប់គ្រងជំនួយសង្គ្រោះ 132
II. **ការស្តារ និងការកសាងឡើងវិញ** 133
១. ការប៉ាន់ប្រមាណការខូចខាតក្រោយពេលគ្រោះមហន្តរាយ 134
២. ការសំអាតបរិស្ថាន 135
៣. ការស្តារហេដ្ឋារចនាសម្ព័ន្ធជាមូលដ្ឋានឡើងវិញ 136

ផ្នែកទី ៥: ផែនការកាត់បន្ថយគ្រោះภัយនៃគ្រោះមហន្តរាយ

មេរៀនទី ១: សេចក្តីណែនាំស្តីពីការរៀបចំផែនការកាត់បន្ថយគ្រោះภัយនៃគ្រោះមហន្តរាយ 139
I. **ទិដ្ឋភាពរួម** 139
II. **គោលបំណងជំពូក** 139
III. **ការធ្វើផែនការកាត់បន្ថយគ្រោះภัយនៃគ្រោះមហន្តរាយគឺជាអ្វី?** 139
១. គោលគំនិតសំខាន់ៗ 139
២. ផ្នែកសំខាន់ៗនៃផែនការកាត់បន្ថយគ្រោះภัយនៃគ្រោះមហន្តរាយ 140

៣. តើការធ្វើផែនការកាត់បន្ថយគ្រោះภัយនៃគ្រោះមហន្តរាយមានប្រយោជន៍អ្វីខ្លះ? 141

IV. **ការរៀបចំកំរងឯកសារថ្នាក់ខេត្ត និងស្រុក** 142

១. ទិដ្ឋภาពរួម 142

២. គោលបំណង 142

៣. គោលគំនិតសំខាន់ៗ 143

៤. ផ្នែកសំខាន់ៗនៃសារវិតាខេត្ត-ស្រុក 143

៥. សំណួរសំរាប់ពិចារណា 144

V. **ការប៉ាន់ប្រមាណគ្រោះថ្នាក់ ภาពងាយรงគ្រោះ និងសមត្ថภาព** 144

១. ទិដ្ឋภาពรวม 144

២. គោលបំណង 145

៣. គោលគំនិតសំខាន់ៗ 145

៤. ផ្នែកសំខាន់នៃการប៉ាន់ប្រមាណមុខสญญาគ្រោះថ្នាក់ ภาពงายรงគ្រោះ និងสมตฺภาพ (HVCA) 148

៤.១ การป๊าน่ประมาณมุขสญญาคโระถ្នาก់ 148

៤.២ การป๊าน่ประมาณลือ ภาพงายรงคโระ 149

៤.៣ การป๊าน่ประมาณสมตฺภาพ 153

៥. សំណួរសំរាប់ពិចារណា 154

VI. **យន្តការស្ថាប័ន និង អង្គការពាក់ពន្ធ័ សំរាប់ការកាត់បន្ថយគ្រោះภัយនៃគ្រោះมหาน្ត្ររาย** 154

១. ទិដ្ឋภาពรวม 154

២. គោលបំណង 154

៣. គោលគំនិតសំខាន់ៗ 155

៤. ការวิภาคអ្នកពាក់ព័ន្ធ និងផលប្រយោជន៍សំខាន់ៗនៃការចូលรวมรบส់អ្នกพาก់ព័ន្ធ 156

៥. នរណាខ្លះជាអ្នกพาก់ព័ន្ធនៅក្នុងการธ្ធើផែนการกาต่บน្ថយคโระภัยនៃคโระมหาน្ត្ররาย? 156

៦. សំណួរសំរាប់ពិចារណា 159

VII. **ឯกสารยองรบส់ស្ថาบัน สำหรับธ្ធើផែนการត្រៀมบงการทีกชื่นน่** 159

១. ទិដ្ឋภาពรวม 159

២. គោលបំណង 159

៣. គោលគំនិតសំខាន់ៗ 159

៤. ផ្នែกสำคัญនៃតើឯกสายองรบส់ស្ថาบัน คือ ជ្ធ? 160

៥. ហេតុអ្ធ្ធីបានជ្ធាឯกสารยองรบส់ស្ថาบันมานสาระสำคัญ? 160

៦. និតិវិធីប្រតិบัติการสูงสุด SOP 160

៧. សំណួរសំរាប់ការពិចារណា 167

មេរៀនទី ២: ទំរង់គំរូ និងផែនការកាត់បន្ថយគ្រោះภัយនៃគ្រោះមហន្តរាយថ្នាក់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ 168

I. **គោលបំណងរួម** 168

II. **ខ្លឹមសារមេរៀន** 168

១. ព័ត៌មាន/ទិន្នន័យសំខាន់ៗសំរាប់រៀបចំផែនការត្រៀមបង្ការគ្រោះមហន្តរាយ 168

១.១ មាតិកា 168

១.២ អារម្ភកថា 168

១.៣ ក្រុមការងារ 168

១.៤ សេចក្ដីផ្ដើម 169

១.៥ ទិន្នន័យទូទៅរបស់ខេត្ត ឬ ស្រុក 170

១.៦ ផែនការសកម្មភាពសំរាប់ការកាត់បន្ថយគ្រោះภัយនៃគ្រោះមហន្តរាយ 175

១.៧ យន្តការស្ថាប័ន និង ការគ្រប់គ្រងគ្រោះមហន្តរាយ 175

១.៨ ផែនការសកម្មភាពរបស់មន្ទីរ-អង្គភាព ឬការិយាល័យជុំវិញខេត្ត/ស្រុក 175

១.៩ ឯកសារភ្ជាប់/ឧបសម្ព័ន្ធផ្សេងៗ 179

III. **ឯកសារយោង** 179

មេរៀនទី ៣: ការធ្វើសមាហរណកម្មផែនការកាត់បន្ថយគ្រោះภัយនៃគ្រោះមហន្តរាយទៅក្នុងផែនការអភិវឌ្ឍថ្នាក់ជាតិ រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ 180

I. **ទិដ្ឋភាពរួម** 180

II. **គោលបំណង** 180

III. **គោលគំនិតសំខាន់ៗ** 180

IV. **ឧបសគ្គធំៗនៃការធ្វើសមាហរណកម្ម** 182

V. **ឯកសារពិគ្រោះ** 183

ផ្នែកទី ៦: ការចាត់ប្រមាណការខូចខាត និងសេចក្ដីត្រូវការ

មេរៀនទី ១: ដំណើរការនៃការចាត់ប្រមាណការខូចខាត និងសេចក្ដីត្រូវការ 185

I. **គោលបំណង** 185

II. **ខ្លឹមសារមេរៀន** 185

១. ទស្សនទានពីការប៉ាន់ប្រមាណការខូចខាត និង សេចក្ដីត្រូវការ 185
២. ដំណើរការប៉ាន់ប្រមាណលើការខូចខាត និង សេចក្ដីត្រូវការ 186
២.១ ការបង្កើតក្រុមប៉ាន់ប្រមាណ (Formation of the Assessment Team)..... 186
២.២ ជំហាននៃការប៉ាន់ប្រមាណ (Steps of Assessment) 186
២.៣ វិធីនៃការរៀបចំនិងអនុវត្តលើការប៉ាន់ប្រមាណពីការខូចខាត និងសេចក្ដីត្រូវការ..... 188
៣. ការប៉ាន់ប្រមាណការខូចខាត និងតម្រូវការតាមផ្នែក 188
៣.១ ការប៉ាន់ប្រមាណសង្គ្រោះបន្ទាន់អំពីសុខភាព 188
៣.២ ការប៉ាន់ប្រមាណអំពីទឹក និងអនាម័យ 192
៣.៣ ការប៉ាន់ប្រមាណអំពីស្បៀង និងអាហារូបត្ថម្ភ 195
III. **ទំរង់របាយការណ៍ផ្សេងៗសំរាប់ប្រើប្រាស់ក្នុងការប៉ាន់ប្រមាណលើការខូចខាតនិងសេចក្ដីត្រូវការ** 197
IV. **ឯកសារយោង**..... 197

ឯកសារបណ្តុះបណ្តាល

ផ្នែកទី ១

ស្ថានការណ៍គ្រោះមហន្តរាយ និង ការគ្រប់គ្រងគ្រោះមហន្តរាយ នៅកម្ពុជា

មេរៀនទី ១: ទស្សនាទានជាមូលដ្ឋាន

I. មុខសញ្ញាគ្រោះថ្នាក់

> មុខសញ្ញាគ្រោះថ្នាក់ គឺជាបាតុភូត សារធាតុ សកម្មភាពរបស់មនុស្ស ឬជាលក្ខខណ្ឌដែលមានគ្រោះថ្នាក់ដែលជាហេតុធ្វើឱ្យ បាត់បង់ ជីវិត របួស ប៉ះពាល់ដល់សុខភាព ខូចខាតទ្រព្យសម្បត្តិ បាត់បង់ជីវភាពរស់នៅ សេវាកម្ម រំខានដល់សង្គម សេដ្ឋកិច្ច និងបង្ក ខូចខាតបរិស្ថាន។

មុខសញ្ញាគ្រោះថ្នាក់ខ្លះកើតឡើងដោយសារធម្មជាតិដូចជា ទឹកជំនន់ រាំងស្ងួត ខ្យល់ព្យុះទីហ្វុង ការរញ្ជួយដី និងបន្ទុះភ្នំភ្លើង ជាដើម។ ទន្ទឹមនេះមុខសញ្ញាគ្រោះថ្នាក់មួយចំនួន បង្កដោយមនុស្ស ដូចជា: ការកើនឡើងជាតិពុលក្នុងបរិស្ថាន ការកាប់បំផ្លាញព្រៃឈើ សង្គ្រាមស៊ីវិល ជាតិគីមី បច្ចេកវិទ្យាជាដើម។

ការបែងចែកឱ្យបានដាច់ដោយឡែកពីគ្នានូវមុខសញ្ញាគ្រោះថ្នាក់ដោយធម្មជាតិ និងបង្ក ដោយមនុស្ស គឺមានការលំបាក និងស្មុគស្មាញ។ **<u>ឧទាហរណ៍</u>**: ការកាប់បំផ្លាញព្រៃឈើដោយ ខុសច្បាប់ ក៏ជាហេតុបណ្តាលឱ្យមានស្ថានភាពគ្រោះទឹកជំនន់ កាន់តែធ្ងន់ធ្ងរផងដែរ និង ជួនកាលវាបណ្តាលឱ្យមានគ្រោះមហន្តរាយ ដោយការបាក់រអិលផ្ទាំងដី ទៀតផង។ តែទោះជាយ៉ាងណា មុខសញ្ញាគ្រោះថ្នាក់ខ្លួនវាផ្ទាល់មិនមែនជាគ្រោះមហន្តរាយនោះទេ មុខសញ្ញាគ្រោះថ្នាក់នឹងក្លាយ ទៅជាគ្រោះមហន្តរាយបាន ដរាបណាវាបានបង្កឱ្យមានផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរ និងបានបង្កឱ្យមាន ការខូចខាត ទ្រព្យសម្បត្តិ និងជីវភាពរស់នៅរបស់មនុស្ស ក្នុងសហគមន៍ ។

II. ភាពងាយរងគ្រោះ

> ភាពងាយរងគ្រោះ គឺជាលក្ខខណ្ឌដែលកំណត់ដោយកត្តារូបវន្ត សង្គម សេដ្ឋកិច្ច បរិស្ថាន ឬជាដំណើរការដែលបង្កើនភាពចុះខ្សោយ របស់សហគមន៍ទៅនឹងផលប៉ះពាល់នៃមុខសញ្ញាគ្រោះថ្នាក់ ។

គ្រួសារ និងសហគមន៍អាចក្លាយជាភាពងាយរងគ្រោះ នៅពេលដែលគេកំពុងប្រឈមមុខនឹងមុខសញ្ញាគ្រោះថ្នាក់ដែលមាន ហើយអាចនឹងទទួលរងគ្រោះដោយសារមុខសញ្ញាគ្រោះថ្នាក់នោះទៀតផង នៅពេលដែលវាកើតឡើង។ តែស្ថានភាពងាយរងគ្រោះ នេះ គឺមិនមានលក្ខណៈដូចៗគ្នានោះទេពីម្នាក់ទៅម្នាក់ ។ **<u>ឧទាហរណ៍</u>** គ្រួសារដែលរស់នៅតាមមាត់ទន្លេ គឺងាយរងគ្រោះចំពោះ មុខសញ្ញាគ្រោះថ្នាក់ជាក់លាក់(ទឹកជំនន់) តែចំពោះគ្រួសារដែលរស់នៅតំបន់ទីទួល គឺមិនងាយរងគ្រោះ ដោយសារទឹកជំនន់ទេ ។

គ្រួសារ ឬ សហគមន៍ អាចនឹងមានស្ថានភាពងាយរងគ្រោះផ្សេងៗគ្នាជាច្រើន ។ ចំពោះគ្រួសារដែលរស់នៅតាមតំបន់ មាត់ទន្លេ គឺជាឧទាហរណ៍មួយអំពីភាពងាយរងគ្រោះផ្នែករូបវន្ត(រូបរាង) ។ សហគមន៍ នឹង កាន់តែងាយរងគ្រោះផ្នែកសង្គមកាន់ តែខ្លាំងនៅពេលដែលមិនមានការដឹកនាំ ឬ គ្មានការសហការគ្នារវាងអ្នកមានទីលំនៅក្នុងសហគមន៍ ព្រោះថាគេមិនអាចជួយគ្នា បាននៅពេលមានគ្រោះមហន្តរាយកើតឡើង ។ សកម្មភាពប្រកបមុខរបរចិញ្ចឹមជីវិតមួយចំនួន អាចនឹងងាយទទួលរងផលប៉ះពាល់

ដោយសារគ្រោះមហន្តរាយជាងសកម្មភាពផ្សេងៗទៀត នៅក្នុងសហគមន៍ដែលបណ្តាលឱ្យមានភាពងាយរងគ្រោះផ្នែកសេដ្ឋកិច្ច ។

សង្គម សហគមន៍ រចនាសម្ព័ន្ធ សេវាកម្មទាំងឡាយ ឬសកម្មភាពផ្សេងៗទៀតដែលងាយរងគ្រោះ ត្រូវបានគេហៅម្យ៉ាងទៀតថាជា **"ការប្រឈមគ្រោះថ្នាក់ Exposure"** យើងគួរកត់សំគាល់ផងដែរ ភាពងាយរងគ្រោះ គឺតែងតែប្រែប្រួល និងផ្លាស់ប្តូរពីពេលមួយទៅពេលមួយទៀត ។

III. គ្រោះមហន្តរាយ

គ្រោះមហន្តរាយ គឺជាការកាត់ផ្តាច់ដ៏ធ្ងន់ធ្ងរ នូវដំណើរការប្រព្រឹត្តទៅនៃសហគមន៍ ឬសង្គមមួយ បង្កឱ្យមានការបាត់បង់ ធំធេង នូវជីវិតមនុស្ស សម្ភារៈ សេដ្ឋកិច្ច ឬបរិស្ថាន ។

គ្រោះមហន្តរាយកើតឡើងពីការរួមគ្នា នៃមុខសញ្ញាគ្រោះថ្នាក់ ល័ក្ខខ័ណ្ឌនៃភាពងាយរងគ្រោះ និងសមត្ថភាព ឬវិធានការមិនគ្រប់គ្រាន់ក្នុងការកាត់បន្ថយផលអវិជ្ជមាននៃគ្រោះภัย ។

<u>គំនិតគួរពិចារណា</u>: តើយើងគួរកំណត់

មានមួយប្រភេទ: គ្រោះមហន្តរាយដោយសារមនុស្ស

ឬមានពីរប្រភេទ: គ្រោះមហន្តរាយដោយសារមនុស្ស និងគ្រោះមហន្តរាយដោយធម្មជាតិ

ត្រូវរកហេតុផលដើម្បីធ្វើការអះអាង

IV. ទំនាក់ទំនងរវាងមុខសញ្ញាគ្រោះថ្នាក់ ភាពងាយរងគ្រោះ និង គ្រោះមហន្តរាយ

គឺជាដំណើរនៃការជួបគ្នារវាងមុខសញ្ញាគ្រោះថ្នាក់ដែលអាចកើតឡើងក្នុងពេលវេលា និងទីកន្លែងជាក់លាក់ណាមួយជាមួយនឹងកំរិតនៃភាពងាយរងគ្រោះរបស់មនុស្ស ឬសហគមន៍ ដែលអាចនឹងទទួលនូវផលប៉ះពាល់ ។ គ្រោះមហន្តរាយកើតឡើងនៅពេលដែលមុខសញ្ញាគ្រោះថ្នាក់បានធ្វើឱ្យមានការខូចខាត ឬបាត់បង់អាយុជីវិត ទ្រព្យសម្បត្តិ នៅ តាមគ្រួសារ និងសហគមន៍ទាំងមូល ។

ការកើតឡើងនូវមុខសញ្ញាគ្រោះថ្នាក់ ឬបាតុភូតធម្មជាតិ ដូចជា: ទឹកជំនន់ រាំងស្ងួត និង ខ្យល់ព្យុះ គឺមិនមែនជាព្រឹត្តិការណ៍គ្រោះមហន្តរាយនោះទេ ។ មុខសញ្ញាគ្រោះថ្នាក់ ដែលជា***ព្រឹត្តិការណ៍ធ្ងន់ធ្ងរ*** នោះអាចក្លាយ ឬក៏បង្កឱ្យមានព្រឹត្តិការណ៍គ្រោះមហន្តរាយ ។ **ឧទាហរណ៍** ខ្យល់ព្យុះ ការបាក់ ឬរអិលផ្ទាំងដី ឧបទ្ទេវហេតុឧស្សាហកម្មផ្សេងៗ ។ ប្រសិនបើគ្មាន ***"ព្រឹត្តិការណ៍ធ្ងន់ធ្ងរ"*** ទេ ក៏គ្មានព្រឹត្តិការណ៍គ្រោះមហន្តរាយដែរ ។

ដូចគ្នានេះដែរយើងឃើញថា មនុស្សជាច្រើនគឺស្ថិតក្នុងស្ថានភាព ងាយរងគ្រោះទៅនឹងគ្រោះមហន្តរាយអស់ជាច្រើនឆ្នាំ បើទោះជាកន្លែងនោះមានគ្រោះภัយកើតឡើងក៏ដោយ ។ **ឧទាហណ៍ :** *ដូចជាប្រជាជនជាច្រើនដែលរស់នៅក្នុងតំបន់* ***លក្ខខណ្ឌដែលគ្មានសុវត្ថិភាព*** *ដូចជា នៅកែ្សរច្រាំងទន្លេដោយពួកគេគ្មានលទ្ធភាពគ្រប់គ្រាន់ ដើម្បីសង់ផ្ទះដែលមានសុវត្ថិភាព*។ ពួកគេប្រកបរបរដែលប្រឈមមុខ *ទៅនឹងគ្រោះថ្នាក់ (ដូចជា នេសាទសមុទ្រ) និង មានចំណូលតិច ។*

គ្រោះមហន្តរាយកើតឡើងបាននៅពេលមានកត្តាទាំងពីរនេះកើតឡើងរួមជាគ្នា។ **លក្ខខណ្ឌដែលគ្មានសុវត្ថិភាព ឬ ភាពងាយរងគ្រោះ** គឺជាស្ថានភាពដែលមនុស្ស និងទ្រព្យសម្បត្តិប្រឈមមុខទៅនឹងមុខសញ្ញាគ្រោះថ្នាក់នៃគ្រោះមហន្តរាយ។ សភាពនេះធ្វើឱ្យសហគមន៍ងាយរងគ្រោះទៅនឹងមុខសញ្ញាគ្រោះថ្នាក់។

គ្រោះមហន្តរាយ = មុខសញ្ញាគ្រោះថ្នាក់ + ភាពងាយរងគ្រោះ



លក្ខខណ្ឌមិនមានសុវត្ថិភាព *ឬ* ***ភាពងាយរងគ្រោះ*** គឺជាការផ្សំផ្គុំ និងច្របាច់បញ្ចូលគ្នានៃកត្តាបង្កគ្រោះថ្នាក់ទាំងឡាយជាច្រើន។ មធ្យោបាយមួយ សំរាប់ជួយឱ្យយើងមានការយល់ដឹងឱ្យកាន់តែច្បាស់ពីកត្តាទាំងនេះ គឺតាមរយៈការចាត់ប្រភេទ ឬក្រុមនៃភាពងាយរងគ្រោះទៅជា ០៣ ក្រុម:

១. ភាពងាយរងគ្រោះផ្នែកសំភារៈ និង រូបវន្ត

<u>ឧទាហរណ៍</u> ប្រជាជនក្រីក្រ ដែលមានធនធាន សំភារៈ តិចតួច ងាយទទួលរងគ្រោះដោយគ្រោះមហន្តរាយជាងអ្នកដែលមានធនធានសំភារៈច្រើន។ ជាទូទៅ អ្នកក្រីក្រតែងតែរស់នៅតាម តំបន់ជាយភូមិ ឬឆ្ងាយពីគេ ពួកគេអត់មានប្រាក់សន្សំ ឬការធានារ៉ាប់រងផ្សេងៗ ពួកគេមានសុខភាពមិនល្អ។ កត្តាទាំងនោះ ធ្វើឱ្យពួកគេងាយរងគ្រោះដោយសារគ្រោះមហន្តរាយកាន់តែខ្លាំង វាមានន័យថា ពួកគេត្រូវចំណាយពេលច្រើនជាង ដើម្បីរៀបចំ ឡើងវិញនូវការខូចខាតដោយសារគ្រោះមហន្តរាយ បើប្រៀបធៀបនឹងអ្នកដែលមានធនធានសំភារៈច្រើន ។

២. ភាពងាយរងគ្រោះផ្នែកសង្គម និង ស្ថាប័ន

ប្រជាជនដែលខ្វះការចូលរួមឱ្យបានពេញលេញក្នុងសកម្មភាពសង្គម ឬស្ថាប័នផ្សេងៗក្នុងសហគមន៍ តែងតែទទួលរងគ្រោះដោយគ្រោះមហន្តរាយខ្លាំងជាងក្រុមមនុស្សជាសមាជិកក្រុមឬស្ថាប័ន ដែលគេបានរៀបចំឡើងយ៉ាងរឹងមាំ និង មានការប្តេជ្ញាចិត្ត ក្នុងការជួយគ្នាទៅវិញទៅមក ។

៣. ភាពងាយរងគ្រោះផ្នែកចិត្តសាស្ត្រសង្គម

មនុស្សដែលមិនសូវមានទំនុកចិត្តទៅលើសមត្ថភាពរបស់ខ្លួន ក្នុងការធ្វើឱ្យមានការផ្លាស់ប្តូរស្ថានភាពរបស់ខ្លួន ឬអ្នកដែល***ញាត់ បង់ទឹកចិត្ត*** ហើយមានអារម្មណ៍ថាខ្លួនត្រូវចុះចាញ់ និង មិនអាចគ្រប់គ្រងនូវព្រឹត្តិការណ៍ដែលកើតឡើងចំពោះគេបាន ក្រុមមនុស្សបែបនេះតែងទទួលរងគ្រោះដោយគ្រោះមហន្តរាយខ្លាំង ជាងក្រុមមនុស្សដែលមានភាពជឿជាក់លើសមត្ថភាពរបស់គេ ក្នុងការផ្លាស់ប្តូរស្ថានភាពរបស់គេ ឬ សំរេចនូវអ្វីដែលគេចង់បាន ។

មេរៀនទី ២: ការគ្រប់គ្រងគ្រោះមហន្តរាយ

I. អ្វីទៅការគ្រប់គ្រងគ្រោះមហន្តរាយ

មានន័យថាសកម្មភាពមួយចំនួន មុនពេល ក្នុងពេល និងក្រោយពេលគ្រោះមហន្តរាយសំដៅថែរក្សា ត្រួតពិនិត្យតាមដានពីគ្រោះមហន្តរាយ និងផ្តល់គម្រោងសកម្មភាពសម្រាប់ជួយមនុស្ស ដែលស្ថិតក្នុងគ្រោះภัយ និង/ឬ សហគមន៍ណាមួយ ដើម្បីបញ្ឈ្ប៉ាសកាត់បន្ថយអប្បរមា ឬស្តារប្រក្រតីភាពឡើងវិញ ពីផលប៉ះពាល់នៃគ្រោះមហន្តរាយ ។



នៅមុនពេលមានគ្រោះមហន្តរាយ	ក្នុងពេលមានគ្រោះមហន្តរាយ	ក្រោយពេលមានគ្រោះមហន្តរាយ
- ការត្រៀមបង្ការ	- ការឆ្លើយតប សង្គ្រោះបន្ទាន់	- ការស្តារឡើងវិញ
- ការកាត់បន្ថយគ្រោះថ្នាក់		- ការកសាងឡើងវិញ
- ការត្រៀមរៀចំ		

១. ការត្រៀមបង្ការគ្រោះមហន្តរាយ

ជាវិធានការដែលធ្វើឡើង សម្រាប់ការពារជាអចិន្ត្រៃយ៍ចំពោះការគំរាមកំហែងដោយគ្រោះមហន្តរាយ ដើម្បីកាត់បន្ថយកំលាំងឬភាពញ៉ីកញ្ជាប់នៃព្រឹត្តិការណ៍ដែលជាមុខសញ្ញាគ្រោះថ្នាក់សំដៅកុំឱ្យក្លាយជាព្រឹត្តិការណ៍ គ្រោះមហន្តរាយបាន។ សកម្មភាពនៃការត្រៀមបង្ការ រួមមាន: សកម្មភាពដែលរៀបចំឡើង ក្នុងគោលបំណងរារាំងការកើតឡើង នៃព្រឹត្តិការណ៍គ្រោះមហន្តរាយ

ឬដើម្បីការពារកុំឱ្យកើតមានព្រឹត្តិការណ៍ទាំងនេះកើតឡើង ដែលជាហេតុនាំឱ្យមានការខូចខាត យ៉ាងធ្ងន់ធ្ងរដល់សហគមន៍ និងហេដ្ឋារចនាសម្ព័ន្ធផ្សេងៗ ។ ***ឧទាហរណ៍:*** ការគ្រប់គ្រងទឹកជំនន់ ការរៀបចំច្បាប់នៃការប្រើប្រាស់ដីធ្លី កម្មវិធីកាត់បន្ថយភាពក្រីក្រ ការឆ្លើយតប(ផ្តល់) តម្រូវការជាមូលដ្ឋាន សុខមាលភាព និងការផ្តល់ការអប់រំ។ សកម្មភាពនៃការការពារ និង ការកាត់បន្ថយ គឺត្រូវបានភ្ជាប់ ទៅនឹងការងារអភិវឌ្ឍន៍ ។

២. ការកាត់បន្ថយគ្រោះថ្នាក់គ្រោះមហន្តរាយ

ជាវិធានការដែលធ្វើឡើងនៅមុនពេលមានគ្រោះមហន្តរាយ សំដៅកាត់បន្ថយនូវផលប៉ះពាល់ពីគ្រោះមហន្តរាយទៅលើ បរិស្ថាន និងសង្គម ។ សកម្មភាពទាំងនេះ គឺរួមបញ្ចូលទាំងវិធានការទាំងឡាយដែលអាចអនុវត្ត ដើម្បីកាត់បន្ថយនូវការខូចខាត និងការបង្អាក់នានាដែលបណ្តាលមកពីមុខសញ្ញាគ្រោះថ្នាក់ ។ ដូច្នេះ ការកាត់បន្ថយគ្រោះថ្នាក់ គឺជាការបន្ថយទំហំនៃការខូចខាតដោយ គ្រោះមហន្តរាយ ។ ហើយវិធានការនេះយើងអាចធ្វើបានទៅតាមរូបភាពពីរយ៉ាង ដូចជា:

- ***វិធានការតាមរូបភាពជារចនាសម្ព័ន្ធ*** ដូចជា: ការសាងសង់ទំនប់ និងការសាងសង់ផ្ទះដែលមាន សុវត្ថិភាព តាក់តែងច្បាប់ (ឧ. ការដាក់ក៏រិតប្រជាជន មិនអោយទៅសាងសង់ផ្ទះ នៅលើទំនប់) ។
- ***វិធានការតាមរូបភាពមិនរចនាសម្ព័ន្ធ*** ដូចជា: ការបណ្តុះបណ្តាល ពង្រឹងសមត្ថភាពគ្រប់គ្រងគ្រោះមហន្តរាយ រៀបចំចងក្រងនូវក្រុមអ្នកស្ម័គ្រចិត្តសំរាប់ សង្គ្រោះ ការយល់ដឹង និងការអប់រំជាសាធារណៈ សុវត្ថិភាពស្បៀង កម្មវិធីនិងការស្វែងរកការគាំទ្រនៅលើការដោះស្រាយបញ្ហា (Advocacy)ជំរុញលើកទឹកចិត្តការប្រើប្រាស់ចំណេះដឹង និងផែនការអនុវត្ត ។

៣. ការត្រៀមរៀបចំសម្រាប់គ្រោះមហន្តរាយ

ការត្រៀមរៀបចំសម្រាប់គ្រោះមហន្តរាយ គឺជាវិធានការ និងសកម្មភាពផ្សេងៗ ដែលគេត្រូវអនុវត្តសំដៅត្រៀមរៀបចំ ជាមុន ដើម្បីធានាថារាល់សកម្មភាព ឬវិធានការដ៏មានប្រសិទ្ធិភាពទាំងឡាយត្រូវបានអនុវត្តយ៉ាងត្រឹមត្រូវនៅពេលមាន គ្រោះមហន្តរាយកើតឡើង។ ការត្រៀមបង្ការគ្រោះមហន្តរាយ គឺដើម្បីកាត់បន្ថយផលប៉ះពាល់នៃគ្រោះមហន្តរាយ ដោយការរៀបចំ ការឆ្លើយតប និងកំណត់ធនធានបំរុងជាស្រេចសម្រាប់ ធ្វើសកម្មភាពផ្សេងៗទៀតតាមលំដាប់លំដោយ ដើម្បីអន្តរាគមន៍ភ្លាមៗ ឱ្យបានទាន់ពេលវេលានៅពេលគ្រោះមហន្តរាយ កើតឡើង។ ***<u>ឧទាហរណ៍:</u>*** ការពង្រឹងសមត្ថភាព គឺដើម្បីធ្វើការប្រកាសអាសន្នជាមុន ការស្រាវជ្រាវនិងសង្គ្រោះ ការជំលៀស និងប្រតិបត្តិការផ្តល់អំណោយសង្គ្រោះ ការរៀបចំនិងការអនុវត្តន៍ផែនការត្រៀមរៀបចំ គ្រោះមហន្តរាយ ស្តុក សំភារ: និងការផ្គត់ផ្គង់ ការទំនាក់ទំនងបន្ទាន់ ការបណ្តុះបណ្តាលក្រុមសង្គ្រោះតូចៗ សមយុទ្ធពីការរៀបចំ ក្រុមសង្គ្រោះ ការផ្សព្វផ្សាយ ឱ្យមានការយល់ដឹងជាសាធារណៈពីគ្រោះមហន្តរាយ ។

៤. ការឆ្លើយតប សង្គ្រោះបន្ទាន់

ការឆ្លើយតប សង្គ្រោះបន្ទាន់ រាំពាក់ពន្ធ័នឹងសកម្មភាពចាំបាច់ផ្សេងៗ ក្នុងការងាររុករកសង្គ្រោះ ដើម្បីស្រោចស្រង់ អាយុជីវិត និងបំពេញតំរូវការជាមូលដ្ឋានរបស់អ្នកកងគ្រោះ ដូចជា: ការផ្តល់ជំរក ទឹក ស្បៀងអាហារ និង ការថែទាំសុខភាព។

ការងារឆ្លើយតប គឺរួមបញ្ចូលទាំងសេវាកម្ម និងសកម្មភាពទាំងអស់ដែលត្រូវអនុវត្ត ដើម្បីជួយដល់ ប្រជាជនដែលរងគ្រោះ ក្រោយគ្រោះមហន្តរាយកើតឡើង ។

<u>ឧទាហរណ៍</u> : ការរុករកសង្គ្រោះជនរងគ្រោះ ការផ្តល់ស្បៀងអាហារ និងសំភារៈផ្សេងៗ សុខភាព អនាម័យ ជួយសម្រួលដល់ការលំបាករបស់អ្នករងគ្រោះ ការជួសជុលសំភារៈ និង បរិក្ខាផ្សេងៗ (ឧ. ស្ពាន មធ្យោបាយនៅក្នុងការ ទំនាក់ទំនង) ។

៥. ការស្តារឡើងវិញ និងកសាងឡើងវិញ

ការស្តារឡើងវិញ គឺជាពាក្យដែលគេប្រើ ដើម្បីបញ្ជាក់ពីវិធានការជាអចិន្ត្រៃយ៍ផ្សេងៗ ដែលគេធ្វើឡើងដើម្បី ជួសជុល ឬជំនួសឡើងវិញនូវលំនៅដ្ឋានដែលខូចខាត ហេដ្ឋារចនាសម្ព័ន្ធដែលខូចខាតនិងដើម្បីធ្វើឱ្យសេដ្ឋកិច្ចដំណើរការឡើងវិញ ។

ការកសាងឡើងវិញ គឺសំដៅទៅលើដំណើរនៃការអនុវត្តដោយសហគមន៍ដែលទទួលផលប៉ះពាល់ ដោយគ្រោះមហន្តរាយ ដើម្បីជំនួសឡើងវិញទាំងស្រុងឱ្យដូចស្ថានភាពដើមមុនពេលមានគ្រោះមហន្តរាយ ។ ការកសាងឡើងវិញ ពាក់ពន្ធ័ទៅនឹងអន្តរាគមន៍ផ្សេងៗ ដើម្បីជំនួសឡើងវិញនូវសេវាកម្មជាមូលដ្ឋាន និងសំរួលដល់ដំណើរការរៀបចំឡើងវិញរបស់អ្នក ដែលទទួលរងគ្រោះ ។

<u>ឧទាហរណ៍ :</u> គាំទ្រដល់ប្រជាពលរដ្ឋ ដើម្បីជួសជុលផ្ទះរបស់គេឡើងវិញ ការបង្កើតជាថ្មីឡើងវិញនូវសេវាកម្ម សំខាន់ៗ ដូចជា បរិក្ខាផ្សេងៗក្នុងសហគមន៍ និងការធ្វើឱ្យដំណើរការឡើងវិញនូវសកម្មភាពសង្គម និងសកម្មភាព សេដ្ឋកិច្ចនានា ។

មេរៀនទី ៣: ស្ថានការណ៍គ្រោះមហន្តរាយ និង ការគ្រប់គ្រងគ្រោះមហន្តរាយនៅកម្ពុជា

I. គោលបំណងរួម

អ្នកចូលរួម និងសិក្ខាកាមទាំងអស់ នឹងអាចយល់ដឹងពីផែនការនិងសកម្មភាពអាទិភាពនានា ដែលទាក់ទងនឹងយុទ្ធសាស្ត្រសំរាប់ការកាត់បន្ថយគ្រោះภัយនៃគ្រោះមហន្តរាយនៅកម្ពុជា ។

II. ស្ថានការណ៍គ្រោះមហន្តរាយ និង ការគ្រប់គ្រងគ្រោះមហន្តរាយនៅកម្ពុជា

១. ប្រភេទគ្រោះមហន្តរាយ និង មុខសញ្ញាគ្រោះថ្នាក់នៅកម្ពុជា

មុខសញ្ញាគ្រោះថ្នាក់ដោយធម្មជាតិដែលប្រទេសកម្ពុជាតែងជួបប្រទះ គឺទឹកជន់ និងរាំងស្ងួត ព្រមទាំងមានមុខសញ្ញាគ្រោះថ្នាក់ធម្មជាតិផ្សេងៗទៀតដូចជា: រោគរាតត្បាត ខ្យល់ព្យុះជាដើម ។ល។ ចាប់តាំងពីឆ្នាំ១៩៨៧ រហូតដល់បច្ចុប្បន្ន ការកើតឡើងនៃមុខសញ្ញាគ្រោះថ្នាក់ទឹកជន់ និងរាំងស្ងួតមានការកើនឡើងជាលំដាប់ ពោលគឺកើតឡើងជារៀងរាល់ឆ្នាំ។ ទឹកជន់ទន្លេ (ទន្លេមេគង្គ និង ទន្លេសាប)កើតឡើង និង បង្កការគំរាមកំហែងដល់តំបន់នៅតាម ដងទន្លេមេគង្គ ទន្លេសាប និង ដែរបស់វា ដោយឡែកតំបន់ខ្ពង់រាប និង តំបន់ឆ្នេរ តែងតែទទួល ការគំរាមកំហែង និង បង្ការ ប៉ះពាល់ដោយទឹកជន់ន់រហ័ស(ទឹកជន់ន់ភ្ជុំ) ។ ទឹកជន់ន់ទាំងពីរប្រភេទនេះជះឥទ្ធិពលមកលើប្រជាជនមួយចំនួនធំដែលបណ្តាល ឱ្យមានមនុស្សស្លាប់ របួស ជំលៀសចេញពីលំនៅដ្ឋាន ប៉ះពាល់ជីវភាពរស់នៅ និង ជាកត្តាជំរុញអោយធ្លាក់ទៅក្នុងភាព ក្រីក្រជាដើម ។

ម្យ៉ាងវិញទៀតការកើតមាន គ្រោះរាំងស្ងួតក៏បាន ជះឥទ្ធិពលដល់សេដ្ឋកិច្ច និង ការងារកសិកម្មរបស់ប្រជាជន ព្រមទាំងផ្តល់នូវផលប៉ះពាល់ទៅ លើវិស័យសេដ្ឋកិច្ច និង កសិកម្មរយៈពេលយូរ និង មានឥទ្ធិពលមិនល្អមកលើប្រជាជន ដែលពឹងផ្អែកតែទៅលើទំនិញ និងសេវាកម្មដែលបានមកពីតំបន់ដែលរងគ្រោះដោយរាំងស្ងួត ប៉ុន្តែការកើតឡើងនូវគ្រោះ រាំងស្ងួតនៅក្នុងប្រទេសគឺមានចំនួនតិចជាងគ្រោះទឹកជន់ ។

ជាទូទៅ មុខសញ្ញាគ្រោះថ្នាក់ទឹកជន់ និងគ្រោះរាំងស្ងួត និងមុខសញ្ញាគ្រោះថ្នាក់ដទៃទៀត មានជាញឹកញាប់ណាស់ ដែលមុខសញ្ញា ទាំងអស់នេះ តែងតែកើតឡើងក្នុងពេលតែមួយ គ្រាន់តែអាចនៅកន្លែងខុសគ្នា ឬ នៅកន្លែងតែមួយ។ មូលហេតុនេះហើយ ដែលធ្វើអោយមានការប៉ះពាល់ និង រំខានដល់ដំណើរការអភិវឌ្ឍ និង ជំរុញអោយ មានការធ្លាក់ចុះនៃសេដ្ឋកិច្ច សង្គមកិច្ច និង បំផ្លាញបរិស្ថាន។ ខេត្តដែលប្រឈមទៅនឹងមុខសញ្ញាគ្រោះថ្នាក់ និង តែងតែទទួលរងការគំរាមគំហែងមានដូចជា: ខេត្តព្រៃវែង ខេត្តកណ្តាល ខេត្តកំពង់ចាម ខេត្តស្វាយរៀង ខេត្តបន្ទាយមានជ័យ ខេត្តកំពង់ស្ពឺ បាត់ដំបង ក្រចេះ ស្ទឹងត្រែង កំពង់ឆ្នាំ ពោធិសាត់ កំពង់ធំ សៀមរាប តាកែវ បន្ទាយមានជ័យ ឧត្តមានជ័យ ខេត្តព្រះសីហនុ ខេត្តកែប និង កោះកុង ។ល។

១.១ គ្រោះទឹកជំនន់

ទឹកជំនន់នៅកម្ពុជាគឺជាបញ្ហាមួយទាក់ទងនិងភូមិសាស្ត្រ ដែលស្ថិតក្នុងចំណោមបញ្ហានានារបស់ប្រទេស។ ប្រការនេះធ្វើឱ្យប្រទេសកម្ពុជាងាយទទួលទឹកជំនន់ជារៀងរាល់ឆ្នាំ ជាពិសេសតាមបណ្តោយបឹងទន្លេសាប និងតំបន់ទំនាបទន្លេមេគង្គ។ ទឹកជំនន់មានផលពីរយ៉ាងនៅពេលទឹកជំនន់ធំ វាធ្វើឱ្យខាតបង់ ប៉ុន្តែបើទឹកជំនន់ធម្មតាវាធ្វើឱ្យមានផលប្រយោជន៍ ដល់ការចិញ្ចឹមជីវិតផ្នែកកសិកម្ម ព្រោះធ្វើឱ្យដីមានសំណើមនិងមានជីវជាតិសម្រាប់ដំណាំកសិកម្ម បង្ក្រាប់ឡើងវិញនូវជាតិទឹក ដែលបាត់បង់ទាំងនៅក្នុងដី និងនៅផ្នែកខាងលើ ហើយវាថែមទាំងមានផលប្រយោជន៍ផ្នែកអេកូឡូហ្សីសម្រាប់ពពួកត្រីទៀតផង ដែលប្រជាជនតាមដងទន្លេពឹងផ្អែកលើការចិញ្ចឹមជីវិតរបស់ពួកគេ។ ទោះជាយ៉ាងណាក៏ដោយប៉ុន្តានឆ្នាំកន្លងមកនេះ គ្រោះទឹកជំនន់បានក្លាយទៅជាហេតុការណ៍ដ៏ធ្ងន់ធ្ងរបណ្តាលអោយបាត់បង់ ជីវិតមនុស្ស បំផ្លិចបំផ្លាញផលដំណាំ និង សត្វពាហនៈ ព្រមទាំងបង្កឱ្យមានការខូចខាតផ្ទះសម្បែង និងបណ្តាញហេដ្ឋារចនាសម្ព័ន្ធនៅតាមមូលដ្ឋានទៀតផង (មានជា អាទិ៍ សាលារៀន មណ្ឌលសុខភាព ផ្លូវថ្នល់ និងស្ពាន ជាដើម)។ នៅក្នុងប្រទេសកម្ពុជា គ្រោះមហន្តរាយដោយទឹកជំនន់មាន ពីរប្រភេទសំខាន់ៗ:

- **ទឹកជំនន់ទន្លេ**

ទឹកជំនន់នៅតាមដងទន្លេ គឺជាបាតុភូតធម្មជាតិដែលកើតតាមរដូវ ជាពិសេសនៅក្នុងរដូវវស្សាដែលខ្យល់មូសុងបាននាំមកនូវទឹកភ្លៀងយ៉ាងច្រើនហូរចាក់ចូលទៅក្នុងអាងទន្លេ បឹង ព្រែក និងអាងស្តុកទឹកនានា ហើយធ្វើអោយផ្ទៃនៃអាងស្តុកទឹកទាំងអស់នេះពេញ និង ហៀរលិចតំបន់ទំនាប ដែលមានទីតាំងនៅជុំវិញទន្លេ និងដែរបស់វា។ ទឹកជំនន់ទន្លេគេចាត់ជាទឹកជំនន់ដែលមានល្បឿនយឺត ដោយសារវាកើតឡើងយឺតៗអាស្រ័យទៅតាមបរិមាណទឹកភ្លៀង។ ទឹកជំនន់ប្រភេទនេះមាន រយៈពេលយូរ ឬឆាប់ វាអាស្រ័យស្ថានភាពដី និងស្ថានភាពភូមិសាស្ត្រ។ តំបន់ខ្លះមាន រយៈពេលមួយសប្តាហ៍ ឬច្រើនជាងនេះ និងតំបន់ខ្លះមានរយៈពេលដល់រាប់ខែក៏មាន។ តំបន់ដែលប្រឈមមុខ និងទទួលរងការប៉ះពាល់ទឹកជំនន់ប្រភេទនេះ វាអាចធ្វើអោយ បាត់បង់ និងខូចខាតដំណាំកសិផល ហេដ្ឋារចនាសម្ព័ន្ធ សេវាកម្ម ដូចជាផ្លូវថ្នល់ តំណផ្លូវដែក និង ការផ្គត់ផ្គង់អគ្គីសនី ។ល។

ជាទូទៅ ទឹកជំនន់ទន្លេបណ្តាលមកពីកត្តាពីរសំខាន់ៗ ដូចជា : **ទីមួយ** នៅពេលកំរិតទឹកទន្លេរួមផ្សំជាមួយទឹកភ្លៀង យ៉ាងគំហុកដែលហូរចាក់ពីដែនទន្លេធ្វើឱ្យទឹកឡើងលិចតំបន់ទំនាបនានា ដែលនៅជុំវិញធ្វើអោយប៉ះពាល់ដល់តំបន់ទាំងនោះ និង **ទីពីរ:** ទឹកជំនន់អាក្រក់ហួសហេតុជួបប្រទះនៅពេលមានទឹកភ្លៀងយ៉ាងខ្លាំងរួមគ្នាជាមួយការមកដល់នូវវិសម្ពាធ និង ខ្យល់ព្យុះត្រូពិកនោះ គ្រោះទឹកជំនន់ទន្លេជាទូទៅនឹងកើតមាននៅ ខេត្តស្ទឹងត្រែង ក្រចេះ កំពង់ចាម ព្រៃវែង កណ្តាល កំពង់ឆ្នាំង ពោធិសាត់ កំពង់ធំ កំពត និង ខេត្តតាកែវ។

- **ទឹកជំនន់ហើស**

ទឹកជំនន់ឡើងរហ័សបណ្តាលមកពីមានភ្លៀងធ្លាក់ដោយគំហុកនៅតំបន់ខាងលើ ជាពិសេស មានភ្លៀងយ៉ាងច្រើនជាប់ៗគ្នាជាច្រើនថ្ងៃនៅតាមជួរភ្នំខ្ពស់ៗ បណ្តាលអោយមានទឹកហូរយ៉ាងគំហុកចុះតាមជ្រោះនិងជ្រលងភ្នំចុះមកតំបន់វាលរាប ធ្វើអោយមានទឹកហូរហៀរពាសពេញតំបន់វាលរាប ។ ដោយសារតែ មានទឹកហូរកំហុកក្នុងរយៈពេលខ្លី ជាហេតុធ្វើអោយយើងពិបាកក្នុងការធ្វើការទស្សន៍ទាយ ឬ ធ្វើការព្យាករណ៍ ទុកជាមុនបាន។ កំលាំងទឹកហូរអាចធ្វើអោយបើ្ងរថយន្ត ផ្ទាំងថ្ម គាស់រំលើ្ងឬសឈើ បំផ្លាញអាគារជាពិសេស វាអាចបំផ្លិចបំផ្លាញហេដ្ឋារចនាសម្ព័ន្ធ (ស្ពាន ផ្លូវថ្នល់ ទំនប់ ជាដើម) បាន យ៉ាងងាយបំផុត។

គ្រោះទឹកជំនន់រហ័ស មានរយៈពេលយូរបំផុតត្រឹមតែពីរ-បីថ្ងៃប៉ុណ្ណោះ ប៉ុន្តែជារឿយៗបណ្តាលឱ្យមានការខូចខាតដល់ផលដំណាំ និង ហេដ្ឋារចនាសម្ព័ន្ធនានា ដែលនៅតំបន់នៅតាមដងស្ទឹង ទន្លេ និង នៅតំបន់ជុំវិញភ្នំខ្ពស់។ ទឹកជំនន់រហ័សនេះធ្វើឱ្យប៉ះពាល់ដល់ខេត្តមួយចំនួន ដូចជា: ខេត្តកណ្តាល កំពង់ស្ពឺ កំពត ពោធិសាត់ បាត់ដំបង រតនគិរី មណ្ឌលគិរី ព្រះវិហារ កំពង់ធំ បន្ទាយមានជ័យ កោះកុង ស្ទឹងត្រែង និង ឧត្តរមានជ័យ ជាដើម។

ព្រឹត្តិការណ៍ទឹកជំនន់ធំៗដែលប៉ះពាល់ដល់ប្រជាពលរដ្ឋគឺកើតឡើងរៀងរាល់៥ឆ្នាំម្តង ឬលើសពីនេះ (១៩៦១, ១៩៦៦, ១៩៧៨, ១៩៩១, ២000, ២00១ និង ២00២)។ គ្រោះទឹកជំនន់មួយក្នុងចំណោមគ្រោះទឹកជំនន់ ដែល ធ្ងន់ធ្ងរបំផុតនោះគឺទឹកជំនន់ក្នុងឆ្នាំ២000 មានប្រជាជនសរុប ៧៥0,៦១៨គ្រួសារ ត្រូវជា ៣,៤៤៨,៦២៤លាននាក់ ក្នុងនោះមាន ៨៥,000គ្រួសារ ត្រូវជា ៣៨៧,000នាក់ ត្រូវបានជម្លៀសជាបណ្តោះអាសន្នពីគេហដ្ឋាន និងភូមិករ។ ចំនួនខូចខាតសរុបត្រូវបានប៉ាន់ប្រមាណមានចំនួន ១៥0លានដុល្លាសហរដ្ឋអាមេរិក និង បាត់បង់ជីវិតមនុស្ស ៣៤៧នាក់ ក្នុងនោះ ៨0% ជាកុមារ។ នៅឆ្នាំ២00១ គ្រោះទឹកជំនន់បានបង្កឱ្យមានការខូចខាត តាមការប៉ាន់ប្រមាណចំនួន ២0 លានដុល្លាសហរដ្ឋអាមេរិក និង បាត់ជីវិតមនុស្សចំនួន ៦២នាក់ (៧0% ជាកុមារ) និង ឆ្នាំ២00២ ការប៉ាន់ប្រមាណការខូចខាតមានចំនួន ១៤ លានដុល្លារអាមេរិក និងបាត់បង់ជីវិតមនុស្ស ២៩នាក់, ៤0% ជាកុមារ។

រូបភាព១: ផែនទីបណ្តាឃុំដែលប្រឈមនឹងទឹកជំនន់



១.២ គ្រោះរាំងស្ងួត

ប្រទេសកម្ពុជា ជាប្រទេសមួយស្ថិតនៅក្នុងតំបន់ត្រូពិចដែលមានរដូវពីរ គឺ: រដូវវស្សា និង រដូវប្រាំង។ រដូវវស្សាជារដូវទទួលឥទ្ធិពលខ្យល់មូសុងចាប់ពីខែឧសភា ដល់ ចុងខែតុលា និង រដូវប្រាំងចាប់ពីខែ វិច្ឆិកា ដល់ ខែមេសា។ ផ្ទៃដីប្រទេសកម្ពុជាជាវាលទំនាបស្ទើរតែទាំងអស់ លើកលែងតែនៅទិសនិរតីដែលមានភ្នំ និង នៅទិសឧត្តរគឺជា "ផ្ទៃដីសំរាប់ដាំដំណាំស្រូវ និង ដាំដើមឈើ ហើយដែលគ្របដណ្តប់ដោយទឹកទន្លេមេគង្គ និង ទន្លេសាប" ។

នៅក្នុងប្រទេសកម្ពុជា ប្រភេទគ្រោះរាំងស្ងួតសំខាន់ដែលមានការព្រួយបារម្ភជាងគេចំពោះថ្នាក់ជាតិនោះ គឺភាពរាំងស្ងួតនៅលើដីនៃកសិកម្ម ដែលជាទីកន្លែងខ្វះសំណើមដីគ្រប់គ្រាន់សំរាប់ដំណាំលូតលាស់ ដែលបណ្តាលមកពីមានភ្លៀងធ្លាក់តិចនៅពេលរដូវភ្លៀង និងរបាយទឹកភ្លៀងមិនទៀងទាត់នៅពេលរដូវដាំដំណាំ។ នៅតាមតំបន់ជនបទភ្លៀងធ្លាក់ប្រចាំឆ្នាំ គឺជាកត្តាកំណត់មួយនៃផលិតភាពខាងដំណាំស្រូវ និង សន្តិសុខស្បៀង។

ប្រភពទឹកភ្លៀងនៅក្នុងប្រទេសកម្ពុជា បានមកពីខ្យល់មូសុងដែលបក់មកពីទិសនិរតី។ ផ្ទៃដីកសិកម្មភាគច្រើនលាតសន្ធឹងនៅក្នុងតំបន់ដែលទទួលរងឥទ្ធិពលភ្លៀងនៃខ្យល់មូសុងនេះ ដែលនៅតាមជួរភ្នំក្រវាញ និង ភ្នំដាំ នៅទិសនិរតី នៃប្រទេស។ ក្រៅពីជួរភ្នំទាំងនេះ ទឹកភ្លៀងធ្លាក់ជាមធ្យមគឺ ៤.000 មីលីម៉ែត្រក្នុងមួយឆ្នាំ។ បន្ទាប់ពីភ្លៀងខ្យល់មូសុងនេះឆ្លងកាត់ភ្នំទាំងនេះរួចមក ភ្លៀងធ្លាក់ជាមធ្យមប្រចាំឆ្នាំក្នុងកំរិតពី១.២៥0 ទៅ ១.៧៥0ម.ម លើតំបន់កសិកម្មសំខាន់ ទាំងនោះ។ ប៉ុន្តែភ្លៀងធ្លាក់ប្រចាំឆ្នាំបានថយចុះនៅ ៥0% នៅពេលដែលមានគ្រោះរាំងស្ងួត និងកើនឡើងបាន ៤0% នៅពេលមានទឹកជំនន់ខ្លាំង។ តំបន់ដែលក្តៅបំផុតនៅក្នុងប្រទេសកម្ពុជា គឺនៅទិសអាគ្នេយ៍ និងទិសពាយ័ព្យ ដែលទទួល ទឹកភ្លៀងធ្លាក់ជាមធ្យមតិចជាង ៤៧0ម.ម នារដូវវស្សា។

ដោយតំបន់កសិកម្មដំណាំស្រូវប្រហែលជា ៨0% ត្រូវពឹងផ្អែកទាំងស្រុងទៅលើទឹកភ្លៀង ទើបប្រហែលជាកត្តាទឹក ភ្លៀងដែលធ្លាក់មិនទៀតទាត់អាចបណ្តាលអោយមានគ្រោះរាំងស្ងួតនៃការធ្វើកសិកម្មនេះនៅពេលដាំដុះក្នុងរដូវភ្លៀង។ គ្រោះរាំងស្ងួតខាងកសិកម្មនៅក្នុងប្រទេសកម្ពុជា មិនមែនជាបញ្ហាមួយពេលរដូវប្រាំងនោះទេ ព្រោះថាទឹកភ្លៀងធ្លាក់ជាមធ្យមនៅរដូវប្រាំង គឺមានតិចបំផុតទៅហើយ ហើយដំណាំដែលពឹងលើទឹកភ្លៀងនោះ វាលូតលាស់ជាធម្មតា។ ដូចនេះវាជាការធម្មតាទៅហើយ ដែលដំណាំដាំដដែល១តែងតែជួបប្រទះនឹងទឹកជន់ផង និង ភាពរាំងស្ងួតផង អំឡុងពេលនៃការ លូតលាស់របស់វា។

នៅក្នុងឆ្នាំ ២00៤-២00៥ នៅពេលដែលរដូវភ្លៀងធ្លាក់ផុតមុនរដូវគ្រានោះបានបង្កឱ្យមានបញ្ហាយ៉ាងធំដល់ការដាំដុះដំណាំស្រូវ ដែលធ្វើអោយប្រទេសកម្ពុជាមានមនុស្សដល់ ០២លាននាក់ បានរងការគំរាមកំហែងដោយខ្វះ ស្បៀងអាហារ។ មិនត្រឹមតែរដូវភ្លៀងនាឆ្នាំ២00៤ បានឈប់ភ្លៀងមុនរដូវប៉ុណ្ណោះទេ ក៏ប៉ុន្តែរដូវភ្លៀងនៅឆ្នាំ២00៥ ថែមទាំងមិនឃើញមានធ្លាក់មកផងដែរនៅក្នុងខែឧសភា ដូចដែលបានគិតដែលបានពន្យាពេលដក់ការដាំដុះដំណាំស្រូវ ដែលប្រជាជនចំនួន ៨៥% ពឹងពឹងអាស្រ័យលើ។ ដីស្រែចំការនៅក្នុងប្រទេសរហូតដល់ទៅ ៣0% មានការប៉ះពាល់ដែលរួមមាន ផ្ទៃដីចំនួន ៥00.000ហិចតានៃដីដាំស្រូវ (ស្មើប្រហែលនឹង២៥% នៃផ្ទៃដីដាំដំណាំសរុប)ដែលត្រូវការជំនួយស្បៀងអាហារពីអន្តរជាតិ ចំពោះតំរូវការបែបនេះ។

រាំងស្ងួតត្រូវបានពិចារណាទៅនឹងការពន្យាពេលនៃអាកាសធាតុហួតហែងខុសពីធម្មតា ដែលមកពីមូលហេតុមានវិសមភាពនៃធារាសាស្ត្រក្នុងតំបន់ ជាធម្មតាការធ្លាក់ភ្លៀងគឺចាប់ផ្តើមពីខែឧសភា ដល់ ខែតុលា ហើយភ្លៀងធ្លាក់ ច្រើនចាប់ពីខែសីហារហូតដល់ពាក់កណ្តាលខែតុលា ។ ជាមួយនេះក៏មាន កូនរដូវប្រាំងក្នុងចន្លោះខែកក្កដា និង ខែសីហា ចំនួនប្រហែលពី ០២សប្តាហ៍ ទៅ ០៣សប្តាហ៍។ បើក្នុងមួយឆ្នាំ១រយៈពេលកូនរដូវប្រាំងនេះ បានអូសបន្លាយពេលយូរ គឺគ្រោះរាំងស្ងួតខាងកសិកម្មអាចនឹងកើតឡើងបន្ថែមទៅលើការធ្លាក់ភ្លៀងយឺតយ៉ាវ និងឆាប់បញ្ចប់រដូវវស្សា។ នៅក្នុងប្រទេសកម្ពុជា គ្រោះរាំងស្ងួតបណ្តាលមកពីកត្តា0៤ប្រភេទ:

- មិនអាចទាយទុកជាមុនបានពីការធ្លាក់ភ្លៀងយឺតយ៉ាវ នៅដើមរដូវវស្សា
- ភ្លៀងធ្លាក់មិនទៀងទាត់ ហើយបរិមាណទឹកភ្លៀង និងរយៈពេលនៃភ្លៀងធ្លាក់ខុសៗគ្នានៅតាមតំបន់
- រដូវភ្លៀងធ្លាក់រហ័សបញ្ចប់ក្នុងរដូវវស្សា
- ការកើតឡើងនៃកូនរដូវប្រាំងដែលមានរយៈពេល ០៣សប្តាហ៍ ឬច្រើនជាងនេះ ក្នុងអំឡុងពេលរដូវវស្សាដែលអាចបណ្តាលឱ្យខូចខាតផលដំណាំផ្សេងៗ ដោយសារគ្មានប្រព័ន្ធស្រោចស្រព។

រាំងស្ងួតបានកំណត់កន្លែងជាក់ស្តែង និងជាក់លាក់បំផុត ហើយម្យ៉ាងទៀត គឺនៅតំបន់ជាច្រើននៅក្នុងប្រទេស ដែលរួមបញ្ចូលទាំងតំបន់ដែលទទួលរងគ្រោះដោយសារគ្រោះទឹកជន់ផងដែរ។ គ្រោះរាំងស្ងួតបានប៉ះពាល់ដល់តំបន់ មួយចំនួននៅក្នុងឆ្នាំ ២00១, ២00២ និង ២00៣។ ផលប៉ះពាល់ផ្ទាល់មានចំនួនច្រើនដោយសារតែបញ្ហាទឹក លើផលិតផលដំណាំកសិកម្ម ជាពិសេសផលិតផលស្រូវ និងបន្ថែជាមួយដីកសិកម្ម៨0% ដែលធ្វើអោយការដាំដុះលែងបាន រយៈពេល ៦ខែ និង ភ្ជាប់ជាមួយអត្រានៃការឆ្លងរោគ និង ការស្លាប់ដោយសារជម្ងឺបណ្តាលមកពីទឹក។

រាំងស្ងួតធំចុងក្រោយនៅប្រទេសកម្ពុជាបានកើតឡើងនៅឆ្នាំ២00២នៅពេលដែលមានភាពរាំងស្ងួតខុសប្រក្រតីក្នុងរដូវវស្សាបានប៉ះពាល់ដល់ឃុំ ចំនួន ៤២0ឃុំ ក្នុងស្រុកចំនួន ៧៦ស្រុក ក្នុងខេត្ត១0 រួមមាន: ខេត្តព្រៃវែង កណ្តាល កំពង់ស្ពឺ តាកែវ ស្វាយរៀង កំពង់ធំ កំពង់ចាម ក្រចេះ ឧត្តរមានជ័យ និង បន្ទាយមានជ័យ។ គ្រោះរាំងស្ងួតបន្តរហូតដល់ពាក់កណ្តាលខែសីហា ដែលជា

រយៈពេលនៃរដូវវស្សាធ្វើឱ្យខូចខាតផ្ទៃដីដំណាំស្រូវ ៦២,៧០២ ហិកតា។ តាមស្ថិតិដែលគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយដកស្រង់បាន គឺមានប្រជាជនជាង ២,០៤៧,៣៤០លាននាក់ ស្មើនឹង ៤៤២,៤១៩គ្រួសារ បានទទួលរងគ្រោះដោយសារគ្រោះរាំងស្ងួត ហើយគឺជាគ្រោះរាំងស្ងួតដ៏ធ្ងន់ធ្ងរបំផុត ដែលជះ ឥទ្ធិពលដល់ប្រទេសជាតិ។ តាមការប៉ាន់ប្រមាណពីការខូចខាតដែលបណ្តាលមកពីគ្រោះរាំងស្ងួត គឺមានចំនួនទឹកប្រាក់ ច្រើនជាងគ្រោះមហន្តរាយដោយ សារទឹកជំនន់។

- **គ្រោះរាំងស្ងួតខាងឧតុនិយម**

តែងតែទាក់ទងនឹងការថយចុះខ្លាំងនៃទឹកភ្លៀងជាធម្មតានៅក្នុងតំបន់មួយ និងកំរិតអង្សាជាមូលដ្ឋានឡើងខ្ពស់ (បើប្រៀបធៀបនឹងកំរិតអង្សាកំដៅជាមធ្យម) និង រយៈពេលនៃការឡើងកំដៅ។ អត្ថន័យនៃគ្រោះរាំងស្ងួត ខាងឧតុនិយម គឺជាការកំនត់ទៅតាមតំបន់។ នៅក្នុងប្រទេសឥណ្ឌា គ្រោះរាំងស្ងួតខាងឧតុនិយម ជាការកើតឡើងនៅពេលដែលតំបន់មួយ បានទទួលទឹកភ្លៀងតាមរដូវតិចជាង ៧៥% នៃកំរិតជាមធ្យមក្នុងរយៈពេលយូរ។ ចំនែកឯនៅក្នុងប្រទេសហ្វីលីពីនវិញ តំបន់មួយដឹងថាកំពុងទទួលរងគ្រោះរាំងស្ងួតនោះ គឺនៅពេលដែលទឹកភ្លៀងមានកំរិតស្មើនឹង ៤0% ក្រោមកំរិតមធ្យមនៃ រយៈពេល 0៣ខែជាប់គ្នា បើប្រៀបធៀបទៅនឹងស្ថិតិទឹកភ្លៀងប្រចាំខែកន្លងទៅនៅក្នុងតំបន់នោះ ។

- **គ្រោះរាំងស្ងួតខាងជលសាស្ត្រ**

សំដៅលើការរីងហួតដែលគួរអោយកត់សំគាល់ទៅលើផ្ទៃទឹក (ទន្លេ បឹង ស្ទឹង និង អាងស្តុកទឹក) និង សំដៅលើការមិនមានទីរ៉ូទឹកនៅក្រោមផ្ទៃដី។ ភាពកើតមានជារឿយៗ និងភាគច្រើននៃគ្រោះរាំងស្ងួតខាងជលសាស្ត្រ គឺតែងតែកំណត់លើទីជំរាល ឬ កំរិតដែនផ្ទៃទឹកទន្លេ។ ប្រសិនបើទឹកហូរជាក់លាក់នៃកំឡុងពេលណាមួយដែលយើងបានកំណត់នោះមានការធ្លាក់ចុះនៅក្រោមកំរិតអប្បបរមាមួយនោះគ្រោះរាំងស្ងួតខាងជលសាស្ត្រ ពិតជាកំពុងកើតមានឡើងហើយ។

- **គ្រោះរាំងស្ងួតខាងកសិកម្ម**

កើតមានឡើងនៅពេលដែលគ្មានសំនើមដីគ្រប់គ្រាន់ និងមានទឹកភ្លៀងមិនគ្រប់គ្រាន់សំរាប់ដាំដំណាំ។ វាជាឥទ្ធិពលមកពីគ្រោះរាំងស្ងួតខាងឧតុនិយម និងជលសាស្ត្រ ទៅលើដំណាំដែលមិនមានសំណើមគ្រប់គ្រាន់ក្នុងការថែទាំទិន្នផល និងការ លូតលាស់ជាមធ្យមនៃដំណាំ។ ឥទ្ធិពលនៃគ្រោះរាំងស្ងួតខាងកសិកម្មមានភាពពិបាកក្នុងការវាស់វែងដោយសារតែភាពសាំញ៉ាំ នៃការលូតលាស់របស់ដំណាំ និងការកើតមាននៃកត្តានានាដូចជា:ដំណាំមានសត្វល្អិតចង្រៃ សំបូររុក្ខជាតិគ្មានប្រយោជន៍ គុណភាពដីអន់ថយ និងដំណាំមានតំលៃចុះថោក។

រូបភាពទី២: ផែនទីឃុំដែលប្រឈមគ្រោះរាំងស្ងួត



១.៣ ជម្ងឺរាតត្បាត

ប្រទេសកម្ពុជាមានប្រវត្តិការកើតមានជម្ងឺ និងរោគរាតត្បាតមានដូចជា ជម្ងឺអាសន្នរោគ គ្រុនចាញ់ គ្រុនឈាម ហើយពេលថ្មីៗនេះមានវីរុសគ្រុន ផ្តាសាយបក្សី (H5N1) ទៀតផង។ កង្វល់អំពីវីរុសគ្រុនផ្តាសាយបក្សី (H5N1) ដែលបានកើត

យ៉ាងខ្លាំងកាលពីប៉ុន្មានឆ្នាំកន្លងទៅថ្មីៗនេះ ហើយបានគំរាមកំហែងយ៉ាងសាហាវនៅតាមជនបទក្នុងខេត្តភាគខាងត្បូងនៃប្រទេសកម្ពុជា។ នៅឆ្នាំ២០០៥ ប្រទេសកម្ពុជាបានជួបប្រទះនូវការផ្ទុះនៃវីរុស គ្រុនផ្តាសាយបក្សី ទៅលើសត្វមាន់-ទា ដែលធ្វើឱ្យប្រទេសកម្ពុជាជាប្រទេសមួយស្ថិតក្នុងចំណោមប្រទេសជាច្រើនក្នុងតំបន់ដែលជួបប្រទះ នឹង ការផ្ទុះឡើងនូវជម្ងឺបែបនេះដែរ។ ចាប់តាំងពីពេលនោះមកមាន ១០ករណី ដែលត្រូវបានគេអះអាងថាបានឆ្លង មកមនុស្ស ហើយបណ្តាលឱ្យស្លាប់មនុស្ស០៨នាក់ ជម្ងឺផ្តាសាយបក្សីខុសពីជម្ងឺផ្តាសាយថ្មី H1N1 ដែលមនុស្សភាគច្រើនមានជម្ងឺស្រាលដូចជាជម្ងឺផ្តាសាយតាមរដូវ។ ជម្ងឺផ្តាសាយថ្មី H1N1 ឆ្លងពីមនុស្សទៅមនុស្ស ដូច្នេះមនុស្សភាគច្រើនសឹងងាយឈឺ (សេក្តីប្រកាសព័ត៌មាន ២១/០៤/២០១០)។

១.៤ ខ្យល់ព្យុះ

ខ្យល់ព្យុះ ឬ ព្យុះសង្ឃរា មិនត្រូវបានចាត់ទុកថាជាបញ្ហាធំដុំសម្រាប់ប្រទេសកម្ពុជាឡើយ ពីព្រោះប្រទេសកម្ពុជាត្រូវបានហ៊ុំព័ទ្ធជុំវិញដោយជួរភ្នំ។ ទោះបីយ៉ាងណាក៏ដោយ តំបន់ជាច្រើននៅក្នុងប្រទេសកម្ពុជា តែងទទួលរងការគំរាមកំហែង និងទទួលការប៉ះពាល់ដោយសារឥទ្ធិពលនៃខ្យល់ព្យុះដែលបក់ពីប្រទេសចិន ពីលីពិន និង ប្រទេសវៀតណាម នៅរដូវវស្សា ពីមេសាដល់ខែ វិច្ឆិការ ខ្យល់ព្យុះត្រូពិកក៏អាចធ្វើអោយប៉ះពាល់ដល់ក២ិតកំពស់ទឹក ដែលបណ្តាលអោយមាន ទឹកជន់ទឹកទន្លេមេគង្គ ដូចដែលបានជួបប្រទះក្នុងបណ្តាឆ្នាំកន្លងមក។

នៅក្នុងឆ្នាំ ១៩៩៧ ខ្យល់ព្យុះឈ្មោះលីនដា បានបក់ហោកទៅលើកោះពូលូវ៉ៃនៅឆ្នេរភាគខាងត្បូងប្រទេសហើយបណ្តាលឱ្យមានការខូចខាតទូកនេសាទចំនួន ៨១គ្រឿង និងអ្នករងគ្រោះរាប់រយគ្រួសារ។ នៅក្នុងឆ្នាំ ១៩៩៩ មានខ្យល់ព្យុះ ចំនួន០២ ដែលបក់ហោកកាត់រាជធានីភ្នំពេញ និងខេត្តកណ្តាល បណ្តាលឱ្យខូចខាតផ្ទះសំបែងជិត ៥០០ខ្នង។ ចាប់ពីខែមេសា ដល់ខែសីហា ឆ្នាំ២000 មានខ្យល់ព្យុះមូសុងមួយបានបក់ហោកទៅលើខេត្តចំនួន០៥ បណ្តាលខូចខាតផ្ទះ សំបែងមួយចំនួនធំ។ នៅក្នុងឆ្នាំ ២00១ ខេត្ត-ក្រុងចំនួន ០៦ ត្រូវបានទទួលរងគ្រោះដោយខ្យល់ព្យុះដែលបានបំផ្លាញ ផ្ទះសំបែងចំនួន ៧៤៣ខ្នង សាលារៀន ៦ និង វត្តចំនួន ២។ នៅឆ្នាំ ២00៧ គ្រោះមហន្តរាយដែលបង្កដោយខ្យល់ព្យុះ បណ្តាលឱ្យមានការខូចខាតដល់ ទ្រព្យសម្បត្តិ និងអាយុជីវិតប្រជាជនជាពិសេសភូមិភាគឦសាន ពាយ័ព្យ និងតំបន់ ឆ្នេរសមុទ្រនៅប្រទេស ដែលមាន ១១ ខេត្ត-ក្រុង ក្នុងនោះមាន ខេត្តបាត់ដំបង កំពង់ស្ពឺ បន្ទាយមានជ័យ កំពត ស្វាយរៀង សៀមរាប ព្រៃវែង កំពង់ធំ កំពង់ចាម កណ្តាល និង កោះកុង ដែលកើតមាន ៥៦លើក រលំផ្ទះ ៥៨៤ខ្នង និង រលើកដំបូល ១,១១២ខ្នង។

នៅចុងឆ្នាំ ២00៩ នៅចន្លោះ ពីថ្ងៃទី ២៦ ខែ កញ្ញា ដល់ថ្ងៃទី ០៥ ខែតុលា ឆ្នាំ២00៩ ខ្យល់ព្យុះកេតសាណា (Ketsana) បានហោកបក់មកលើប្រទេសកម្ពុជាដោយបានកំទេចផ្ទះសំបែងរបស់ប្រជាពលរដ្ឋអស់ជាច្រើនខ្នង បង្កការខូចខាតដល់សំណង់អគារជាច្រើន និងបណ្តាលអោយមានទឹកជន់ន់យ៉ាងខ្លាំង មុនពេលដែលខ្យល់ព្យុះនេះបន្ថយឥទ្ធិពលរបស់ខ្លួន ទៅជាសម្ពាធត្រូពិចវិញ ជាមួយនឹងកម្លាំងខ្យល់មានល្បឿនយឺតជាងមុន និងមានភ្លៀងធ្លាក់ជោគជាំយ៉ាងខ្លាំង។ យោងតាម គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ (NCDM) ខេត្តចំនួន ១៤ ក្នុងចំណោមខេត្តទាំង ២៤ បានទទួលរងឥទ្ធិពលពី ខ្យល់ព្យុះ និងទឹកជន់ន់ ដែលបានកើតឡើងភ្លាមៗជាបន្តបន្ទាប់នោះ។ ខ្យល់ព្យុះនេះ បានធ្វើអោយមានមនុស្សស្លាប់ចំនួន ៤៣ នាក់ រងរបួសធ្ងន់ចំនួន ៨៧ នាក់ និងប្រជាពលរដ្ឋប្រហែល ៤៩.៧៨៧ គ្រួសារបាត់បង់ផ្ទះសំបែង និងប្រាក់ចំណូលដើម្បី ចិញ្ចឹមជីវិត។ មានប្រជាពលរដ្ឋចំនួន ១៨0.000 នាក់ដែលទទួលរងឥទ្ធិពល (ទាំងដោយផ្ទាល់ និង ដោយប្រយោល) ដែល ស្មើនឹង ១,៤% នៃប្រជាជនសរុប។

ស្រុកភាគច្រើនដែលទទួលការខូចខាតគឺស្ថិតនៅក្នុងចំណោមស្រុកក្រីក្របំផុតនៅក្នុងប្រទេស។ ការខូចខាតយ៉ាងខ្លាំងដល់ទ្រព្យសម្បត្តិ ជីវភាពរស់នៅ និងហេដ្ឋារចនាសម្ព័ន្ធសាធារណៈនៅក្នុង តំបន់ទាំងនោះ នឹងមានផលប៉ះពាល់រយៈពេលវែងទៅលើការរស់នៅ របស់សហគមន៍។

គ្រោះមហន្តរាយធម្មជាតិកាលពីអតីតកាល មានផលប៉ះពាល់គួរអោយកត់សម្គាល់នៅក្នុងតំបន់ជនបទដែលមានប្រជាជន ប្រមាណ ៧៩.៨ ភាគរយ ត្រូវបានប៉ាន់ស្មានថារស់នៅក្នុងតំបន់ក្រីក្រទាំងនោះ (CSES, 2007)។ ទឹកដីប្រទេស កម្ពុជាប្រហែល ៨០ ភាគរយលាតសន្ធឹងនៅក្នុងអាងទន្លេមេគង្គ និងទន្លេសាប ដែលត្រូវបានស្គាល់ថាមានការប្រែប្រួលកម្ពស់ ទឹករវាងរដូវប្រាំង និងរដូវវស្សា។ កត្តានេះបណ្តាលអោយមានវដ្តប្រចាំឆ្នាំនៃគ្រោះរាំងស្ងួត និងទឹកជំនន់ដែលបង្ករការ ខូចខាតដល់ផលិតកម្មកសិកម្ម និងជីវភាពរបស់ប្រជាពលរដ្ឋ និងជាកត្តារាំងស្ទះដល់កំណើនសេដ្ឋកិច្ច និងការកាត់បន្ថយ ភាពក្រីក្រទៀតផង។ មានការ ប៉ាន់ស្មានថាគ្រោះទឹកជំនន់បានលេបត្រុចាក់ជីវិតមនុស្សប្រហែល ១00 នាក់ជារៀងរាល់ឆ្នាំ និងបង្ករការខាតបង់ផ្នែកកសិកម្ម អស់ទឹកប្រាក់ពី ១00 ទៅ ១៧0 លានដុល្លារអាមេរិកជារៀងរាល់ឆ្នាំ។

- **ការខូចខាត និងការខាតបង់ដោយសារខ្យល់ព្យុះ កេតសាណា**

ការខូចខាត និងការខាតបង់ដែលបណ្តាលមកពីខ្យល់ព្យុះកេតសាណានៅក្នុងប្រទេសកម្ពុជា ត្រូវផ្តោតទៅលើ ខេត្តស្ទឹងត្រែង ភាគខាងត្បូងខេត្តព្រះវិហារ ភាគខាងជើងខេត្តកំពង់ធំ (ដែលរងការខូចខាតធ្ងន់ធ្ងរបំផុត) និងភាគខាងលិច ខេត្តសៀមរាប។ ខ្យល់ព្យុះនេះបាននាំមកជាមួយនូវទឹកជំនន់ភ្លាមៗដែលជន់លិចភាគជាច្រើននៃខេត្តរតនៈគីរី មណ្ឌលគីរី ក្រចេះ ឧត្តរមានជ័យ បន្ទាយមានជ័យ បាត់ដំបង កំពង់ចាម កំពង់ឆ្នាំង ព្រះសីហនុ និងកំពត ដោយបន្ថែមការខូចខាត និងការខាតបង់ កាន់តែច្រើនឡើងថែមទៀត។

ដោយទទួលស្គាល់ឥទ្ធិពលរយៈពេលវែងរបស់ខ្យល់ព្យុះនេះ ទៅលើប្រជាជនដែលងាយរងគ្រោះនោះ រដ្ឋាភិបាលដែលតាម រយៈក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (MEF) ព្រមទាំងគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ (NCDM) ដោយមានជំនួយ ពីសំណាក់ធនាគារពិភពលោក និងស្ថិតក្នុងភាពជាដៃគូជាមួយបណ្តាដៃគូអភិវឌ្ឍន៍ដទៃទៀត បានធ្វើការវាយ តម្លៃការខូចខាត ការខាតបង់ និងតម្រូវការ បន្ទាប់ពីមានគ្រោះមហន្តរាយ (PDNA) ដ៏ទូលំទូលាយដើម្បីរកអោយឃើញ វិសាលភាពនៃការខូចខាត និងការខាតបង់ដែលបណ្តាលមកពីគ្រោះមហន្តរាយនេះ ព្រមទាំងដើម្បីកំណត់ផែនការស្តារ ឡើងវិញ ដែលមានលក្ខណៈទូលំទូលាយ និងអាចអនុវត្តបាន។ PDNA បានប៉ាន់ស្មានថាការខូចខាត និងការខាតបង់សរុប ដែលបណ្តាលមកពីខ្យល់ព្យុះកេតសាណានេះ គិតជាទឹកប្រាក់មានចំនួន ១៣២ លានដុល្លារអាមេរិក ដែលក្នុងចំនួននេះ ការខូចខាតគិតជាទឹកប្រាក់ចំនួន ៥៨ លានដុល្លារអាមេរិក និងការខាតបង់គិតជាទឹកប្រាក់ចំនួន ៧៤ លានដុល្លារអាមេរិក។

តារាង១ បង្ហាញអំពីសេចក្តីសង្ខេបទូទៅនៃការខូចខាត និងការខាតបង់ដែលត្រូវបានបែងចែកទៅតាមវិស័យ ផ្សេងៗ។ ពាក់ព័ន្ធនឹងចំណែកនៃការខូចខាត និងការខាតបង់សរុប វិស័យផលិតភាពមានចំណែកភាគរយខ្ពស់ជាងគេ (៥៦%) បន្ទាប់មកតាម វិស័យសង្គម (២៦%) និងហេដ្ឋារចនាសម្ព័ន្ធ (១៨%) ចំណែកឯវិស័យបន្ទាប់បន្សំមានផលប៉ះ ពាល់តិចតួចបំផុតអាចកាត់ចោលបាន បើប្រៀបធៀបនឹងវិស័យដទៃទៀត។

តារាង ១ : សេចក្តីសង្ខេបការខូចខាត និងការខាតបង់ (DALA)			
វិស័យ និងអនុវិស័យ	ផលប៉ះពាល់នៃគ្រោះមហន្តរាយ គិតជាដុល្លារអាមេរិក		
	ការខូចខាត	ការខាតបង់	សរុប
ហេដ្ឋារចនាសម្ព័ន្ធ	**១៧.២៥៩.០៥១**	**១១.៤៨៧.៥៧៧**	**២៨.៧៤៦.៦២៨**
ដឹកជញ្ជូន	១៤.៣៨៨.៨៣២	១១.០៧៦.៦៩៨	២៥.៤៦៥.៥៣០
ផ្គត់ផ្គង់ទឹក និងអនាម័យ	៦៤.៣៣៩	៣៩២.៦៨៩	៤៥៧.០២៨
គ្រប់គ្រងទឹក និងធារាសាស្ត្រ	២.៧៧៩.០០០	១៣.០០០	២.៧៩២.០០០
ចាមពល	២៦.៨៨០	៥.១៩០	៣២.០៧០
វិស័យសង្គម	**៣៩.៥៤៨.៥៦៣**	**៣.៣៣៣.៨១៣**	**៤២.៨៨២.៣៧៦**
ការផ្តល់លំនៅដ្ឋាន និងទីជម្រក	១៥.២៨១.៩៥២	៣.២៩៤.៣៩៨	១៨.៥៧៦.៣៥០
សុខាភិបាល	៥៧.០៧២	៣៩.៤១៥	៩៦.៤៨៧
ការអប់រំ	២៤.២០៩.៥៣៩		២៤.២០៩.៥៣៩
វិស័យផលិតភាព	**១.០៥១.១២៤**	**៥៩.០០៨.១៦២**	**៦០.០៥៩.២៨៦**
កសិកម្ម បសុសត្ត និងនេសាទ	៩១.២៧០	៥៦.៤២០.៨៤៦	៥៦.៥១២.១១៦
ឧស្សាហកម្ម និងពាណិជ្ជកម្ម	៩៥៩.៨៥៤	២.៥៨៧.៣១៦	៣.៥៤៧.១៧០
វិស័យបន្ទាប់បន្សំ	**២០៥.៣៥៨**	**១០២.៧៦៧**	**៣០៨.១២៥**
បរិស្ថាន	៣១.០៧៣	៩៨.៣៦៧	១២៩.៤៤០
រដ្ឋបាលសាធារណៈ	១៧៤.២៨៥	៤.៤០០	១៧៨.៦៨៥
សរុប	**៥៨.០៦៤.០៩៦**	**៧៣.៩៣២.៣១៩**	**១៣១.៩៩៦.៤១៥**

ផលប៉ះពាល់ធំបំផុតនៅក្នុងវិស័យផលិតភាព គឺកើតមានលើវិស័យកសិកម្ម បសុសត្ត និងនេសាទ។ វិស័យកសិកម្ម តែងកងផ្តល់ផលិតផលក្នុងស្រុកសរុប (GDP) ច្រើនរបស់ប្រទេសកម្ពុជាច្រើនជាង ៣០ ភាគរយ ហើយក៏ជាផ្នែកដ៏សំខាន់ក្នុងការគាំទ្រសេដ្ឋកិច្ចជនបទពាក់ព័ន្ធនឹងការផ្តល់សន្តិសុខស្បៀង។ ខ្យល់ព្យុះនេះបានជះឥទ្ធិពលលើខេត្តចំនួន ១០ ដោយបានបំផ្ទិចបំផ្លាញដំណាំស្រូវចំនួន ៤០.១៣៦ ហិចតា និងធ្វើអោយខូចខាតចំនួន ៦៧.៣៥៥ ហិចតាដែលសុទ្ធតែមុនពេល ប្រមូលផលបន្តិច។ ការខាតបង់ផលិតកម្មសាច់ដែលមានសក្តានុពលនោះ ក៏មានកម្រិតខ្ពស់ផងដែរ ដោយធ្វើអោយ DaLa សរុបសម្រាប់វិស័យនេះ មានទឹកប្រាក់ចំនួន ៥៦ លានដុល្លារអាមេរិក ។ នៅក្នុងវិស័យឧស្សាហកម្ម និងពាណិជ្ជកម្ម មីក្រូសហគ្រាស និងកសិសហគ្រាស ដែលដើរតួនាទីយ៉ាងសំខាន់នៅក្នុងការអភិវឌ្ឍសេដ្ឋកិច្ចជាតិ ត្រូវបានទទួលរងផល ប៉ះពាល់ធ្ងន់ធ្ងរបំផុតពីខ្យល់ព្យុះនេះ។

ការខូចខាត និងការខាតបង់ហេដ្ឋារចនាសម្ព័ន្ធត្រូវបានផ្តោតទៅលើ**វិស័យដឹកជញ្ជូន**។ ខ្យល់ព្យុះនេះ បានបង្ករការខូចខាតដល់ប្រព័ន្ធផ្លូវថ្នល់ នៅក្នុងខេត្តចំនួន ១៨ (ផ្លូវក្នុងក្រុង ផ្លូវជាតិ ផ្លូវខេត្ត និងផ្លូវជនបទ) ។ ការខាតបង់ជាចម្បង គឺបណ្តាលមកពីការចំណាយកាន់តែខ្ពស់ទៅលើដំណើរការយានយន្ត និងពេលវេលាដឹកជញ្ជូនទំនិញ និងអ្នកដំណើរកាន់តែមានរយៈពេលយូរ ដែលពាក់ព័ន្ធនឹងស្ថានភាពផ្លូវដុនដាប។ ផលប៉ះពាល់នៃការខូចខាតនេះ មានលក្ខណៈគួរអោយកត់សម្គាល់ ជាពិសេសដោយសារវិស័យស្ពានថ្នល់ មានតួនាទីយ៉ាងសំខាន់នៅក្នុងការផ្តល់ច្រក ចូលទៅដល់ប្រជាជន ដែលរស់នៅតាមទីជនបទ និងមានសារសំខាន់ដើម្បីឈានទៅសម្រេចគោលបំណងធ្វើអោយមានកំណើនសេដ្ឋកិច្ច និង កាត់បន្ថយភាពក្រីក្រ។

ចំពោះ**ការគ្រប់គ្រងទឹក និងធារាសាស្ត្រ** ការខូចខាតគឺភាគច្រើនដោយសារការយកថ្មចេញពីក្បាលប្រឡាយនៅតាមបណ្តាញខ្សែទឹក ដោយសារលំហូរខ្សែទឹកដែលមានល្បឿនលឿន និងការចម្រោះថ្មកំបោរតាមជម្រាលមាត់ប្រឡាយ។ ជាចុងក្រោយ ការខូចខាត និងការខាតបង់ដែលទទួលរងនៅក្នុងវិស័យ**ផ្គត់ផ្គង់ទឹក និងអនាម័យ** មានការប្រែប្រួលនៅតាមបណ្តាខេត្តដែលទទួល

ឥទ្ធិពលដោយមានផលប៉ះពាល់ធំបំផុតនៅក្នុងខេត្តកំពង់ធំ ស្ទឹងត្រែង និងក្រចេះ។ ការខូចខាតលើបណ្តាញលូដែលនាំអោយមានការបង្ហាក់ដល់ការផ្គត់ផ្គង់ទឹក និងជះឥទ្ធិពលដល់ការបង្កើតប្រាក់ចំណូល គឺជាបុព្វហេតុ ដ៏ចម្បងនៃការខូចខាត និងការខាតបង់ចំពោះប្រព័ន្ធផ្គត់ផ្គង់ទឹកនៅក្នុងទីក្រុង។ នៅតាមតំបន់ជនបទ ផលប៉ះពាល់មាន ភាគច្រើនគឺដោយសារទឹកជំនន់ជន់លិចអណ្តូងលូ និងបង្គន់ និងការស្រុតដីទាបជាងបាតអណ្តូង ដែលនាំអោយមានការប្រេះ ហើយជាចុងក្រោយបណ្តាលអោយផុលទឹកច្រាលឡើងលើ។

នៅក្នុង**វិស័យសង្គម** ការខូចខាត និងការខាតបង់មានទំហំធំបំផុតនៅក្នុងវិស័យអប់រំ បន្ទាប់មកគឺលំនៅស្ថាន និង សុខភាព។ សាលារៀនជាច្រើនត្រូវបានរងការខូចខាតយ៉ាងខ្លាំងដោយសារខ្យល់ព្យុះកេតសាណា (សាលារៀនចំនួន ១២% នៅក្នុងប្រទេសកម្ពុជាត្រូវបានទទួលរងឥទ្ធិពលនេះ) ហើយសាលារៀនជាច្រើនចាំបាច់ត្រូវបានបិទទ្វារដោយសារទឹកជំនន់ ដោយផ្ទាល់ ឬដោយគ្មានលទ្ធភាពចូលទៅដល់បរិវេណសាលារៀន។ គុណភាពអន់របស់កម្រាលឥដ្ឋធ្វើពីបេតុងមិនបានបង្ហាប់ បានល្អ ដែលយកមកប្រើប្រាស់ក្នុងការសាងសង់អគារសាលារៀន និងក្បឿនប្រក់ដំបូលដែលមិនបានតំរៀបអោយត្រូវជ្រុងគ្នា ល្អគឺជាបុព្វហេតុដ៏ចម្បងនៃការខូចខាតអគារសាលារៀន។ ចំពោះករណីផ្ទះសំបែង ខេត្តកំពង់ធំ ព្រះវិហារ រតនគីរី និងក្រចេះ ត្រូវបានរងឥទ្ធិពលធ្ងន់ធ្ងរបំផុត។ នៅក្នុងវិស័យសុខាភិបាល ខណៈដែលមណ្ឌលសុខភាពភាគច្រើននៅល្អជាធម្មតា បញ្ហាដែល ប្រជាជនងាយរងគ្រោះមានការលំបាកក្នុងការទទួលបានសេវាថែទាំសុខភាពដែលមានស្រាប់នោះ កាន់តែធ្ងន់ធ្ងរបន្ថែមទៀត ដោយសារផលប៉ះពាល់នៃខ្យល់ព្យុះកំណាចនេះ និងទឹកជំនន់ជាបន្តបន្ទាប់ ។

- **ផលប៉ះពាល់ផ្នែកម៉ាក្រូសេដ្ឋកិច្ច**

ដោយមានផលប៉ះពាល់ភាគច្រើនទៅលើដំណាំស្រូវ ប៉ុន្តែផលប៉ះពាល់តិចតួចទៅលើប្រភពកំណើនដទៃទៀតនោះមានការប៉ាន់ស្មានថា ខ្យល់ព្យុះនេះបានបង្ករអោយមានការខាតបង់គិតជាទឹកប្រាក់ចំនួន ១៧ លានដុល្លារអាមេរិក (៦៩ ពាន់លានរៀល) នៃតម្លៃបន្ថែមទៅលើផលិតផលក្នុងស្រុកសរុប។ ការខូចខាតដ៏គួរអោយកត់សម្គាល់នេះ បានធ្វើអោយមានការធ្លាក់ចុះកំណើនសេដ្ឋកិច្ចរហូតដល់ចំណុច ០,២% សម្រាប់ឆ្នាំ ២០០៩។ ដូច្នេះការនេះនាំអោយមានការកាត់បន្ថយអត្រា កំណើន សម្រាប់ឆ្នាំ ២០០៩ ដែលបានមកពីការប៉ាន់ស្មានកាលពីដើមឆ្នាំ ពីចំនួន ២,១ % មកនៅត្រឹមតែ ១,៩២ % វិញ។[1]

ផលប៉ះពាល់ទៅលើប្រាក់ចំណូលសារពើពន្ធមិនទំនងជាមានលក្ខណៈគួរអោយកត់សម្គាល់ឡើយ ប៉ុន្តែផលប៉ះពាល់ទៅលើការចំណាយអាចមានសារសំខាន់។ ការផ្តល់ហិរញ្ញប្បទានសម្រាប់សេចក្តីត្រូវការក្នុងរយៈពេលមធ្យម និងរយៈពេលវែងអាចជាផលប៉ះពាល់គួរអោយកត់សម្គាល់ទៅលើលំហាសារពើពន្ធ។ ដូចដែលបានពន្យល់នៅក្នុងសេចក្តីព្រាងច្បាប់ ថវិកាសម្រាប់ឆ្នាំ ២០១០ ដែលបានដាក់ជូនរដ្ឋសភាកាលពីខែធ្នូនោះ ប្រាក់ចំណូលជារួមនៅក្នុងឆ្នាំ ២០០៩ អាចមានតិចជាងបណ្តាឆ្នាំមុនៗ ដោយសារកំណើនសេដ្ឋកិច្ចដែលមានល្បឿនកាន់តែយឺតយ៉ាវ ចំណែកឯការចំណាយចាំបាច់ជារួមនៅក្នុងឆ្នាំ ២០០៩ នឹងកាន់តែខ្ពស់ជាងបណ្តាឆ្នាំមុនៗ។ ដូចនេះ ការផ្តល់ហិរញ្ញប្បទានដែលត្រូវការជាចាំបាច់ដើម្បីកសាងហេដ្ឋារចនា សម្ព័ន្ធរូបវ័ន្តឡើងវិញ និងស្តារជីវភាពរស់នៅនឹងបង្កើនឱនភាព។ ហេតុដូច្នេះ តម្រូវអោយមានការផ្តល់ហិរញ្ញប្បទានបន្ថែម ទាំងក្នុងស្រុក និងពីបរទេស។

[1] ប្រសិនបើតួលេខដែលបានព្យាករណ៍ចេញពីស្ថាប័នដទៃត្រូវបានប្រើប្រាស់ និងប្រើប្រាស់ចំណុច ០,២ %នៃការធ្លាក់ចុះកំណើននោះ កំណើន សម្រាប់ឆ្នាំ ២០០៩ គឺ IMF (-២,៥) WB (-២,៤) ADB (-១,៧)

- **ផលប៉ះពាល់ទៅលើជីវភាពរស់នៅ និងផលប៉ះពាល់វិស័យផ្សេងទៀត**

កម្រិតភាពក្រីក្រនៅក្នុងខេត្តទាំង ១៤ ដែលរងការបំផ្ទិចបំផ្លាញដោយខ្យល់ព្យុះកេតសាណា មានកម្រិតខ្ពស់ជាងកម្រិតមធ្យមរបស់ជាតិ ហើយខ្យល់ព្យុះនេះនឹងធ្វើអោយវិសមភាពនោះមានការកើនឡើង ។ ចំណូលរបស់គ្រួសារនៅក្នុង ខេត្តទាំងនេះ ពឹងផ្អែក ជាចម្បងទៅលើការធ្វើស្រែចំការ និងការទទួលបានភោគទ្រព្យពីធម្មជាតិ ដូចជាត្រី និងផលិតផល ព្រៃឈើ ដែលមិនមែនជាឈើហ៊ុប (NTFPs) ដើម្បីចិញ្ចឹមជីវិត។ រាល់សកម្មភាពទាំងអស់នេះ ភាគច្រើនបានរងផលប៉ះពាល់ ពីខ្យល់ព្យុះនេះ។ ស្ថានភាពទាំងនេះអាចនឹងកាន់តែធ្ងន់ធ្ងរនៅក្នុងឆ្នាំ ២០១០ ដោយសារមុនកើតមានខ្យល់ព្យុះនេះមាន ប្រជាជនប្រមាណ ៤៥.000 គ្រួសារបាន និងកំពុងរងគ្រោះដោយសារកង្វះស្បៀងអាហារ[២] រួចទៅហើយ ហើយសមាមាត្រ ដ៏ធំនៃដំណាំស្រូវ ដែលអាចត្រូវបានប្រមូលផលនៅក្នុងខែវិច្ឆិកា និងខែធ្នូ ឆ្នាំ២00៩ នេះ ត្រូវរងការខូចខាត និងបំផ្ទិចបំផ្លាញអស់។ ដូចនេះនឹងនាំអោយបាត់បង់ការងារដែលធ្លាប់តែធ្វើនៅពេលទំនេរពីការងារស្រែចំការ បន្ទាប់ពីការប្រមូលផលស្រូវ ដែលប្រកបដោយសក្តានុពលមក។ ការវាយតម្លៃបានបង្ហាញថា នៅក្នុងភូមិ ឬឃុំមួយ ក្រុមប្រជាជន និងគ្រួសារក្រីក្របំផុត ដែលដំណាំស្រូវរបស់ខ្លួនត្រូវបានបំផ្ទិចបំផ្លាញទាំងស្រុងនោះ គឺជាក្រុមដែលងាយរងគ្រោះខ្លាំងបំផុត ជាទូទៅគឺគ្រួសារដែល មានស្ត្រី មនុស្សចាស់ជាមេគ្រួសារ និងគ្រួសារដែលមានសមាជិកពិការ។ ក្រុមជនជាតិដើមដែលរស់នៅក្នុងតំបន់ខ្ពស់រាប ខេត្តរតនគីរី មណ្ឌលគីរី ស្ទឹងត្រែង និងកំពង់ធំ ក៏ស្ថិតនៅក្នុងចំណោមប្រជាជនដែលងាយរងគ្រោះបំផុតផងដែរ។

- **លក្ខខ័ណ្ឌតម្រូវ សម្រាប់ការគ្រប់គ្រងគ្រោះមហន្តរាយ**

ខ្យល់ព្យុះកេតសាណាផ្តល់ឱកាសដល់ប្រទេសកម្ពុជា ដោយសារគ្រោះមហន្តរាយនេះបានធ្វើអោយលេចឡើងនូវវិស័យជាមូលដ្ឋានមួយចំនួនសម្រាប់កំណែទម្រង់នៅក្នុងប្រព័ន្ធឆ្លើយតបគ្រោះអាសន្ន និងការកាត់បន្ថយគ្រោះภัយនៃគ្រោះមហន្តរាយរបស់ប្រទេសកម្ពុជា។ ដំណើរការប្រមូល និងគ្រប់គ្រងទិន្នន័យនៅក្នុងការវាយតម្លៃការខូចខាត និងការខាតបង់ និងនៅក្នុងការតាមដានជំនួយគ្រោះអាសន្ន គួរតែត្រូវបានកែលម្អអោយកាន់តែប្រសើរឡើង រួមជាមួយនឹងសកម្មภาพกสางสมត្ថภาพสម្រាប់ក្រសួងពាក់ព័ន្ធ និងគណៈកម្មាធិការជំនួយគ្រោះមហន្តរាយថ្នាក់ជាតិ និងថ្នាក់មូលដ្ឋាន ដើម្បីសម្របសម្រួលការចូលរួមរបស់ខ្លួននៅក្នុងដំណើរការស្តារឡើងវិញនេះ។ ប្រព័ន្ធប្រកាសអាសន្នរបស់ប្រទេសកម្ពុជា គួរតែត្រូវបានវាយតម្លៃ ហើយគួរតែមានការវិនិយោគទៅការកែលម្អប្រព័ន្ធនេះអោយមានภาพประเสริฐ។ ការគ្រប់គ្រងការកាត់បន្ថយគ្រោះภัยនៃគ្រោះមហន្តរាយគួរតែត្រូវបានដាក់បញ្ចូលទៅក្នុងសកម្មภาพ និង គោលនយោបាយរបស់ក្រសួងពាក់ព័ន្ធរបស់ប្រទេសកម្ពុជា ហើយកិច្ចការបន្ថែមគួរតែត្រូវបានធ្វើឡើង ដើម្បីពង្រឹងមូលដ្ឋានស្ថាប័ន និងមូលដ្ឋានច្បាប់ សម្រាប់ក្របខ័ណ្ឌការគ្រប់គ្រងហានិภัยគ្រោះមហន្តរាយរបស់ប្រទេសកម្ពុជា។

- **លក្ខខ័ណ្ឌតម្រូវសម្រាប់ការស្តារ និងការកសាងឡើងវិញ**

ក្របខណ្ឌស្តារឡើងវិញបន្ទាប់ពីខ្យល់ព្យុះកេតសាណាដែលបានស្នើឡើងសម្រាប់ប្រទេសកម្ពុជា មានគោលបំណងឆ្លើយតបចំពោះតម្រូវការសាងសង់ឡើងវិញ និងការស្តារឡើងវិញរបស់សហគមន៍ដែលទទួលរងផលប៉ះពាល់ ស្របពេលកំពុងបង្កើតមូលដ្ឋានសម្រាប់វិធានការកាត់បន្ថយហានិภัยសម្រាប់រយៈពេលកាន់តែវែង ដើម្បីកាត់បន្ថយផលប៉ះពាល់នៃគ្រោះមហន្តរាយទាំងឡាយនាពេលអនាគត។ ដើម្បីបញ្ជៀសការបង្កើតហានិภัยស្រដៀងគ្នានាពេលអនាគតដល់ប្រជាជន និងសហគមន៍ដំណើរការ

[២] NCDM បទបង្ហាញកាលពីថ្ងៃទី ១0 ខែវិច្ឆិកា ឆ្នាំ ២00៩

ស្តារឡើងវិញ សំដៅដឹកនាំដោយគោលការណ៍គន្លឹះចំនួនបីគឺ (i) តម្លាភាព (ii) គណនេយ្យភាព និងការអនុវត្តដោយ ផ្អែកលើលទ្ធផល និង (iii)វិធីសាស្ត្រដែលធ្វើឡើងនៅសហគមន៍ ដោយយកចិត្តទុកដាក់លើប្រជាជន និងដែលមានសមធម៌ ដើម្បីបន្ធូរបន្ថយហានិភ័យនាពេលអនាគត ។

វិស័យអាទិភាពដែលត្រូវបានកំណត់ដោយការប៉ាន់ប្រមាណសេចក្តីត្រូវការក្រោយគ្រោះមហន្តរាយ (PDNA) សម្រាប់ការស្តារឡើងវិញនេះ រួមមាន**ផ្លូវថ្នល់ កសិកម្ម ធារាសាស្ត្រ ឧស្សាហកម្ម និងពាណិជ្ជកម្ម អប់រំ និងលំនៅដ្ឋាន** ហើយអាទិភាពទាំងនេះត្រូវបានប្រមូលផ្តុំជាក្រុមឡើងវិញអាស្រ័យទៅតាម សេចក្តីត្រូវការរយៈពេលខ្លី (0-6 ខែ) រយៈពេលមធ្យម (១-២ ឆ្នាំ) និងរយៈពេលវែង (១-៥ ឆ្នាំ) ។ តារាងខាងក្រោម (តារាង ២) សង្ខេបអំពីលក្ខខ័ណ្ឌតម្រូវសម្រាប់វិស័យអាទិភាពទាំងនេះ ។

តារាង ២ : តម្រូវការស្តារឡើងវិញ និងការសាងសង់ឡើងវិញ

តារាង ២ : សេចក្តីសង្ខេបតម្រូវការ				
វិស័យ និងអនុវិស័យ	**តម្រូវការស្តារឡើងវិញ គិតជាដុល្លារអាមេរិក**			
	រយៈពេលខ្លី	**រយៈពេលមធ្យម**	**រយៈពេលវែង**	**សរុប**
ហេដ្ឋារចនាសម្ព័ន្ធ	**៧.១១៤.២០៦**	**១៣.៤០៦.៦២៦**	**៨៥.៩៦០.៥១១**	**១០៦.៤៨១.៣៤៣**
ដឹកជញ្ជូន	៥.១២៤.២០៦	៩.២៦៤.៦២៦	៧៦.៣៦០.៥១១	៩០.៧៤៩.៣៤៣
ផ្គត់ផ្គង់ទឹក និងអនាម័យ		៥០០.០០០	៤.២៥០.០០០	៤.៧៥០.០០០
គ្រប់គ្រងទឹក និងធារាសាស្ត្រ	១.៦៩០.០០០	២.៧៩២.០០០	៣.៥០០.០០០	៧.៩៨២.០០០
ថាមពល	៣០០.០០០	៨៥០.០០០	១.៨៥០.០០០	៣.០០០.០០០
វិស័យសង្គម	**១៤.៥៩៣.៧១០**	**២៥.៦៦០.៧៤០**	**២.៦៨០.០០០**	**៤២.៩៣៤.៤៥០**
ការផ្តល់លំនៅដ្ឋាន និងទីជម្រក	១២.០៨៩.០០០	២.០៨៧.៨០០		១៤.១៧៦.៨០០
សុខាភិបាល	៦០៤.៧១០	១.២៦៣.៤០០	២.៦៨០.០០០	៤.៥៤៨.១១០
ការអប់រំ	១.៩០០.០០០	២២.៣០៩.៥៤០		២៤.២០៩.៥៤០
វិស័យផលិតភាព	**៥.៩៦០.០០០**	**១២.៨០០.០០០**	**៤១.២០០.០០០**	**៥៩.៩៦០.០០០**
កសិកម្ម បសុសត្ត និងនេសាទ	៥.០០០.០០០	១០.០០០.០០០	៣៥.០០០.០០០	៥០.០០០.០០០
ឧស្សាហកម្ម និងពាណិជ្ជកម្ម	៩៦០.០០០	២.៨០០.០០០	៦.២០០.០០០	៩.៩៦០.០០០
វិស័យបន្ទាប់បន្សំ	**១៩៦.០៨៥**	**២.៣៩៦.០០០**	**២.៨០៣.៦០០**	**៥.៣៩៥.៦៨៥**
បរិស្ថាន	១៨១.០០០	២.២៣២.៤០០	២.៨០៣.៦០០	៥.២១៧.០០០
រដ្ឋបាលសាធារណៈ	១៥.០៨៥	១៦៣.៦០០		១៧៨.៦៨៥
សរុប	**២៧.៨៦៤.០០១**	**៥៤.២៦៣.៣៦៦**	**១៣២.៦៤៤.១១១**	**២១៤.៧៣១.៤៧៨**
ការគ្រប់គ្រងគ្រោះ មហន្តរាយ				**<u>៨.៩៣៧.០០០</u>**

អាទិភាពនៅក្នុងវិស័យ**ដឹកជញ្ជូន** រួមមានការកសាងឡើងវិញនូវបណ្តាញផ្លូវថ្នាក់ជាតិ ខេត្ត និងនៅជនបទ ដែលរងការខូចខាតពីខ្យល់ព្យុះនេះ និងការបង្កើតបទដ្ឋានជាក់លាក់សម្រាប់ការកសាង និងការថែទាំផ្លូវថ្នល់ ជាពិសេសសម្រាប់តំបន់ងាយទទួលរងគ្រោះពីទឹកជំនន់បំផុត ។

ការស្តារឡើងវិញនូវវិស័យ**កសិកម្ម** មានសារៈសំខាន់ ជាពិសេសដោយមានការគំរាមកំហែងដ៏ខ្លាំងក្លាទៅលើសន្តិ សុខស្បៀងនៅក្នុងបណ្តាខេត្តដែលទទួលរងគ្រោះបំផុត ។ ក្របខ័ណ្ឌស្តារសម្បទាដែលត្រូវបានស្នើឡើងរួមមានសកម្មភាពអាទិភាព ចាប់ពីការបន្ត

ការផ្តល់ជំនួយក្នុងទម្រង់ជាការផ្តល់គ្រាប់ពូជ ជី និងសម្ភារៈ ការបង្កើនផែនការផ្តល់ប្រាក់ដើម្បីការងារ ការផ្តល់ស្បៀងដើម្បីការងារ និងផែនការបង្កើតការងារមូលដ្ឋាន និងការបង្កើតប្រព័ន្ធកសិកម្មដែលធន់នឹងគ្រោះថ្នាក់ ។

តម្រូវការ**ការគ្រប់គ្រងទឹក និងធារាសាស្ត្រ** រួមមានការជួសជុលប្រព័ន្ធធារាសាស្ត្រ ដែលខូចខាតការបង្កើតយុទ្ធសាស្ត្រគ្រប់គ្រងទឹកសម្រាប់ការកាត់បន្ថយហានីភ័យគ្រោះទឹកជំនន់ និងគ្រោះរាំងស្ងួត ព្រមទាំងការបង្កើនបទដ្ឋាន រចនាសម្ព័ន្ធ ដែលធន់នឹងគ្រោះថ្នាក់ ដែលពាក់ព័ន្ធនឹងធារាសាស្ត្រនៅក្នុងរយៈពេលវែង ។

វិស័យ**ឧស្សាហកម្ម និងពាណិជ្ជកម្ម** បានគូសបញ្ជាក់អំពីអាទិភាពចំនួនបួន ដែលមានដូចជាការជួសជុល និងការដាក់ជំនួសគ្រឿងយន្ត និងឧបករណ៍ដែលខូចខាត ការធ្វើអោយគ្រឿងយន្តកាន់មានលក្ខណៈទំនើបដែលអាចធន់នឹងគ្រោះថ្នាក់ ការគាំទ្រក្របខ័ណ្ឌនិយតកម្ម និងការកសាងសមត្ថភាព ហើយចុងក្រោយគឺការលើកកម្ពស់ការយល់ដឹងជាសាធារណៈអំពីការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយក្នុងចំណោមវិស័យឯកជន ។

នៅក្នុងវិស័យ**ផ្តល់ទីជម្រក** អាទិភាពគឺការជួសជុល/ការសាងសង់ផ្ទះដែលត្រូវបានបំផ្លិចបំផ្លាញ និងរងការខូចខាតខ្លាំងបំផុតអោយមានភាពប្រសើរឡើង នៅក្នុងរយៈពេលខ្លី និងការពិនិត្យបទដ្ឋានផ្តល់ទីជម្រក និងការសាងសង់ដែលធន់នឹងគ្រោះថ្នាក់នៅក្នុងរយៈពេលមធ្យម និងរយៈពេលវែង ។

ចំពោះវិស័យដែលមិនត្រូវបានកំណត់ជាវិស័យអាទិភាពនោះ កម្មវិធីស្តារសម្បទានឹងនៅតែត្រូវដឹកនាំដោយគោលការណ៍ដូចគ្នាហើយនឹងដាក់បញ្ចូល DRM នៅក្នុងដំណើរការនេះ ។

១.៥ ភ្លើងឆេះព្រៃ និងអគ្គីភ័យ

- **ភ្លើងឆេះព្រៃ**

ភ្លើងឆេះព្រៃតែងតែកើតមានឡើងនៅតំបន់ភ្នំ នៅក្នុងរដូវប្រាំងចាប់ពីខែមិនា រហូតដល់ ខែឧសភា ជារៀងរាល់ឆ្នាំ។ រដូវនេះជារដូវក្តៅបណ្តាលអោយស្លឹកឈើជ្រុះ និង រុក្ខជាតិតូចៗងាប់ ដែលជាហេតុធ្វើអោយងាយនឹងទទួលរងការឆេះ។ នៅពេលបច្ចុប្បន្នដោយសារតែមានអាកាសធាតុប្រែប្រួល និង ដោយសារការគ្រប់គ្រង និង ការប្រើប្រាស់ដីមិនបានល្អ វានឹងអាចធ្វើអោយភ្លើងឆេះព្រៃនៅកម្ពុជា កាន់តែមានភាពធ្ងន់ធ្ងរ និង អាចមានការគំរាមកំហែងដល់ព្រៃឈើ ធនធានធម្មជាតិ និង សត្វព្រៃផ្សេងៗ។ ការឆេះព្រៃទ្រង់ទ្រាយតូចនេះ តែងកើតឡើងរៀងរាល់ឆ្នាំនៅតំបន់ព្រៃឈើខ្ពឹម ចំការស្រល់ ព្រៃឬស្សី ក្នុងអំឡុងពេលរដូវក្តៅ ពីពាក់កណ្តាលខែវិច្ឆិកា ដល់ពាក់កណ្តាលខែមេសា។ នៅឆ្នាំ ១៩៩៧ មានគ្រោះមហន្តរាយ ទ្រង់ទ្រាយតូចមួយបណ្តាលមកពីអគ្គីភ័យឆេះព្រៃស្រល់នៅភ្នំគីរីរម្យ។ ទោះជាយ៉ាងក៏ដោយ នៅពេលអនាគតការឆេះព្រៃ អាចជាការគំរាមកំហែងមួយផងដែរ ជាពិសេសវាបណ្តាលមកពីការកាប់ទន្ទ្រានព្រៃយកដី។

- **អគ្គីភ័យ**

អគ្គីភ័យគឺកើតមានឡើងនៅតាមទីប្រជុំជនដែលមានមនុស្សរស់នៅច្រើន បានបង្កឱ្យមានការខូចខាតយ៉ាងធំធេង ពីព្រោះសំណង់មិនរឹងមាំសង់ជាប់ៗគ្នា មិនមានផ្លូវសម្រាប់រថយន្តអគ្គីភ័យចូលទៅដល់ ហើយនៅតាមខេត្តក៏មានការ ខ្វះខាតសំភ្លារៈ និងរថយន្តពន្លត់អគ្គីភ័យបម្រើការមិនគ្រប់គ្រាន់ឡើយ។ នៅក្នុងឆ្នាំ ២០០១ តាមរបាយការណ៍ ដែល គ.ជ.គ.ម ដកស្រង់បានឱ្យដឹងថា មានករណីភ្លើងឆេះផ្ទះមានចំនួន ៤៦ករណី ដែលបណ្តាលឱ្យខូចខាតផ្ទះសំបែងចំនួន ៣,៣១៦ខ្នង និងបណ្តាលឱ្យស្លាប់ បាត់បង់ជីវិតមនុស្សចំនួន ០៥នាក់ និងរងរបួសចំនួន២០នាក់ផ្សេងទៀត។ នៅឆ្នាំ ២០០៧ មូលដ្ឋានរងគ្រោះមាន ១៨ខេត្ត-ក្រុង ហើយការខូចខាតធ្ងន់ធ្ងរមាននៅភ្នំពេញ ខេត្តតាកែវ ពោធិសាត់ បន្ទាយមានជ័យ និង ខេត្តកណ្តាល និងធ្វើអោយមនុស្សចំនួន ១៤ស្លាប់ ឆេះផ្ទះអស់ ៤៥១ខ្នង តូបផ្សារ ១,០៦៤តូប ឆេះស្រូវ ២០០តោន និង របួស២នាក់។

១.៦ ការប្រែប្រួលអាកាសធាតុ

ដោយប្រទេសកម្ពុជាជាប្រទេសដែលពឹងផ្អែកលើវិស័យកសិកម្មព្រះរាជាណាចក្រកម្ពុជាជាប្រទេសងាយរងគ្រោះ ខ្លាំងបំផុតពីឥទ្ធិពលនៃការប្រែប្រួលអាកាសធាតុ ហើយផលប៉ះពាល់ខ្លាំងបំផុតនោះ គឺទំហំនៃការខូចខាតដោយសារ គ្រោះរាំងស្ងួត និងគ្រោះទឹកជំនន់ និងការថយចុះនូវផលដំណាំ មកពីការខ្សត់ទឹកធ្វើឱ្យប្រជាជនមួយចំនួនកើតជម្ងឺ ដែលបណ្តាលមកពីមេរោគឆ្លងតាមទឹក។ តាមអនុសាសន៍ដែលបានកំណត់ក្នុង NAPA 2006 គឺដោយសារបច្ចុប្បន្ននេះពុំមានលទ្ធភាពព្យាករណ៍ពីផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ នៅថ្នាក់តំបន់ និងថ្នាក់មូលដ្ឋាននៅឡើយ ដើម្បីជួយការពង្រឹងសមត្ថភាពក្នុងការបន្សាំនឹងការប្រែប្រួលអាកាសធាតុ ក៏មិនអាចព្យាករណ៍ទុកជាមុនត្រឹមត្រូវបានដែរ។

១.៧ មុខសញ្ញាគ្រោះថ្នាក់ដោយបច្ចេកវិទ្យា និង មនុស្ស

មុខសញ្ញាគ្រោះថ្នាក់បង្កឡើងដោយមនុស្សដែលប្រទេសកម្ពុជានៅតែប្រឈមមុខជាមួយនោះ គឺគ្រាប់មីន និងយុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ បានបន្សល់ទុកដោយសារតែជម្លោះប្រដាប់អាវុធជាប្រវត្តិសាស្ត្រធ្វើឱ្យកម្ពុជាជាប្រទេសមួយរង ផលប៉ះពាល់ធ្ងន់ធ្ងរបំផុតដោយសារគ្រាន់មីន និង គ្រាប់យុទ្ធភ័ណ្ឌមិនទាន់ផ្ទុះទាំងនោះ។ មុខសញ្ញាគ្រោះថ្នាក់ដែលបង្កឡើងដោយមនុស្សមួយទៀតដែលកើតឡើងជាញឹកញាប់ មានដូចជា: អគ្គីភ័យ និង គ្រោះថ្នាក់ចរាចរ។ កំណើនមុខសញ្ញា គ្រោះថ្នាក់ បាក់ស្រុតអាគារ និងបច្ចេកវិទ្យាក៏អាចរំពឹងទុកថានឹងអាចកើតមានផងដែរ នាពេលអនាគត។

ក្នុងព្រះរាជាណាចក្រកម្ពុជាសព្វថ្ងៃនេះមានការកើនឡើងយ៉ាងខ្លាំងនូវគ្រោះថ្នាក់ចរាចរដូចជា: នៅឆ្នាំ២០០៧ ដោយសារកំណើនយានយន្តគ្រប់ប្រភេទ អ្នកបើកបរលឿន បើកបរក្នុងពេលស្រវឹង ពិសេសស្របគ្នានឹងផ្លូវគមនាគមន៍ ត្រូវបានស្តារ និងលួងទៀតផង គ្រោះថ្នាក់ចរាចរមានចំនួន ៩,៤៤៩លើក ខូចខាតយានយន្តគ្រប់ប្រភេទ ១៦,៩៨២គ្រឿង បណ្តាលឱ្យមនុស្សស្លាប់ ១,៥៤៥នាក់ ក្នុងនោះអ្នករបួសធ្ងន់ចំនួន ៧,១៥០នាក់ និង របួសស្រាលចំនួន ១៧,៦៥៥នាក់។

តារាងខាងក្រោម គឺផ្តល់នូវរបាយការណ៍សង្ខេបពីគ្រោះមហន្តរាយដោយធម្មជាតិ ដែលបានកើតមានឡើងនៅក្នុងប្រទេសកម្ពុជា នៅចន្លោះពីឆ្នាំ១៩៨៧ ដល់ ឆ្នាំ២០០៩ :

ឆ្នាំ	គ្រោះមហន្តរាយ	មនុស្សស្លាប់	មនុស្សរបួស	សាលា	ផ្ទះខូច	ផ្ទះប៉ះពាល់	ស្រូវខូច (ហ.ត)	ស្រូវប៉ះពាល់ (ហ.ត)	ដំណាំខូច (ហ.ត)	វត្ត
១៩៨៧ ដល់ ២០០៤	ទឹកជំនន់	១.១០៤	៥៣		២៧១.៨០៧					
	រាំងស្ងួត	៥								
	ជំងឺរាតត្បាត	៧៨៤								
២០០៥	រន្ទះបាញ់	១២	៩	១១	១១៥					
	ទឹកជំនន់	៤		៣០	១៧០០		១៣០០		២០០	៩
	អគ្គីភ័យ	៩	១៨	៣៩២						
	គ្រោះថ្នាក់ចរាចរ	៤០១	៣.១៩៥							
២០០៦	ទឹកជំនន់	១២					១២.៧៨១	៧៥.៦៦៦		
	រាំងស្ងួត						៧.៥៤០	៧៧៧		
	ផ្ការីសាយបក្សី	៤								
	ខ្យល់ព្យុះ	១១	៥៧		៦៤២	៥៤៩				
	អគ្គីភ័យ	៦			២៦៧					

	គ្រោះថ្នាក់ចរាចរ	១.១៥៧	៨.៤៥៥							
២០០៧	អគ្គីភ័យ	១៤	២		៤៥១					
	ខ្យល់ព្យុះ				៥៨៤	១.១១២				
	រន្ទះបាញ់	៤៥	៦							
	ធ្លាក់យន្តហោះ	២២	៥							
	ទឹកជំនន់	៥			១១	២.២៩៨	១៦.២៤១	២.១០៥		
	រាំងស្ងួត						៥.៦៥៣	២.៩៣៦		
	មមាចត្នោត							៨៩.៦៣០		
	គ្រោះថ្នាក់ចរាចរ	១.៥៤៥	២៤.៨០៥							
	ច្រាំងបាក់				១	៧៧				
២០០៨	ទឹកជំនន់						៨៦៩	១៨.៩០៧		
	រាំងស្ងួត						១.៧៩៣	៨១.៥៥០		
	ខ្យល់ព្យុះ	១០	២៣	៦	៨៤១	៨៣៥				១
	រន្ទះបាញ់	៩៥	២២							
	អគ្គីភ័យ	៥	៩		៨៦៣					
	បាក់ច្រាំងទន្លេ				៣៩					
	ធ្លាក់យន្តហោះ	៤								
២០០៩	ទឹកជំនន់ និង	៥៦	៦៩	១.១៦៩	៣១.៥៦៥	៨០៤	៦១.២៧០		៣.០៤៤	
	ព្យុះកេតសានា									
	រាំងស្ងួត						២.៦២១	៥៧.៩៦៥		
	អគ្គីភ័យ	១១	១២		៧២២					
	ខ្យល់ព្យុះ	៧	៥៩	១០	៧៤៩	៨៣៩				២
	រន្ទះបាញ់	១៤០	៥៩							
	ផ្តាសាយបក្សី និង H1N1	១៥	៥៥៤							
	បាក់ច្រាំងទន្លេ				៦	៤៤				
	សរុប	**៥.៤៨៣**	**៣៧.៣៦៤**	**១.៦១៨**	**៣៨.៥៥៦**	**៦.៥៥៨**	**១១០.០៦៨**	**៣២៩.៥៣៦**	**៣.២៤៤**	**១២**

ប្រភព: EM-DAT: The OFDA/CRED International Disaster Database, www.em-dat.net universite catholique de Louvain - Brussels – Belgium.

ឆ្នាំ	គ្រោះមហន្តរាយ	មនុស្សរងគ្រោះ (គ្រួសារ)	សត្ត (គោ ជ្រូក)	ផ្ទៃដីលំ (ម)	ផ្ទៃដីជាតិ (ម)	ស្ពាន	ធារាស្ត្រ (ម)	ទូប(ផ្ទះ)	បង្គន់	អណ្តូង
១៩៨៧ ដល់ ២០០៤	ទឹកជំនន់	៩.៤២៣.៨៣៦								
	រាំងស្ងួត	៦.៥៥០.០០០								
	ជំងឺរាតត្បាត	៤១៣.៧៥០								
២០០៥	ទឹកជំនន់	២.៥០០	៣.៥០០							
	អគ្គីភ័យ							៣២០		
២០០៦	ទឹកជំនន់	៧១.៨៧០		៧០.២៤៥		២៤	៣៩			
	អគ្គីភ័យ							៣០		
២០០៧	អគ្គីភ័យ							១.០៦៤		
	ទឹកជំនន់	១៦.៤០៨		៣៤.០៥៦						
២០០៨	ទឹកជំនន់									
	ផ្តាសាយបក្សី		៣២៦							
	រន្ទះបាញ់		១៣							

	អគ្គីភ័យ							១.១៦០		
២០០៩	ទឹកជន់ និង ព្យុះកេតសានា	១៥៤.២៦៨			១៦៦				៦.៦៩៣	១.៦៩៦
	អគ្គីភ័យ							២៣០		
	រន្ទះបាញ់		៣៨							
	សរុប	**១៥.៦៣២.៦៣២**	**៣.៨៧៧**	**១០៤.៣០១**	**១៦៦**	**២៤**	**៣៩**	**១.៣៩០**	**៦.៦៩៣**	**១.៦៩៦**

ប្រភព: EM-DAT: The OFDA/CRED International Disaster Database, www.em-dat.net universite catholique de Louvain - Brussels – Belgium.

១.៤ ភាពងាយរងគ្រោះ

ល័ក្ខខ័ណ្ឌសេដ្ឋកិច្ច-សង្គមនៅប្រទេសកម្ពុជាត្រូវបានកែលំអជាច្រើនក្នុងប៉ុន្មានឆ្នាំនេះ សន្ទស្សន៍នៃការអភិវឌ្ឍន៍មនុស្ស (HDI) ពីចំណាត់ថ្នាក់លេខ១៥៣ នៅក្នុងឆ្នាំ ១៩៩៧ មកចំណាត់ថ្នាក់លេខ១៣១ ក្នុងឆ្នាំ ២០០៧។ ហើយប្រទេសកម្ពុជាជាប្រទេសមួយក្នុងចំណោមប្រទេសតតីលោកនៅលើពិភពលោក ដែលទទួលរងផលប៉ះពាល់នៃសង្គ្រាម អស្ថេរភាពសង្គម និង អស្ថេរភាពខាង នយោបាយអស់រយៈពេលជិត៣០ឆ្នាំ ។ ប្រជាជន ប្រមាណ ៣៤.៦៧% ភាគរយកំពុងរស់នៅក្រោមបន្ទាត់នៃភាពក្រីក្រ ហើយប្រជាជននៅជនបទដាច់ស្រយាលប្រមាណ ៩០% ភាគរយគឺជាអ្នកក្រីក្រ (NSDP ២០០៦)។ ការរស់នៅរបស់ពួកគេពឹងផ្អែកទាំងស្រុងលើវិស័យ កសិកម្ម នេសាទ និងអនុផលព្រៃដែលប៉ុន្មានឆ្នាំកន្លងទៅនេះពួកគេតែងតែទទួលនូវផលប៉ះពាល់ដោយគ្រោះទឹកជំនន់និងគ្រោះរាំងស្ងួតបានកើតឡើងជាញឹកញាប់។ ក្នុងឆ្នាំ២០០៣គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ និងអង្គការស្បៀងអាហារពិភពលោក បានគូសផែនទីបង្ហាញតំបន់ដែលរងគ្រោះខ្លាំងជាងគេទាំងនោះ។ ហើយមានប្រមាណ ៥០០ឃុំ ត្រូវបានកំណត់ថាជាតំបន់ប្រឈមនឹងគ្រោះមហន្តរាយធម្មជាតិ ក្នុងនោះមាន ២៦០ឃុំ ប្រឈមនឹងទឹកជំនន់ ហើយ ២៩៣ឃុំប្រឈមនឹងគ្រោះរាំងស្ងួត។ ចំនួននេះ គឺស្មើនឹងមួយភាគបីនៃចំនួនឃុំសរុប នៅទូទាំងប្រទេស។

ទោះបីប្រជាជនរស់នៅក្នុងតំបន់ដែលទទួលរងដោយគ្រោះទឹកជំនន់ និងគ្រោះរាំងស្ងួតបានរៀបចំបង្កើតយុទ្ធសាស្ត្រនានាដើម្បីដោះស្រាយពីផលប៉ះពាល់នៃមុខសញ្ញាគ្រោះថ្នាក់ទាំងអស់នោះក៏ដោយ ក៏សមត្ថភាពដោះស្រាយរបស់ពួកគេនៅមានកំរិតនៅឡើយ។ ភាពក្រីក្រគឺជាឫសគល់នៃភាពងាយរងគ្រោះរបស់ប្រជាជន ដែលរស់នៅក្នុងតំបន់ប្រឈមនឹងគ្រោះមហន្តរាយ ដូច្នេះហើយគ្រោះមហន្តរាយគឺជាកត្តាបង្កឱ្យមានភាពក្រីក្រ។ តាមការសិក្សាដែលរៀបចំឡើងដោយកាកបាទក្រហមកម្ពុជាឱ្យដឹងថា ភាពក្រីក្រនៅកម្ពុជាមានភាពខុសគ្នាទៅតាមភូមិសាស្ត្រ ដែលនាំឱ្យប្រជាជនងាយរងគ្រោះដោយសារគ្រោះទឹកជំនន់ និងគ្រោះរាំងស្ងួត ។

ក្នុងលក្ខណៈដែលធនធានធម្មជាតិ និងការអភិវឌ្ឍន៍សេដ្ឋកិច្ច-សង្គមត្រូវបានគ្រប់គ្រង ឬគ្រប់គ្រងមិនបានត្រឹមត្រូវក្តី ក៏មានផលប៉ះពាល់ដោយផ្ទាល់ផងដែរ ទៅលើភាពងាយរងគ្រោះរបស់ប្រជាជនទូទៅ។ ការតាំងទីលំនៅ និងការប្រើប្រាស់ដីធ្លីមិនបានគ្រោងទុក បានបង្កឱ្យមានកំណើនប្រជាជនកើនឡើងយ៉ាងឆាប់រហ័ស នៅតំបន់លិចទឹកទន្លេមេគង្គ។ ការបាត់បង់ព្រៃឈើបណ្តាលឱ្យទំហំផ្ទៃទឹកកាន់តែធំ និងការច្រោះបាក់ដី។ ប្រព័ន្ធស្រោចស្រព និងវិធានការ

រក្សាទឹកទុកសំរាប់ប្រើប្រាស់នៅមិនទាន់គ្រប់គ្រាន់ ជាពិសេសប្រឈមមុខនឹងគ្រោះថ្នាក់នៃគ្រោះ រាំងស្ងួត។ ភាពលេចធ្លោដោយសារមុខសញ្ញាគ្រោះថ្នាក់ធម្មជាតិ គឺទាក់ទងគ្នាទៅនឹងភាពរងគ្រោះខាងរូបវន្ត សង្គម សេដ្ឋកិច្ច និងបរិស្ថានដែលត្រូវមានការការពារប្រជាជនដើម្បីឱ្យពួកគាត់រស់នៅក្នុងបរិស្ថានសុវត្ថិភាព។



III. ឯកសារយោង

- ផែនការសកម្មភាពជាតិនៃយុទ្ធសាស្ត្រសម្រាប់ការកាត់បន្ថយគ្រោះภัยនៃគ្រោះមហន្តរាយ: ២០០៨-២០១៥ របស់គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ (NCDM)
- EM-DAT: The OFDA/CRED Internatonal Disaster Database, www.em-dat.net universite catholique de Louvain - Brussels – Belgium (1987-2009)
- CCCO (Climate Change Committee Office): Flood and Dreought probality mapes and its diagrams on vulnerability level by provinces in Cambodia.

ឯកសារបណ្តុះបណ្តាល

ផ្នែកទី ២

ក្រុមខ័ណ្ឌការងារ
គ្រប់គ្រងគ្រោះមហន្តរាយ នៅកម្ពុជា

មេរៀនទី ១: គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ

I. គោលបំណងរួម

អ្នកចូលរួម និងសិក្ខាកាមទាំងអស់ នឹងអាចយល់ដឹងពីយន្តការនៃការបង្កើតឡើងនូវគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ សមាសភាព រចនាសម្ព័ន្ធ បេសកកម្ម មុខងារ-ភារកិច្ច និងការទទួលខុសត្រូវរបស់ គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ ។

II. ខ្លឹមសារមេរៀន

១. សមាសភាពនៃគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ

នៅឆ្នាំ១៩៩៥ រាជរដ្ឋាភិបាលកម្ពុជា បានបង្កើតឡើងគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ (National Committee for Disaster Management) ហៅកាត់ថា (គ.ជ.គ.ម) (NCDM)។ ជាបន្តបន្ទាប់ គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយត្រូវបានរៀបចំ និងកែលំអ។ នៅឆ្នាំ២០០៤ គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ ត្រូវបានរាជរដ្ឋាភិបាលទូលថ្វាយព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា សុំត្រាស់បង្គាប់បង្កើតគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ ដូចមានព្រះរាជក្រឹត្យលេខ: នស.រកត.០២០២.០៤០ ចុះថ្ងៃទី ១៦ ខែកុម្ភៈ ឆ្នាំ២០០២ និង ព្រះរាជក្រឹត្យលេខ: នស.រកត.០៨០៤.២៣៦ ចុះថ្ងៃទី ៣១ ខែ សីហា ឆ្នាំ២០០៤ ។

គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ

១.	នាយករដ្ឋមន្ត្រី	ប្រធាន
២.	ឥស្សរជនជាន់ខ្ពស់មួយរូប	អនុប្រធានទី១
៣.	ឥស្សរជនជាន់ខ្ពស់មួយរូប	អនុប្រធានទី២
៤.	រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ	អនុប្រធាន
៥.	រដ្ឋមន្ត្រីក្រសួងការពារជាតិ	អនុប្រធាន
៦.	រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី	សមាជិក
៧.	រដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ	សមាជិក
៨.	រដ្ឋមន្ត្រី ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ	សមាជិក
៩.	រដ្ឋមន្ត្រី ក្រសួងបរិស្ថាន	សមាជិក
១០.	រដ្ឋមន្ត្រី ក្រសួងធនធានទឹក និង ឧតុនិយម	សមាជិក
១១.	រដ្ឋមន្ត្រី ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ	សមាជិក
១២.	រដ្ឋមន្ត្រី ក្រសួងពាណិជ្ជកម្ម	សមាជិក
១៣.	រដ្ឋមន្ត្រី ក្រសួងសុខាភិបាល	សមាជិក

១៤.	រដ្ឋមន្ត្រី ក្រសួងអភិវឌ្ឍន៍ជនបទ	សមាជិក
១៥.	រដ្ឋមន្ត្រី ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល	សមាជិក
១៦.	រដ្ឋមន្ត្រី ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា	សមាជិក
១៧.	រដ្ឋមន្ត្រី ក្រសួងសាធារណៈការ និងដឹកជញ្ជូន	សមាជិក
១៨.	រដ្ឋមន្ត្រី ក្រសួងអប់រំ យុវជន និងកីឡា	សមាជិក
១៩.	រដ្ឋមន្ត្រី ក្រសួងកិច្ចការនារី	សមាជិក
២០.	តំណាងអគ្គមេបញ្ជាការកងយោធពលខេមរភូមិន្ទ	សមាជិក
២១.	តំណាងប្រធានកាកបាទក្រហមកម្ពុជា	សមាជិក
២២.	រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល	សមាជិក

២. បេសកកម្ម

គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយត្រូវដឹកនាំការគ្រប់គ្រងគ្រោះមហន្តរាយនៅព្រះរាជាណាចក្រកម្ពុជា ។

៣. មុខងារ ការកិច្ច និង ការទទួលខុសត្រូវ

- អង្កេតតាមដានវាយតំលៃប្រមូល វិភាគ គ្រប់គ្រងទិន្នន័យគ្រោះภัยនៃគ្រោះមហន្តរាយ និង រៀបចំចងក្រងរបាយការណ៍ស្តីពីស្ថានភាពគ្រោះមហន្តរាយ ដើម្បីផ្តល់យោបល់ជូនរាជរដ្ឋាភិបាល ដាក់ចេញនូវ គោលការណ៍ គោលនយោបាយ, សារាចរ, សេចក្តីប្រកាស និងវិធានការណ៍ សំរាប់ការគ្រប់គ្រង គ្រោះមហន្តរាយ ។
- លើកសំណើជូនរាជរដ្ឋាភិបាលអំពីសេចក្តីត្រូវការនិងការប្រើប្រាស់ប្រភពធនធានដូចជា: មូលនិធិ សម្ភារៈ ប្រេងឥន្ធនៈ មធ្យោបាយប្រើប្រាស់ និងធនធានមនុស្ស ដើម្បីដំណើរការកិច្ចប្រតិបត្តិការការងារគ្រប់គ្រងគ្រោះមហន្តរាយ និងសំរាប់ជួយដល់ជនរងគ្រោះដែលប៉ះពាល់ពីមុខសញ្ញាគ្រោះថ្នាក់ដោយ ធម្មជាតិ និងដោយមនុស្ស ។
- អភិវឌ្ឍន៍ធនធានមនុស្សតាមរយៈការបណ្តុះបណ្តាលបច្ចេកទេស ជំនាញ និងចំណេះដឹងដល់មន្ត្រី ទទួលបន្ទុកការងារគ្រប់គ្រងគ្រោះមហន្តរាយ នៅថ្នាក់ជាតិ ក្រសួងពាក់ព័ន្ធ រាជធានី-ខេត្ត-ក្រុង ស្រុក-ខ័ណ្ឌ ឃុំ-សង្កាត់ ភូមិ និងអប់រំផ្សព្វផ្សាយការយល់ដឹងសាធារណៈដល់ប្រជាពលរដ្ឋនៅសហគមន៍ អំពីគ្រោះមហន្តរាយដោយ ធម្មជាតិ និងដោយមនុស្ស ។
- សហការជាមួយក្រសួងស្ថាប័នរបស់រាជរដ្ឋាភិបាល ភ្នាក់ងារអង្គការសហប្រជាជាតិ អង្គការអន្តរជាតិ អង្គការក្រៅរដ្ឋាភិបាល ព្រមទាំងសប្បុរសជនផងដើម្បីអនុវត្ត ដែលជាគោលនយោបាយជាតិនៃការងារគ្រប់គ្រងគ្រោះមហន្តរាយនានា ដូចជា: ការត្រៀមបង្ការ ការសំរាល ការត្រៀម រៀបចំដើម្បីទប់ទល់ ទៅនឹងមុខសញ្ញាគ្រោះថ្នាក់ដោយធម្មជាតិ និងដោយមនុស្ស ។
- ធ្វើការទំនាក់ទំនងសំរបសំរួលកិច្ចសហប្រតិបត្តិការថ្នាក់ជាតិ ថ្នាក់តំបន់ និងកិច្ចសហប្រតិបត្តិការអន្តរជាតិ ក្នុងការផ្តល់ព័ត៌មានឱ្យគ្នាទៅវិញទៅមកអំពីស្ថាភាព និងស្ថានការណ៍គ្រោះមហន្តរាយ សំដៅកាត់បន្ថយផលប៉ះពាល់ពីគ្រោះមហន្តរាយ ។

- ធ្វើការសំរបសំរួលជាមួយក្រសួង ស្ថាប័នរបស់រាជរដ្ឋាភិបាល ភ្នាក់ងារអង្គការសហប្រជាជាតិ អង្គការ អន្តរជាតិ អង្គការក្រៅរដ្ឋាភិបាល សហគមន៍អន្តរជាតិ និងសប្បុរសជនក្នុងស្រុក ដើម្បីកៀរគរ ស្វែងរកជំនួយ សំរាប់ឆ្លើយតប សង្គ្រោះបន្ទាន់ និងស្តារឡើងវិញរាល់ការខូចខាត ដោយគ្រោះ មហន្តរាយ ។

៤. រចនាសម្ព័ន្ធគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ

៤.១ ខុទ្ធកាល័យប្រធានគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ

ខុទ្ធកាល័យប្រធានគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ មានភារៈទទួលបន្ទុកសំរួលរាល់កិច្ចការប្រធាន ជាក់ស្តែង អនុប្រធានទី១ ជំនួសមុខឱ្យប្រធាន ដោះស្រាយគ្រប់កិច្ចការនិងប្រតិបត្តិការផ្ទាល់ ដោយសរុបរបាយការណ៍ជូនប្រធាន គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ ។ រីឯអ្នកជំនួយការក៏ត្រូវបំរើឱ្យការងារអនុប្រធានទី១ដែរ ។ ភារកិច្ចរបស់ខុទ្ធកាល័យ មានជាអាទិ៍ :

- រ៉ាប់រង ទំនាក់ទំនងការងារ
- ផ្តល់យោបល់ជូនប្រធាន ឬអនុប្រធានទី១ គ.ជ.គ.ម ចំពោះកិច្ចការទូទៅ និង ចំពោះសំណុំរឿង ទាំងឡាយ ដែលប្រធាន ឬអនុប្រធានទី១ បានប្រគល់អោយពិនិត្យ ។
- ចែកផ្សាយអំពីគោលការណ៍ណែនាំរបស់ប្រធាន ឬ អនុប្រធានទី១ គ.ជ.គ.ម ។
- រៀបចំកាលវិភាគរបស់ប្រធាន ឬ អនុប្រធានទី១ គ.ជ.គ.ម ។
- រៀបចំសម័យប្រជុំការងារ គ.ជ.គ.ម ។
- បញ្ជូនបញ្ជាប្រធាន ឬ អនុប្រធានទី១ គ.ជ.គ.ម ។
- តាមដានការអនុវត្តន៍បទបញ្ជារបស់ប្រធាន ឬ អនុប្រធានទី១ គ.ជ.គ.ម ។

៤.២ អគ្គលេខាធិការដ្ឋាន

អគ្គលេខាធិការដ្ឋាននេះ មានភារកិច្ច ជាសេនាធិការឱ្យគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយលើការងារ:

- ធានានិរន្តរភាពនៃដំណើរការរដ្ឋបាល របស់គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ ។
- សិក្សាស្រាវជ្រាវតំបន់ងាយរងគ្រោះដោយទឹកជំនន់ រាំងស្ងួត ខ្យល់ព្យុះ ភ្លើងឆេះព្រៃ ជំងឺរាតត្បាត និង មុខសញ្ញាគ្រោះថ្នាក់ដទៃទៀត ដោយរៀបចំផែនការត្រៀមបង្ការ ឆ្លើយតបសង្គ្រោះបន្ទាន់ ។
- ណែនាំការងារ ជំនាញបច្ចេកទេសដល់លេខាធិការដ្ឋានគណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយ រាជធានី-ខេត្ត-ក្រុង ស្រុក-ខ័ណ្ឌ ឃុំ-សង្កាត់ និង សហគមន៍ជួយសង្គ្រោះ ដើម្បីជាមូលដ្ឋាន ក្នុងការប្រមូលទិន្នន័យគ្រោះមហន្តរាយសំរាប់ធ្វើការវាយតំលៃប៉ាន់ស្មានអំពីការខូចខាតនិងតំរូវការ និង រៀបចំកម្មវិធីស្តារ និង កសាងឡើងវិញនូវហេដ្ឋារចនាសម្ព័ន្ធដែលខូចខាត ដោយសំរបសំរួល ការងារជាមួយស្ថាប័ននានា ភ្នាក់ងារ អង្គការសហប្រជាជាតិ អង្គការអន្តរជាតិ អង្គការក្រៅ រដ្ឋាភិបាល ដែលពាក់ព័ន្ធ ។
- លើកផែនការបណ្តុះបណ្តាលជំនាញបច្ចេកទេស ដល់បុគ្គលិកគ្រប់គ្រងគ្រោះមហន្តរាយ ថ្នាក់កណ្តាល រាជធានី-ខេត្ត-ក្រុង, ស្រុក-ខ័ណ្ឌ ឃុំ-សង្កាត់ និងសហគមន៍ជួយសង្គ្រោះ ក្នុងក្របខ័ណ្ឌបណ្តុះ-បណ្តាលក្នុងប្រទេស និង ក្រៅប្រទេស ។

- សំរបសំរួលការងារជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ សមាគមជាតិ អាជ្ញាធរដែនដី ទីភ្នាក់ងារអង្គការសហប្រជាជាតិ អង្គការអន្តរជាតិ អង្គការក្រៅរដ្ឋាភិបាលនានា ដើម្បីជំរៀសប្រជាជនងាយរងគ្រោះទៅទីសុវត្ថិភាព ការពារសន្តិសុខ អប់រំសាធារណៈ ឆ្លើយតបសង្គ្រោះបន្ទាន់និងរៀបចំកម្មវិធី ផ្សេងៗ ។
- លើកយោបល់រាល់លិខិតស្នាមពាក់ព័ន្ធ ការងារគ្រប់គ្រងគ្រោះមហន្តរាយ កិច្ចព្រមព្រៀង និងបូកសរុបរបាយការណ៍ផ្សេងៗ ។

អគ្គលេខាធិការដ្ឋានគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ មាននាយកដ្ឋានចំនួន ០៥ ចំណុះ :

- នាយកដ្ឋាន រដ្ឋបាល និងហិរញ្ញវត្ថុ
- នាយកដ្ឋាន ព័ត៌មាន និងទំនាក់ទំនង
- នាយកដ្ឋាន ឆ្លើយតបសង្គ្រោះបន្ទាន់ និងស្តារឡើងវិញ
- នាយកដ្ឋាន ត្រៀមរៀបចំ និងបណ្តុះបណ្តាល
- នាយកដ្ឋាន សំរបសំរួលការងាររុករក ឧបទ្ទវហេតុយន្តហោះ និង នាវា ។



- **<u>រចនាសម្ព័ន្ធ:</u>** **គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ**

(គ.ជ.គ.ម. NCDM)



មេរៀនទី ២: គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយរាជធានី-ខេត្ត

I. គោលបំណងរួម

អ្នកចូលរួម និងសិក្ខាកាមទាំងអស់នឹងអាចយល់ដឹងពីយន្តការនៃការបង្កើតឡើងនូវ គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយរាជធានី-ខេត្ត សមាសភាព រចនាសម្ព័ន្ធ បេសកកម្ម មុខងារ-ភារកិច្ចនិងការទទួលខុសត្រូវរបស់គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយរាជធានី-ខេត្ត ។

II. ខ្លឹមសារមេរៀន

១. សមាសភាព

- អភិបាលរាជធានី-ខេត្ត ជាប្រធាន
- អភិបាលរងរាជធានី-ខេត្ត ជាអនុប្រធាន
- ប្រធានមន្ទីរជុំវិញរាជធានី-ខេត្ត ជាសមាជិក
- ស្នងការនគរបាលរាជធានី-ខេត្ត ជាសមាជិក
- បញ្ជាការកងរាជអាវុធហត្ថ រាជធានី-ខេត្ត ជាសមាជិក
- មេបញ្ជាការតំបន់ប្រតិបត្តិការសឹក រាជធានី-ខេត្ត ជាសមាជិក
- នាយកសាខាកាកបាទក្រហម រាជធានី-ខេត្ត ជាសមាជិក

២. បេសកកម្ម

គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយរាជធានី-ខេត្ត ត្រូវដឹកនាំការគ្រប់គ្រងគ្រោះមហន្តរាយនៅតំបន់ជុំវិញ រាជធានីនិងខេត្តរបស់ខ្លួន ។

៣. រចនាសម្ព័ន្ធ



៣.១ លេខាធិការដ្ឋាន

ជាសេនាធិការសំរាប់ធានានិរន្តរភាពការងារ ដែលដឹកនាំដោយនាយខុទ្ទកាល័យសាលាខេត្ត-ក្រុង ធ្វើជាលេខាអចិន្ត្រៃយ៍ និងមានជំនួយការមួយចំនួនទៀតសំរាប់ជួយការងារតាមការចាំបាច់ ។

៣.២ ក្រុមប្រតិបត្តិការគណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយរាជធានី-ខេត្ត

គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយរាជធានី-ខេត្តនីមួយៗ មានក្រុមប្រតិបត្តិការចំនួន ០៤ ។ ក្នុងក្រុម នីមួយៗ មានអភិបាលរងរាជធានី-ខេត្ត ០១រូប ជាប្រធាន ។

ក្រុមស្រាវជ្រាវ រុករក និង សន្តិសុខ	
• **ប្រធានក្រុម** - ភិបាលរងរាជធានី-ខេត្ត ០១រូប • **សមាសភាព អនុប្រធាន** ១. មេបញ្ជាការតំបន់ប្រតិបត្តិការ សឹករាជធានី ខេត្ត ២. ស្នងការនគរបាលរាជធានី ខេត្ត ៣. មេបញ្ជាការកងរាជអាវុធហត្ថ រាជធានី ខេត្ត ៤. ប្រធានមន្ទីរអប់រំយុវជន និងកីឡា និងតំណាងមន្ទីរជុំវិញខេត្តជាសមាជិក • **សមាសភាព សមាជិកក្រុម** - តំណាងមន្ទីរជុំវិញខេត្ត	• **តួនាទី និង ការទទួលខុសត្រូវ** - តាមដានព័ត៌មាននិងរបាយការណ៍ពីស្ថានភាពនិងផលប៉ះពាល់ដើម្បីត្រៀមលក្ខណៈ និង ប្រតិបត្តិការសង្គ្រោះ ។ - ជួយសង្គ្រោះប្រជាជនដែលងាយរងគ្រោះ និងប្រជាជនរងគ្រោះ ដោយសារគ្រោះមហន្តរាយ ។ - កំនត់ប្រជាជនដែលស្ថិតនៅតំបន់ប្រឈមមុខនិងតំបន់ងាយរងគ្រោះ ។ - ជួយក្រុមប្រតិបត្តិការដទៃទៀត និង ក្រុមសង្គ្រោះថ្នាក់ស្រុកទៅតាមការស្នើសុំជាក់ស្តែង ។ - ការពារសុវត្ថិភាព សន្តិសុខ សណ្តាប់ធ្នាប់ នៅទីសុវត្ថិភាពដែលជនរងគ្រោះស្នាក់នៅ និងការពារទ្រព្យសម្បត្តិ ផ្ទះសំបែងរបស់ប្រជាជន ដែលបានភៀសខ្លួន ។ - គ្រប់គ្រង និង សង់ជម្រកបណ្តោះអាសន្ននៅលើទីទួលសុវត្ថិភាព ។ - ចែករំលែកព័ត៌មានពាក់ព័ន្ធជាប្រចាំដល់ក្រុមដទៃ មន្ទីរឬអង្គភាព និង អង្គការនានា នៅក្នុងខេត្ត ។ - សហការ និងជួយសម្របសម្រួលដល់អង្គការនានាពាក់ព័ន្ធក្នុងការជម្លៀស និងសង្គ្រោះ ។ - ជួយសម្របសម្រួល និងការពារមធ្យោបាយដឹកជញ្ជូនសម្ភារជំនួយ និងជួយដឹកប្រជាពលរដ្ឋរងគ្រោះ ។ - កំណត់មធ្យោបាយ និងឧបករណ៍បំរើឱ្យការងារជម្លៀសនិងសង្គ្រោះ ។ - ចូលរួមប្រជុំដើម្បីចែករំលែកព័ត៌មាន បទពិសោធន៍ និងចូលរួមការប្រជុំផ្សេងទៀត តាមការចង្អុលបង្ហាញរបស់គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយខេត្ត ។ - តួនាទីផ្សេងទៀតនឹងអនុវត្តតាមផែនការ និងការចង្អុលបង្ហាញរបស់គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយខេត្ត ។

ក្រុមសុខភាព អនាម័យ និង ទឹកស្អាត	
• **ប្រធានក្រុម** - អភិបាលរងរាជធានី-ខេត្ត ០១រូប • **សមាសភាព អនុប្រធានក្រុម** ១. ប្រធានមន្ទីរសុខាភិបាល ២. ប្រធានមន្ទីរអភិវឌ្ឍន៍ជនបទ ៣. ប្រធានមន្ទីរកិច្ចការនារី ៤. ប្រធានមន្ទីរឧស្សាហកម្ម រ៉ែ និង ថាមពល • **សមាសភាព សមាជិកក្រុម** - តំណាងមន្ទីរជុំវិញខេត្ត	• **តួនាទី និង ការទទួលខុសត្រូវ** - ផ្តល់ការអប់រំ ផ្សព្វផ្សាយ និងដំបូន្មានក្នុងការថែទាំសុខភាព អនាម័យ និងការប្រើប្រាស់ទឹកស្អាត និង បង្ការជំងឺរាតត្បាតផ្សេង ១ ។ - ផ្តល់ការហ្វឹកហ្វឺនវិជ្ជាសង្គ្រោះបឋមដល់ក្រុមស្រាវជ្រាវ និងសង្គ្រោះ និងក្រុមអ្នកស្ម័គ្រចិត្តតាមសហគមន៍ ។ - ប្រតិបត្តិការសង្គ្រោះបន្ទាន់ និងព្យាបាលដល់ប្រជាជនរងគ្រោះដោយសារគ្រោះថ្នាក់ផ្សេងៗ ។ - តាមដានត្រួតពិនិត្យបញ្ហាទាក់ទងនឹងសុខភាព អនាម័យ ទឹកស្អាត និងបញ្ហាជំងឺផ្សេងៗទៀត ដែលបណ្តាលមកពីមុខសញ្ញាបង្ការគ្រោះមហន្តរាយ ។ - វាយតម្លៃ និងប៉ាន់ប្រមាណផលប៉ះពាល់និងសេចក្តីត្រូវការផ្នែក សុខភាព អនាម័យ និងទឹកស្អាត ។ - ធ្វើរបាយការណ៍ពីស្ថានភាពទាក់ទងនឹង សុខភាព អនាម័យ ទឹកស្អាត និងជំងឺរាតត្បាតផ្សេងៗ ជូនគណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយខេត្ត និងអង្គភាពពាក់ព័ន្ធ នានា ។ - សហការ និងជួយសម្របសម្រួលដល់បណ្តាអង្គការពាក់ព័ន្ធក្នុងការជួយលើផ្នែក សុខភាព អនាម័យ និងទឹកស្អាត ។ - ចូលរួមប្រជុំដើម្បីចែករំលែកព័ត៌មាន បទពិសោធន៍ និងកិច្ចប្រជុំផ្សេងទៀតតាមការចង្អុលបង្ហាញរបស់គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយខេត្ត ។ - តួនាទីផ្សេងទៀតនឹងអនុវត្តតាមផែនការ និងការចង្អុលបង្ហាញរបស់គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយរាជធានី-ខេត្ត ។

ក្រុម ព័ត៌មាន អប់រំ និងផ្សព្វផ្សាយ	
• **ប្រធានក្រុម** - អភិបាលរងរាជធានី-ខេត្ត ០១រូប • **សមាសភាព អនុប្រធានក្រុម** ១. ប្រធានមន្ទីរធនធានទឹក និងឧតុនិយម ២. ប្រធានមន្ទីរព័ត៌មានខេត្ត ៣. ប្រធានមន្ទីរបរិស្ថាន	• **តួនាទី និង ការទទួលខុសត្រូវ** - តាមដានព័ត៌មាន និងរបាយការណ៍ពីស្ថានភាពនិងផលប៉ះពាល់ផ្សេងៗ - ផ្សព្វផ្សាយព័ត៌មានព្យាករណ៍ និងប្រកាសប្រាប់ឱ្យដឹងជាមុនពីមុខសញ្ញាគ្រោះថ្នាក់យោងតាមប្រភពព័ត៌មានទាំងឡាយដែលទទួលបាន ។ - វាយតម្លៃ និងប៉ាន់ប្រមាណផលប៉ះពាល់ និងសេចក្តីត្រូវការ ទាំងក្នុងពេល និងក្រោយពេលគ្រោះមហន្តរាយ ។ - គ្រប់គ្រង និងទុកដាក់ព័ត៌មានទាក់ទងនឹងគ្រោះមហន្តរាយ ។

• **សមាសភាព សមាជិកក្រុម** - តំណាងមន្ទីរជុំវិញខេត្ត	- សហការ និងជួយសម្របសម្រួលដល់អង្គការនានាក្នុងការវាយតម្លៃ និងប៉ាន់ប្រមាណប៉ះពាល់ និង សេចក្ដីត្រូវការរបស់ជនរងគ្រោះ ។ - ប្រមូល និងចងក្រងព័ត៌មានទាក់ទងនឹងក្រុមអ្នកងាយរងគ្រោះ និងតំបន់ប្រឈមមុខនឹងមុខសញ្ញាគ្រោះថ្នាក់នានានៅក្នុងខេត្ត ។ - ចូលរួមជាមួយក្រុមដទៃ នៅពេលមានការស្នើសុំជាក់ស្តែង ។ - ដឹកនាំ និងចូលរួមប្រជុំដើម្បីចែករំលែកព័ត៌មាន និងបទពិសោធន៏ ដល់ក្រុមប្រតិបត្តិការដទៃ និង អង្គការពាក់ព័ន្ធនានា ។ - ផ្សព្វផ្សាយ និងអប់រំការយល់ដឹងធារណៈ ដល់ប្រជាពលរដ្ឋតាមប្រព័ន្ធផ្សព្វផ្សាយដែលមាននៅក្នុងខេត្ត ទាក់ទងនឹងវិធានការកាត់បន្ថយផលប៉ះពាល់ផ្សេងៗ ដែលបណ្ដាលឱ្យមានគ្រោះមហន្តរាយ ។ - តួនាទីផ្សេងទៀត នឹងអនុវត្តតាមផែនការ និងការចង្អុលបង្ហាញរបស់គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយរាជធានី-ខេត្ត ។

ក្រុមឆ្លើយតប សង្គ្រោះបន្ទាន់	
• **ប្រធានក្រុម** - អភិបាលរងរាជធានី-ខេត្ត ០១រូប • **សមាសភាព អនុប្រធានក្រុម** ១. នាយកសាខាកាកបាទក្រហមរាជធានី-ខេត្ត ២. ប្រធានមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និង យុវនិតិសម្បទា ៣. ប្រធានមន្ទីរសាធារណការ និងដឹកជញ្ជូន ៤. ប្រធានមន្ទីររុក្ខាប្រមាញ់ និងនេសាទ ៥. ប្រធានមន្ទីរដែនដីនគរូបនិយកម្ម • **សមាសភាព សមាជិកក្រុម** - តំណាងមន្ទីរជុំវិញខេត្ត	• **តួនាទី និង ការទទួលខុសត្រូវ** - តាមដានព័ត៌មាន និងរបាយការណ៏ពីស្ថានភាពនិងផលប៉ះពាល់ផ្សេងៗ ដោយសារគ្រោះមហន្តរាយនានា ។ - ប្រមូលព័ត៌មាននិងរបាយការណ៏ពីក្រុមប្រតិបត្តិការផ្សេងៗ ដើម្បីពិនិត្យលទ្ធភាពក្នុងការផ្ដល់ជំនួយសង្គ្រោះ ។ - វាយតម្លៃនិងប៉ាន់ប្រមាណសេចក្ដីត្រូវការ របស់ជនរងគ្រោះដើម្បីធ្វើការឆ្លើយតបឱ្យបានទាន់ពេលវេលា និងមានប្រសិទ្ធភាព ។ - ចុះស្រង់ស្ថិតិប្រជាជនរងគ្រោះនៅតាមទីសុវត្ថិភាពដើម្បីផ្ដល់ជំនួយសង្គ្រោះបន្ទាន់ និងជ្រើសរើសអ្នកទទួលជំនួយសង្គ្រោះ ដោយមានការចូលរួម ពីក្រុមដទៃទៀត ។ - គ្រប់គ្រង ថែរក្សា ស្តុកទុកជំនួយសង្គ្រោះ និងសម្ភារៈផ្សេងៗទៀត ។ - បែងចែក និងដឹកជញ្ជូនជំនួយសង្គ្រោះដល់ប្រជាពលរដ្ឋរងគ្រោះ ។ - ទំនាក់ទំនងនិងអំពាវនាវដល់ស្ថាប័ន អង្គការមនុស្សធម៏ សប្បុរសជន និងអង្គការផ្សេងទៀត ដើម្បីស្វែងរកជំនួយ និងការគាំទ្រ ។ - សម្របសម្រួល និងចង្អុលបង្ហាញទីតាំងជនរងគ្រោះដល់បណ្ដាអង្គការ មនុស្សធម៏ និងសប្បុរសជនដែលគេមានបំណងចង់ចែកជំនួយសង្គ្រោះ ដោយ ខ្លួនគេ ។ - បន្ត តាមដានស្ថានភាព និងសេចក្ដីត្រូវការរបស់ជនរងគ្រោះ ។

	- ដឹកនាំ និងចូលរួមប្រជុំដើម្បីចែករំលែកព័ត៌មាន និងបទពិសោធន៍ ដល់ក្រុមប្រតិបត្តិការ និងអង្គការពាក់ព័ន្ធនានា។ - តួនាទីផ្សេងទៀតនឹងអនុវត្តតាមផែនការ និងការចង្អុលបង្ហាញរបស់ គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយរាជធានី-ខេត្ត។

៤. មុខងារ និងតួនាទីរួម របស់គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយរាជធានី-ខេត្ត

១. អនុវត្តគោលនយោបាយជាតិ ស្តីពីការគ្រប់គ្រងគ្រោះមហន្តរាយ។

២. ធ្វើការណែនាំនិងគាំទ្រដល់សកម្មភាពគណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយស្រុក/ខណ្ឌ ឃុំ/សង្កាត់។

៣. ផ្តល់យោបល់ជូនគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយចំពោះសកម្មភាពរបស់ស្ថាបន័ពាក់ពន្ធ័ កាកបាទ ក្រហមកម្ពុជា ការឧបត្ថម្ភរបស់អង្គការជាតិ-អន្តរជាតិ ដែលចូលរួមទប់ស្កាត់ ត្រៀមរៀបចំ សង្គ្រោះបន្ទាន់ និងស្តារឡើងវិញ។

៤. ធ្វើរបាយការណ៍ជូនគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ ស្តីពីការខូចខាតនិងធ្វើសំណើរសុំ ឧបត្ថម្ភថវិកា សំភារៈបរិក្ខារ មធ្យោបាយ និងកំលាំងអន្តរាគមន៍សំរាប់ដោះស្រាយក្នុងពេលមាន គ្រោះមហន្តរាយ។

៥. អនុវត្តកម្មវិធីបណ្តុះបណ្តាល ដើម្បីពង្រឹងជំនាញបច្ចេកទេសដល់មន្ត្រីរាជការ ក្នុងការគ្រប់គ្រងគ្រោះមហន្តរាយ និងអនុវត្តកម្មវិធីអប់រំសាធារណៈនៅតាមសហគមន៍។

III. ឯកសារយោង

- អនុក្រឹត្យលេខ ៣០ អនក្រ.បក ចុះថ្ងៃទី០៩ ខែមេសា ឆ្នាំ២០០២។

មេរៀនទី ៣: គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយក្រុង-ស្រុក-ខ័ណ្ឌ

I. គោលបំណងរួម

អ្នកចូលរួម និងសិក្ខាកាមទាំងអស់នឹងអាចយល់ដឹងពីយន្តការនៃការបង្កើតឡើងនូវ គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយក្រុង-ស្រុក-ខណ្ឌ សមាសភាព រចនាសម្ព័ន្ធ បេសកកម្ម មុខងារ-ភារកិច្ច និងការទទួលខុសត្រូវរបស់គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយនេះ ។

II. ខ្លឹមសារមេរៀន

១. សមាសភាព

- អភិបាល ក្រុង- ស្រុក-ខ័ណ្ឌ ជាប្រធាន
- អភិបាលរង ក្រុង-ស្រុក-ខ័ណ្ឌ ជាអនុប្រធាន
- ប្រធានការិយាល័យជុំវិញ ក្រុង-ស្រុក-ខ័ណ្ឌ ជាសមាជិក
- អធិការនគរបាល ក្រុង-ស្រុក-ខ័ណ្ឌ ជាសមាជិក
- មេបញ្ជាការកងរាជអាវុធហត្ថ ក្រុង-ស្រុក-ខ័ណ្ឌ ជាសមាជិក
- មេបញ្ជាការសឹករងរង ក្រុង-ស្រុក-ខ័ណ្ឌ ជាសមាជិក
- ប្រធានអនុសាខាកាកបាទក្រហម ក្រុង-ស្រុក-ខ័ណ្ឌ ជាសមាជិក

២. បេសកកម្ម

គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយក្រុង-ស្រុក-ខ័ណ្ឌ ត្រូវដឹកនាំការគ្រប់គ្រងគ្រោះមហន្តរាយនៅតំបន់ ជុំវិញក្រុង ស្រុក និង ខ័ណ្ឌនីមួយៗរបស់ខ្លួន ។

៣. រចនាសម្ព័ន្ធ



៣.១ លេខាធិការដ្ឋាន

ជាសេនាធិការ សំរាប់ធានានិរន្តភាពការងារ ដែលដឹកនាំដោយប្រធានមន្ទីរសាលាក្រុង-ស្រុក-ខ័ណ្ឌ ធ្វើជាលេខាអចិន្ត្រៃយ៍ និងមានជំនួយការមួយចំនួនទៀតសំរាប់ជួយការងារតាមការចាំបាច់ ។

៣.២ ក្រុមប្រតិបត្តិការ គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយ ស្រុក-ខ័ណ្ឌ

គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយស្រុក-ខណ្ឌនីមួយៗ មានក្រុមប្រតិបត្តិការចំនួន ០៤ ។ ក្រុមនីមួយៗមានអភិបាលរងក្រុង-ស្រុក និងខណ្ឌ ០១រូបៗ ជាប្រធាន ។

ក្រុមស្រាវជ្រាវ រុករក និង សន្តិសុខ	
• **ប្រធានក្រុម** - អភិបាលរងក្រុង-ស្រុក-ខ័ណ្ឌ ០១រូប • **សមាសភាព អនុប្រធានក្រុម** ១. មេបញ្ជាការកងរាជអាវុធហត្ថស្រុក ២. អធិការនគរបាល ៣.មេបញ្ជាការផ្នែកសឹករងស្រុក ៤. ប្រធានការិ.អប់រំ យុវជន និងកីឬ្ឬ • **សមាសភាព សមាជិកក្រុម** - តំណាងការិយាល័យជុំវិញ ក្រុង-ស្រុក-ខ័ណ្ឌ	• **តួនាទី និង ការទទួលខុសត្រូវ** - តាមដានព័ត៌មាន និងរាយការណ៍ពីស្ថានភាព និងផលប៉ះពាល់ដើម្បីត្រៀមលក្ខណៈ និងប្រតិបត្តិការសង្គ្រោះ ។ - ជួយសង្គ្រោះប្រជាជនដែលងាយរងគ្រោះ និង ប្រជាជនរងគ្រោះ ដោយសារគ្រោះមហន្តរាយ ។ - កំណត់ប្រជាជនដែលស្ថិតនៅតំបន់ប្រឈមមុខនិងតំបន់ងាយរងគ្រោះ ។ - ជួយអាជ្ញាធរភូមិ ឃុំ និង ក្រុមប្រតិបត្តិការដទៃទៀតទៅតាមការស្នើសុំជាក់ស្តែង ។ - សហការជាមួយអាជ្ញាធរភូមិ ឃុំ ដើម្បីការពារសុវត្ថិភាព សន្តិសុខ សណ្តាប់ធ្នាប់នៅទីសុវត្ថិភាពដែលជនរងគ្រោះស្នាក់នៅ និងការពារទ្រព្យសម្បត្តិ ផ្ទះសំបែងរបស់ប្រជាជនដែលបានភៀសខ្លួន ។ - សហការជាមួយអាជ្ញាធរភូមិ ឃុំ ដើម្បីគ្រប់គ្រង និងសង់ជម្រកបណ្តោះអាសន្ននៅលើទីទួលសុវត្ថិភាព ។ - ផ្តល់ព័ត៌មានពាក់ព័ន្ធដល់អាជ្ញាធរភូមិ ឃុំ និង ចែករំលែកព័ត៌មានពាក់ព័ន្ធជាប្រចាំដល់ក្រុមដទៃ ការិយាល័យ និង អង្គភាព និង អង្គការនានានៅក្នុងស្រុក ។ - សហការនិងជួយសម្របសម្រួលដល់អាជ្ញាធរភូមិ ឃុំ អង្គការពាក់ព័ន្ធនានាក្នុងការជម្លៀស និង សង្គ្រោះ ។ - ជួយសម្របសម្រួល និង ការពារមធ្យោបាយដឹកជញ្ជូនសម្ភារៈជំនួយ និងជួយដឹកប្រជាពលរដ្ឋរងគ្រោះ ។ - ធ្វើការជាមួយអាជ្ញាធរភូមិ ឃុំ ដើម្បីកំណត់មធ្យោបាយ និង ឧបករណ៍សម្រាប់បម្រើសម្របសម្រួលការងារ ជម្លៀស និង សង្គ្រោះ ។

	- ចូលរួមប្រជុំដើម្បីចែករំលែកព័ត៌មាន បទពិសោធន៍ និង ចូលរួមការប្រជុំផ្សេងៗទៀត តាមការចង្អុលបង្ហាញរបស់ គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយស្រុក ។ - តួនាទីផ្សេងៗទៀតនឹងអនុវត្តតាមផែនការ និងការចង្អុលបង្ហាញពីគណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយរាជធានី-ខេត្ត ។

ក្រុមសុខភាព អនាម័យ និង ទឹកស្អាត	
• **ប្រធានក្រុម** - អភិបាលរងក្រុង-ស្រុក-ខ័ណ្ឌ ០១រូប • **សមាសភាព អនុប្រធានក្រុម** ១. ប្រធានការិយាល័យសុខាភិបាល ២. ប្រធានការិយាល័យអភិវឌ្ឍន៍ជនបទ ៣. ប្រធានការិយាល័យកិច្ចការនារី ៤. ប្រធានការ.ឧស្សាហកម្ម-រ៉ែ ថាមពល • **សមាសភាព សមាជិកក្រុម** - តំណាងការិយាល័យជុំវិញ ក្រុង-ស្រុក-ខ័ណ្ឌ	• **តួនាទី និង ការទទួលខុសត្រូវ** - សហការជាមួយអាជ្ញាធរភូមិ ឃុំ ដើម្បីផ្តល់ការអប់រំនិងផ្សព្វផ្សាយក្នុងការថែទាំសុខភាព អនាម័យ និងការប្រើប្រាស់ទឹកស្អាត និង បង្ការជំងឺរាតត្បាតផ្សេងៗ ។ - ផ្តល់ការហ្វឹកហ្វឺនវិជ្ជាសង្គ្រោះបឋមដល់ក្រុមស្រាវជ្រាវនិងសង្គ្រោះ និងក្រុមអ្នកស្ម័គ្រចិត្តតាមសហគមន៍ ។ - សហការជាមួយមណ្ឌលសុខភាពនានា និង អាជ្ញាធរភូមិ-ឃុំ ដើម្បីប្រតិបត្តិការសង្គ្រោះបន្ទាន់ និង ព្យាបាល ដល់ប្រជាជនរងគ្រោះដោយសារគ្រោះថ្នាក់ផ្សេងៗ ។ - សហការជាមួយអាជ្ញាធរភូមិ-ឃុំ និងមណ្ឌលសុខភាពនានា ដើម្បីតាមដានត្រួតពិនិត្យបញ្ហាទាក់ទងនឹងសុខភាព អនាម័យ ទឹកស្អាត និង បញ្ហាជម្ងឺផ្សេងៗទៀត ដែលបណ្តាលមកពីមុខសញ្ញាបង្កពីគ្រោះមហន្តរាយនានា ។ - ដឹកនាំ និង សហការជាមួយមណ្ឌលសុខភាព និង អាជ្ញាធរភូមិ ឃុំ ដើម្បីវាយតម្លៃ និងប៉ាន់ប្រមាណផលប៉ះពាល់ និង សេចក្តីត្រូវការ ផ្នែកសុខភាព អនាម័យ និង ទឹកស្អាត ។ - ធ្វើរបាយការណ៍ពីស្ថានភាពទាក់ទងនឹងសុខភាព អនាម័យ ទឹកស្អាត និង ជំងឺរាតត្បាតផ្សេងៗ ជូនគណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយស្រុក-ខេត្ត និង អង្គភាពពាក់ព័ន្ធនានា ។ - សហការ និង ជួយសម្របសម្រួលដល់បណ្តាអង្គការពាក់ព័ន្ធក្នុងការជួយដល់ផ្នែកសុខភាព អនាម័យ និង ទឹកស្អាត ។ - ចូលរួមប្រជុំដើម្បីចែករំលែកព័ត៌មាន និង បទពិសោធន៍ តាមការចង្អុលបង្ហាញរបស់គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយស្រុក ។ - តួនាទីផ្សេងទៀតនឹងអនុវត្តតាមផែនការនិងការចង្អុលបង្ហាញរបស់គណៈ-កម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយរាជធានី ខេត្ត ។

ក្រុមព័ត៌មាន អប់រំ និង ផ្សព្វផ្សាយ	
• **ប្រធានក្រុម** - អភិបាលរងក្រុង-ស្រុក-ខ័ណ្ឌ ០១រូប • **សមាសភាព អនុប្រធានក្រុម** ១. ប្រធានការិយាល័យធនធានទឹក ២. ប្រធានការិយាល័យព័ត៌មាន ៣. ប្រធានការិយាល័យបរិស្ថាន • **សមាសភាព សមាជិកក្រុម** - តំណាងការិយាល័យជុំវិញ ក្រុង-ស្រុក-ខ័ណ្ឌ	• **តួនាទី និង ការទទួលខុសត្រូវ** - តាមដានព័ត៌មាន និងរាយការណ៍ពីស្ថានភាពនិងផលប៉ះពាល់ផ្សេងៗ - ផ្សព្វផ្សាយព័ត៌មានព្យាករណ៍ និងប្រកាសប្រាប់ជូនដំណឹងជាមុនពីមុខសញ្ញាគ្រោះថ្នាក់យោងតាមប្រភពព័ត៌មានទាំងឡាយដែលទទួលបាន ។ - ដឹកនាំ និងសហការជាមួយអាជ្ញាធរភូមិ ឃុំ ដើម្បីវាយតម្លៃ និងប៉ាន់ប្រមាណផលប៉ះពាល់និងសេចក្ដីត្រូវការ ទាំងក្នុងពេល និងក្រោយពេលគ្រោះមហន្តរាយ ។ - គ្រប់គ្រង និងទុកដាក់ព័ត៌មានទាក់ទងនឹងគ្រោះមហន្តរាយ ។ - សហការ និងជួយសម្របសម្រួលដល់អង្គការនានាក្នុងការវាយតម្លៃ និងប៉ាន់ប្រមាណប៉ះពាល់ និងសេចក្ដីត្រូវការរបស់ជនរងគ្រោះ ។ - ប្រមូល និងចងក្រងព័ត៌មានទាក់ទងនឹងក្រុមអ្នកងាយរងគ្រោះ និងតំបន់ប្រឈមមុខនឹងគ្រោះទឹកជំនន់នានានៅក្នុងស្រុក ។ - ចូលរួមជាមួយអាជ្ញាធរភូមិ ឃុំ និងក្រុមដទៃ នៅពេលមានការស្នើសុំជាក់ស្តែង ។ - ដឹកនាំ និងចូលរួមប្រជុំដើម្បីចែករំលែកព័ត៌មាន និងបទពិសោធន៍ ដល់ក្រុមប្រតិបត្តិការដទៃ និង អង្គការពាក់ព័ន្ធ នានា ។ - ដឹកនាំការផ្សព្វផ្សាយ និងអប់រំការយល់ដឹងធារណៈដល់ប្រជាពលរដ្ឋតាមប្រព័ន្ធផ្សព្វផ្សាយដែលមាននៅក្នុងខេត្ត ទាក់ទងនឹងវិធានការនានា លើការកាត់បន្ថយផលប៉ះពាល់ផ្សេងៗ ដែលបណ្ដាលមកពីមុខសញ្ញាគ្រោះថ្នាក់ ។ - តួនាទីផ្សេងៗទៀត នឹងអនុវត្តតាមផែនការ និងការចង្អុលបង្ហាញរបស់គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយរាជធានី-ខេត្ត ។

ក្រុមឆ្លើយតប សង្គ្រោះបន្ទាន់	
• **ប្រធានក្រុម** - អភិបាលរងក្រុង-ស្រុក-ខណ្ឌ ០១រូប • **សមាសភាព អនុប្រធានក្រុម** ១. ប្រធានសាខាកាកបាទក្រហមក្រុង-ស្រុក ២. ប្រធានការិយាល័យ សង្គមកិច្ច	• **តួនាទី និង ការទទួលខុសត្រូវ** - តាមដានព័ត៌មាន និងរាយការណ៍ពីស្ថានភាព និង ផលប៉ះពាល់ ផ្សេងៗ ដោយសារគ្រោះមហន្តរាយនានា ។ - ប្រមូលព័ត៌មាន និងរបាយការណ៍ ពីអាជ្ញាធរភូមិ-ឃុំ និងក្រុមប្រតិបត្តិការផ្សេងៗ ដើម្បីផ្ញើជូនគណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយខេត្ត ពិនិត្យលទ្ធភាពក្នុងការផ្តល់ជំនួយសង្គ្រោះ ។

៣.ប្រធានការិ.រុក្ខាប្រមាញ់ និង នេសាទ ៤. ប្រធានការិ.សាធារណការ និងដឹកជញ្ជូន • **សមាសភាព សមាជិកក្រុម** - តំណាងការិយាល័យជុំវិញ ក្រុង-ស្រុក-ខ័ណ្ឌ	- ដឹកនាំ និងសហការជាមួយអាជ្ញាធរភូមិ ឃុំ ដើម្បីវាយតម្លៃ និងប៉ាន់ប្រមាណសេចក្ដីត្រូវការរបស់ជនរង គ្រោះដើម្បីធ្វើការឆ្លើយតប សម្របសម្រួលបានទាន់ពេលវេលា និងមានប្រសិទ្ធិភាព ។ - ដឹកនាំប្រតិបត្តិការដទៃ ដើម្បីចុះស្រង់ស្ថិតិប្រជាជនរងគ្រោះ នៅតាមទីសុវត្ថិភាពដើម្បីផ្ដល់ជំនួយសង្គ្រោះបន្ទាន់ និងជ្រើសរើសអ្នកទទួលជំនួយសង្គ្រោះ ដោយមានការចូលរួមពីអាជ្ញាធរភូមិ ឃុំ ។ - គ្រប់គ្រង ថែរក្សាស្ដុកទុក ជំនួយសង្គ្រោះនិងសម្ភារៈផ្សេងៗទៀត ។ - ធ្វើការជាមួយក្រុមទទួលខុសត្រូវនៅថ្នាក់ខេត្ត ដោយមានការសហការជាមួយអាជ្ញាធរភូមិ ឃុំ ដើម្បីបែងចែក និងដឹកជញ្ជូនជំនួយសង្គ្រោះដល់ប្រជាពលរដ្ឋរងគ្រោះ ។ - ធ្វើការជាមួយគណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយស្រុក និងខេត្ត ដើម្បីទំនាក់ទំនង និងអំពាវនាវ ដល់ស្ថាប័ន អង្គការ មនុស្សធម៌ សប្បុរសជន និងអង្គការផ្សេងទៀត ដើម្បីស្វែងរកជំនួយ និងការគាំទ្រ ។ - សម្របសម្រួល និងចង្អុលបង្ហាញទីតាំងជនរងគ្រោះ ដល់បណ្ដាអង្គការ មនុស្សធម៌ និងសប្បុរសជន ដែលគេមានបំណងចង់ចែកជំនួយសង្គ្រោះ ដោយខ្លួនគេ ។ - ធ្វើការជាមួយអាជ្ញាធរភូមិ ឃុំ ដើម្បីបន្ដការតាមដានស្ថានភាព និងសេចក្ដីត្រូវការរបស់ជនរងគ្រោះ ។ - ដឹកនាំ និងចូលរួមប្រជុំដើម្បីចែករំលែកព័ត៌មាន និងបទពិសោធន៍ ដល់ក្រុមប្រតិបត្តិការ និងអង្គការពាក់ព័ន្ធនានា ។ - តួនាទីផ្សេងទៀតនឹងអនុវត្តតាមផែនការ និងការចង្អុលបង្ហាញរបស់ គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយរាជធានី-ខេត្ត ។

៤. មុខងារ និង តួនាទីរបស់គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយក្រុង-ស្រុក-ខណ្ឌ

- អនុវត្តគោលនយោបាយជាតិ ដែលពាក់ព័ន្ធក្នុងការងារគ្រប់គ្រងគ្រោះមហន្តរាយ ។
- ផ្ដល់យោបល់ជូនគណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយរាជធានី-ខេត្ត អំពីស្ថានភាពថ្មីៗ
- ជ្រើសរើសមន្ត្រីដើម្បីចូលរួមក្នុងវគ្គបណ្ដុះបណ្ដាលថ្នាក់ជាតិ រាជធានី-ខេត្ត ស្ដីពីការគ្រប់គ្រងគ្រោះ មហន្តរាយ ។
- រៀបចំ និងផ្សព្វផ្សាយព័ត៌មាន ដល់សាធារណៈជនអំពីគ្រោះមហន្តរាយ ។
- បញ្ជូនរបាយការណ៍ ស្ដីពីសេចក្ដីត្រូវការទៅគណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយ រាជធានី-ខេត្ត ស្ដីពីការខូចខាត និងតំរូវការផ្សេងៗ ។

- ដឹកនាំប្រតិបត្តិការក្នុងពេលមានគ្រោះមហន្តរាយ រួមមាន: ជំនួយសង្គ្រោះ ការជំលៀស ការផ្តល់ ទីជំរក និងការផ្តល់ជំនួយសុខាភិបាល ។
- បញ្ជូនរបាយការណ៍សរុប ស្តីពីប្រតិបត្តិការជំនួយសង្គ្រោះទៅគណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយ រាជធានី-ខេត្ត ។

III. ឯកសារយោង

- អនុក្រឹត្យលេខ ៣០ អនក្រ.បក ចុះថ្ងៃទី០៩ ខែមេសា ឆ្នាំ២០០២ ។

មេរៀនទី ៤: គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយ ឃុំ-សង្កាត់

I. គោលបំណងរួម

អ្នកចូលរួម និងសិក្ខាកាមទាំងអស់នឹងបានយល់ដឹងពីយន្តការ នៃការបង្កើតឡើងនូវ គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយឃុំ-សង្កាត់ សមាសភាព រចនាសម្ព័ន្ធ បេសកកម្ម មុខងារ-ភារកិច្ចនិងការទទួលខុសត្រូវរបស់ គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយនេះ ។

II. ខ្លឹមសារមេរៀន

១. សមាសភាព

គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយឃុំ-សង្កាត់ ត្រូវបានបង្កើតឡើងតាមអនុក្រិត្យលេខ ៦១ អនក្រ.បក ចុះថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០០៦ របស់រាជរដ្ឋាភិបាល និងលិខិតណែនាំលេខ ១៨១ គ.ជ.គ.ម ចុះថ្ងៃទី ១១ ខែកក្កដា ឆ្នាំ២០០៦ របស់គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ ។ មេឃុំ-ចៅសង្កាត់ ជាអ្នកចុះហត្ថលេខាលើដីកាបង្កើត គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយឃុំ-សង្កាត់ និងក្រុមទាំង ០៣ ។

គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយឃុំ-សង្កាត់មានសមាសភាព ដូចខាងក្រោម:

- មេឃុំ ឬ ចៅសង្កាត់ ជាប្រធាន
- ជំទប់ទី១ ឬ ចៅសង្កាត់រងទី១ ជាអនុប្រធាន
- ប្រធានប៉ូលីនគរបាលរដ្ឋបាលឃុំ-សង្កាត់ ជាសមាជិក
- ប្រធានកម្រងសាលាបឋមសិក្សា ជាសមាជិក
- ប្រធានមណ្ឌលសុខភាពឃុំ-សង្កាត់ ជាសមាជិក
- ជនបង្គោលទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ ជាសមាជិក
- ភ្នាក់ងារសុខភាពសត្វឃុំ-សង្កាត់ ជាសមាជិក
- អ្នកស្ម័គ្រចិត្តកាកបាទក្រហម ជាសមាជិក
- ព្រឹទ្ធាចារ្យក្នុងឃុំ ជាសមាជិក
- មេភូមិគ្រប់ភូមិ ជាសមាជិក
- ស្មៀន ជាលេខាអចិន្ត្រៃយ៍

បញ្ជាក់: សមាសភាពខាងលើ គឺជាការចង្អុលបង្ហាញនៅពេលចេញដីកា ត្រូវកំណត់ឈ្មោះបុគ្គលិកទទួលខុសត្រូវឱ្យ បានច្បាស់លាស់ ។

២. បេសកកម្ម

គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយឃុំ-សង្កាត់ ត្រូវដឹកនាំការគ្រប់គ្រងគ្រោះមហន្តរាយនៅតំបន់ជុំវិញ ឃុំ និងសង្កាត់ របស់ខ្លួន ។

៣. រចនាសម្ព័ន្ធ



៤. តួនាទី ការទទួលខុសត្រូវរបស់ប្រធាន អនុប្រធាន លេខាធិការដ្ឋាន និងក្រុមប្រតិបត្តិការ

៤.១ ប្រធាន

<u>អាណត្តិប្រធាន:</u> មេឃុំ-ចៅសង្កាត់ ជាប្រធានគណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយឃុំ-សង្កាត់មិនអាចយកអ្នកផ្សេងធ្វើជាប្រធានបានឡើយ ហើយមិនអាចបញ្ឈប់ពីមុខតំណែងប្រធានមុនអាណត្តិរបស់ខ្លួនជាមេឃុំ ឬចៅសង្កាត់នោះដែរ ។

<u>តួនាទីរបស់ប្រធាន:</u>

- ដឹកនាំ និងសម្រេចកិច្ចការរបស់គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយឃុំ-សង្កាត់ ក្នុងនាមជាប្រធាន និងក្នុងក្របខណ្ឌជាមេឃុំ និងចៅសង្កាត់ រួមទាំងការចុះហត្ថលេខាលើការបង្កើតគណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយឃុំ-សង្កាត់ ក្រុមប្រតិបត្តិការទាំង០៣ ការណែនាំការប្រកាសប្រាប់ឱ្យដឹងមុនពីគ្រោះអាសន្ននៅក្នុង ឃុំ-សង្កាត់របស់ខ្លួន និង ចេញលិខិតកោះអញ្ជើញប្រជុំគណៈកម្មាធិការគ្រប់គ្រងគ្រោះ មហន្តរាយឃុំ-សង្កាត់ ។
- ដឹកនាំការប្រជុំរបស់គណៈកម្មាធិការគ្រប់ក្រងគ្រោះមហន្តរាយឃុំ-សង្កាត់ ។

- ធ្វើសហប្រតិបត្តិការ និងដឹកនាំការអនុវត្តន៍គំរោងកម្មវិធី ការងារគ្រប់គ្រងគ្រោះภัយនៃគ្រោះមហន្តរាយ នៅមូលដ្ឋានសហគមន៍ជាមួយស្ថាប័នពាក់ព័ន្ធ អង្គការជាតិ-អន្តរជាតិ អង្គការមិនមែនរដ្ឋាភិបាល និងដៃគូនានា ដែលត្រូវអនុវត្តនៅក្នុងឃុំ-សង្កាត់របស់ខ្លួន ។
- ដឹកនាំការងារប្រចាំថ្ងៃរបស់គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយឃុំ-សង្កាត់របស់ខ្លួន ។
- ដឹកនាំការងារបណ្តុះបណ្តាលសំរាប់សកម្មភាពត្រៀមបង្ការ និងការត្រៀមរៀបចំ សំរាប់ឆ្លើយតប គ្រោះអាសន្ន និងការស្តារឡើងវិញ ដោយបញ្ជ្រាបការគ្រប់គ្រងគ្រោះภัយនៃគ្រោះមហន្តរាយទៅក្នុងការអភិវឌ្ឍន៍សហគមន៍ មូលដ្ឋាន ។

៤.២ អនុប្រធាន

<u>អាណត្តិអនុប្រធាន:</u> ជំទប់ទី១ ឬចៅសង្កាត់រងទី១ ជាអនុប្រធានគណៈកម្មាធិការគ្រប់គ្រងគ្រោះ មហន្តរាយឃុំ-សង្កាត់ មិនអាចយកអ្នកផ្សេងធ្វើជាអនុប្រធាន ហើយមិនអាចបញ្ឈប់ពីមុខតំណែងអនុប្រធានមុនអាណត្តិរបស់ខ្លួន ជាជំទប់ទី១ និង ចៅសង្កាត់រងទី១ នោះដែរ ។

<u>តួនាទីរបស់អនុប្រធាន:</u> ជួយការងារប្រធាន និង ជំនួសប្រធាននៅពេលប្រធានអវត្តមាន ។

៤.៣ លេខាធិការដ្ឋាន

ត្រូវបានបង្កើតឡើងដើម្បីជាសេនាធិការឱ្យប្រធាន និងអនុប្រធានគណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយឃុំ-សង្កាត់ ក្នុងការបូកសរុបសភាពការណ៍បង្កបង្កើនផល គ្រោះមហន្តរាយ និងសកម្មភាពរបស់ក្រុមទាំង០៣ ដើម្បីរាយការណ៍ជូនថ្នាក់បន្តបន្ទាប់ ដែលទទួលការងារគ្រប់គ្រងគ្រោះមហន្តរាយហើយមានតួនាទីទទួលខុសត្រូវលើការងារ:

- ទទួលនិងផ្តល់ពត៌មានបន្ទាន់ពីមុខសញ្ញាគ្រោះថ្នាក់និងគ្រោះអាសន្នផ្សេងៗដោយមនុស្សនិងធម្មជាតិ
- ទទួលរបាយការណ៍ និងគ្រប់គ្រងទុកដាក់ឯកសារ
- បូកសរុបសភាពការណ៍ និងតាមដានត្រួតពិនិត្យវាយតំលៃ
- ធ្វើកំណត់ហេតុប្រជុំគណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយឃុំ

៤.៤ ក្រុមសន្តិសុខ និងរុករកសង្គ្រោះ

ត្រូវបានបង្កើតឡើងដើម្បីរៀបចំ ត្រៀមបង្ការមុខសញ្ញាគ្រោះថ្នាក់ដែលបង្កឡើងដោយមនុស្ស និងធម្មជាតិ ប្រតិបត្តិការ នៅពេលមានគ្រោះអាសន្ន រំដោះប្រជាជនចេញពីគ្រោះថ្នាក់ ជម្លៀសប្រជាជន ការពារសន្តិសុខ សុវត្ថិភាព ពន្លត់អគ្គិภัយ ការរុករក និងសង្គ្រោះអ្នករងគ្រោះ ព្រមទាំងមានតួនាទីទទួលខុសត្រូវ ដូចខាងក្រោម:

- កសាងផែនការ រៀបចំកំលាំង មធ្យោបាយ សំភារៈសំរាប់បំរើការរុករកនិងសង្គ្រោះ និង សន្តិសុខ សណ្តាប់ធ្នាប់ ។
- អប់រំផ្សព្វផ្សាយ និងពន្យល់ដល់ប្រជាពលរដ្ឋក្នុងឃុំ-សង្កាត់ អំពីវិធានការត្រៀមបង្ការកាត់បន្ថយគ្រោះថ្នាក់ ត្រៀមរៀបចំសំរាប់កាត់បន្ថយគ្រោះអាសន្ននិងគ្រោះภัយផ្សេងៗ ព្រមទាំងខ្ជឹមសារ និងសញ្ញា ប្រកាសអាសន្ន និង សកម្មភាពត្រូវអនុវត្ត ។
- កំណត់ ផ្តល់សញ្ញាពីលំនៅដ្ឋានមួយទៅលំនៅដ្ឋានមួយដើម្បីងាយស្រួលពេលមានគ្រោះអាសន្នកើតឡើង ។

- ថែរក្សាទុកដាក់ឱ្យបានល្អនូវឧបករណ៍ មធ្យោបាយប្រកាសអាសន្ន (មេក្រូ ជួង ត្រដោក ស្គរ ចង្កៀង) ធានាថាប្រើប្រាស់បាន ។
- រៀបចំផែនទីមុខសញ្ញាគ្រោះថ្នាក់ទីសុវត្ថិភាព និងគំនូសបង្ហាញផ្លូវពីកន្លែងមានប្រជាពលរដ្ឋរស់នៅទៅកាន់កន្លែងជម្លៀស ព្រមទាំងមានបញ្ជីប្រជាជនដែលអាចត្រូវជម្លៀសផងដែរ ។
- កន្លែងដែលកំណត់ទុកសំរាប់ជម្លៀស គឺធានាអាចប្រើប្រាស់បាន មានសុវត្ថិភាព និងធ្វើផែនការជម្លៀស បង្កើតវិធីសាស្ត្រក្នុងការជម្លៀស ឱ្យមានប្រសិទ្ធិភាពតាមផែនការ ។
- ការពារសន្តិសុខ កន្លែងស្នាក់នៅបណ្តោះអាសន្នរបស់ជនរងគ្រោះ និងការពារមិនឱ្យមានការបន្ទំចូលលួចប្លន់ ព្រមទាំងថែរក្សាការពារ ទ្រព្យសម្បត្តិ ផ្ទះសំបែង របស់ប្រជាពលរដ្ឋដែលបានចាកចោលបណ្តោះអាសន្ន ទៅទីសុវត្ថិភាព ។
- ត្រួតពិនិត្យការចេញចូលនៅតំបន់កើតហេតុការណ៍ និង ទីទួលសុវត្ថិភាព ។
- ដាក់ផ្លាកសញ្ញាតំបន់គ្រោះថ្នាក់ និងសញ្ញាសំគាល់ និងសញ្ញាហាមឃាត់ផ្សេងៗ ។
- ផ្តល់កំលាំងការពារក្បួនដឹកជញ្ជូនសំភារៈបរិក្ខារ និងប្រតិបត្តិការ ដែលចូលមកបំពេញការងារនៅតំបន់ រងគ្រោះ ។
- រៀបចំកំលាំងប្រតិបត្តិការដំណាក់កាលដំបូង សំរាប់ពន្លត់អគ្គិភ័យ ។
- ផ្សព្វផ្សាយវិធានការផ្សេងៗ ដែលជាលក្ខណៈត្រៀមបង្ការនូវយថាហេតុ នៃមុខសញ្ញាគ្រោះថ្នាក់ដោយមនុស្ស តាមមធ្យោបាយដែលអាចធ្វើបាន ។
- ដឹកនាំបុគ្គលិកសង្គ្រោះនិងសំរបសំរួលធ្វើការបណ្តុះបណ្តាលជំនាញផ្នែកសង្គ្រោះបឋមនិងជួយសង្គ្រោះ ។

៤.៥ ក្រុមសុខភាព និង អនាម័យ

ត្រូវបានបង្កើតឡើង ដើម្បីធ្វើប្រតិបត្តិការការពារអាយុជីវិតប្រជាជន តាមរយៈការគាំការពារសុខភាព ស្រាវជ្រាវ រកប្រភពនៃជំងឺ និងការពារជំងឺឆ្លងទាំងមនុស្ស-សត្ត ជំងឺរាតត្បាតជម្លៀសអ្នកជំងឺនៅតាមកន្លែងមន្ទីរពេទ្យសង្គ្រោះបន្ទាន់ ហើយមានតួនាទីទទួលខុសត្រូវដូចខាងក្រោម:

- អប់រំផ្សព្វផ្សាយដល់ប្រជាពលរដ្ឋឱ្យមានការយល់ដឹងពីការថែរក្សាសុខភាព ការទទួលទានចំណីអាហារ ការត្រៀមបង្ការមុខសញ្ញាគ្រោះថ្នាក់ ដែលបង្កដោយមនុស្ស និងធម្មជាតិ ។
- បណ្តុះបណ្តាលជំនាញផ្នែកសង្គ្រោះបឋម ថែទាំសុខភាព អនាម័យដល់សហគមន៍
- អប់រំផ្សព្វផ្សាយការយល់ដឹងជាសាធារណៈ ដល់ប្រជាពលរដ្ឋក្នុងឃុំ-សង្កាត់ អំពីរោគសញ្ញាផ្សេងៗ នៃជំងឺសត្ត ការការពារ ការព្យាបាលជំងឺសត្ត ការសំអាតអនាម័យទ្រុងសត្ត និង អនាម័យខ្លួនប្រាណមនុស្ស ការបរិភោគ ចំអិនសាច់សត្ត ។
- រិះរកវិធីសាស្ត្រ សំរាប់ណែនាំដល់ប្រជាពលរដ្ឋឱ្យចេះជួយខ្លួនឯង និងប្រើប្រាស់អ្វីដែលមានក្នុងមូលដ្ឋាន ដើម្បីឆ្លើយតបពេលមានជួបគ្រោះអាសន្នកើតឡើង ។
- ត្រួតពិនិត្យ និងក្តាប់ជាប់ជាប្រចាំនូវស្ថិតិសត្ចិញ្ចឹមនៅក្នុងឃុំ-សង្កាត់
- ចាក់ថ្នាំបង្ការជំងឺសត្ត

- ត្រួតពិនិត្យមិនឱ្យមានការទិញលក់សត្វឈឺ និងសត្វស្លាប់ដោយជំងឺ និងការដឹកជញ្ជូនសត្វនៅក្នុងរង្វង់ឃុំ-សង្កាត់
- ពង្រឹងបទបញ្ជាអនាម័យ អនុវត្តផែនការត្រួតពិនិត្យតំបន់កខ្វក់ ការចាក់សំរាម
- ត្រួតពិនិត្យស្ថានភាពអនាម័យរបស់សហគមន៍ អណ្តូងទឹក ស្រះទឹក និងការប្រើប្រាស់ទឹក
- កំណត់ទីកន្លែងអាគារដែលអាចប្រើប្រាស់ជាមូលដ្ឋាន រៀបចំទីស្នាក់ការពេទ្យពេលមានគ្រោះអាសន្នកើតឡើង និងគ្រប់គ្រងព្យាបាលដល់អ្នកជំងឺស្រាលៗ ។

៤.៦ ក្រុមឆ្លើយតប និងព័ត៌មាន

ត្រូវបានបង្កើតឡើងដើម្បីធ្វើប្រតិបត្តិការផ្តល់ព័ត៌មានអំពីមុខសញ្ញាគ្រោះថ្នាក់ដោយធម្មជាតិ និងដោយមនុស្ស ដែលកើតឡើងនៅមូលដ្ឋានឃុំ-សង្កាត់ ទាក់ទងនឹងតម្រូវការរបស់ប្រជាពលរដ្ឋដែលរងគ្រោះ និង ធ្វើការចែក ផ្សាយព័ត៌មាន បង្ហាញហេតុផល ព្រមទាំងធ្វើការអំពាវនាវរកជំនួយ ផ្តល់ជំនួយដល់ក្រុមរងគ្រោះ អនុវត្តគំរោង ស្បៀងពលកម្ម ហើយមានតួនាទីទទួលខុសត្រូវដូចខាងក្រោម:

- សហការជាមួយអង្គការអន្តរជាតិ អង្គការមិនមែនរដ្ឋាភិបាល កសាងគំរោងត្រៀមបង្ការគ្រោះមហន្តរាយ តាមបែបរចនាសម្ព័ន្ធ និង មិនមែនរចនាសម្ព័ន្ធ ។
- រៀបចំទីសុវត្ថិភាពឱ្យមានលក្ខណៈសមស្របអាចស្នាក់នៅបាន
- ស្រង់ចំនួនប្រជាជនរងគ្រោះ ដែលជម្លៀសទៅរស់នៅតាមទីទួលសុវត្ថិភាព
- ផ្តល់ការស្នាក់នៅដល់ប្រជាជនរងគ្រោះ រៀបចំជំរកបណ្តោះអាសន្ន ឬនៅតាមគេហដ្ឋាននានា ដែលម្ចាស់គេបានអនុញ្ញាត
- គ្រប់គ្រងសំភារៈជំនួយសង្គ្រោះ ដូចជា: អង្ករ ស្បៀងអាហារជាដើម ។
- រាយការណ៍ពីស្ថានភាពជនរងគ្រោះនិងសកម្មភាពផ្តល់ជំនួយ វាយតំលៃការខូចខាតនិងសេចក្តីត្រូវការ ។
- តាមដានត្រួតពិនិត្យសុខុមាលភាពរបស់ប្រជាជនរស់នៅក្នុងទីសុវត្ថិភាព ។
- ចែកចាយអំណោយសំភារៈសង្គ្រោះបន្ទាន់ ។
- ដាស់សតិអារម្មណ៍ និងបំផុសស្មារតីលើកទឹកចិត្ត ។
- ស្វែងរកបញ្ហាផ្សេងៗនិងព្យាយាមដោះស្រាយបញ្ហា ។
- រៀបចំផ្តល់ឱកាសរកការងារដល់ជនរងគ្រោះ ដូចជា: កម្មវិធីស្បៀងពលកម្ម និងប្រាក់ពលកម្ម ផ្តល់មីក្រូ ឥណទានជាដើម ។

៤.៧ ចុះងារ និង ភារកិច្ចរបស់គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយឃុំ-សង្កាត់

- អនុវត្តគោលនយោបាយដែលទាក់ទងទៅនឹងការគ្រប់គ្រងគ្រោះមហន្តរាយ ។
- កសាងផែនការត្រៀមបង្ការកាត់បន្ថយគ្រោះថ្នាក់ ការត្រៀមរៀបចំ ដើម្បីការពារអាយុជីវិតមនុស្ស-សត្ត សន្តិសុខ សណ្តាប់ធ្នាប់ សុវត្ថិភាពផលិតផលកសិកម្ម សេវាសាធារណៈ បរិស្ថាន និង អនុវត្តដើម្បីកាត់ បន្ថយគ្រោះภัយ នៅពេលមានមុខសញ្ញាគ្រោះថ្នាក់ពីធម្មជាតិ និងមនុស្ស ។
- សម្របសម្រួលផែនការខាងលើជាមួយគណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយស្រុក-ខ័ណ្ឌ

- រៀបចំបង្កើត និងគ្រប់គ្រងទីទួលសុវត្ថិភាព
- រៀបចំគោលការណ៍ណែនាំ អនុវត្ត និងគាំទ្រសកម្មភាពគ្រប់គ្រងគ្រោះภัយនៃគ្រោះមហន្តរាយនៅមូលដ្ឋានសហគមន៍ ។
- ជាសេនាធិការរបស់គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយស្រុក ក្នុងការងារកាត់បន្ថយគ្រោះមហន្ត-រាយ និងផ្តល់យោបល់ពីសកម្មភាពរបស់ស្ថាប័នពាក់ព័ន្ធ សមាគមជាតិ ភ្នាក់ងារអង្គការសហប្រជាជាតិ អង្គការជាតិ និងអន្តរជាតិ អង្គការមិនមែនរដ្ឋាភិបាល ដែលបានរួមចំណែកក្នុងការងារកាត់បន្ថយគ្រោះ មហន្តរាយ និងភាពងាយរងគ្រោះនៅមុនពេល ក្នុងពេល និងក្រោយពេលគ្រោះមហន្តរាយ ។
- រៀបចំចងក្រងក្រុមប្រតិបត្តិការសំរាប់ធ្វើសកម្មភាពរួមមាន: (១).ក្រុមសន្តិសុខនិងរុករកសង្គ្រោះ (២).ក្រុមសុខភាព និងអនាម័យ, និង (៣).ក្រុមឆ្លើយតបនិងពិតមាន ។
- ជ្រើសរើសអ្នកស្ម័គ្រចិត្តចូលរួមបំពេញការងារក្នុងក្រុមប្រតិបត្តិការទាំង ០៣
- រៀបចំកម្មវិធីបណ្តុះបណ្តាលដល់ក្រុមប្រតិបត្តិការទាំងបី លើជំនាញទទួលខុសត្រូវព្រមទាំងអប់រំផ្សព្វផ្សាយការយល់ដឹងជាសាធារណៈដល់មូលដ្ឋានសហគមន៍ ពីគ្រោះภัយនៃគ្រោះមហន្តរាយ មុខសញ្ញាគ្រោះថ្នាក់ និងវិធានការគ្រប់គ្រងគ្រោះภัย ។
- លើកគំរោងប្រើប្រាស់ថវិកា សំភារៈបរិក្ខារ មធ្យោបាយប្រើប្រាស់ និងកំលាំង សំរាប់ធ្វើសកម្មភាព តាមដំណាក់នីមួយៗនៃការគ្រប់គ្រងគ្រោះមហន្តរាយ ដើម្បីដាក់ស្នើតាមលំដាប់ថ្នាក់របស់ខ្លួន និងអង្គការនានា
- ធ្វើរបាយការណ៍ជូន គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយស្រុក-ខណ្ឌ អំពីស្ថានភាពដែលនឹងអាចកើតមាន និងកើតមានមុខសញ្ញាគ្រោះថ្នាក់នៅមូលដ្ឋានសហគមន៍របស់ខ្លួន ។
- ធ្វើរបាយការណ៍ពីសភាពការណ៍គ្រោះមហន្តរាយជូនគណៈកម្មការគ្រប់គ្រងគ្រោះមហន្តរាយស្រុក-ខណ្ឌ ។
- ផ្តល់ពត៌មានដល់ថ្នាក់លើរបស់ខ្លួនអំពីការកើតឡើងនូវមុខសញ្ញាគ្រោះថ្នាក់ឱ្យបានលឿននិងបន្ទាន់បំផុត ។
- ធ្វើការប្រជុំ១ខែម្តងជាទៀងទាត់ ដើម្បីត្រួតពិនិត្យសកម្មភាពរបស់ក្រុមទាំង០៣ និងដោះស្រាយបញ្ហា ដែលកើតមានរបស់ក្រុមទាំង០៣ តាមការកោះអញ្ជើញរបស់ប្រធាន និងក្នុងលក្ខណៈមានគ្រោះអាសន្ន ត្រូវមានការកោះអញ្ជើញប្រជុំបន្ទាន់ ។

III. ឯកសារយោង

- សេចក្តីណែនាំអនុវត្តន៍ស្តីពី បង្កើតគណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយឃុំ-សង្កាត់ (CCDM) លេខ១៨១ គ.ជ.ត.ម ចុះថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០០៦

ឯកសារបណ្តុះបណ្តាល

ផ្នែកទី ៣

ការចាត់ប្រមាណគ្រោះภัយ
បែបចូលរួម

មេរៀនទី ១: ការនាំឱ្យស្គាល់ទៅនឹងការប៉ាន់ប្រមាណគ្រោះภัย

I. គោលបំណងរួម

- ដើម្បីនាំឱ្យស្គាល់ពីគ្រោះภัย និងធាតុសំខាន់ៗរបស់ មុខសញ្ញាគ្រោះថ្នាក់ ภาពងាយរងគ្រោះ និង សមត្ថภาព។
- ដើម្បីបង្ហាញពីជំហានានា សំរាប់ធ្វើការវិភាគ និងអនុវត្ត លើការប៉ាន់ប្រមាណពី មុខសញ្ញាគ្រោះថ្នាក់ ภาពងាយរងគ្រោះ និងសមត្ថภาព ដើម្បីក្តាប់បាននូវគ្រប់ព័ត៌មាន ស្ថានภาពប្រឈម និងធនធានផ្សេងៗ សំរាប់ការត្រៀមរៀបចំ និងកាត់បន្ថយ បានទាន់ពេលវេលា ចំពោះគ្រោះមហន្តរាយនានា។

II. តើការប៉ាន់ប្រមាណគ្រោះภัយ (RA) ជាអ្វី?

> គឺជាវិធីសាស្ត្រ ដើម្បីកំណត់លក្ខណៈ និងទំហំនៃគ្រោះภัยដោយធ្វើការវិភាគលើមុខសញ្ញាគ្រោះថ្នាក់ដែលអាចកើតមាន និងវាយតម្លៃលើល័ក្ខខ័ណ្ឌដែលមានស្រាប់នៃภาពងាយរងគ្រោះ ដែលកត្តាទាំងពីរនេះអាចបង្កមហន្តរាយដល់មនុស្ស ទ្រព្យ សម្បត្តិ សេវាកម្ម ជីវภาពរស់នៅ និងបរិស្ថាន។

ប្រជាជនក្រីក្រត្រូវប្រឈមមុខនឹងគ្រោះថ្នាក់ដ៏ខ្លាំងទៅនឹងមុខសញ្ញាគ្រោះថ្នាក់ ជាពិសេសកសិករ អ្នកគ្មានដីធ្លី ស្ត្រី មនុស្សពិការ មនុស្សចាស់ៗ និងអ្នកនេសាទត្រី ជាដើម។ អ្នកទាំងអស់នេះ តែងតែជួបប្រទះនឹងមុខសញ្ញាគ្រោះថ្នាក់ និងការបាត់បង់ជីវិត និងធនធានជាញឹកញាប់ដែលបណ្តាលអោយពួកគេកាន់តែមានគ្រោះថ្នាក់ឡើង។ ដូចនេះ ដោយផ្អែកលើបញ្ហាចម្បងៗទាំងនេះ ការរៀបចំសកម្មภาពកាត់បន្ថយគ្រោះภัยដល់អ្នកដែលមានគ្រោះថ្នាក់ទាំងអស់នេះ គឺពិតជាមិនអាចខ្វះបាន ហើយការចូលរួមយ៉ាងច្រើនពីសហគមន៍នៅក្នុងដំណើរការរៀបចំសកម្មภาពនេះ ក៏ជាតំរូវការដ៏ចាំបាច់ផងដែរ។

គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ(NCDM) គឺជាអ្នកដើរតួដ៏សំខាន់ក្នុងការឆ្លើយតបទៅនឹងគ្រោះមហន្តរាយនានា និងរៀបចំសកម្មภาពកាត់បន្ថយគ្រោះภัย ដែលមានលក្ខណៈដ៏យូរអង្វែង នៅក្នុងប្រទេសកម្ពុជា។

យើងសង្កេតឃើញថា មានអង្គការជាតិ-អន្តរជាតិ និងអង្គការសហប្រជាជាតិជាច្រើន បានចូលរួមនៅក្នុងការឆ្លើយតបនឹងគ្រោះមហន្តរាយ និងគោលគំនិតការងារកាត់បន្ថយគ្រោះภัย ដែលមានទិសដៅផ្តល់ផលប្រយោជន៍ដល់អ្នកក្រីក្រ និងក្រុមងាយរងគ្រោះថ្នាក់។ ឧបករណ៍សំរាប់ប៉ាន់ប្រមាណគ្រោះภัยនៅតាមសហគមន៍ ត្រូវបានប្រើប្រាស់នៅគ្រប់ក៏រិត ដើម្បីឱ្យមានការចូលរួមយ៉ាងច្រើនពីដៃគូអនុវត្តន៍សំខាន់ៗ ក្នុងការធានាឱ្យមានប្រសិទ្ធិภาពនៃការចូលរួមពីសហគមន៍ដែល ងាយរងគ្រោះថ្នាក់ ដើម្បីសំរេចបាននូវគោលបំណង និងសកម្មภาពកាត់បន្ថយគ្រោះภัยរយៈពេលយូរអង្វែង។

III. តើការប៉ាន់ប្រមាណគ្រោះภัยដោយមានការចូលរួមនៅតាមសហគមន៍ជាអ្វី?

ការប៉ាន់ប្រមាណគ្រោះภัยដោយមានការចូលរួមនៅតាមសហគមន៍ គឺជាដំណើរការដោយមានការចូលរួមមួយ ក្នុងការកំណត់ពីប្រភពល័ក្ខខ័ណ្ឌ និង ទំហំនៃឥទ្ធិពលជាអវិជ្ជមាននៃមុខសញ្ញាគ្រោះថ្នាក់ដល់សហគមន៍ និងគ្រួសារនៅក្នុងកំឡុងពេលមួយនៃការប៉ាន់ប្រមើលទុកជាមុន។ វាធ្វើការកំណត់ពីលទ្ធภาព ឬឥទ្ធិពលជាអវិជ្ជមាន (ការខូចខាត និងការបាត់បង់) ទៅលើ

សមាសភាគគ្រោះថ្នាក់ (ជីវិត និងសុខភាពរបស់មនុស្សដែលមាន ដូចជា: រចនាសម្ព័ន្ធគ្រួសារ និងសហគមន៍, សេវាកម្ម និងមធ្យោបាយសំរួលនានា ផ្ទះសំបែង សាលារៀន មន្ទីរពេទ្យ ជាដើម ហើយនិងសកម្មភាពចិញ្ចឹមជីវិត និងសេដ្ឋកិច្ច ដែលមានដូចជា: ការងារ គ្រឿងបរិក្ខារ ផលដំណាំ សត្វពាហណៈជាដើម និងផ្លូវថ្នល់ និងស្ពាន)។ តើហេតុអ្វីបានជាមាន គ្រួសារ និងក្រុមមនុស្ស មួយចំនួន ងាយរងគ្រោះថ្នាក់ទៅនឹងមុខសញ្ញាគ្រោះថ្នាក់? ហើយហេតុអ្វីបានជានៅមានមុខសញ្ញា គ្រោះថ្នាក់មួយចំនួនទៀត ក៏មិនត្រូវបានគេធ្វើការវិភាគ?

យន្តការ និង ធនធាន(សមត្ថភាព)សំរបសំរួល ដែលមាននៅក្នុងសហគមន៍ ក៏ជាគោលគំនិតដ៏សំខាន់ផងដែរ នៅក្នុងការប៉ាន់ប្រមាណគ្រោះภัយនៅតាមសហគមន៍។

ការចូលរួមរបស់សមាជិកសហគមន៍ គឺជាផ្នែកដ៏សំខាន់មួយនៃការប៉ាន់ប្រមាណគ្រោះภัយនៅតាមសហគមន៍ ដែលបានកំណត់ពីយុទ្ធសាស្ត្រ និង ឧបករណ៍ដែលបានប្រើប្រាស់។ ការប៉ាន់ប្រមាណគ្រោះภัយនៅតាមសហគមន៍ បានប្រមូលដាក់រួមគ្នាទាំងទិន្នន័យបឋមនិងទិន្នន័យបន្ទាប់ ដែលពាក់ព័ន្ធទៅនឹងមុខសញ្ញាគ្រោះថ្នាក់ និង ការគំរាមកំហែងផ្សេងៗទៀត ទៅឱ្យ សហគមន៍។ ទោះបីជាចំណេះដឹងនៅតាមមូលដ្ឋានសំខាន់ក៏ដោយ ក៏ទិន្នន័យបែបវិទ្យាសាស្ត្រ នៅតែមានលក្ខណៈសំខាន់ជាងដែរ ដែលនៅក្នុងស្ថានภาពមួយនៅពេលសហគមន៍មិនទាន់បានជួបប្រទះនឹងមុខសញ្ញាគ្រោះថ្នាក់នោះ។ ឧបករណ៍វាយតំលៃ សภาពการณ์ និងរាយការណ៍បន្ទាន់ដោយមានការចូលរួម ត្រូវបានកែសំរួលសំរាប់ការប៉ាន់ប្រមាណគ្រោះภัยនៅតាម សហគមន៍។

IV. ជំហានៃការប៉ាន់ប្រមាណគ្រោះภัยដោយមានការចូលរួមនៅតាមសហគមន៍

ខាងក្រោមនេះ គឺជាការពិពណ៌នាទៅតាមជំហាននៃស្បៀវភៅសំរាប់អ្នកអនុវត្តនៅមូលដ្ឋាន ក្នុងការរៀបចំការងារប៉ាន់ប្រមាណគ្រោះภัยនៅតាមសហគមន៍:

១. ការជ្រើសរើសសហគមន៍

វាមានសារៈសំខាន់ណាស់ក្នុងការកំនត់ពីសហគមន៍ដែលយើងនឹងធ្វើការនៅក្នុង។

១.១ លក្ខខ័ណ្ឌនៅក្នុងការជ្រើសរើសសហគមន៍

ដើម្បីធ្វើការសំរេចចិត្តឱ្យបានត្រឹមត្រូវពីទីតាំងធ្វើការងារ ឬ សហគមន៍ណាមួយដែលត្រូវជ្រើសយកនោះ យើងត្រូវរៀបចំលក្ខខ័ណ្ឌមួយសំរាប់ដំណើរការជ្រើសរើសនេះ។ ខាងក្រោមនេះ ជាគន្លឹះមួយចំនួនដែលគួរអនុវត្ត:

- សภาពធ្ងន់ធ្ងរនៃការជួបប្រទះរបស់សហគមន៍ទៅនឹងគ្រោះภัย(សហគមន៍ដែលងាយរងគ្រោះបំផុត)
- ចំនួនមនុស្សដែលនឹងទទួលបានកម្មវិធីកាត់បន្ថយគ្រោះภัยនៃគ្រោះมหาธรรมជាតិ
- ត្រូវជ្រើសរើសសហគមន៍ណាដែលមិនមានអង្គការក្រៅរដ្ឋาภิบาล ឬភ្នាក់ងារដទៃៗច្រើន ដែលធ្វើការងារផ្តោតលើការកាត់បន្ថយគ្រោះภัยនៃគ្រោះมหาธรรมជាតិនៅក្នុងសហគមន៍នោះ
- ការកើតមានកាន់តែច្រើនឡើងនូវមុខសញ្ញាគ្រោះថ្នាក់នានា និងការបាត់បង់ជីវិត និងធនធានជាញឹកញាប់

១.២ លក្ខខ័ណ្ឌយេនឌ័រនៅក្នុងការជ្រើសរើសសហគមន៍

បទពិសោធន៍របស់បុរស និងស្ត្រីអាចមានภาพខុសគ្នា ទាំងនៅក្នុងជីវិតប្រចាំថ្ងៃ ពិសេសលើគ្រោះมหาธรรมជាតិ។ អត្រាមរណៈរបស់ស្ត្រីហាក់បីដូចជាមានកំរិតខ្ពស់នៅក្នុងហេតុการณ์គ្រោះมหาธรรมជាតិ។ ស្ត្រី និង ក្មេងស្រី មានការទំនុកបំរុង និងផ្តត់ផ្គង់តិចតួច

ហើយទទួលបានសេវាថែទាំសុខភាពនៅខ្សោយជាងបុរស និង ក្មេងប្រុស។ អង្គការ អ៊ុកស្វាមអាមេរិចកាំង បានអនុវត្តដោយយុត្តិធម៌ និងស្មើភាពរវាងស្ត្រី និងបុរស នៅក្នុងកម្មវិធីទាំងអស់របស់ខ្លួន។ នៅពេលអនុវត្តការងារ ប៉ាន់ប្រមាណគ្រោះภัយនៅតាមសហគមន៍ យើងចាំបាច់ត្រូវតែដឹងថា តើបញ្ហាយេនឌ័រ(Gender) ជះឥទ្ធិពលយ៉ាងណាខ្លះ ដល់ដំណើរការប្រមូល ការវិភាគ និងការប្រើប្រាស់ព័ត៌មាន ក្នុងការកំណត់ពីសកម្មภาพអាទិភាព និងសកម្មภาพទូទៅ?

នៅពេលយើងធ្វើការនៅឯកំរិតមូលដ្ឋាន យើងអាចនិយាយបានថា អ្នកដែលចូលរួមនៅក្នុងដំណើរការប៉ាន់ប្រមាណគ្រោះภัយនៅតាមសហគមន៍ គឺមិនអាចយល់ដឹងបានទាំងស្រុងទៅលើបញ្ហាយេនឌ័រនោះទេ ។ ដូចនេះហើយយើងនឹងមានការពិបាកណាស់ក្នុងការជំរុញឱ្យស្ត្រីចូលរួមបានយ៉ាងពេញលេញនៅក្នុងដំណើរការប៉ាន់ប្រមាណនេះ ឬ ពិបាកក្នុងការប្រមូលព័ត៌មានដែលឆ្លុះបញ្ចាំងពីបទពិសោធន៍ខុសគ្នារបស់ស្ត្រី និង បុរសទៅលើ បញ្ហាគ្រោះภัย ។

បញ្ហានេះត្រូវតែអនុវត្តបានខ្ជាប់ខ្ជួន ដោយត្រូវដឹងថា ដំណើរការអនុវត្តការងារប៉ាន់ប្រមាណគ្រោះภัยនេះ នឹងមិនគ្រប់គ្រាន់សំរាប់ផ្លាស់ប្តូរទំលាប់ដ៏យូរនៅក្នុងតំបន់ ។ ទោះជាយ៉ាងណាក៏ដោយ យើងត្រូវតែខិតខំប្រមូលព័ត៌មានទាំងឡាយណាដែលអាចឱ្យយើងយល់ដឹងពីកំរិតខុសគ្នានៃគ្រោះภัยដែលជួបប្រទះដោយស្ត្រី និង បុរស ហើយដើម្បីធានាថា សកម្មภาพ អាទិភាព និងសកម្មภาพตามដាន ត្រូវផ្អែកលើការយោគយល់គ្នាដោយយុត្តិធម៌រវាងបុរស និង ស្ត្រី និងកាត់បន្ថយគ្រោះภัย សំរាប់មនុស្សទាំងអស់គ្នា។ ដំណើរការប្រមូលព័ត៌មាន និងការប្រើប្រាស់ឧបករណ៍ក៏រួមមានការយល់ដឹងពីภาพខុសគ្នា រវាងបុរស និងនារី។ ជាឧទាហរណ៍ យើងចាំបាច់ ត្រូវតែរៀបចំពេលវេលាវគ្គសំរាប់ឧបករណ៍មួយចំនួន ដូចនេះហើយស្ត្រីអាចចូលរួមនៅពេលផ្សេងៗគ្នាពីបុរស។ លក្ខខ័ណ្ឌជ្រើសរើសសំរាប់ស្ត្រីនៅក្នុងការជ្រើសរើសសហគមន៍:

- ធានាអោយមានภาพស្មើគ្នារវាងស្ត្រី និងបុរស ក្នុងការទទួលបានផលប្រយោជន៍ពីគំរោង
- ចំនួនស្ត្រីយ៉ាងតិច៤0% បានចូលរួមយ៉ាងពេញលេញនៅក្នុងគំរោងកាត់បន្ថយគ្រោះมหาธาย
- ផ្តល់ឱកាសដល់ស្ត្រីឱ្យបានច្រើនក្នុងការចូលរួមក្នុងការសំរេចចិត្ត និង ការឈរឈ្មោះជាអ្នកដឹកនាំ ។

ក្រោយពីជ្រើសរើសសហគមន៍រួចមក បុគ្គលិកអនុវត្តនៅមូលដ្ឋាននឹងចំណាយពេលវេលាខ្លះនៅក្នុងការដើរកាត់ទទឹង ដើម្បីស្វែងយល់ដឹងពីសហគមន៍ និងការរៀបចំផែនទីសង្គមកិច្ច ។

២. ដំណើរកាត់ទទឹង

ដំណើរកាត់ទទឹង ជាដំណើរជាប្រព័ន្ធនៅតាមសហគមន៍ ដើម្បីស្វែងរកនូវภาพខុសគ្នាលើការប្រើប្រាស់ដី សកម្មภาพ សេដ្ឋកិច្ច ប្រព័ន្ធអេកូឡូស៊ី ជាដើម ហើយធ្វើការកត់ត្រា គូររូបภาพ និងសួរសំនួរដល់អ្នកផ្តល់ព័ត៌មានសំខាន់ៗ ដើម្បីបង្កើតជាដ្យាក្រាមកាត់ទទឹង ឬផែនទីកាត់ទទឹង ។

២.១ តើគំនូសកាត់ទទឹងជាអ្វី?

ដំណើរកាត់ទទឹង ត្រូវបានរៀបចំដោយการคูร "បន្ទាត់កាត់ទទឹងមួយ" នៅលើផែនទីសហគមន៍ ។ បន្ទាត់នេះរត់កាត់តាមតំបន់ទាំងអស់នៃសហគមន៍ ដើម្បីផ្តល់នូវการพิจารณาមើលជាតំណាងមួយ ។ ដែលដំណើរកាត់ទទឹងនេះ នឹងប្រើប្រាស់នៅក្នុងการพิจารณาមើលលើប្រភេទខុសៗគ្នានៃวัตถุธาตุนานาនៅក្នុងสหคมน์ ។ ខាងក្រោមនេះ គឺជាឧទាហរណ៍មួយចំនួននៃวัตถุธาตุขุสๆคๆ ដែលដំណើរกาต์ทุทืงนี้สามารถนำมาใช้ประโยชน์เพื่อพิจารณาเบื้องต้น:

- លក្ខខ័ណ្ឌសាងសង់ផ្ទះ
- ផ្ទះដែលរឹងមាំធន់នឹងទឹកជំនន់
- តំបន់ដែលសមស្របសំរាប់ធ្វើការជំលៀស
- ការប្រើប្រាស់ដី (តំបន់ដីកសិកម្ម តំបន់លំនៅឯកជន តំបន់រួម)
- ប្រភេទដី
- ចំណីអាហារលក់នៅឯទីផ្សារសេរី
- លក្ខខ័ណ្ឌអនាម័យ
- ពាណិជ្ជកម្ម និងស្រីពេស្យានៅតាមផ្លូវមិនស្របច្បាប់
- លទ្ធភាពនៃការដឹកជញ្ជូនសាធារណៈ
- វត្តមាននៃមន្ទីរពេទ្យ
- ប្រភេទគំរោងហេដ្ឋារចនាសម្ព័ន្ធ
- អង្គការក្រៅរដ្ឋាភិបាល និងអង្គការនានានៅក្នុងសហគមន៍
- ប្រភេទហាងតូចៗនៅក្នុងសហគមន៍ (កន្លែងលក់ថ្នាំពេទ្យ តូបលក់គ្រឿងទេស)
- ទំនាក់ទំនងរវាងបុរស និង នារី

upland	lowland	creek	lowland	canal	village	upland	creek	upland
water source								
rain	rain irriga-tion	rain runoff/ see-page	rain irrigation		rain well	rain	rain	rain
soil								
sandy loam		rocky	clay	rocky	sandy clay loam	sandy clay loam		clay
crops								
rice sugar-cane eggplant beans corn	rice sesba-nia pepper beans tomato	bam-boo	rice sesbania pepper beans tomato	bamboo	okra horse-raddish grapes beans	peanuts cassava rice corn beans	bam-boo	rice bean sugar-cane
forages								
grass-land for grazing	glirici-dia	grass	azolla	grass		weeds in plots	guines grass	grass-land

២.២ ការរៀបចំផែនទីសង្គមកិច្ច

វាមានសារៈសំខាន់ណាស់ក្នុងការរៀបចំផែនទីសង្គមកិច្ចក្នុងពេលធ្វើដំណើរកាត់ទទឹង។ ការរៀបចំផែនទីនេះនឹងជាឱកាសមួយក្នុងការមានទំនាក់ទំនងល្អជាមួយនឹងសហគមន៍។ យើងអាចសូមជួបជាមួយនឹងមនុស្សចាស់ៗដែលអាចជាមេភូមិ ហើយស្នើឱ្យមានកិច្ចប្រជុំរួមរវាងភូមិទាំងអស់ហើយនិងត្រូវបញ្ជាក់ឱ្យបានច្បាស់នូវការចូលរួមរបស់ស្ត្រីនៅក្នុងកិច្ចប្រជុំនោះ។
យើងត្រូវរៀបចំកាលបរិច្ឆេទ និងពេលវេលាសមរម្យមួយសំរាប់ប្រជាជនមូលដ្ឋាន។

នៅពេលប្រជុំ តួនាទីរបស់បុគ្គលិកអនុវត្តនៅមូលដ្ឋាន គឺគ្រាន់តែជួយប្រជាពលរដ្ឋក្នុងការចាប់ផ្តើមពិភាក្សា ហើយគូសផែនទីដែលមាន ដូចជា:

- តំបន់សរុបនៅក្នុងភូមិ
- ផ្ទះសំបែង (ត្រូវតែខុសៗគ្នាដោយប្រើក្បឿង និងរបស់ផ្សេងៗទៀត)
- វត្តអារាម ឬកន្លែងសាសនាផ្សេងៗ
- សាលារៀន
- ផ្សារ
- ដីកសិកម្ម (ខុសៗគ្នាដោយដំណាំស្រូវ និងដំណាំផ្សេងៗទៀត)
- ទន្លេ
- ស្រះទឹក
- ប្រភពទឹក
- ផ្លូវថ្នល់



សូមកុំបង្អាក់ការពិភាក្សារបស់សហគមន៍ ហើយត្រូវឱ្យពួកគេគូសផែនទីនោះ។ ពេលខ្លះប្រជាជននៅតាមសហគមន៍មានភាពរីករាយណាស់ក្នុងការគូសផែនទីនៅលើផ្ទាល់ដី ហើយពេលខ្លះពួកគេចូលចិត្តគូសផែនទីនៅលើក្រដាស។ ដូចនេះយើងត្រូវផ្តល់ជំរើសដល់ពួកគេ ដែលប្រសិនបើពួកគេគូសផែនទីនៅលើដីផ្ទាល់ យើងត្រូវចំលងផែនទីនោះដាក់នៅលើក្រដាស ហើយត្រូវបញ្ជាក់ឱ្យបានច្បាស់ជាមួយនឹងសហគមន៍ថា តើផែនទីទាំងពីរនេះដូចគ្នាដែរឬទេ? ហើយត្រូវរក្សាទុកផែនទីនោះ សំរាប់ប្រើប្រាស់នៅពេលក្រោយ។

៣. ការប្រមូលព័ត៌មាន និងការបញ្ជាក់ពីកាលបរិច្ឆេទបន្ទាប់

វាមានភាពចាំបាច់ខ្លាំងណាស់ ក្នុងការប្រមូលព័ត៌មានបឋមពីប្រភពបន្ទាប់ ។ សូមប្រមូលឱ្យបានមុនពេលនៃការរៀបចំដំណើរការកាត់ទទឹង និង ការរៀបចំផែនទីសង្គមកិច្ច ។

ព័ត៌មានបឋម សំដៅលើទិន្នន័យ ឬព័ត៌មានថ្មីៗដែលនៅក្នុងទំរង់ដើមរបស់វា ហើយនៅមិនទាន់ធ្វើការវិភាគបកស្រាយ ឬវាយតំលៃដោយអ្នកណាផ្សេងនៅឡើយ ។ ព័ត៌មានបន្ទាប់ ជាព័ត៌មានទាំងឡាយណាដែលបានធ្វើការបកស្រាយ ផ្តល់យោបល់វិភាគ និងវាយតំលៃទៅលើប្រភពដើម ។ នៅពេលខ្លះព័ត៌មានទាំងនេះមានឡើងបន្ទាប់ពីប្រភពដើម ដែលបានបង្ហាញទៅដល់អ្នកដទៃ ដើម្បីផ្តល់ជាយោបល់ ។

ព័ត៌មានបន្ទាប់ដែលសំខាន់ ត្រូវបានចែកជាពីរផ្នែក គឺព័ត៌មានវិទ្យាសាស្ត្រ និងព័ត៌មានសេដ្ឋកិច្ចសង្គម ។ ខាងក្រោមនេះជាឧទាហរណ៍នៃព័ត៌មានបន្ទាប់បែបវិទ្យាសាស្ត្រ ដែលយើងនឹងប្រមូល:

- ទិសដៅទឹកភ្លៀងរយៈពេលច្រើនរដូវ កាលពីឆ្នាំមុនៗ
- កំរិតទឹក/ទំហំទឹក/កំឡុងពេលទឹកជំនន់ចុងក្រោយ
- គ្រោះរាំងស្ងួត និងព័ត៌មានព្យាករណ៍
- ខ្យល់ព្យុះ/ការទាយទុកជាមុនពីទឹកជំនន់/ការលិចទឹកកាលពីមុនៗ
- ទឹកភ្លៀងធ្លាក់ជាបន្តបន្ទាប់ (ច្រើនជាង ៣ ថ្ងៃ) កាលពីអតីតកាលនារដូវកាលសំខាន់ និងការទាយទុកជាមុន

ព័ត៌មានសំខាន់ៗបែបវិទ្យាសាស្ត្រខាងលើនេះ គឺមាននៅក្នុងក្រសួងធនធានទឹកនិងឧតុនិយម ឬព័ត៌មានមួយចំនួនទៀតត្រូវប្រមូលពីប្រភពមូលដ្ឋាន ។

ព័ត៌មានសេដ្ឋកិច្ចសង្គម ដែលនឹងត្រូវប្រមូលនៅមុនពេលសកម្មភាពនៅមូលដ្ឋាន គឺបានសង្កត់ធ្ងន់ដូចខាងក្រោមដែលមានធនធាន:

ព័ត៌មាន	ប្រភពព័ត៌មាន
- ចំនួនប្រជាជន:	- ក្រសួងផែនការ ឬ ប្រមូលពីធនធាននៅក្នុងខេត្ត
- ការអប់រំ:	- ក្រសួងអប់រំ ឬ ប្រមូលពីធនធាននៅក្នុងខេត្ត
- ផែនការសុខភាព និងគ្រួសារ:	- ក្រសួងសុខាភិបាល ឬ ប្រមូលពីធនធាននៅក្នុងខេត្ត
- ផ្នែកទំនាក់ទំនង (ផ្លូវថ្នល់ ស្ពាន លូទឹក ទ្វាបង្ហូរទឹក)	- ក្រសួងសាធារណៈការ និងដឹកជញ្ជូន,ក្រសួងអភិវឌ្ឍន៍ជនបទ ឬ ឬ ប្រមូលពីធនធាននៅក្នុងតំបន
- សកម្មភាពសេដ្ឋកិច្ច (ជំរើសចិញ្ចឹមជីវិត)	- ការិយាល័យខេត្ត ស្រុក និង ការិយាល័យឃុំ អង្គការក្រៅរដ្ឋាភិបាល និងភ្នាក់ងារ អង្គការសហប្រជាជាតិ
- ស្ថាប័ន (អប់រំ សាសនា រដ្ឋាភិបាល អង្គការក្រៅរដ្ឋាភិបាល សមាគម វប្បធម៌)	- ការិយាល័យខេត្ត ស្រុក និងការិយាល័យឃុំ អង្គការក្រៅរដ្ឋាភិបាល និងភ្នាក់ងារ អង្គការសហប្រជាជាតិ
- ការប្រើប្រាស់ដី លំនៅដ្ឋាន ហេដ្ឋារចនាសម្ព័ន្ធ ព្រៃឈើ	- ខាងពាណិជ្ជកម្ម/អាជីវកម្ម, ក្រសួងគ្រប់គ្រងដែនដី

ដីតំបន់សើម ការចិញ្ចឹមត្រី កសិកម្ម ការដំណាំដាំដុះបានតែ ម្ពង ពីរដង និងបីដង ជាដើម	នគរូបនីយកម្ម និងសំណង់, ក្រសួង ផែនការ, ក្រសួង កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ, ក្រសួង អភិវឌ្ឍន៍ជនបទ, អង្គការក្រៅរដ្ឋាភិបាល អង្គការសហប្រជាជាតិ
- ប្រភេទដី	- ក្រសួងដែនដី នគរូបនីយកម្ម និងសំណង់, ក្រសួង ផែនការ, ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ, ក្រសួងអភិវឌ្ឍន៍ជនបទ, អង្គការក្រៅរដ្ឋាភិបាល ភ្នាក់ងារអង្គការសហប្រជាជាតិ ការិយាល័យខេត្ត ស្រុក និង ឃុំ
- ស្បៀងអាហារ ការដាំព្រៃឈើ និង កសិកម្ម	- ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ, ក្រសួងអភិវឌ្ឍន៍ជនបទ, អង្គការក្រៅរដ្ឋាភិបាល, ភ្នាក់ងារអង្គការសហប្រជាជាតិ មន្ទីរ ការិយាល័យ ខេត្ត ស្រុក និង ឃុំ
- ជីវចំរុះ, ទឹក និងអនាម័យ	- ក្រសួងបរិស្ថាន, ក្រសួងសុខាភិបាល ឬប្រមូលបានពី ធនធានក្នុងតំបន់
- ផែនទីសហគមន៍	- អង្គការក្រៅរដ្ឋាភិបាល, សាលាឃុំ ប្រធានភូមិ

ដំណើរការនៃព័ត៌មានខាងលើនេះរួចមក បុគ្គលិកអនុវត្តនៅមូលដ្ឋាននឹងចាប់ផ្តើមដំណើរការបញ្ជាក់លើព័ត៌មានទាំងនេះជាមួយនឹងប្រជាជនមូលដ្ឋាន និង គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយដែលទាក់ទង។ ដំណើរការបញ្ជាក់នេះ នឹងត្រូវធ្វើការគិត និងរៀបចំឱ្យបានយ៉ាងត្រឹមត្រូវ។ ដំណើរការនេះត្រូវធ្វើជាបញ្ជីមួយដែលរៀបចំ ដោយបុគ្គលិកអនុវត្តនៅមូលដ្ឋាន ដើម្បីទទួលបានទស្សនៈមតិយោបល់នានាលើព័ត៌មានបន្ទាប់។ យើងក៏អាចធ្វើការបញ្ជាក់នេះបាន នៅពេលធ្វើដំណើរកាត់ទទឹង និងពេលរៀបចំផែនទីសង្គមកិច្ច។

៣.១ វិធីសាស្ត្របញ្ជាក់ពីព័ត៌មានបន្ទាប់ដែលពាក់ព័ន្ធ

គោលបំណង: នៅចុងបញ្ចប់នៃសកម្មភាពនេះ សិក្ខាកាមទាំងអស់នឹងអាចធ្វើការបញ្ជាក់ពីព័ត៌មានបន្ទាប់ ដែលពាក់ព័ន្ធជាមួយនឹងសហគមន៍។

៣.២ វិធីសាស្ត្រ

- ទាក់ទងជាមួយនឹងសិក្ខាកាមដែលពាក់ព័ន្ធនៅក្នុងការរៀបចំផែនទីសង្គមកិច្ច
- ប្រមូលព័ត៌មានបន្ទាប់សំខាន់ៗ (វិទ្យាសាស្ត្រ និង សេដ្ឋកិច្ចសង្គម) ពីប្រជាជន ការិយាល័យ ឬស្ថាប័ននានា
- ធ្វើការវិភាគទៅលើព័ត៌មានដែលអាចមាន ដើម្បីបង្កើតនូវតារាងដែលងាយយល់ដែលខុសពីន័យបច្ចេកទេស

៣.៣ ចំណើរការ

- បុគ្គលិកអនុវត្តនៅមូលដ្ឋាននឹងពន្យល់ពីគោលបំណង និងការងារលំអិត ដើម្បីឱ្យសិក្ខាកាមអាចចូលរួមបានដោយសេរីនៅក្នុងវគ្គ

- បន្ទាប់មក បុគ្គលិកអនុវត្តនៅមូលដ្ឋាននឹងបង្ហាញពីផែនទី និងព័ត៌មានបន្ទាប់ ដែលប្រមូលបានពីប្រភពពាក់ព័ន្ធនានា ទៅដល់សិក្ខាកាម ដើម្បីឱ្យពួកគេយល់និងអាចបញ្ជាក់បានដ៏ត្រឹមត្រូវ
- បុគ្គលិកអនុវត្តនៅមូលដ្ឋាន នឹងចងក្រងជាឯកសារនូវការបំលាស់ប្តូរសំខាន់ៗនានានៅលើផែនទី ឬក្រាហ្វិកនៅចំពោះមុខ សិក្ខាកាម ឬក៏ឱ្យសិក្ខាកាមឡើងគូសបញ្ជាក់ពីការផ្លាស់ប្តូរទាំងនោះ
- បុគ្គលិកអនុវត្តនៅមូលដ្ឋាន នឹងប្រៀបធៀបពីផែនទីដែលគូរដោយសហគមន៍ ជាមួយនឹងផែនទីដែលបានគូរថ្មីៗ

មេរៀនទី ២: ការប៉ាន់ប្រមាណពីមុខសញ្ញាគ្រោះថ្នាក់

ដើម្បីសំរេចឱ្យបាននូវកម្មវិធីកាត់បន្ថយគ្រោះภัยនៃគ្រោះមហន្តរាយដោយជោគជ័យនោះ វាមានภาពចាំបាច់ខ្លាំងណាស់ដែលសហគមន៍ និងបុគ្គលិកអនុវត្តនៅមូលដ្ឋានត្រូវតែដឹងពីមុខសញ្ញាគ្រោះថ្នាក់ និងផលប៉ះពាល់របស់វា។

ដើមឈើប្រភពកំលាំងនៃមុខសញ្ញាគ្រោះថ្នាក់ ដោយការចូលរួមគ្នាជាមួយនឹងសិក្ខាកាម យើងត្រូវគូររូបដើមឈើ ដ៏ធំមួយដែលដើមរបស់វា គឺតំណាងឱ្យមុខសញ្ញាគ្រោះថ្នាក់ ហើយត្រូវលើកសំនួរសួរដល់សិក្ខាកាមពីមូលហេតុដែលបណ្តាលឱ្យមានមុខសញ្ញាគ្រោះថ្នាក់ ហើយត្រូវសរសេរនូវចំលើយដាក់នៅលើរឹសដើមឈើនោះ។ បន្ទាប់មកយើងត្រូវសួរសិក្ខាកាម ឱ្យកំណត់ពីឥទ្ធិពលជាអវិជ្ជមានពីមុខសញ្ញាគ្រោះថ្នាក់នោះមកលើសហគមន៍ ហើយត្រូវសរសេរចំលើយដាក់នៅលើផ្លែនៃដើមឈើមុខសញ្ញាគ្រោះថ្នាក់នោះ។ យើងត្រូវសំរបសំរួលការពិភាក្សាដោយការបង្ហាញពីទំនាក់ទំនងរវាងរឹសឈើ(មូលហេតុ នៃមុខសញ្ញាគ្រោះថ្នាក់, ដើម (មុខសញ្ញាគ្រោះថ្នាក់) និង ផ្លែ (ឥទ្ធិពលនៃមុខសញ្ញាគ្រោះថ្នាក់) ។



I. តើការប៉ាន់ប្រមាណពីមុខសញ្ញាគ្រោះថ្នាក់ គឺជាអ្វី?

ការប៉ាន់ប្រមាណពីមុខសញ្ញាគ្រោះថ្នាក់ ជាការសិក្សាពីប្រភព និងលក្ខណៈនៃមុខសញ្ញាគ្រោះថ្នាក់ ឬការគំរាមកំហែង នានាដែលត្រូវយកមកពិភាក្សាដូចខាងក្រោម:

- **ប្រភព:** កត្តាមួយ ឬច្រើន ដែលបង្កើតឱ្យមានមុខសញ្ញាគ្រោះថ្នាក់

- **សញ្ញាផ្តល់ព័ត៌មានជាមុន:** សញ្ញាបែបវិទ្យាសាស្ត្រ និង នៅក្នុងតំបន់ ដែលមុខសញ្ញាគ្រោះថ្នាក់ប្រហែលជានឹងកើតមានឡើង (ឧទាហរណ៍: ពពកខ្មៅ នៅមុនពេលមានភ្លៀង)
- **ការផ្តល់ព័ត៌មានជាមុន:** ជាពេលវេលាចន្លោះរវាងការផ្តល់ព័ត៌មាន និងផលប៉ះពាល់ (ឧទាហរណ៍ ២-៣ ថ្ងៃមុននៃការបាក់ដី ដោយសារមានខ្យល់ព្យុះសង្ឃរានឹងមកដល់ពីសមុទ្រចិន) ។
- **កំលាំង:** កត្តាដែលអាចឱ្យមានការខូចខាត គឺមានខ្យល់ (ខ្យល់ព្យុះសង្ឃរា), ទឹក (មានភ្លៀងធ្លាក់ច្រើន, ទឹកជន់ខ្ពស់, រលកធំ, ទឹកកខ្វក់ដែលបណ្តាលឱ្យមានជំងឺឆ្លង), ដី(រអិលបាក់, សឹកវិចរីល, ការហូរ ច្រោះដី), ការរញ្ជួយដី(ការញ័ររដី, បាក់ដី, ដីក្លាយជារាវ, ព្យុះរលកសមុទ្រ), ជំលោះ(សង្គ្រាម ភាពវកម្ម), ឧស្សាហកម្ម/បច្ចេកទេស(កង្វក់ ការធ្លាយវិទ្យុសកម្ម) ។
- **អត្រានៃការកើតមាន:** តើមុខសញ្ញាគ្រោះថ្នាក់តែងតែកើតឡើងតាមរដូវកាល, ជាប្រចាំឆ្នាំ, ក្នុងរយៈពេល ១០ឆ្នាំម្តង, ឬកើតមានម្តងក្នុងមួយជីវិត?
- **តាមរដូវកាល:** តើមុខសញ្ញាគ្រោះថ្នាក់តែងតែកើតឡើងនៅពេលណាមួយនៅក្នុងឆ្នាំ ឬ(រដូវត្រជាក់ ឬរដូវ ក្តៅ នៅក្នុងខែវិច្ឆិកា ដល់ ខែមេសា)?
- **អំឡុងពេល:** តើមុខសញ្ញាគ្រោះថ្នាក់កើតឡើងមានរយៈពេលយូរប៉ុនណា (រញ្ជួយដី និងក្រោយពេល រញ្ជួយ គឺថ្ងៃ/សប្តាហ៍/ខែ ដែលតំបន់នោះលិចទឹក និងរយៈពេលដែលកងកំលាំងទាហាន ចុះអន្តរាគមន៍)?

សូមយកផែនទីសង្គមកិច្ច ដែលបានរៀបចំកាលពីមុន មកគូសដាក់បញ្ចូលនូវផែនទីមុខសញ្ញាគ្រោះថ្នាក់ ។

II. ការគូសផែនទីមុខសញ្ញាគ្រោះថ្នាក់

១. គោលបំណង

ផែនទីមុខសញ្ញាគ្រោះថ្នាក់ ត្រូវបានរៀបចំដើម្បីចង្អុលបង្ហាញពីតំបន់នានានៅក្នុងសហគមន៍ដែលបានគំរាមកំហែង និងប្រឈមខ្លាំងទៅនឹងសញ្ញាគ្រោះថ្នាក់ ។

២. វិធីសាស្ត្រ

- ការងារជាក្រុម
- សំនួរ និងចំលើយ

៣. ជំហានសៅក្នុងការគូសផែនទីមុខសញ្ញាគ្រោះថ្នាក់

បុគ្គលិកអនុវត្តនៅមូលដ្ឋាននឹងពន្យល់ពីជំហាននៅក្នុងការគូសផែនទីភូមិ:

- យើងត្រូវសំរេចជ្រើសរើសពីប្រភេទផែនទីដែលត្រូវគូរ?
- ស្វែងរកបុរសនិងស្ត្រីណាដែលដឹងពីតំបន់នោះ ហើយមានឆន្ទៈចែករំលែកបទពិសោធន៍របស់ពួកគេ (ហើយក៏ត្រូវសួរដល់ក្មេងៗឱ្យគូសផែនទីភូមិរបស់ពួកគេ ដែលវានឹងបង្ហាញពីការយល់ដឹងរបស់ពួកគេ និងពីកន្លែងដែលពួកគេចូលចិត្តជាងគេនៅក្នុងភូមិ)
- ជួយប្រជាជនឱ្យចាប់ផ្តើមគូសផែនទី ប៉ុន្តែត្រូវឱ្យពួកគេគូរដោយខ្លួនពួកគេផ្ទាល់

៤. កិច្ចការក្រុម

- បែងចែកក្រុមទៅតាមភូមិរបស់ពួកគេ ហើយសួរពួកគេឱ្យគូសផែនទីដើម ដែលពួកគេបានរៀបចំ ជាផែនទីសង្គមកិច្ច កាលពីពេលមុន ។
- ចំពោះផែនទីដើម យើងត្រូវដាក់ថង់ប្លាស្ទិច ហើយប្រើប្រាស់ប៊ិចពណ៌ ក្នុងការកំណត់ពីតំបន់ដាក់លាក់ណាមួយ, រូបផ្ទះ និងមធ្យោបាយនានា ដែលងាយរងគ្រោះនឹងមុខសញ្ញាគ្រោះថ្នាក់ណាមួយ។ ឧទាហរណ៍: ទឹកជំនន់ (រួមមានការណែនាំឱ្យស្គាល់ពីទឹកជំនន់ និង ជំរៅទឹក) ។

នៅពេលធ្វើការប៉ាន់ប្រមាណពីមុខសញ្ញាគ្រោះថ្នាក់នៅតាមកំរិតមូលដ្ឋាន វាមានសារៈសំខាន់ណាស់ក្នុងការយល់ដឹងពីអ្វីដែលថាការវិភាគនេះ ជាមូលដ្ឋានសំរាប់ជំហានបន្ទាប់ក្នុងការប៉ាន់ប្រមាណពីគ្រោះภัย គឺការប៉ាន់ប្រមាណពីភាពងាយរងគ្រោះថ្នាក់ និងសមត្ថភាព។ *យើងចង់ធ្វើការកំណត់ពីគ្រោះภัยនៅចំពោះមុខនៃមុខសញ្ញាគ្រោះថ្នាក់ណាមួយ*។ ដូចនេះយើងត្រូវតែមានសមត្ថភាពក្នុងការកំណត់ពីមុខសញ្ញាគ្រោះថ្នាក់ដែលបង្កឱ្យមានការខូចខាតធ្ងន់ធ្ងរ ហើយត្រូវចាត់អាទិភាពលើមុខសញ្ញាគ្រោះថ្នាក់ដោយអាស្រ័យលើគ្រោះภัยធំៗរបស់វា។ តារាងបញ្ជីសំខាន់នៃមុខសញ្ញាគ្រោះថ្នាក់ ដែលមិនបានធ្វើចំណាត់ថ្នាក់នឹងមិនជួយយើងធ្វើការប៉ាន់ប្រមាណបានយ៉ាងគ្រប់គ្រាន់ទៅលើគ្រោះภัยនោះបានឡើយ។ យើងមានជំហានពីរដែលត្រូវប្រើប្រាស់នៅពេលប៉ាន់ប្រមាណពីមុខសញ្ញាគ្រោះថ្នាក់ នោះគឺ:

ជំហាន	តើអ្វីដែលយើងត្រូវកំនត់?	នីតិវិធី
១-កំនត់ពីមុខសញ្ញាគ្រោះថ្នាក់សំខាន់ៗទៅដល់សហគមន៍	មុខសញ្ញាគ្រោះថ្នាក់នីមួយៗ ដែលយើងត្រូវតែកំនត់: - កំលាំង (ការខូតខាត,ទំហំ) - សញ្ញាផ្តល់ព័ត៌មានជាមុន - ការផ្តល់ព័ត៌មានជាមុន - ល្បឿននៃការចាប់ផ្តើម ដំបូង - អត្រានៃការកើតមាន - រយៈពេលនៃការកើតមាន - អំឡុងពេល	ចូរអោយសហគមន៍ចុះបញ្ជីនូវមុខសញ្ញាគ្រោះថ្នាក់ ទាំងអស់នោះ ដែលពួកគេដឹង ហើយយើងក៏អាចប្រាប់ពីមុខសញ្ញាគ្រោះថ្នាក់ដទៃទៀតដែលពួកគេភ្លេចដោយសារតែវាកន្លងហួសរយៈពេលយូរ រវាងការកើតនាពេលបច្ចុប្បន្ន និងការកើតមានចុងក្រោយនៃមុខសញ្ញាគ្រោះថ្នាក់នោះ។ យើងត្រូវឱ្យសហគមន៍ ពិភាក្សាលើមុខ សញ្ញាគ្រោះថ្នាក់នីមួយៗ ដោយអាស្រ័យលើសមាសភាគដែលពួក គេត្រូវកំណត់ (កំលាំង,កំឡុងពេល ជាដើម)។ យើងត្រូវធានាឱ្យ ឱ្យមានព័ត៌មានគ្រប់គ្រាន់ ដើម្បីបំពេញនៅក្នុង "ទំរង់មុខសញ្ញា គ្រោះថ្នាក់" ។
២-ផ្តល់អាទិភាពទៅលើមុខសញ្ញាគ្រោះថ្នាក់	ផ្តល់អាទិភាពដោយផ្អែកលើ: ; - ការខូចខាតជាប់គ្នាដែលកំពុងកើតមាន - ឱកាសនៃការកើតមាន (លទ្ធភាព)	ផ្អែកលើព័ត៌មានដែលទទួលបានពីជំហានទី ១ ចូរប្រឹងប្រែង សំរេចនូវការឯកភាពគ្នាមួយជាមួយនឹងសហគមន៍ទៅលើមុខសញ្ញា គ្រោះថ្នាក់ទាំងនោះ ដែលនឹងសំខាន់សំរាប់យកមកគិតពិចារណា។ ចូរជួយខ្លួនអ្នកនៅលើតារាងម៉ាទ្រិច នៃការខូចខាត/លទ្ធភាព ក្នុង ការជ្រើសរើសមុខសញ្ញាគ្រោះថ្នាក់ណាមួយដើម្បីចាត់អាទិភាព។



គោលបំណងនៃឧបករណ៍ប៉ាន់ប្រមាណ នេះនឹងជួយសមាជិកសហគមន៍កំណត់ពីមុខសញ្ញាគ្រោះថ្នាក់រួមនៅក្នុងសហគមន៍ ។ សិក្ខាកាមក៏អាចប្រើប្រាស់ផែនទីកំណត់ពីតំបន់ដែលមានមុខសញ្ញាគ្រោះថ្នាក់ផងដែរ ។ ចំពោះការអនុវត្តន៍ គឺវាមានសារៈសំខាន់ណាស់ ដែលត្រូវតែគិតពិចារណា គឺ:

- ការប៉ាន់ប្រមាណពីមុខសញ្ញាគ្រោះថ្នាក់ មិនមែនដូចគ្នានឹងការប៉ាន់ប្រមាណលើបញ្ហានោះទេ ។ វាមានភាពចាំបាច់ណាស់ ដើម្បីឱ្យសហគមន៍យល់ដឹងពីអ្វីជាមុខសញ្ញាគ្រោះថ្នាក់នោះ ។ យើងត្រូវរកពាក្យណាដែលមានន័យដូចគ្នា ចំពោះពាក្យ មុខសញ្ញាគ្រោះថ្នាក់នៅក្នុងភាសាមូលដ្ឋាន ឬភាសានៅក្នុងសហគមន៍ទាំងមូល ។
- ត្រូវឱ្យប្រជាជនសហគមន៍ជ្រើសរើសប្រភេទមុខសញ្ញាគ្រោះថ្នាក់ចំនួន៥ ដែលសំខាន់បំផុត ដែលពួកគេបានជួបប្រទះកន្លងមក ហើយកំណត់ពីសំភារៈដែលអាចមាននៅមូលដ្ឋាន ដើម្បីជាតំណាងឱ្យមុខសញ្ញាគ្រោះថ្នាក់ ដែលយើងបានជ្រើសរើសនោះ ។
- បន្ទាប់មកយើងត្រូវដាក់និមិត្តសញ្ញា នៃមុខសញ្ញាគ្រោះថ្នាក់នៅក្នុងតំបន់នៅលើផែនទីសហគមន៍ ដែលមានមុខសញ្ញាគ្រោះថ្នាក់ ។

III. **កំនត់ចំណាំលើបញ្ហាយែនឌ័រ**

ដោយសារតែមានតំបន់ខ្លះមានការចូលរួមរបស់ស្ត្រី និង យុវជន នៅមានកំរិតដោយកត្តាវប្បធម៌ ទើបការងារគូសផែនទីត្រូវបានរៀបចំចែកជាបីក្រុមផ្សេងៗគ្នា ។ បន្ទាប់មកគេបានប្រៀបធៀបផែនទីទាំងបីនោះដើម្បីរកឱ្យឃើញនូវផែនទីដ៏ល្អមួយដែលពួកគេគិតថាសមស្របសំរាប់ប្រើប្រាស់របស់គេ ។

IV. ទំរង់មុខសញ្ញាគ្រោះថ្នាក់

ប្រើប្រាស់ទំរង់មុខសញ្ញាគ្រោះថ្នាក់នេះ ដើម្បីទទួលបាន និងបញ្ជាក់ពីព័ត៌មានដែលត្រូវការសំរាប់មុខសញ្ញា គ្រោះថ្នាក់នោះ ។

មុខសញ្ញាគ្រោះថ្នាក់	ឈ្មោះមុខសញ្ញាគ្រោះថ្នាក់ (រៀបរាប់ដោយសង្ខេបបើចាំបាច់)
ប្រវត្តិ	លក្ខណៈប្រវត្តិសាស្ត្រនៃមុខសញ្ញាគ្រោះថ្នាក់នៅក្នុងសហគមន៍
អត្រានៃការកើតមាន	តើមុខសញ្ញាគ្រោះថ្នាក់តែងតែកើតមានឡើងទៅតាមរដូវកាល, មួយឆ្នាំម្តង ឬ រៀងរាល់ ៥ ឆ្នាំម្តង?
ល្បឿននៃការចាប់ផ្តើមដំបូង	ភាពល្បឿនរហ័សនៃការមកដល់នៃផលប៉ះពាល់ គឺយើងអាចសំគាល់បានយ៉ាងច្បាស់រវាង មុខសញ្ញាគ្រោះថ្នាក់កើតឡើងស្ទើរតែមិនមានសញ្ញាផ្តល់ដំណឹងជាមុន (រញ្ជួយដី) និង មុខសញ្ញាគ្រោះថ្នាក់ដែលអាច ទាយទុកបានពី ២ ទៅ ៣ ថ្ងៃមុន (ខ្យល់ព្យុះសង្ឃរា) ទៅនឹងមុខសញ្ញាគ្រោះថ្នាក់ដែលមានល្បឿនយឺត ដូចជាគ្រោះរាំងស្ងួត និងទុរភិក្ស ។
ទីតាំង	តើទំហំដីប៉ុន្មានដែលទទួលរងផលប៉ះពាល់ដោយមុខសញ្ញាគ្រោះថ្នាក់? តើមានតំបន់ជាក់លាក់ណាមួយ ដែលមានមុខសញ្ញាគ្រោះថ្នាក់នេះកើតឡើងដែរ ឬទេ?
រយៈពេល	តើមុខសញ្ញាគ្រោះថ្នាក់កើតឡើងរយៈពេលប៉ុន្មាន (រញ្ជួយដី និងក្រោយពេលរញ្ជួយ និងថ្ងៃ/សប្តាហ៍/ខែ ដែលតំបន់នោះលិចទឹក និងរយៈពេលដែលកងកំលាំងទាហាន ចុះធ្វើកិច្ចប្រតិបត្តិការ)?
ការខូចខាត	តាមប្រវត្តិសាស្ត្រ តើអ្វីជាការខូចខាតធ្ងន់ធ្ងរដែលមុខសញ្ញាគ្រោះថ្នាក់អាចបង្ករអោយមាន (ដោយមិនចាំបាច់កំនត់ពីដំណាក់កាល ដែលជាមូលហេតុគ្រោះภัยកើតឡើង)។ ក្រៅពីភាពងាយរងគ្រោះថ្នាក់ ដែលត្រូវវិភាគនៅពេលក្រោយ យើងនៅមានកត្តាជាច្រើន ដែលធ្វើឱ្យមុខសញ្ញាគ្រោះថ្នាក់ខូតខាតកាន់តែច្រើនជាងមុនដែលមាន ដូចជា: - តើសញ្ញាផ្តល់ដំណឹងជាមុនមានភាពច្បាស់លាស់ដែរ ឬទេ? - ការផ្តល់ដំណឹងជាមុននៃមុខសញ្ញាគ្រោះថ្នាក់: ពេលវេលាចន្លោះរវាងការផ្តល់ដំណឹងជាមុន និង ឥទ្ធិពល - កត្តាដទៃៗទៀតដូចដែលបានបង្ហាញ ដូចជាអំឡុងពេល និង ល្បឿននៃការ ចាប់ផ្តើមដំបូង

លើសពីនេះទៀត ក្នុងករណីដែលមុខសញ្ញាគ្រោះថ្នាក់មានភាពកាន់តែខ្លាំងឡើង ដោយសារតែការប្រែប្រួលអាកាសធាតុ នោះទើបវាមានសារៈសំខាន់ខ្លាំងណាស់ក្នុងការវាយតំលៃលើការប៉ាន់ប្រមាណពីទស្សនៈនាពេលបច្ចុប្បន្ន (របាយការណ៍របស់អន្តរភ្នាក់ងារលើការប្រែប្រួលអាកាសធាតុ IPCC) និងសំភារៈវិទ្យាសាស្ត្រនាពេលថ្មីៗ ពិសេសលទ្ធភាពនានាសំរាប់តំបន់ជាក់លាក់ណាមួយ ដែលស្ថិតនៅក្រោមការពិនិត្យមើលលើមុខសញ្ញាគ្រោះថ្នាក់ណាមួយ។ ការវាយតំលៃពីសក្តានុពលនៃមុខសញ្ញាគ្រោះថ្នាក់ដែលទាក់ទងនឹងការប្រែប្រួលអាកាសធាតុ គឺតម្រូវឱ្យមានវិធីជាច្រើនដែលផ្តោតភាគច្រើនលើការប្រែប្រួលនានានៅក្នុងកំរិតមិនច្បាស់លាស់នៃលក្ខខ័ណ្ឌអនាគត និង ផ្តោតលើលទ្ធផលនៃការរៀបចំណាមួយពេលអនាគត។ យើងនៅមានភាពមិនច្បាស់លាស់ជាច្រើននៅក្នុងការព្យាករណ៍លើការប្រែប្រួលអាកាសធាតុ គឺដោយសារតែការកើនឡើងនៃការប្រែប្រួលងាកចេញពីលក្ខខ័ណ្ឌនៃវិទ្យាសាស្ត្រអាកាសធាតុកាលពីអតីតកាលដ៏យូរអង្វែង។ ប្រព័ន្ធទាំងនេះបានកំពុងតែក្លាយទៅជាលក្ខខ័ណ្ឌអាកាសធាតុថ្មីមួយដែល

យើងពិតជាមិនអាចដឹងបាន។ ការយល់ដឹងពីទំនាក់ទំនងគ្នានៃភាពមិនច្បាស់លាស់នៅក្នុងការវាយតំលៃមុខសញ្ញាគ្រោះថ្នាក់ គឺមានសារៈសំខាន់ណាស់ក្នុងការកាត់បន្ថយภาពមិនច្បាស់លាស់ ទាំងនេះអោយបានកាន់តែច្រើន។

V. តារាងម៉ាទ្រិច ស្តីពីការខូចខាត និង វិសាលภาព

តាមរយៈការពិភាក្សាកន្លងមក យើងបានឯកภาពគ្នានៅក្នុងក្រុមក្នុងការចាត់ថ្នាក់នូវមុខសញ្ញាគ្រោះថ្នាក់នីមួយៗ ទៅក្នុងប្រអប់នីមួយៗទាំង ៩ ដោយផ្អែកលើអ័ក្សទាំងពីរនោះ។ ជំហានបន្ទាប់ នឹងត្រូវចាប់ផ្តើមធ្វើការប៉ាន់ប្រមាណពីภาពងាយរងគ្រោះថ្នាក់ និងសមត្ថภาព ចំពោះមុខសញ្ញាគ្រោះថ្នាក់ដែលបានចាត់ថ្នាក់ជាមួយនឹងលេខចំនួនធំនៅក្នុងតារាងម៉ាទ្រិច។

ភាពងាយរង

	សក្តានុពលនៃការខូចខាត		
	ក៏រិតខ្ពស់	ក៏រិតមធ្យម	ក៏រិតទាប
ក៏រិតខ្ពស់	៩	៦	៣
ក៏រិតមធ្យម	៦	៤	២
ក៏រិតទាប	៣	២	១

មេរៀនទី ៣: ការប៉ាន់ប្រមាណភាពងាយរងគ្រោះ និងសមត្ថភាព

- **គោលបំណង:** នៅចុងបញ្ចប់សកម្មភាពនេះ សិក្ខាកាមនឹងអាច:
  - កំនត់បានពីភាពងាយរងគ្រោះរបស់សហគមន៍
  - កំនត់បានពីសមាភាគគ្រោះថ្នាក់ ដែលនឹងអាចបំផ្ទិចបំផ្លាញដោយមុខសញ្ញាគ្រោះថ្នាក់ (នរណា, ជាអ្វី, នៅកន្លែងណា, មានចំនួនប៉ុន្មាន, ហើយមានតំលៃប៉ុន្មាន)
  - វិភាគលើកត្តា និងលក្ខខ័ណ្ឌនានា ដែលជាមូលហេតុសមាសភាគគ្រោះថ្នាក់ អាចនឹងត្រូវបំផ្ទិចបំផ្លាញដោយមុខសញ្ញាគ្រោះថ្នាក់ផ្សេងៗ
- **វិធីសាស្ត្រ**
  - ការងារជាក្រុម
  - សំនួរ និង ចំលើយ
- **ដំណើរការ**
  - ពិភាក្សាទៅលើគោលបំណងនៃសកម្មភាព
  - លើកជាសំណួរសួរបញ្ជាក់នូវបញ្ហាទាក់ទងនឹងគោលបំណងសកម្មភាពដល់សិក្ខាកាម និងពន្យល់បន្ថែម ប្រសិនបើចាំបាច់
  - សួរដល់សិក្ខាកាមនូវអ្វីដែលពួកគេបានយល់ ស្តីពីភាពងាយរងគ្រោះថ្នាក់ភាព
  - ប្រមូលយកនូវចំលើយទាំងអស់ ហើយត្រូវសរសេរដាក់លើក្រដាស ឬក្តារខៀន
  - ត្រូវពិភាក្សាលើនិយមនៃភាពងាយរងគ្រោះថ្នាក់
  - ត្រូវចោទសួរដល់សិក្ខាកាម ដើម្បីកំណត់ពីនិយមន័យនៃភាពងាយរងគ្រោះថ្នាក់
  - ប្រមូលយកនូវចំលើយមួយចំនួន ហើយពិភាក្សាខ្លីៗលើនិយមន័យនៃភាពងាយរងគ្រោះថ្នាក់
  - ហើយក៏ត្រូវពិនិត្យផងដែរនូវភាពខុសគ្នារវាងភាពងាយរងគ្រោះថ្នាក់ និង គ្រោះภัយ

I. ការប៉ាន់ប្រមាណពីភាពងាយរងគ្រោះ

ភាពងាយរងគ្រោះថ្នាក់ គឺជាទំរង់មួយដ៏សាំញ៉ាំនៃកត្តា និងលក្ខខ័ណ្ឌជាច្រើនដែលជះឥទ្ធិពលដល់សមត្ថភាពរបស់ សហគមន៍ ក្នុងការការពារ កាត់បន្ថយ និងត្រៀមបង្ការ ឬ ឆ្លើយតបទៅនឹងហេតុការណ៍មុខសញ្ញាគ្រោះថ្នាក់ ហើយទាំងនេះក៏ជាចំណុចខ្សោយជាច្រើនផងដែរ ដែលមាននៅក្នុងសហគមន៍ គ្រួសារ និង បុគ្គល ។

ការប៉ាន់ប្រមាណពីភាពងាយរងគ្រោះ គឺជាដំណើរការដោយមានការចូលរួម ដើម្បីកំណត់នូវអ្វីដែលសមាសភាគ គ្រោះថ្នាក់ជួបនឹងប្រភេទមុខសញ្ញាគ្រោះថ្នាក់ណាមួយ និង ដើម្បីវិភាគពីមូលហេតុដែលបណ្តាលឱ្យសមាសភាគទាំងនេះមានគ្រោះថ្នាក់ ។

១. សមាសភាគគ្រោះថ្នាក់

- ត្រូវចោទសួរដល់សិក្ខាកាមថាតើនរណា ហើយជាអ្វី កើតនៅកន្លែងណា វាមានចំនួនប៉ុន្មាន ហើយមានទំហំប៉ុន្មាន ដែលតែងតែបានបំផ្ទិចបំផ្លាញនៅពេលមានគ្រោះภัย ។
- ត្រូវសរសេរចំលើយនោះ ដាក់នៅលើក្រដាសធ្លាំងធំ ។
- ត្រូវធ្វើមតិសំយោគលើចំលើយនោះ ហើយពិភាក្សាលើ "សមាសภาคគ្រោះថ្នាក់" នោះ ។

២. តើសមាសភាគគ្រោះថ្នាក់ ជាអ្វី?

សមាសภาคគ្រោះថ្នាក់រួមមាន: មនុស្ស គ្រួសារ ផ្ទះសំបែង ទ្រព្យសម្បត្តិ ផលដំណាំ ជីវภาពរស់នៅ ផលប្រយោជន៍សហគមន៍ និង រដ្ឋาภิบาล ហេដ្ឋารจนาสម្ព័ន្ធ និង បរិស្ថាន ដែលវាអាចត្រូវបានបំផ្ទិចបំផ្លាញដោយ មុខសញ្ញាគ្រោះថ្នាក់នោះ ។

៣. ប្រភេទនៃภาពงายรงคฺรោះ

យើងត្រូវដឹងថា ภาพงายรงคฺรោះថ្នាក់មានច្រើនប្រភេទណាស់ គឺ:

ภาพงายรงคฺรោះ		
រូបវន្ត/សំភារ:	**ផ្នែកสงฺคม/ตามสฺถาบัน**	**ផ្នែกอากปฺปกิริยา/ហេតុផលជំរុញ**
- **กฺตาบริสฺถาน: ទំហំព្រៃឈើ ទន្ទេ ប្រភេទដី** - **สณฺฐานดี: ภูํ ព្រំដែន** - **อากาสธาตุ: ការធ្លាក់ភ្លៀងរដូវกาล** - **មុខសញ្ញาคฺรោះថ្នាក់: ការកើតឡើងញឹកញាប់ ប្រវត្តិ និង ឥទ្ធិពล** - **กํรงต์ติมานประชาสฺตฺร: ចំនួนประชาชน กำลังแลกหฺม ការធ្វើ อนฺตฺราประเวสน์ สาสนา ជំងឺ និงการสฺถาบ่** - **เสวาสงฺคม: สุขภาพ ការอบรำ อนามัย** - **ដំណាំ อุปกรณ์กสิกหฺม บจฺเจก วิทฺยาผลิตกหฺม โรคพิส និงชีวิต นานา និงชีวิตผลิตกหฺม**	- รจนาสม្ព័ន្ធគ្រួសาร: ขฺยาย ឬขฺลาํง - รจนาสม្ព័ន្ធ និงคุณสมฺบัติនៃการ ដึกนำ - รจนาสม្ព័ន្ធនៃการធ្វើการสํเรจจิต - กิริตនៃการจูลรูม - การบែงចែก និงชีเลาะ (ชาติสาสน์, สาสนา, มโนคมวิชฺชา, กฺรุมนยาบาย, ภาสา) - สมภาพกฺนุงการจูลรูมกฺนุง ชีเณีรการนยาบาย - องฺคการสหคมน์ตามผฺลูวการ និงมินผฺลูวการ ขางทํเงฺม ทํลาบ่ និงองฺคการกฺรา รฐาภิบาล - ทํนาก่ทํนงชาមูยนีง รฐาภิบาล និงรจนา สม្ព័ន្ធรฐบาล	- กริยาบถอวิชฺชมานจำเพาะการผฺลาสฺบูร - คำนิตจงฺบำผฺลาญพิภพโลก, บริสฺถาน និง คำนิตจงฺบาน - ขฺวะคาลคำนิตจาบ่ผฺเฎีม - ชีเณีรี, การปฺเตชฺชาจิต, อารมฺณ์ มูเม๊า - ชีเณีรีอรูป - ชีเณีรี, ภาพอสฺสงฺขีม, การบาก่ทีกจิต - ขฺวะภาพชฺเรีชาก่ลีขฺนงงง (จำณุะเค) - ขฺวะการรูบรูม និงสบาประติบตฺติการ ฉฺากฺนุงสหคมน์ - ทสฺสนะจำเพาะอตีตกาล บจฺจุปฺปนฺนกาล និง อนาคตกาล

៣.១ ការគូរផែនទីភាពងាយរងគ្រោះ (ការគូរផែនទីភាពងាយរងគ្រោះថ្នាក់ អាចរៀបចំបាន លុះត្រាតែផែនទីមុខសញ្ញាគ្រោះថ្នាក់ ត្រូវបានរៀបចំរួច)

- **គោលបំណង**
  - កំណត់ពីភាពងាយរងគ្រោះថ្នាក់របស់សហគមន៍ និង កំណត់ពីសមាសភាគគ្រោះថ្នាក់ទាំងអស់នៅក្នុងសហគមន៍ ដោយប្រើប្រាស់ផែនទីមុខសញ្ញាគ្រោះថ្នាក់តែមួយ ដែលយើងទើបគូសរួច ។

- **វិធីសាស្ត្រ**
  - ការធ្វើការងារជាក្រុម
  - សំនួរ និង ចំលើយ

- **ដំណើរការ**
  - ប្រើប្រាស់ផែនទីមុខសញ្ញាគ្រោះថ្នាក់ខាងលើ
  - ចោទសួរដល់សិក្ខាកាម តើកន្លែង/តំបន់ណាខ្លះដែលមានគ្រោះថ្នាក់នៅក្នុងសហគមន៍ (វាលស្រែ, កន្លែងដាំដំណាំ, កន្លែង ធ្វើការកសិកម្ម) ?
  - ចោទសួរដល់សិក្ខាកាម តើអ្វីខ្លះជាហេដ្ឋារចនាសម្ព័ន្ធ ឬមធ្យោបាយសំរួលនានា ដែលមានគ្រោះថ្នាក់នៅក្នុងសហគមន៍ (សាលារៀន, វត្តអារាម, មណ្ឌលសហគមន៍, មន្ទីរពេទ្យ, ស្ពាន, ផ្លូវថ្នល់, បង្គន់អនាម័យ, ផ្ទះសំបែងជាដើម?
  - តើមានធនធានអ្វីខ្លះដែលអាចជួបនឹងគ្រោះថ្នាក់ (សត្វពាហនៈ, ត្រី, វិប្បធម៌, មនុស្សចាស់, ស្ត្រី, កុមារ, ជនពិការជាដើម)?
  - យើងត្រូវអោយសិក្ខាកាមដាក់ព័ត៌មាននៅខាងលើទៅក្នុងផែនទីមុខសញ្ញាគ្រោះថ្នាក់
  - យើងត្រូវឱ្យសិក្ខាកាមបង្ហាញពីសមាសភាគគ្រោះថ្នាក់ទាំងអស់ ដែលត្រូវដាក់នៅលើផែនទីភាពភាយរងគ្រោះ ?

៤. ជំហានក្នុងការកំណត់ពីភាពងាយរងគ្រោះដែលពាក់ព័ន្ធនឹងទំរង់សំពាធ និងបញ្ជ្រៀស (PAR model)

ជំហានទាំង ៤ ខាងក្រោម យើងត្រូវតែអនុវត្តនៅពេលធ្វើការកំណត់ពីភាពងាយរងគ្រោះពាក់ព័ន្ធ ទៅនឹងទំរង់ សំពាធ និងបញ្ជ្រៀស (PAR model) ៖

បរិបទនៃភាពងាយរងគ្រោះ.....



ខាងក្រោមនេះ គឺជាឧទាហរណ៍នៃប្រភេទសំណួរជាច្រើន ដែលអ្នកនឹងសួរ ឬជាប្រធានបទដែលត្រូវយកមកធ្វើការបកស្រាយក្នុងដំណាក់កាលនីមួយៗនៃដំណាក់កាលទាំងបួននេះ។ *នេះមិនមែនជាតារាងបញ្ជីដ៏ពេញលេញមួយនោះទេ តែត្រូវបានចាត់ទុកជាការណែនាំជួយដាស់ស្មារតីរបស់អ្នកតែប៉ុណ្ណោះ ។*

៤.១ ដំណាក់កាលទី ១: សមាសភាគគ្រោះថ្នាក់

យើងត្រូវចោទជាសំណួរថា តើសកម្មភាពសេដ្ឋកិច្ច ឬធនធានណាខ្លះ ដែលទទួលរងផលប៉ះពាល់ខ្លាំងបំផុតពីមុខសញ្ញាគ្រោះថ្នាក់? ហើយថាតើប្រជាជនត្រូវលក់ទ្រព្យសម្បត្តិ ឬដែលទ្រព្យសម្បត្តិណាខ្លះដែលពួកគេត្រូវលក់មុនដំបូង និង បន្ទាប់? តើតំរូវការចាំបាច់នោះទទួលរងផលប៉ះពាល់ដែរឬទេ? ហើយរយៈពេលយូរប៉ុនណា? តើវាមានការពិបាកក្នុងការខ្ចីលុយពីគេដែរឬទេនៅពេលមានគ្រោះថ្នាក់? តើធនធានធម្មជាតិណាខ្លះដែលទទួលរងផលប៉ះពាល់ដោយមុខសញ្ញាគ្រោះថ្នាក់ ហើយរយៈពេលប៉ុន្មាន? តើអាគារណាខ្លះដែលទទួលរងផលប៉ះពាល់ ហើយវាប៉ះពាល់យ៉ាងដូចម្តេច? តើសេវាសុខភាព សហគមន៍ និងរដ្ឋាភិបាល ប្រព័ន្ធទំនាក់ទំនង និងប្រព័ន្ធអគ្គិសនី ទទួលរងផលប៉ះពាល់យ៉ាងដូចម្តេច? តើមានបញ្ហាអ្វីខ្លះដែល កើតមានចំពោះប្រជាជនរងគ្រោះ (ស្លាប់, រងរបួស, ឈឺ, ព្រាត់ប្រាស់គ្នា និងមានជំងឺ)? តើមានជំងឺអ្វីខ្លះដែលប៉ះពាល់ដល់ប្រជាជនក្នុងមូលដ្ឋាន ហើយនរណាខ្លះដែលទទួលរងផលប៉ះពាល់ខ្លាំងបំផុត? តើការទំនាក់ទំនងគ្នារបស់ក្រុមផ្សេងៗមានការ ផ្លាស់ប្តូរយ៉ាងដូចម្តេចនៅពេលមានវិបត្តិបែបនេះ ហើយតើការផ្លាស់ប្តូរនេះផ្តល់នូវផលអ្វីខ្លះ? តើការទំនាក់ទំនងរវាងបុរស និងស្ត្រី ការផ្លាស់ប្តូរយ៉ាងដូចម្តេច?

៤.២ ដំណាក់កាលទី ២: លក្ខខ័ណ្ឌគ្មានសុវត្ថិភាព

យើងត្រូវចោទជាសំណួរថា តើមូលហេតុអ្វីបានជាមុខសញ្ញាគ្រោះថ្នាក់តែងតែរំខានដល់សកម្មភាពសេដ្ឋកិច្ច? តើមូលហេតុអ្វីបានជាប្រជាជនមិនអាចទទួលបាននូវតំរូវការចាំបាច់របស់ពួកគេនៅពេលមានគ្រោះថ្នាក់? តើមូលហេតុអ្វីបានជាប្រជាជនយើងមានការពិបាកក្នុងការទទួលបានប្រាក់កម្ចី? តើហេតុអ្វីបានជាធនធានធម្មជាតិទទួលរងផលប៉ះពាល់ដោយ មុខសញ្ញាគ្រោះថ្នាក់ ហើយវាត្រូវការរយៈពេលប៉ុន្មានដើម្បីស្តារឡើងវិញ? តើហេតុអ្វីបានជាធនធានដែលបានស្ថាបនា ត្រូវទទួលរងផលប៉ះពាល់? តើហេតុអ្វីបានជាប្រជាជនដែលងាយរងគ្រោះថ្នាក់តែងតែទទួលរងផលប៉ះពាល់ខ្លាំង (ការផ្លាស់ទី, សុខភាព, ការងារ, ការអប់រំ)?

តើពួកគេមានចំណេះដឹងទៅលើអ្វីដែលត្រូវធ្វើនៅពេលមានមុខសញ្ញាគ្រោះថ្នាក់កើតឡើងដែរឬទេ? តើហេតុអ្វីបានជាទំនាក់ទំនងសង្គមចុះខ្សោយនៅក្រោយពេលនៃមុខសញ្ញាគ្រោះថ្នាក់កើតឡើង។ តើពួកគេមានជំលោះគ្នាដែរឬទេ នៅពេលដែលពួកគេជួបនឹងគ្រោះថ្នាក់? ហើយតើពួកគេមានកង្វះខាតនូវភាពជាអ្នកដឹកនាំដែរឬទេ នៅ ពេលមានវិបត្តិ?

៤.៣ ចំណាក់កាលទី ៣: អានុភាពចម្បងៗ

យើងត្រូវពិចារណាទៅលើបញ្ហាឱកាសការងារធ្វើ និងប្រាក់ខែ, ប្រាក់ឥណទាន និងប្រាក់សន្សំ, អាជ្ញាធរមូលដ្ឋាន, កម្មសិទ្ធិដីធ្លី, ការបំផ្លាញព្រៃឈើ, ឧស្សាហកម្ម និងភាពកខ្វក់, កសិកម្ម, ការកើនឡើង និងលំហូរចំនួនប្រជាជន, ច្បាប់សាងសង់, សេវាសុខភាព, សេវាមូលដ្ឋាន, ការអប់រំនិងបណ្តុះបណ្តាល, ការដឹកនាំតាមទំនៀមទំលាប់, ក្រុមមនុស្ស នៅក្នុងសង្គម, និងអានុភាពផ្សេងៗទៀត។ តើបញ្ហាទាំងនេះនឹងបង្កឱ្យមានលក្ខខ័ណ្ឌងាយរងគ្រោះបែបណាខ្លះ?

៤.៤ ចំណាក់កាលទី ៤: ចូលហេតុគ្រិះនៃភាពងាយរងគ្រោះ

យើងត្រូវគិតពីបញ្ហារចនាសម្ព័ន្ធគ្រប់គ្រង (ភាពយល់ច្បាស់, ទំនួលខុសត្រូវ,ការចូលរួម), មនោគមវិជ្ជា (សាសនា, វណ្ណៈ, ជាតិសាសន៍ និងការរើសអើងភេទ), ការយល់ដឹងពីគ្រោះภัย និងនីតិវិធី ចំពោះគ្រោះមហន្តរាយ (ជំនឿ វិប្ផធម៌),

រចនាសម្ព័ន្ធសេដ្ឋកិច្ចសង្គម (កម្មសិទ្ធិដីធ្លី, ការគ្រប់គ្រងទីផ្សារ, ការប្រមូលទ្រព្យសម្បត្តិ), អាកាសធាតុ និងធនធានធម្មជាតិ និងធនធានតាមភូមិសាស្ត្រ, ប្រជាធិបតេយ្យ (ការកើនឡើង, សំពាធ, រចនាសម្ព័ន្ធចំនួនប្រជាជន), គោលនយោបាយអប់រំ, ការទទួលបានសេវាសុខភាព, ការទទួលបានផែនការ សុខុមាលភាពសង្គម។ យើងមានសំណួរជាច្រើនទៀត ដែលសំខាន់ក្នុងការកំនត់ពីដើមហេតុចម្បងៗនៃភាពងាយរងគ្រោះដែលមានដូចជា: តើប្រជាជនយើងមិនបានទទួលនូវឱកាសការងារមែនដែរឬទេ ហើយមូលហេតុអ្វី? តើវាជាការពិតដែរឬទេ ដែលប្រជាជនយើងមិនបានទទួលនូវ ប្រាក់ឈ្នួលដោយយុត្តិធម៌ មូលហេតុអ្វី? តើប្រជាជនយើងមិនបានទទួលនូវផែនការហិរញ្ញវត្ថុមែនដែរឬទេ មូលហេតុអ្វី? តើមូលហេតុអ្វីបានជាមានការខ្វះខាតធនធានធម្មជាតិ និងមូលហេតុអ្វីបានជាពួកគេមិនទទួលបាននូវធនធានទាំងនេះ? តើមូលហេតុអ្វីបានជាប្រជាជនមិនអាចការពារបាននូវការខូចខាតទៅលើធនធានដែលមាន? តើប្រជាជនមានអានុភាពយ៉ាង ណាទៅលើការសំរេចចិត្តរបស់អ្នកដឹកនាំ?

៥. ការផ្តល់អាទិភាពលើភាពងាយរងគ្រោះ

តារាងម៉ាទ្រិចសំរាប់ការវិភាគពីភាពងាយរងគ្រោះខាងក្រោមនេះ គឺជាលទ្ធផលនៃការងារដែលបានធ្វើនៅក្នុងជំហានទាំងបួនខាងលើនេះ នៅពេលដែលគេបានផ្តល់នូវអាទិភាពទៅលើភាពងាយរងគ្រោះ។

សមាសភាគគ្រោះថ្នាក់	លក្ខខ័ណ្ឌធានសុវត្ថិភាព	អានុភាពចំបងៗ	មូលហេតុគ្រឹះ
តើអ្វីខ្លះដែលអាចជាផលប៉ះពាល់ពីមុខសញ្ញាគ្រោះថ្នាក់?	តើមូលហេតុអ្វីបានជាមុខសញ្ញាគ្រោះថ្នាក់ជះឥទ្ធិពលទៅលើសមាសភាគគ្រោះថ្នាក់	តើនរណាបង្កើតឱ្យមានលក្ខខ័ណ្ឌងាយរងគ្រោះ ថ្នាក់? តើវាកើតឡើង បានយ៉ាងដូចម្តេច?	តើមូលហេតុអ្វីបានជាលក្ខខ័ណ្ឌងាយរងគ្រោះ ថ្នាក់ត្រូវបានបង្កើតឡើង ហើយ/ឬក៏មិនត្រូវបានដឹងលឺដោយអានុភាពចំបងៗ?
ធនធានសេដ្ឋកិច្ច			
ធនធានធម្មជាតិ			

ធនធានសំណង់			
ធនធានបុគ្គល			
ធនធានសង្គម			

ដកស្រង់ចេញពី TearFund (ឆ្នាំ២០០៦)

II. ការប៉ាន់ប្រមាណពីសមត្ថភាព

(ការគូរផែនទីសមត្ថភាពអាចរៀបចំបាន លុះត្រាតែផែនទីមុខសញ្ញាគ្រោះថ្នាក់ និងផែនទីភាពងាយរងគ្រោះ ត្រូវបានរៀបចំរួចរាល់)

- **គោលបំណង**
  - ដើម្បីរៀបចំនូវការគូសផែនទីសមត្ថភាពរបស់សហគមន៍ និងកំនត់ពីធនធានដែលអាចមាន ដែលនឹងប្រើប្រាស់ដោយសមាជិកសហគមន៍នៅក្នុងការងារកាត់បន្ថយគ្រោះภัยនៃគ្រោះមហន្តរាយ ។
- **វិធីសាស្ត្រ**
  - ការងារជាក្រុម
  - សំនួរ និង ចំលើយ
- **ជំរណីរការ**
  - ប្រើប្រាស់ផែនទីមុខសញ្ញាគ្រោះថ្នាក់ និងផែនទីភាពងាយរងគ្រោះថ្នាក់ខាងលើ
  - តើអ្នកតែងតែទៅកន្លែងណានៅពេលគ្រោះមហន្តរាយកើតមានឡើង?
  - តើអ្នកត្រូវគេចចេញយ៉ាងដូចម្តេចនៅពេលគ្រោះមហន្តរាយកើតមានឡើង?
  - ត្រូវសួរដល់សិក្ខាកាមថា តើអ្វីខ្លះជាហេដ្ឋារចនាសម្ព័ន្ធ ឬមធ្យោបាយសំរួលនានា ដែលមាននៅក្នុង សហគមន៍ ឬនៅតាមទីតាំងនានា (សាលារៀន, វត្តអារាម, មណ្ឌលសហគមន៍, មន្ទីរពេទ្យ, ស្ពាន, ផ្លូវថ្នល់, បន្ទន់ អនាម័យ, ផ្ទះសំបែង)?
  - តើតំបន់ ឬទីទួលសុវត្ថិភាពមាននៅទីណាសំរាប់សហគមន៍នៅពេលគ្រោះមហន្តរាយ?
  - តើធនធានអ្វីខ្លះដែលអាចប្រើប្រាស់បាននៅក្នុងសហគមន៍នៅពេលគ្រោះមហន្តរាយ?
  - តើនរណាដែលអាចទទួលបាន និងគ្រប់គ្រងលើធនធានដែលអាចមាន?
  - បុគ្គលិកអនុវត្តនៅមូលដ្ឋានម្នាក់ ត្រូវកត់ត្រាទុកនូវចំលើយទាំងអស់ខាងលើ?
  - ត្រូវឱ្យសិក្ខាកាមទាំងអស់ដាក់នូវចំលើយនៃសំនួរទី ១, ២, ៣, ៤, ៥, ៦ និង ៧ ទៅក្នុងផែនទីមុខសញ្ញា គ្រោះថ្នាក់ និង ផែនទីភាពងាយរងគ្រោះ?
  - ត្រូវឱ្យសិក្ខាកាមបង្ហាញពីលទ្ធផលនៃការគូសផែនទីសមត្ថភាព ។

១. តើអ្វីជាសមត្ថភាព?

សមត្ថភាពជាការរួមបញ្ចូលគ្នានៃកំលាំង និងធនធានទាំងអស់ដែលមាននៅក្នុងសហគមន៍ សង្គម អង្គការ ដែលអាចកាត់បន្ថយកំរិតនៃគ្រោះภัย ឬតទ្ធិពលនៃគ្រោះមហន្តរាយ។ សមត្ថភាពរួមមានវិធីសាស្ត្រ បែបរួបរួន ស្ថាប័ន សង្គម ឬសេដ្ឋកិច្ច ក៏ដូចជាបុគ្គលដែលមានជំនាញ ឬលក្ខណៈជារួមគ្នា ដូចជាការដឹកនាំ និងការគ្រប់គ្រង។ សមត្ថភាពក៏អាចថាជាសេចក្ដីអង់អាចក្លាហាន (ការរស់នៅជាមួយគ្រោះภัย-UNISDR, 2004)។

២. ការប៉ាន់ប្រមាណពីសមត្ថភាព: ប្រភេទនៃការវិភាគ

ដើម្បីធ្វើឱ្យវាមានលក្ខណៈដូចគ្នានឹងការកំនត់ពីភាពងាយរងគ្រោះថ្នាក់នោះ ដូចនេះ វិធីសាស្ត្រនៃការ វិភាគទាំង ៥ ខាងក្រោមនេះ ត្រូវបានគេយកមកប្រើប្រាស់នៅពេលដែលរៀបចំនូវកិច្ចការប៉ាន់ប្រមាណពី សមត្ថភាព។

សេដ្ឋកិច្ច	ធម្មជាតិ	សំណង់	បុគ្គល	សង្គម
ដូចជាប្រាក់ចំណូល, ប្រាក់សន្សំ, ប្រាក់កម្ចី	ដូចជាដី, ព្រៃឈើ, ទឹក	ដូចជា ផ្ទះសំបែង, អណ្ដូង, សំភារៈនានា	ដូចជាមនុស្ស, ចំណេះ ដឹង, សុខភាព, ជំនាញ	ដូចជា ទំនាក់ទំនង គណៈកម្មាធិការ, បណ្ដាញ

៣. ជំហានក្នុងការកំណត់ពីភាពងាយរងគ្រោះដែលពាក់ព័ន្ធនឹងទំរង់សំពាធ និងបញ្ជ្រៀស (PAR model)

ជំហានទាំង ៤ ខាងក្រោម នឹងត្រូវយកមកអនុវត្តនៅពេលធ្វើការកំនត់ពីភាពងាយរងគ្រោះពាក់ព័ន្ធទៅនឹងទំរង់ សំពាធ និងបញ្ជ្រៀស (PAR model) ៖



ខាងក្រោមនេះ គឺជាឧទាហរណ៍នៃប្រភេទសំនួរជាច្រើនដែលអ្នកនឹងសួរ ឬជាប្រធានបទ ដែលត្រូវយកមកបកស្រាយក្នុងជំហាននីមួយៗនៃជំហានទាំងបួននេះ។ *នេះមិនមែនជាតារាងបញ្ជាក់ដ៏ពេញលេញមួយនោះទេ តែត្រូវបានចាត់ទុកជាការណែនាំជួយដាស់ស្មារតីរបស់អ្នកតែប៉ុណ្ណោះ។*

៣.១ ជំណាក់កាលទី ១: សមាសភាគដែលត្រូវការពារ

យើងត្រូវគិតទៅលើចំនុចមួយចំនួនដូចជា តើនរណាខ្លះដែលរងផលប៉ះពាល់តិចតួចបំផុតនៅក្នុងពេល និងក្រោយពេលនៃមុខសញ្ញាគ្រោះថ្នាក់? តើសកម្មภาពនិងធនធានសេដ្ឋកិច្ចណាខ្លះដែលរងផលប៉ះពាល់តិចតួចបំផុតនៅក្នុងពេល និងក្រោយពេលនៃមុខសញ្ញាគ្រោះថ្នាក់? តើធនធានណាខ្លះដែលមិនបានលក់ដូរ សូម្បីនៅពេលមានវិបត្តិ?តើយើងអាចខ្ចីលុយបានដែរឬទេ ប្រសិនបើមានภาពចាំបាច់នោះ? តើធនធានធម្មជាតិណាខ្លះ និងអាគារណាខ្លះដែលមិនបានរងផលប៉ះពាល់? តើធនធានទឹក, ប្រដាប់ប្រើប្រាស់ និង គ្រឿងបរិក្ខារ, អាគារ សំណង់ របស់សហគមន៍ និងរដ្ឋาภิบาล, ប្រព័ន្ធទំនាក់ទំនង, ប្រព័ន្ធអគ្គិសនី ត្រូវបានការពារ ឬពុំបានទទួលរងផលប៉ះ ពាល់ពីមុខសញ្ញាគ្រោះថ្នាក់មែនដែរឬទេ? តើមានធនធានធម្មជាតិណាខ្លះដែលទទួលបានផលប្រយោជន៍ពីមុខសញ្ញាគ្រោះថ្នាក់? តើបណ្តាក្រុមណាខ្លះដែលទទួលរងផលប៉ះពាល់តិចតួចបំផុត? ហើយ តើមានទំនាក់ទំនងដែលត្រូវបានពង្រឹង?

៣.២ ជំណាក់កាលទី ២: ការកំនត់ពីលក្ខខ័ណ្ឌសុវត្ថิภาព

តើសកម្មภาព និងធនធានសេដ្ឋកិច្ចជាក់លាក់ណាខ្លះដែលមិនរងផលប៉ះពាល់ពីមុខសញ្ញាគ្រោះថ្នាក់? តើមូលហេតុអ្វីបានជាប្រជាជនមិនបានលក់ដូរធនធានរបស់ខ្លួន ហើយតើប្រជាជនអាចទទួលបាននូវតំរូវការចាំបាច់ របស់ខ្លួនបានយ៉ាងដូចម្តេចនៅពេលមានមុខសញ្ញាគ្រោះថ្នាក់? តើប្រជាជនមានអាហារ និងប្រាក់បំរុងទុកសំរាប់ ប្រើប្រាស់នៅពេលមានវិបត្តិដែរឬទេ? តើមូលហេតុអ្វីបានជាធនធានធម្មជាតិមិនទទួលរងផលប៉ះពាល់? ហើយតើមូលហេតុអ្វីបានជាធនធានធម្មជាតិមួយចំនួន ទទួលបាននូវផលប្រយោជន៍? តើធនធានធម្មជាតិណាខ្លះដែលបានស្តារឡើងវិញយ៉ាងឆាប់រហ័ស ហើយមូលហេតុអ្វី? ហេតុអ្វីបានជាធនធានធម្មជាតិត្រូវបានប្រើប្រាស់ពេលមានគ្រោះภัយ? តើមានធនធានធម្មជាតិណាខ្លះត្រូវបានប្រើប្រាស់នៅក្នុងមធ្យោបាយពិសេសក្នុងការការពារប្រជាជន? ហេតុអ្វីបានជាសមាសภาคសំណង់មិនទទួលរងផលប៉ះពាល់ ហើយតើវាត្រូវបានការពារបានយ៉ាងដូចម្តេច? តើមានសំណង់អាគារដែលត្រូវបានប្រើប្រាស់នៅពេលមុន កំឡុងពេល និងក្រោយ ពេលនៃមុខសញ្ញាគ្រោះថ្នាក់ដែរឬទេ? តើប្រជាជនអាចការពារបានទៅលើអាគារទាំងនោះបានដែរឬទេ? តើប្រជាជនមាន ជំរើសណាផ្សេងដែរឬទេ ប្រសិនបើផ្ទះវិថ្នល់ត្រូវបានបំផ្ទិចបំផ្លាញ? ហេតុអ្វីបានជាប្រជាជនមួយចំនួនទទួល រងផលប៉ះពាល់ តិចតួច (ការចល័ត, សុខภาព, ជំនាញវិជ្ជาជីវៈ, ការអប់រំ, ចំណេះដឹងប្រពៃណី)? តើប្រជាជនមានចំណេះដឹងណាមួយ ជាក់លាក់ដែរឬទេទៅលើអ្វីដែលត្រូវធ្វើនៅពេលមានគ្រោះภัยកើតឡើង? តើមាននរណាម្នាក់បានដើរតួនាទីពិសេសក្នុងការជួយអ្នកដទៃនៅពេលមានគ្រោះថ្នាក់ដែរឬទេ?
តើហេតុអ្វីបានជាបណ្តាក្រុមមួយចំនួនអាចទប់ទល់នឹងគ្រោះថ្នាក់បាន? តើហេតុអ្វីបានជាចំណងទាក់ទងមួយចំនួនរឹងមាំបាននៅពេលមានវិបត្តិ? តើតួនាទីអ្វីដែលគ្រួសារត្រូវធ្វើ?

៣.៣ ជំណាក់កាលទី ៣: អាងភាពចំបងៗដែលបានបញ្ជ្រៀស

យើងត្រូវពិចារណាលើបញ្ហាមួយចំនួន ដូចជា តើអង្គภาព ឬស្ថาบันណាខ្លះ ដែលមាននៅពេលគ្រោះภัយ? ហើយតើអង្គภาព និងស្ថาบันទាំងនេះជួយប្រជាជនខាងផ្នែកសេដ្ឋកិច្ចនៅពេលមានគ្រោះภัយដែរឬទេ? តើនរណាខ្លះដែលមាន ឬគ្រប់គ្រងលើការប្រើប្រាស់ធនធានធម្មជាតិនៅក្នុងតំបន់មូលដ្ឋาน? តើមានមធ្យោបាយណាខ្លះ ដែលអាចទទួលបាននូវធនធនធម្មជាតិនៅពេលមានវិបត្តិ? តើនរណាខ្លះដែលមាន ឬគ្រប់គ្រងលើការប្រើប្រាស់អាគារសុវត្ថิภาព, យានយន្ត ឬទូក កាណូត? ហើយតើប្រជាជនក្រីក្រអាចទទួលបាននូវធនធានធម្មជាតិទាំងនេះបានដែរឬទេ? តើនរណាខ្លះដែលទទួលបានសេវា ទូរស័ព្ទ ឬវិទ្យុ? តើនរណាខ្លះដែលមានចំណេះដឹង/ ជំនាញក្នុងការទប់ទល់នឹងគ្រោះมหาន្តราย? តើចំណេះដឹង/ ជំនាញនេះ បានផ្តល់ទៅអោយអ្នកដទៃផ្សេងទៀតបាន

យ៉ាងដូចម្តេច? តើគេមានប្រព័ន្ធសំរាប់បញ្ជូនសារផ្តល់ព័ត៌មានជាមុនដែរឬទេ? តើនរណាដែលដើរតួនាទីដឹកនាំនៅក្នុងពេលគ្រោះภัย? តើនរណាជួយបានច្រើនបំផុតដល់អ្នករងគ្រោះ? តើការជួយនោះ ប្រព្រឹត្តទៅដោយស្មើភាពដល់ជនរងគ្រោះទាំងអស់ដែរឬទេ? តើអ្នកក្រីក្រ និង អ្នកដែលរងគ្រោះបំផុត ទទួលបានជំនួយ ពិសេសណាមួយដែរឬទេ? តើអ្នកដឹកនាំបានផ្តល់នូវការណែនាំច្បាស់លាស់ដល់ប្រជាជននៅពេលមានគ្រោះภัยដែរឬទេ?

៣.៤ ជំណាក់កាលទី ៤: ការកំនត់ពីចូលហេតុគ្រិះថ្នាក់

បញ្ហាមួយចំនួនដែលត្រូវដោះស្រាយរួមមានដូចជា តើគំនិត និងគោលនយោបាយ និងគោលការណ៍ សេដ្ឋកិច្ចណាខ្លះកំពុងតែជួយអន្តរាគមន៍? តើប្រជាជនទទួលបាននូវឱកាសការងារដ៏ល្អដែរឬទេ? ប្រសិនបើមែន តើប្រជាជនទទួលបានប្រាក់ឈ្នួលបានយ៉ាងត្រឹមត្រូវដែរឬទេ? តើប្រជាជនទទួលបានផែនការហិរញ្ញវត្ថុដែរឬទេ? ហើយតើលុយដែលឱ្យខ្ចីនោះមានលក្ខខ័ណ្ឌត្រឹមត្រូវដែរឬទេ?

៤. ការផ្តល់អាទិភាពលើសមត្ថភាព

តារាងម៉ាទ្រិចសំរាប់ការវិភាគពីសមត្ថភាពខាងក្រោមនេះ គឺជាលទ្ធផលនៃការងារដែលបានធ្វើនៅក្នុងជំហានទាំង ០៤ ខាងលើ នៅពេលដែលសមត្ថភាពត្រូវបានគេផ្តល់អាទិភាព ។

សមាសភាគ	លក្ខខ័ណ្ឌសុវត្ថិភាព	អានុភាពចំបង១ដែលបានបញ្ជៀស	មូលហេតុគ្រិះជាវិជ្ជមាន
តើសមាសភាគអ្វីខ្លះដែលមិនរងផលប៉ះពាល់ពីមុខសញ្ញាគ្រោះ ថ្នាក់?	តើសមត្ថភាពអ្វីខ្លះដែលមានសំរាប់ជួយការពារសមាសភាគគ្រោះថ្នាក់ពីគ្រោះថ្នាក់?	តើនរណាជួយបង្កើតឱ្យមាន លក្ខខ័ណ្ឌសុវត្ថិភាព? តើវាកើតឡើងបានយ៉ាងដូចម្តេច?	តើមូលហេតុអ្វីបានជា លក្ខខ័ណ្ឌសុវត្ថិភាពត្រូវ បានការពារ?
ធនធានសេដ្ឋកិច្ច			
ធនធានធម្មជាតិ			
ធនធានសំណង់			
ធនធានបុគ្គល			
ធនធានសង្គម			

ដកស្រង់ចេញពី TearFund (ឆ្នាំ២០០៦)

មេរៀនទី ៤: ការណែនាំការចុះធ្វើការងារជាក់ស្តែងអំពីការប៉ាន់ប្រមាណគ្រោះภัย

- **គោលបំណង**
  - ការវិភាគ និងការវាយតំលៃលើគ្រោះภัย គឺដើម្បីទទួលបាននូវរូបភាពដ៏ត្រឹមត្រូវមួយនៃគ្រោះภัย និងផលវិបាករបស់វានីមួយៗ។ ការងារនេះនឹងឱ្យសហគមន៍វាយតំលៃដោយខ្លួនពួកគេផ្ទាល់អាស្រ័យលើផលប៉ះពាល់ ដែលពួកគេមានទៅលើវិស័យ និង សមាសភាគនានា ដែលជួយឱ្យសហគមន៍ពួកគេបានរីកចំរើន។

- **វិធីសាស្ត្រ**
  - ក្រុមពិភាក្សាធំ

- **ដំណើរការ**
  - សួរសិក្ខាកាមឱ្យពន្យល់ពីមុខសញ្ញាគ្រោះថ្នាក់នៅក្នុងសហគមន៍
  - បុគ្គលិកអនុវត្តនៅមូលដ្ឋាន ត្រូវសរសេរនូវចំលើយនៃគ្រោះภัยដែលមានមុខសញ្ញាគ្រោះថ្នាក់នានា ដាក់នៅលើក្រដាសផ្ទាំងធំមួយ ហើយចំលើយនៃគ្រោះภัยដែលគ្មានមុខសញ្ញាគ្រោះថ្នាក់ដាក់នៅលើក្រដាសផ្ទាំងធំមួយផ្សេងទៀត។
  - សិក្ខាកាមត្រូវដាក់ចំណាត់ថ្នាក់នៃគ្រោះภัយជាពីរ គឺ "គ្រោះภัยដែលមានមុខសញ្ញាគ្រោះថ្នាក់" និង "គ្រោះภัយដែលគ្មានមុខសញ្ញាគ្រោះថ្នាក់"។
  - នៅពេលបញ្ហាត្រូវបានចំណាត់ថ្នាក់រួចហើយ បុគ្គលិកអនុវត្តនៅមូលដ្ឋាន ត្រូវពន្យល់ដល់សិក្ខាកាមថាការប៉ាន់ប្រមាណពីគ្រោះภัยនៅតាមសហគមន៍នឹងត្រូវអនុវត្តបានតែទៅលើ "គ្រោះภัยដែលមានមុខសញ្ញាគ្រោះថ្នាក់" តែប៉ុណ្ណោះ នៅក្នុងជំហានបន្ទាប់។
  - ត្រូវឱ្យសិក្ខាកាមម្នាក់បង្ហាញពីគ្រោះภัยដែលមានមុខសញ្ញាគ្រោះថ្នាក់ទៅដល់សិក្ខាកាមទាំងអស់
  - បុគ្គលិកអនុវត្តនៅមូលដ្ឋាន ត្រូវពន្យល់ដល់សិក្ខាកាមពីរបៀបកំនត់លើផលវិបាកជាក់លាក់ណាមួយទប់ទល់នឹងផលវិបាកនីមួយៗនៃគ្រោះภัย។
  - ត្រូវសរសេរផលវិបាកដែលធ្ងន់ធ្ងរមួយម្តងៗទប់ទល់នឹងផលវិបាកនីមួយៗនៃគ្រោះภัយ
  - បន្ទាប់មកបុគ្គលិកអនុវត្តនៅមូលដ្ឋានត្រូវពន្យល់ពីការចិញ្ចឹមជីវិត និងល័ក្ខខ័ណ្ឌកំនត់ពីឥទ្ធិពល ហើយបំពេញនៅក្នុងប្រអប់នីមួយៗទៅតាមឥទ្ធិពលនីមួយៗនៃគ្រោះภัย ដោយផ្អែកលើសក្តានុពលនៃឥទ្ធិពលដែលគ្រោះภัยមាននៅពេលវាកើតឡើង។
  - នៅចុងក្រោយ ដោយផ្អែកលើការចិញ្ចឹមជីវិត និងកំរិតនៃផលវិបាកនៃគ្រោះภัยជាក់លាក់ណាមួយនោះ បុគ្គលិកអនុវត្តនៅមូលដ្ឋាន ត្រូវឱ្យសិក្ខាកាមវាយតំលៃលើគ្រោះภัยអាស្រ័យលើសក្តានុពលរបស់វា នៅក្នុងមូលដ្ឋាន។

- ក្រោយពីកំនត់ក៏រិតនៃគ្រោះภัយរួច បុគ្គលិកអនុវត្តនៅមូលដ្ឋានត្រូវអោយសហគមន៍ពិភាក្សាគ្នាអំពី ថាតើផលវិបាកធ្ងន់ធ្ងរគ្រោះภัយមួយណាអាចគ្រប់គ្រងបានដោយបុគ្គល និងសហគមន៍បានដែរឬទេ (គ្រោះภัយដែល ទទួលយកបាន) ឬត្រូវការជំនួយពីខាងក្រៅ (គ្រោះภัយមិនអាចទទួលយកបាន) ដោយផ្អែកលើការវាយតំលៃ គ្រោះภัយរួចមក?
- ដើម្បីអោយសិក្ខាកាមមានការយល់ដឹងបានកាន់តែប្រសើរ យើងត្រូវលើកឧទាហរណ៍ជាក់ស្តែង។ ទោះជាយ៉ាងណាក៏ដោយ។ ឧទាហរណ៍នេះ អាចនឹងមិនទាក់ទងនឹងគ្រោះภัយដែលយើងបានកំនត់នោះ ដែលវានឹងមានការប៉ះពាល់បន្តិចទៅលើអារម្មណ៍របស់សិក្ខាកាម។
- បុគ្គលិកអនុវត្តនៅមូលដ្ឋាន នឹងត្រូវសរសេរតារាងបញ្ជីពីរផ្សេងគ្នានូវគ្រោះภัយដែលអាចទទួលយកបាន និងគ្រោះภัយដែលមិនអាចទទួលយកបាន ហើយត្រូវពិភាក្សាជាមួយនឹងសិក្ខាកាមថា ដំណើរការប៉ាន់ប្រមាណគ្រោះภัយនៅសហគមន៍នឹងវិភាគទៅលើគ្រោះภัយដែលមិនអាចទទួលយកបាននៅពេលវគ្គបន្ទាប់ៗទៀត។

ឧទាហរណ៍:

គ្រោះภัយ	សក្តានុភាពនៃឥទ្ធិពល	ឥទ្ធិពល	ការចិញ្ចឹមជីវិត	ក៏រិត	លទ្ធភាព
១- គ្រោះภัយទឹកជន់ នៅក្នុងតំបន់ដីសណ្តរនឹងបំផ្ទិចបំផ្លាញផលដំណាំ និង សត្វពាហណ:	ការបាត់បង់នៃផលដំណាំចិញ្ចឹម ជីវិត និងសត្វពាហណ:, កង្វះ ខាតចំណីអាហារ, ខូចខាតផល ទ្រព្យសម្បត្តិ	ច្រើន	អាច	ខ្ពស់	មិនអាចទទួលយកបាន
២- គ្រោះภัយទឹកជន់ នៅក្នុងព្រលានយន្តហោះ និងតំបន់ក្បែរ១នឹងបង្ករឱ្យ មានការបាត់បង់ជីវិត	ការតាំងលំនៅថ្មី, លក់ទ្រព្យ សម្បត្តិ/ ខ្ចីលុយគេ, អាកប្បកិ រិយាប្រឆាំងនឹង សង្គមកើនឡើង, ការរាលដាលជំងឺ, គ្រោះថ្នាក់សុខភាព, ប្រាក់ចំនួល គ្រួសារ មានវិបត្តិ	ល្អម	ប្រហែល	ល្អម	មិនអាចទទួលយកបាន
៣-	.....				អាចទទួល យកបាន

I. ជំរើសការងារលើការកាត់បន្ថយគ្រោះภัយ

១. ប្រតិទិនរដូវកាល

ប្រតិទិនរដូវកាលត្រូវបានប្រើប្រាស់សំរាប់ការយល់ដឹង នៅពេលដែលសហគមន៍ជួបនឹងមុខសញ្ញាគ្រោះថ្នាក់ណាមួយ។ ប្រតិទិនរដូវកាល ក៏មានសារៈសំខាន់ផងដែរសំរាប់កំណត់ពីសកម្មភាពនៅក្នុងភូមិ ដូចជា: រដូវដាំដុះ, សកម្មភាព សេដ្ឋកិច្ច និងវប្ប:ធម៌សង្គម, រដូវបុណ្យទាន និងព្រឹត្តិការណ៍នានានៅក្នុងឆ្នាំ។

ប្រតិទិនរដូវកាលនេះ ក៏អាចប្រើប្រាស់ក្នុងការកំនត់ពីតួនាទីរបស់បុរស និងស្ត្រី និងកុមារ នៅក្នុងហេតុការណ៍ណាមួយនៅក្នុងភូមិក្នុងកំឡុងពេលនៃឆ្នាំនោះ។

ប្រតិទិនរដូវកាលនេះមានសារៈសំខាន់ណាស់សំរាប់: កំណត់ពីរយៈពេលនៃការលំបាក, គ្រោះภัย, ជំងឺ, ទុរភិក្ស, ប្រាក់បំណុល, ภาពងាយរងគ្រោះថ្នាក់ កំណត់ពីអ្វីដែលប្រជាជនត្រូវធ្វើនៅក្នុងរយៈពេលទាំងនេះ តើពួកគេផ្លាស់ប្តូរធនធាននៃការចិញ្ចឹមជីវិតបានយ៉ាងដូចម្តេច? នៅពេលណាដែលពួកគេមានប្រាក់សន្សំ? នៅពេលណាដែលពួកគេមានពេលសំរាប់សកម្ម្ภาពសហគមន៍? តើអ្វីខ្លះជាយុទ្ធសាស្ត្រដោះស្រាយរបស់ពួកគេ? កំណត់ពីការបែងចែកផ្នែកយេនឌ័រលើការងារនៅក្នុងពេលគ្រោះមហន្តរាយ និង ពេលធម្ម្ภาតា។

២. ប្រតិទិនរដូវកាលនៃការចិញ្ចឹមជីវិត

២.១ គោលបំណង

- ដើម្បីយល់ដឹងពីជំរើសចិញ្ចឹមជីវិត និងទំហំរដូវកាលរបស់វា

២.២ វិធីសាស្ត្រ

- ក្រុមការងារ
- សំនួរ និង ចំលើយ

២.៣ ជំហ៊ានការ

- រៀបចំផ្ទាំងក្រដាសសធំ ដែលរៀបចំដោយមានដាក់ខែនៅខាងលើ ហើយទុកកន្លែងសំរាប់សរសេរពីជំរើសនៃការចិញ្ចឹមជីវិតនៅខាងឆ្វេងដៃ
- បុគ្គលិកអនុវត្តនៅមូលដ្ឋាន ត្រូវចាប់ផ្តើមការពិភាក្សាគ្នា ដោយការសួរសំនួរជុំវិញបញ្ហាចិញ្ចឹមជីវិត និង ពេលវេលានៅក្នុងសហគមន៍ដូចជាការដាំដុះ, ការនេសាទ, ការបរបាញ់សត្វ, ការប្រមូលNTFP ជាដើម
- ក្រោយពីការយល់ដឹងពីស្ថានภาពនៃការចិញ្ចឹមជីវិត និងពេលវេលារួចហើយ បុគ្គលិកអនុវត្តនៅមូលដ្ឋានត្រូវឱ្យសិក្ខាកាមពិភាក្សា និងរៀបចំតារាងបញ្ជីមួយស្តីពីជំរើសនៃការចិញ្ចឹមជីវិតនៅក្នុងតំបន់របស់ពួកគេ
- ត្រូវឱ្យសិក្ខាកាមកំនត់នូវខែសំរាប់ការអនុវត្តលើជំរើសនីមួយៗនៃការចិញ្ចឹមជីវិតដែលមាននៅក្នុងតំបន់របស់ពួកគេ
- ត្រូវឱ្យសិក្ខាកាមពិភាក្សារួមគ្នា ដើម្បីបញ្ចប់លើប្រតិទិនរដូវកាលនៃជំរើសចិញ្ចឹមជីវិតនៅមូលដ្ឋានរបស់ពួកគេ
- ត្រូវឱ្យសិក្ខាកាមបង្ហាញពីលទ្ធផលនៃការពិភាក្សាទៅដល់សមាជិកក្រុមទាំងអស់

ឧទាហរណ៍:

ការចិញ្ចឹមជីវិត	មករា	កុម្ភៈ	មីនា	មេសា	ឧសភា	មិថុនា	កក្កដា	សីហា	កញ្ញា	តុលា	វិច្ឆិកា	ធ្នូ
ការដាំដុះដំណាំ												
ការនេសាទ												
ការប្រមូលផល												

៣. ប្រតិទិនរដូវកាលនៃមុខសញ្ញាគ្រោះថ្នាក់

៣.១ គោលបំណង

- ដើម្បីអោយយល់ដឹងអត្រានៃកើតមានមុខសញ្ញាគ្រោះថ្នាក់ និងការផ្លាស់ប្តូររបស់វា ដោយសារតែការប្រែប្រួលអាកាសធាតុនៅក្នុងតំបន់ និង តើវានឹងត្រូវបានកែសំរួលបែបណាជាមួយនឹងសកម្មភាពចិញ្ចឹមជីវិតនោះ?

៣.២ វិធីសាស្ត្រ

- ការងារក្រុម
- សំនួរ និង ចំលើយ

៣.៣ ជំហានការ

- រៀបចំផ្ទាំងក្រដាសសធំ ដែលរៀបចំដោយមានដាក់ខែនៅខាងលើ ហើយទុកកន្លែងសំរាប់សរសេរពីជំរើសនៃការចិញ្ចឹមជីវិតនៅខាងឆ្វេងដៃ
- ត្រូវអោយសិក្ខាកាមរៀបចំតារាងបញ្ជីនៃមុខសញ្ញាគ្រោះថ្នាក់ដែលកើតមាននៅក្នុងសហគមន៍ពួកគេ (សូមមើលនៅក្នុងផែនទីមុខសញ្ញាគ្រោះថ្នាក់)
- អោយសិក្ខាកាមម្នាក់ឡើងបង្ហាញពីតារាងបញ្ជីនោះ ហើយសួរដល់សិក្ខាកាមដទៃទៀត តើនៅមានចំណុចណាខ្វះខាត និងបន្ថែមបន្ថយទៀតដែរឬទេ?
- បុគ្គលិកអនុវត្តនៅមូលដ្ឋាន ត្រូវសួរដល់សិក្ខាកាម តើខែណាដែលមានទឹកជំនន់, គ្រោះរាំងស្ងួត និងសត្វល្អិតកើតមាននៅក្នុងតំបន់ពួកគេ? ហើយតើខែណាដែលស្ថានភាពនោះកាន់តែអាក្រក់?
- ក្រោយពីការយល់ដឹងពីស្ថានភាពនៃមុខសញ្ញាគ្រោះថ្នាក់ និងពេលវេលានេះរួចហើយ បន្ទាប់មកត្រូវឱ្យសិក្ខាកាមពិភាក្សា និងរៀបចំប្រតិទិនរដូវកាលនៃមុខសញ្ញាគ្រោះថ្នាក់ដែលមាននៅក្នុងតារាងបញ្ជី សំរាប់តំបន់របស់ពួកគេ
- អោយសិក្ខាកាមកំនត់នូវខែនៃការកើតមានឡើងនីមួយៗនៃមុខសញ្ញាគ្រោះថ្នាក់ ហើយសិក្ខាកាមក៏ត្រូវកំណត់ផងដែរ ពីខែណាដែលស្ថានភាពនោះកាន់តែអាក្រក់
- សិក្ខាកាមនឹងពិភាក្សារវាងពួកគេផ្ទាល់ ដើម្បីបញ្ចប់ទៅលើប្រតិទិនរដូវកាលនៃមុខសញ្ញាគ្រោះថ្នាក់ដែលកើតមាននៅក្នុងតំបន់របស់ពួកគេ
- ចោទជាសំនួរមួយចំនួនដល់សិក្ខាកាម ពិសេសត្រូវសុំមតិយោបល់ពីសិក្ខាកាម ដែលមានវ័យចំណាស់ៗនូវសំនួរដែលថា:
    - តើកំលាំងទឹកជំនន់កាលពី ១០ឆ្នាំមុន មានលក្ខណៈបែបម៉ែច?
    - តើអ្នកឃើញមានការផ្លាស់ប្តូរខ្លះទេនៅក្នុងរយៈពេលនៃការកើតឡើងនោះ និងកំលាំងទឹកជំនន់ នៅរយៈពេលនោះ? ប្រសិនបើមាន សូមធ្វើការកំនត់ដាក់នៅលើប្រតិទិនរដូវកាល នៅក្រោយពេលដែលឯកភាពគ្នាលើប្រើប្រាស់ពណ៌ និងសញ្ញារួចហើយនោះ
- ត្រូវអោយសិក្ខាកាមឡើងបង្ហាញពីលទ្ធផលនៃការពិភាក្សាទៅដល់សមាជិកក្រុមទាំងអស់

ឧទាហរណ៍:

មុខសញ្ញាគ្រោះថ្នាក់	មករា	កុម្ភៈ	មីនា	មេសា	ឧសភា	មិថុនា	កក្កដា	សីហា	កញ្ញា	តុលា	វិច្ឆិកា	ធ្នូ
ទឹកជំនន់												
គ្រោះរាំងស្ងួត												

៤. ការវិភាគរកហេតុផល

៤.១ គោលបំណង

- ដើម្បីកំនត់ពីសក្តានុពលនៃមូលហេតុនៃលក្ខខ័ណ្ឌគ្រោះภัยជាក់លាក់ដែលទាក់ទងនឹងវិស័យ គ្រោះថ្នាក់, សមាសภาค និងទីតាំងសហគមន៍ និងជំរើសដែលអាចមានសំរាប់កាត់បន្ថយគ្រោះภัย ។

៤.២ វិធីសាស្ត្រ

- ពិភាក្សាក្រុមធំ និងសំនួរ-ចំលើយ

៤.៣ ជំហ៊ានការ

- បង្ហាញ និងពិភាក្សាម្តងទៀតទៅលើតារាងបញ្ជីនៃលក្ខខ័ណ្ឌគ្រោះภัยដែលជាអាទិភាពយ៉ាងតិច ១០លក្ខខ័ណ្ឌ) ។
- បង្ហាញពីទំរង់វិភាគហេតុផលដាក់នៅលើក្តារខៀន ឬជញ្ជាំង សំរាប់ឱ្យសិក្ខាកាមមើលនៅពេលពួកគេកំណត់ពីមូលហេតុនៃគ្រោះภัยដែលជាអាទិភាព និងជំរើស ដែលអាចមានសំរាប់ការកាត់បន្ថយ ។
- បុគ្គលិកអនុវត្តនៅមូលដ្ឋាន ត្រូវពិភាក្សាទៅលើកំរិតខុសគ្នានៃមូលហេតុ និងជំរើស មានន័យថាទៅលើកំរិតបន្ទាន់, មធ្យម និងកំរិតទាបនៃមូលហេតុ និងជំរើសនានាលើលក្ខខ័ណ្ឌគ្រោះภัยជាក់លាក់ណាមួយ ។
- កំណត់ពីជំរើសនីមួយៗនៃមូលហេតុ ឬមូលហេតុរួម ។ នៅពេលកំនត់ពីជំរើស យើងត្រូវឱ្យសិក្ខាកាមកំណត់ឱ្យបានច្បាស់លាស់ពីអ្វីដែលត្រូវធ្វើ និងនៅកន្លែងណា?
ការប្រឈមមួយដែលអ្នកអនុវត្តការឆ្លើយតបគ្រោះអាសន្ន ប្រឈមមុខអំឡុងពេលមានការកើតឡើង នៃមុខសញ្ញាគ្រោះថ្នាក់ ឧទាហរណ៍: ទឹកជំនន់ គឺការប្រើប្រាស់ទឹកស្អាត និងសំភារៈអនាម័យ។ ការប៉ាន់ប្រមាណរហ័សត្រូវតែធ្វើឡើងក្នុងអំឡុងដំណាក់កាលធ្វើផែនការកាត់បន្ថយគ្រោះภัយនៃគ្រោះមហន្តរាយ ឬផែនការត្រៀមបង្ការដើម្បីកំនត់សមត្ថភាពសំរបសំរួលដែលមានស្រាប់ និងតំរូវការសំរាប់ការធ្វើឱ្យប្រសើរឡើងសំរាប់ប្រព័ន្ធផ្គត់ផ្គង់ទឹកសមស្រប។ ការផ្គត់ផ្គង់ទឹក និងមន្ទីរពាក់ព័ន្ធត្រូវតែធ្វើការងារជិតស្និទ្ធជាមួយភ្នាក់ងារជាតិ និងអន្តរជាតិសំរាប់ការធានាឱ្យមានទឹកស្អាតសំរាប់ផឹក ចំអិន ជោកគត់ និងសំរាប់សត្វ។

តួនាទីរបស់ PCDM និង DCDM សំរាប់ផ្តល់ទឹកស្អាត អនាម័យកំឡុងពេលទឹកជំនន់

- ជំរុញអង្គការ-ភ្នាក់ងារពាក់ព័ន្ធ ពោលគឺមន្ទីរសុខាភិបាលខេត្តក្រុងនិងមណ្ឌលសុខភាពផ្តល់សេវាសុខភាព តាមរយៈក្រុមចល័តឱ្យទៅជនរងគ្រោះដែលកំពុងរស់នៅក្នុងតំបន់សុវត្ថិភាព។
- ក្រុមសុខាភិបាល និងអនាម័យខេត្ត ត្រូវជួយក្រុមថែទាំសុខភាពស្រុកក្នុងការលើកកំពស់ការយល់ដឹង របស់ប្រជាជនក្នុងមូលដ្ឋានអំពីការថែទាំសុខភាពនិងអនាម័យជាមូលដ្ឋាន។
- ក្រុមសុខភាពនិងអនាម័យមកពីខេត្ត-ស្រុក ត្រូវធ្វើការប៉ាន់ប្រមាណជាមូលដ្ឋានអំពីឥទ្ធិពលលើសុខភាព និងការឆ្លងជំងឺនៅក្នុងតំបន់លិចទឹក។
- ក្រុមសុខភាពនិងអនាម័យស្រុកត្រូវរាយការណ៍ជាទ្សៀងទាត់អំពីស្ថានភាពសុខភាពទូទៅ អនាម័យ និងទឹកស្អាតនៅក្នុងតំបន់លិចទឹក ជូនទៅមន្ទីរសុខាភិបាលខេត្ត ក្រសួងសុខាភិបាល និងអង្គការពាក់ព័ន្ធ។
- កុមសុខភាពនិងអនាម័យខេត្ត និងមន្ទីរសុខាភិបាលខេត្ត ត្រូវតែស្នើសុំជំនួយបន្ថែមពីក្រសួងសុខាភិបាល នៅពេលចាំបាច់។
- DCDM ត្រូវតែធ្វើការជាមួយអាជ្ញាធរមូលដ្ឋានដើម្បីស៊ើបអង្កេតស្ថានភាពសុខភាព ជំងឺឆ្លង និងជំងឺរាត ត្បាតដែលទាក់ទងនឹងអានាម័យ និងនៅក្នុងតំបន់របស់ខ្លួន។

ការប្រើប្រាស់ទឹក ឬការឆ្លងជំងឺពីទឹក គឺគ្រោះថ្នាក់ដល់សុខភាព ដែលបណ្តាលមកពីទឹក។ ទឹកមានមេរោគកើតឡើងដោយសារមូលហេតុផ្សេងៗ។ ការផ្គត់ផ្គង់ទឹកស្អាតតែងតែមានមេរោគ ឧទាហរណ៍នៅពេល ទឹកជំនន់ហូរមកពីប្រព័ន្ធលូទឹកស្អុយ តំបន់កសិកម្ម និងអនុផលនានា។ បន្ថែមលើនេះទំនងជាមានមេរោគពីខ្លួនហូរចូលទៅក្នុងទឹកស្អាត។ បើទោះជាស្បែកប៉ះពាល់ជាមួយទឹកជំនន់មិនមានគ្រោះថ្នាក់ដល់សុខភាព ធ្ងន់ធ្ងរក្តីក៏មានគ្រោះថ្នាក់ ដែលក្លាយជាឈឺដោយសារការបរិភោគអ្វីមួយដែលមានមេរោគពីទឹកជំនន់ដែរ។ ការថែទាំត្រឹមត្រូវ ត្រូវតែបូមទឹកដែលមានមេរោគនោះចេញហើយបើវាបណ្តាលអោយមានជំងឺឆ្លង ត្រូវរកពេទ្យមកព្យាបាលជាបន្ទាន់។

ដូច្នេះការពិចារណាសំខាន់ៗក្នុងការធ្វើផែនការសំរាប់ការផ្គត់ផ្គង់ទឹកស្អាត គឺ :

- ការធានាផ្គត់ផ្គង់ទឹកហូបក្នុងជំរុំសង្គ្រោះ តំបន់សុវត្ថិភាព និងប្រជាជនដែលនៅតាមផ្ទះផ្ទាល់ខ្លួនក្នុងអំឡុងពេលគ្រោះអាសន្ន។
- ការស្តារប្រព័ន្ធផ្គត់ផ្គង់ទឹកឡើងវិញ ដូចជា អណ្តូងស្នប់ ឧបករណ៍ស្តុកទឹក និងប្រព័ន្ធផ្គត់ផ្គង់ទឹកជ្រៅក្នុងដំណាក់កាលស្តារឡើងវិញ។

អនាម័យគឺជាចំណុចសំខាន់ក្នុងការគ្រប់គ្រងគ្រោះអាសន្ន។ អាជ្ញាធរខេត្ត-ក្រុង ដែលមានការជួយពីក្រុមអ្នកស្ម័គ្រចិត្តមូលដ្ឋាន ត្រូវតែធានាបរិក្ខាអនាម័យល្អប្រសើរនៅតាមជំរុំសង្គ្រោះក្នុងតំបន់ និងជំរកសុវត្ថិភាពនិង ផ្តល់បង្គន់សមរម្យ ប្រព័ន្ធបង្ហូរទឹក និងប្រដាប់សំលាប់មេរោគធ្វើឱ្យតំបន់ស្អាត។

ការរាតត្បាតនៃជំងឺឆ្លងក្រោយពេលការកើតឡើងរបស់មុខសញ្ញាគ្រោះថ្នាក់នានា ឧទាហរណ៍: ទឹកជំនន់គឺមិនធម្មតា ដូច្នេះត្រូវយកចិត្តទុកដាក់ចំពោះលទ្ធភាពដែលអាចកើតឡើងដោយសារតែបរិក្ខាអនាម័យខូចខាត ឬភាពចង្អៀតក្នុងចំណោមប្រជាជនផ្ទាស់ទីជំរក ឬតំបន់សុវត្ថិភាព។ ថ្នាំពេទ្យសំរាប់គ្រាអាសន្នត្រូវរក្សាទុកជាស្រេចនៅតាមមណ្ឌលសុខភាព និងអនុសាសន៍ជាក់លាក់សំរាប់ការចាក់ថ្នាំបង្ការត្រូវតែមានតាមករណី ឬបានកំនត់ដោយមន្ទីរសុខាភិបាលខេត្ត និងមូលដ្ឋាន។

បន្ថែមលើនេះ សុខភាពរាងកាយ ផែនការស្តីពីការផ្តល់ការថែទាំនិងគាំទ្រផ្លូវចិត្តដល់ប្រជាជនរងគ្រោះ (ជាពិសេស កុមារ) ត្រូវតែគិតគូរ ។

VII. ការធ្វើផែនការជីវភាពរស់នៅ

ដើម្បីធ្វើអោយផលប៉ះពាល់បណ្តាលមកពីមុខសញ្ញាគ្រោះថ្នាក់ មានកំរិតតិចបំផុតទៅលើសកម្មភាព រកចំណូលរបស់សហគមន៍ ការគ្រប់គ្រងមុនត្រូវតែធ្វើឡើងដើម្បីធានាឱ្យមានជំរើសសំរាប់ជីវភាពរស់នៅក្នុងកំឡុងពេលនៃការកើតឡើង នៃមុខសញ្ញាគ្រោះថ្នាក់ ឧទាហរណ៍: ទឹកជំនន់ និងដើម្បីសំរបសំរួល ការស្តារសេដ្ឋកិច្ច រហ័សឡើងវិញក្រោយពេលនៃការកើតឡើងនៃមុខសញ្ញាគ្រោះថ្នាក់(ការផ្តល់លទ្ធភាពក្នុងការប្រកបមុខរបរ មុនពេល និងក្រោយពេលមុខសញ្ញាកើតឡើង) ។ ការណ៍នេះមានសារៈសំខាន់បំផុត ជាពិសេសក្នុងករណីដែលមុខសញ្ញាគ្រោះថ្នាក់កើតឡើងក្នុងរយៈពេលវែងខុសពីធម្មតា ។ ភ្នាក់ងារសំខាន់ៗដែលត្រូវដឹកនាំដំណើរការនេះ គឺសហគន៍មូលដ្ឋាន ដូចជា ក្រុមកសិករ ឬសមាគមន៍អ្នកនេសាទដែលកំពុង ធ្វើការនៅក្នុងតំបន់ និងសហការជាមួយនឹងប្រជាជនមូលដ្ឋាន និងស្ថានភាពរស់នៅរបស់ពួកគេ ។ វិធីសាស្ត្រដែលមានការចូលរួមមានសារៈសំខាន់ចាប់ពីពេលចាប់ផ្តើមដំណើរការដើម្បីធានាថា អ្នកទទួលការគ្រប់គ្រងតាមផែនការមានសំលេងលើបញ្ហា ដែលកើតមានចំពោះជីវិតរបស់ពួកគេ ។

ទាក់ទិននឹងអាជ្ញាធរមូលដ្ឋាន និងសហគមន៍ អង្គការមូលដ្ឋានអាចគូសផែនទី និងអនុវត្តសកម្មភាពខុសៗពីគ្នាដូចបានចែងនៅខាងក្រោម :

- ការកាប់រានដីដាំដំណាំ ជាពិសេស នៅលើដីខ្ពស់
- ការបង្កើតធានាគារស្រូវ និងគ្រាប់ធញ្ញជាតិ
- តំរូវការរបរនេសាទ(គ្រួសារដែលរស់នៅក្នុងផ្ទះសង់ផុតពីទឹកអាចធ្វើនេសាទកំឡុងពេលទឹកឡើង)
- ការផ្តល់ការបណ្តុះបណ្តាលអំពីរបៀបធ្វើសិប្បកម្មសំរាប់ស្ត្រី និងសមាជិកសហគមន៍ដែលមានរបួសផ្លូវចិត្ត ឱ្យមានជំរើសរកចំណូលកំឡុងពេលនៃការកើតឡើងនៃមុខសញ្ញាគ្រោះថ្នាក់ ឧទាហរណ៍: ទឹកជំនន់ ។
- បង្កើតថវិកាសំរាប់កសិកម្មនៅនៅក្នុងសហគមន៍ ។
- ការរៀបចំសួនដាំបន្លែ ។
- ការផ្តួចផ្តើមគំនិតពិភាក្សាជាមួយទីប្រជុំជន ឃុំ ភូមិ សំរាប់បង្កើតការទទួលបានទីផ្សារនៅក្នុងតំបន់របស់ពួកគេដើម្បីលក់ផលិតផល ។
- បង្កើតក្រុមស្តារឡើងវិញសេដ្ឋកិច្ចសហគមន៍ និងផែនការស្តារជីវភាពសហគមន៍រហ័ស ។
- ការត្រៀមប្រតិទិនរដូវដាំដុះផ្អែកលើព្រឹត្តិការណ៍ជាប្រវត្តិសាស្ត្រ និងការព្យាករណ៍ថ្មីៗ ។

ស្ថាប័នរដ្ឋពាក់ព័ន្ធអាចដើរតួជាទីប្រឹក្សាសំខាន់ក្នុងការធ្វើផែនការនិងអនុវត្តសកម្មភាពតាំងនេះ ។ ឧទាហរណ៏: មន្ទីរកសិកម្ម អាចជួយផ្តល់ការណែនាំក្នុងការរៀបចំប្រតិទិនរដូវដាំដុះរួមគ្នាជាមួយមន្ទីរគ្រប់គ្រងធនធានទឹក រីឯមន្ទីរកិច្ចការនារី និងសង្គមកិច្ច អាចផ្តល់ការបណ្តុះបណ្តាលជំនាញល្អប្រសើរសំរាប់ប្រជាជនមូលដ្ឋាន ។

VIII. លំហាត់ "ហ្វឹកហ្វឹន Drills" និងសមយុទ្ធ "ធ្វើត្រាប់ Mock"

លំហាត់ ហ្វឹកហ្វឹន និង សមយុទ្ធធ្វើត្រាប់ បំរើគោលបំនងលើកកំពស់ការយល់ដឹងរបស់សហគមន៍ និងកសាងសមត្ថភាពត្រៀមបង្ការនៅតាមមូលដ្ឋាន។ ត្រូវបង្កើតស៊ីណារីយ៉ូសប្បនិមិត្តស្រដៀងគ្នានឹងស្ថានភាពពិត និងហាត់ធ្វើសមយុទ្ធដើម្បីបង្ហាញបច្ចេកទេសដែលប្រជាជនអាចត្រៀមបង្ការដោយខ្លួនឯងបានល្អបំផុតទប់ទល់នឹងមុខសញ្ញាគ្រោះថ្នាក់ណាមួយ។ លំហាត់ទាំងនេះកសាងជំនាញពិសេសរបស់សហគមន៍ ដូចជា :

- ការជំលៀសពេលគ្រោះអាសន្ន
- ការទទួលស្គាល់ ការស្វែងយល់ ការឆ្លើយតប និងការប្រកាសអាសន្នសមស្របនិងត្រៀមរួចជាស្រេចដែលមាននៅតាម មូលដ្ឋានអំឡុងពេលមានគ្រោះអាសន្ន។
- ដឹងច្បាស់អំពីតំបន់សុវត្ថិភាព-មណ្ឌលជំលៀស និងផ្លូវដែលមាន។
- បង្កើតឱ្យមានការស្ម័គ្រចិត្ត។

លំហាត់ Drills និង សមយុទ្ធ Mock របស់ក្រុមគ្រប់គ្រងគ្រោះអាសន្នជាក់លាក់ ត្រូវបានអនុវត្តនៅក្នុងព្រឹត្តិការណ៍សាធារណៈសំរាប់ឱ្យសាធារណៈជនមើល សំរាប់ការលើកទឹកចិត្ត និងការយល់ដឹងរបស់សាធារណៈជន ទូទៅ។

មេរៀនទី ៣: ការយល់ដឹងជាសាធារណៈ

I. គោលបំណង

នៅចុងបញ្ចប់មេរៀននេះ សិក្ខាកាមនឹងអាច :

- បែងចែកបានរវាងការផ្សព្វផ្សាយការយល់ដឹងជាសាធារណៈ និង ការស្វែងការគាំទ្រ
- កំនត់បាននូវលក្ខណៈនៃការផ្សព្វផ្សាយការយល់ដឹងជាសាធារណៈ
- បង្កើតបាននូវជំហានសំខាន់ៗសំរាប់រៀបចំផែនការផ្សព្វផ្សាយការយល់ដឹងជាសាធារណៈ

II. ខ្លឹមសារមេរៀន

១. និយមន័យ

ការយល់ដឹងជាសាធារណៈ គឺជាដំណើការមួយដែលប្រជាជនរស់នៅក្នុងតំបន់ប្រឈមនឹង មុខសញ្ញាគ្រោះថ្នាក់ត្រូវតែដឹងអំពីគ្រោះថ្នាក់ជាក់លាក់ដែលបណ្តាលមកពីមុខសញ្ញាគ្រោះថ្នាក់នានា។ វាជាការអប់រំ ការជូនដំណឹង និងការប្រកាសភាពអាសន្នដល់សហគមន៍អំពីគ្រោះអាសន្ន និងការជួយពួកគេឱ្យត្រៀមរៀបចំឱ្យបានល្អប្រសើរ សំរាប់ឆ្លើយតបនឹងស្ថានភាពគ្រោះអាសន្នដែលនឹងកើតឡើងដោយពឹងផ្អែកតិចតួចលើជំនួយ ឬអន្តរាគមន៍ពីខាងក្រៅ តាមរយៈវិធានការ សមស្រប ដើម្បីបង្ការការបាត់បង់អាយុជីវិតមនុស្ស និង ការខូចខាត ទ្រព្យសម្បត្តិជាអប្បរមា។ គោលបំណងនៃការលើក កំពស់ការយល់ដឹងជាសាធារណៈ គឺត្រូវ :

- បង្កើនចំណេះដឹងសាធារណជនអំពី លក្ខណៈ ផលវិបាក និង ឥទ្ធិពលរបស់មុខសញ្ញាគ្រោះថ្នាក់ ដែលអាចមាន។
- ធ្វើឱ្យចំណេះដឹងសាធារណជន អំពីវិធានការកាត់បន្ថយគ្រោះថ្នាក់ជាក់ស្តែងមានភាពល្អប្រសើរឡើងនៅតាមផ្ទះ ដែលសហគមន៍អាចអនុវត្តដោយខ្លួនឯង។
- ជូនដំណឹងអំពីប្រព័ន្ធប្រកាសដឹងមុនគ្រោះមហន្តរាយ និងមធ្យោបាយទំនាក់ទំនងផ្សេងៗដើម្បីទទួលសញ្ញាប្រកាសអាសន្ន និងព័ត៌មាននានា ។
- ផ្សព្វផ្សាយព័ត៌មានអំពីកម្មវិធីត្រៀមរៀបរបស់អាជ្ញាធរគ្រប់គ្រងគ្រោះមហន្តរាយខេត្ត និងស្រុក រួមទាំង ផែនការត្រៀមរៀបចំសម្រាប់គ្រោះមហន្តរាយ និងក្បៀវគរការគាំទ្រសំរាប់សកម្មភាព សហការ ឆ្លើយតប ។
- ជាដំណើរការដែលប្រជាជនងាយរងគ្រោះអាចយល់ដឹងបានពីលក្ខណៈនៃមុខសញ្ញាគ្រោះថ្នាក់ និងសក្តានុពលដែលមុខសញ្ញាទាំងអស់នោះក្លាយទៅជាគ្រោះមហន្តរាយ
- ជាការបែងចែកផ្សព្វផ្សាយពត៌មានដែលមានលក្ខណៈជាប្រព័ន្ធពីមុខសញ្ញាគ្រោះថ្នាក់ និងការគំរាមកំហែង ដែលប្រជាជនអាចធ្វើបានចំពោះមុខសញ្ញាថ្នាក់ទាំងនោះ ដើម្បីជំរុញឱ្យប្រជាជនឆ្លើយតបបានទៅនឹងព្រឹត្តិការណ៍ ដើម្បីការពារ អាយុជីវិត និង ទ្រព្យសម្បត្តិរបស់គេ។
- ជាដំណើរការដែលប្រជាជនរស់នៅតំបន់ប្រឈមមុខនឹងមុខសញ្ញាគ្រោះថ្នាក់ មានការយល់ដឹងថា គេកំពុងប្រឈមមុខនឹងគ្រោះภัยនិងដឹងពីគ្រោះថ្នាក់ជាក់លាក់ដែលគេកំពុងប្រឈមមុខ ព្រមទាំងផ្តល់ព័ត៌មានជាមុនពីវិធានការសមស្រប ដែលអាចធ្វើបានសំរាប់ការពារអាយុជីវិត និង កាត់បន្ថយការខូចខាតទ្រព្យសម្បត្តិរបស់គេបាន។

២. គោលបំណងនៃការផ្សព្វផ្សាយការយល់ដឹងជាសាធារណៈ:

- លើកកំពស់ចំណេះដឹង និងការយល់ដឹងជាសាធារណៈអំពីមុខសញ្ញាគ្រោះថ្នាក់លក្ខណៈ និងផលវិបាកនានាដែលអាចកើតមានឡើង
- លើកកំពស់ចំណេះដឹងអំពីវិធានការត្រៀមបង្ការដែលអាចអនុវត្តបាន
- ផ្តល់ព័ត៌មានដល់សាធារណជនអំពីប្រព័ន្ធផ្តល់ពត៌មានជាមុនដែលនឹងត្រូវផ្តល់អោយ ព្រមទាំងវិធានការដែលត្រូវធ្វើនៅពេលគេទទួលបាននូវការផ្តល់ពត៌មានជាមុន
- បង្កើនចំណេះដឹងអំពីរបៀបឆ្លើយតបទៅនឹងស្ថានភាពគ្រោះអាសន្ន
- ស្វែងរកការគាំទ្រសំរាប់ផែនការកាត់បន្ថយគ្រោះภัยនៃគ្រោះមហន្តរាយ និង សកម្មภาพ ឆ្លើយតប ។

៣. លក្ខណៈនៃការផ្សព្វផ្សាយការយល់ដឹងជាសាធារណៈ:

- **ជាដំណើរការដែលត្រូវធ្វើជាបន្តបន្ទាប់:** ការផ្សព្វផ្សាយបង្កើនការយល់ដឹងជាសាធារណៈ ជាដំណើរការដែលត្រូវធ្វើជាបន្តបន្ទាប់ ដែលវាមិនមែនគ្រាន់តែជាការផលិតឯកសារផ្សព្វផ្សាយដូចជា ផ្ទាំងរូបภาพ ឬស្បៀវភៅអប់រំតែមួយមុខប៉ុណ្ណោះទេ ។
- **ការចូលរួម:** ក្រុមគោលដៅ គឺជាអ្នកដែលចូលរួមយ៉ាងសកម្ម នៅក្នុងដំណាក់កាលនៃការរៀបចំ និងអនុវត្តកម្មវិធី ព្រមទាំងធ្វើអោយមានការចូលរួមពាក់ព័ន្ធពីអ្នកជំនាញ ផងដែរ ។
- **ចំពោះសហគមន៍ណាមួយជាក់លាក់:** ការប៉ាន់ប្រមាណ និងវាយតំលៃលើមុខសញ្ញាគ្រោះថ្នាក់ណាមួយ គឺជា មូលដ្ឋានសំខាន់នៅក្នុងការរៀបចំកម្មវិធី ផ្សព្វផ្សាយបង្កើនការយល់ដឹងជាសាធារណៈ
- **ក្រុមគោលដៅណាមួយជាក់លាក់:** ត្រូវតែផ្អែកទៅតាមសេចក្ដីត្រូវការរបស់អ្នកប្រើប្រាស់ព័ត៌មាន ឬក្រុមណាមួយជាក់លាក់ ដែលមានសារៈសំខាន់ចពោះពួកគេ ឧទាហរណ៍: ស្ត្រី មនុស្សចាស់ ក្មេងៗ ឬ ក្រុមជនជាតិภาคติช ។ល។
- ជាផ្នែកមួយនៃប្រព័ន្ធប្រកាសឱ្យដឹងមុន និង ប្រព័ន្ធឆ្លើយតបគ្រោះអាសន្ន

៤. កត្តាសំខាន់ៗ សំរាប់ធ្វើការកំណត់ចម្រុះបដោយប្រសិទ្ធภาพ

កត្តាសំខាន់ៗនៅក្នុងផ្សព្វផ្សាយបង្កើនការយល់ដឹងជាសាធារណៈ គឺការបង្កើតឡើងតាមមធ្យោបាយមួយដែលវាជាក់លាក់ទៅនឹងប្រភេទ និងទំហំនៃមុខសញ្ញាគ្រោះថ្នាក់នៅក្នុងតំបន់ภูมิศาស្ត្រណាមួយជាក់ស្តែង។ ដើម្បីសំរេចបានលទ្ធផលល្អនៅក្នុងអនុវត្តកម្មវិធីផ្សព្វផ្សាយបង្កើនការយល់ដឹងជាសាធារណៈ សំណួរមួយចំនួន គួរតែគិតពិចារណាដូចជា:

- តើនរណាខ្លះជាប្រជាជនគោលដៅ(សាធារណជនទូទៅឬក្រុមគោលដៅជាក់លាក់)?
- តើត្រូវផ្សព្វផ្សាយសារអ្វីខ្លះ(ការយល់ដឹងអំពីទឹកជំនន់ ឬ សារជាក់លាក់ផ្សេងទៀត ដូចជាសុខภาพ ជំរក)?
- តើត្រូវប្រើវិធីសាស្ត្រទំនាក់ទំនងប្រភេទអ្វីសំរាប់ការផ្សព្វផ្សាយសារ (ប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន ប្រព័ន្ធផ្សព្វផ្សាយព័ត៌មានបោះពុម្ព សកម្មภาพสหคมน์)?
- តើត្រូវធ្វើយុទ្ធនាការនៅពេណា?
- តើនរណានឹងរៀបចំធ្វើយុទ្ធនាការ (អាជ្ញាធរខេត្ត-ស្រុកដោយសហការជាមួយសមាជិកមន្ទីររបស់ខ្លួន ឬជា មួយអង្គការ ឬសហការជាមួយភ្នាក់ងារដែលបានលើកឡើងខាងលើ)?

ដោយសារតែយុទ្ធនាការ និងកម្មវិធីលើកកំពស់ការយល់ដឹងភាគច្រើនបំពេញបំណងសាធារណៈជនក็ដោយវាត្រូវតែធានាថា សារងាយយល់ (ទោះជាលាយលក្ខ័អក្សរ ឬក្រាហ្វិក ក្តី) នៅពេលផ្សព្វផ្សាយ។ វាត្រូវចងចាំថា មនុស្សខ្លះមិនអាចទទួលព័ត៌មានបានពីទូរទស្សន៍ វិទ្យុ។ល។ ទេ ហើយមនុស្សខ្លះមិនចេះអានអក្សរ។ ដូច្នេះ គួរតែប្រើវិធីសាស្ត្ររួមផ្សំ ដើម្បីចូលដល់ក្រុមមនុស្សដែលមិនអាចទទួលព័ត៌មានបាន។

ខាងក្រោមនេះ គឺជាកត្តាគន្លឹះសំរាប់ធានាធ្វើអោយការផ្សព្វផ្សាយបង្កើនការយល់ដឹងប្រកបដោយប្រសិទ្ធភាព និងទទួលបានជោគជ័យ:

- **ការជឿទុកចិត្ត:** អ្នកទទួលព័ត៌មានត្រូវតែមានជំនឿទុកចិត្តចំពោះប្រភពព័ត៌មាន។ បញ្ហានេះវាចាំបាច់ណាស់ ដែលត្រូវធ្វើអោយមានជំនឿរវាងអ្នកផ្តល់ពត៌មាន និង អ្នកទទួលពត៌មាន។
- **បរិបទ:** វាជាផ្នែកមួយនៃបរិយាកាសរបស់អ្នកទទួលពត៌មាន ដើម្បីអាចអោយខ្លួនគេមានទំនាក់ទំនងទៅនឹងពត៌មានដែលគេផ្តល់ឱ្យ ឧទាហរណ៍: ធ្វើឱ្យឯកសារផ្សព្វផ្សាយ មានលក្ខណៈសមស្របទៅនឹងស្ថានភាពរបស់មូលដ្ឋាន និងងាយយល់។ ប្រជាជននឹងឆ្លើយតបបានយ៉ាងមានប្រសិទ្ធិភាព ប្រសិនបើគេយល់បានថា គេប្រឈមមុខនឹង គ្រោះภัយ។
- **ខ្លឹមសារ:** ខ្លឹមសារនៃព័ត៌មានត្រូវតែមានន័យសំរាប់អ្នកទទួលព័ត៌មាន។ ខ្លឹមសារនៃពត៌មាន ត្រូវតែស៊ីចង្វាក់គ្នានឹងបរិបទរបស់អ្នកទទួល ព្រមទាំងមានទំនាក់ទំនងនឹងបញ្ហាដែលគេធ្លាប់ជួបប្រទះ។ វាត្រូវមានការពិតជាក់ស្តែងអំពីមុខសញ្ញាគ្រោះថ្នាក់ និងបទពិសោធន៍របស់មនុស្ស ប្រសើរជាផ្អែកតែទៅលើស្ថិតិ ឬទិន្នន័យណាមួយ។
- **ភាពច្បាស់លាស់:** វាត្រូវតែជាពាក្យពេចន៍ងាយស្រួលយល់។ ការប្រើប្រាស់ពាក្យពេចន៍នៅក្នុងការ ផ្តល់ពត៌មាន និងការរៀបចំឯកសារផ្សព្វផ្សាយ ត្រូវតែឱ្យមានលក្ខណៈងាយយល់បាន និង ងាយយកទៅអនុវត្ត។
- **និរន្តរភាព និង ភាពមិនប្រែប្រួល:** ព័ត៌មាន ឬ សារត្រូវតែមានលក្ខណៈដូចគ្នា រវាងព័ត៌មានមួយទៅព័ត៌មានមួយផ្សេងទៀត។ ការប្រើព័ត៌មាន ឬសារដូចៗគ្នា វាជាការជួយក្នុងការបង្កើនការចាប់អារម្មណ៍ និងជៀសវាងបាននូវការយល់ច្រលំផងដែរ។
- **បណ្តាញ ឬ ប្រព័ន្ធផ្សព្វផ្សាយ:** បណ្តាញ ឬប្រព័ន្ធផ្សព្វផ្សាយដែលបានរៀបចំឡើង ត្រូវតែប្រើប្រព័ន្ធ ឬបណ្តាញណាមួយជាក់លាក់ដែលមានជំនឿទុកចិត្តដោយអតិថិជន។
- **សមត្ថភាព:** ត្រូវយកចិត្តទុកដាក់លើកត្តានានាដូចជា ឥរិយាបថរបស់អ្នកទទួលព័ត៌មាន កំរិតនៃការយល់ដឹងនិងចំណេះដឹងជាដើម។ ឧទាហរណ៍: ភាសាដែលប្រើប្រាស់នៅពត៌មាន ឬនៅក្នុងឯកសារផ្សព្វផ្សាយត្រូវជាភាសាដែលក្រុមគោលដៅអាចយល់បានយ៉ាងងាយ។
- **ការឆ្លុះប្រឌិត:** ពត៌មាន សារ ឬឯកសារផ្សព្វផ្សាយផ្ទាំងរូបភាព ត្រូវតែមានលក្ខណៈទាក់ទាញការចាប់ អារម្មណ៍របស់សាធារណៈជន។ ការប្រើប្រាស់រូបភាព ឬ ក្រាហ្វិចណាដែលងាយស្រួលយល់ និង ងាយស្រួលប្រែក្លាយទៅជាសកម្មភាពជាក់ស្តែង។

៥. មធ្យោបាយសំរាប់ផ្សព្វផ្សាយលើកកំពស់ការយល់ដឹងជាសាធារណៈ:

- ការប្រជុំសហគមន៍
- ក្រុមពិភាក្សានៅតាមសហគមន៍

- បិទផ្ទាំងរូបភាព ឬ ព្រឹត្តិបត្តិព័ត៌មាន
- សំដែងសិល្ប:
- ចែកចាយឯកសារផ្សព្វផ្សាយ មេរៀន ស្បៀវភៅអប់រំ ។ល។
- រៀបចំវេទិកានានា
- ផ្សព្វផ្សាយព័ត៌មាន សារព័ត៌មានជាតិ សារព័ត៌មានក្នុងស្រុក ផ្សព្វផ្សាយតាមវិទ្យុ ឬ ទូរទស្សន៍
- ការផ្ញែងសុន្ទរកថានៅទីសាធារណ: ឬ បោះពុម្ពផ្សព្វផ្សាយអត្ថបទនានា
- ការបញ្ជាំងភាពយន្តអប់រំ ការតាំងពិពណ៌រូបភាព
- កម្មវិធីផ្សាយតាមវិទ្យុខ្លីៗ
- កម្មវិធីតម្រង់ទិសពីសហគមន៍ ដូចជា: ការសំដែងតាមដងផ្លូវ ការចែកខិតប័ណ្ណ យុទ្ធនាការនៅ តាមផ្ទះនិង កម្មវិធីតាមសាលារៀន ។

៦. ភ្ជាន ១ និងការទទួលខុសត្រូវសំខាន់ៗក្នុងការផ្សព្វផ្សាយលើកកំពស់ការយល់ដឹងជាសាធារណ:

នៅតាមថ្នាក់ខេត្ត និងស្រុក អ្នកពាក់ព័ន្ធទាំងអស់ដូចជា អ្នកដឹកនាំសហគមន៍ អង្គការប្រព័ន្ធផ្សព្វផ្សាយ ក្នុងស្រុក គ្រូបង្រៀន អ្នកអនុវត្តការគ្រប់គ្រងគ្រោះមហន្តរាយ និងសហគមន៍ ត្រូវតែចូលរួមនៅក្នុងការបង្កើត និងអនុវត្តសកម្មភាពលើកកំពស់ការយល់ដឹងពីគ្រោះមហន្តរាយ ។ គណ:កម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយខេត្ត និងស្រុក គួរតែសហការជាមួយមន្ទីរពាក់ព័ន្ធដូចជា មន្ទីរព័ត៌មាន មន្ទីរអប់រំយុវជន និងកីឡា មន្ទីរវប្បធម៌ និងវិចិត្រសិល្ប:ជាដើម ។ វាបំរើគោលបំណងពីរយ៉ាងអំពីការលើកកំពស់ ការចូលរួមធំទូលាយរបស់មន្ទីរពាក់ព័ន្ធ ដែលជាទូទៅមិនចូលរួមសកម្មក្នុងមុខងារកាត់បន្ថយគ្រោះមហន្តរាយ ហើយក្នុងពេលដំណាលគ្នានេះ បង្កើនប្រភពធនធានសំរាប់ត្រៀមបង្ការគ្រោះមហន្តរាយ ។ ក្នុងនាមជាភ្នាក់ងារសំរបសំរួល គណ:កម្មាធការគ្រប់គ្រងគ្រោះមហន្តរាយអាចដើរតួនាទីដូចតទៅ:

- បង្កើតយុទ្ធសាស្ត្រផ្សព្វផ្សាយបង្កើនការយល់ដឹងជាសាធារណ:អំពីមុខសញ្ញាគ្រោះថ្នាក់របស់ខេត្ត ឬស្រុក ដែលមានការចូលរួមពីមន្ទីរ និង ភ្នាក់ងារពាក់ព័ន្ធ ។
- ពិគ្រោះយោបល់ជាមួយក្រុមអ្នកស្ម័គ្រចិត្ត អង្គការ(ជាតិ និង អន្តរជាតិ) និងពិភាក្សាយុទ្ធសាស្ត្រ សំរាប់ផ្សព្វផ្សាយឱ្យមានការទំនាក់ទំនងល្អប្រសើរ (ទៅនឹងកម្មវិធីរបស់អង្គការដែលមានស្រាប់) និងការគ្របដណ្ដប់ភូមិសាស្ត្រ និងកំរិតធនធានពីគំរោងដែលកំពុងដំណើរការបន្ត្ររបស់ ផ្នែកក្រៅរដ្ឋាភិបាល ។
- បង្កើតក្រុម ហើយបណ្ដុះបណ្ដាលពួកគេឱ្យបង្កើត និង អនុវត្តយុទ្ធនាផ្សព្វផ្សាយបង្កើន ការយល់ដឹងជាសាធារណ: ។
- អនុវត្តការធ្វើអន្តរាគមន៍សាកល្បងដូចជា ការដាក់ឱ្យប្រើប្រាស់សប្ដាហ៍ត្រៀមបង្ការគ្រោះមហន្តរាយ ការរៀបចំការប្រគួតប្រជែងសិល្ប:តាមកម្រងបញ្ហា តែងសេចក្ដី ស្ដីពីគ្រោះមហន្តរាយនៅតាមសាលា យុទ្ធនាការ និងការប្រជុំ ជាសាធារណ: ។

គណ:កម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយខេត្ត ឬស្រុកតែឯង មិនអាចធានាការយល់ដឹងទូលំទូលាយអំពីគ្រោះមហន្តរាយបានទេ ។ ដូច្នេះការខិតខំប្រឹងប្រែងសហការគួរតែធ្វើឡើងដើម្បីឱ្យមានការប្រជុំរួមគ្នា ជាមួយអ្នកពាក់ព័ន្ធ អង្គការសង្គមស៊ីវិល អង្គការក្រៅរដ្ឋាភិបាល (ទាំងក្នុងស្រុក និងអន្តរជាតិ) រួមទាំងសាខាកាកបាទក្រហម និងក្រុម អ្នកស្ម័គ្រចិត្តដែលមានមូលដ្ឋាន

នៅក្នុងតំបន់គោលដៅ និងអង្គការធំៗ (ដូចជា: ក្រុមស្ត្រី កសិករ និង សមាគមន៍យុវជន)។ វាគឺជាការសហការមានការធានាគ្រប់គ្រាន់ និងពង្រីកដើម្បីគ្របដណ្ដប់តំបន់ភូមិសាស្ត្រទូលំទូលាយ។ ភាពជាដៃគូរគួរតែធ្វើជាមួយអង្គការពាណិជ្ជកម្មនានា ក្នុងខេត្ត ដូចជា: ក្រុមហ៊ុនពាណិជ្ជកម្ម ស្ថាប័នហិរញ្ញវត្ថុ និងសហគ្រាសឯកជន។ គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយ ឬក្រុមអ្នកស័ក្តិចិត្ត ត្រូវធ្វើការនៅក្នុងតំបន់ជាក់លាក់មួយ ឬធ្វើការយ៉ាងជិតស្និទ្ធិជាមួយសហគមន៍ និងដោយមានទំនាក់ទំនងនិងការយល់ដឹងល្អពីសហគមន៍។ ដូច្នេះការយល់ដឹងដែលបានកើនឡើងនៅក្នុងចំណោមអាជ្ញាធរ និងអ្នកស័ក្តិចិត្ត ដើម្បីកាត់បន្ថយគ្រោះមហន្តរាយ ដោយផ្សារភ្ជាប់ទៅនឹងការអភិវឌ្ឍន៍ថ្មីៗនៅតាមមូលដ្ឋាន គឺជាជំហានពិតប្រាកដមួយឆ្ពោះទៅរកការបង្កើនការយល់ដឹង របស់សហគមន៍ទាំងមូល។

មេរៀនទី ៤: ប្រព័ន្ធប្រកាសឱ្យដឹងមុន (Early Warning System)

I. គោលបំណង

សិក្ខាកាម ឬអ្នកចូលរួមទាំងអស់ នឹងបានយល់ដឹងទូលំទូលាយពីសារៈប្រយោជន៍, លំហូរព័ត៌មាន, សញ្ញាប្រកាសអាសន្ន របៀបកត់ត្រាកំពស់ទឹក និងដាក់តួលេខនៅលើក្ដារខៀន នៃប្រព័ន្ធផ្ដល់ពិតមានជាមុនអំពីទឹកជំនន់នៅថ្នាក់ជាតិ និងសហគមន៍ពិសេសអាចប្រើប្រាស់ និងចូលរួមអនុវត្តសកម្មភាពកាត់បន្ថយផលប៉ះពាល់របស់វា ដើម្បីធ្វើឱ្យសហគមន៍ខ្លួនមានសុវត្ថិភាពខ្ពស់ ។

II. ខ្លឹមសារមេរៀន

១. និយមន័យ

ប្រព័ន្ធប្រកាសឱ្យដឹងជាមុន គឺជាការប្រាប់ ឬ ផ្ដល់ដំណឹងជាមុនដល់ប្រជាជន ដើម្បីអោយដឹងអំពីគ្រោះមហន្តរាយ (ទឹកជំនន់មិនធម្មតា) ដែលអាចកើតឡើងនៅពេលដ៏ខ្លីខាងមុខ ។ ការប្រកាសឱ្យដឹងមុននេះ ជាដំណាក់កាលចាប់ផ្ដើមសំរាប់អោយបុគ្គល ឬប្រជាជន ធ្វើការសំរេចចិត្តចាត់វិធានការឬធ្វើសកម្មភាពផ្សេងៗ ដើម្បីការពារនិងកាត់បន្ថយគ្រោះថ្នាក់ឯ្ទានទាន់ពេលនិងមានប្រសិទ្ធភាព ។

២. សារៈសំខាន់នៃប្រព័ន្ធប្រកាសឱ្យដឹងមុន

ការព្យាករណ៍ និងការប្រកាសឱ្យដឹងមុន គឺជាព័ត៌មានសំខាន់សំរាប់ការប្រតិបត្តិទាន់ពេលវេលារបស់ កម្មវិធីត្រៀមរៀបចំសម្រាប់គ្រោះមហន្តរាយ ជាពិសេសក្នុងការអនុវត្តសកម្មភាពសំខាន់ៗទាន់ពេលវេលាដូចជា ការរើទីលំនៅរបស់ប្រជាជនទៅកាន់តំបន់សុវត្ថិភាព និងការពង្រាយធនធានសំរាប់ធ្វើសកម្មភាពឆ្លើយតបនឹងគ្រោះមហន្តរាយជាដើម ។ ដូច្នេះការបង្កើតប្រព័ន្ធមួយដែលធានា និងសំរបសំរួលចលនាព័ត៌មានសំខាន់ៗក្នុងកំឡុងពេលវិបត្តិ គួរតែជាការត្រៀមរៀបចំមុន ។

ប្រព័ន្ធប្រកាសឱ្យដឹងមុន (EWS) អាចសំរបសំរួលការផ្សព្វផ្សាយព័ត៌មានសំខាន់ៗអំពីស្ថានភាពមុខសញ្ញាគ្រោះថ្នាក់អំពីពេលវេលា និងទីកន្លែង ដែលមុខសញ្ញាគ្រោះថ្នាក់នឹងកើតឡើង ដើម្បីឱ្យការសំរេចចិត្តយកវិធានការការពារទាន់ពេលវេលានិងស្របទៅតាមកំរិតប្រកាសអាសន្នគ្រោះថ្នាក់ដែលដឹង គឺប្រភេទប្រព័ន្ធប្រកាសឱ្យដឹងមុនដែលសាមញ្ញ និងតែងមានប្រសិទ្ធិភាពខ្ពស់ ។

៣. ផ្នែកផ្សេងៗនៃប្រព័ន្ធប្រកាសឱ្យដឹងមុន

ជាទូទៅប្រព័ន្ធប្រកាសឱ្យមុន មាន ៥ ផ្នែកសំខាន់ ១ ដូចតទៅ:

- កំនត់ និង ការព្យាករណ៍ទុកជាមុន ពីមុខសញ្ញាគ្រោះថ្នាក់ដែលអាចកើតមានឡើង
- គណនា និង រៀបចំបង្កើតពត៌មានសំរាប់ធ្វើការផ្ដល់ពត៌មានជាមុន
- ផ្សព្វផ្សាយព័ត៌មានជាមុន
- រៀបចំផែនការសហគមន៍ដើម្បីឆ្លើយតប
- មុខងារចាំបាច់សំរាប់ ការផ្ដល់ព័ត៌មានជាមុនដែលមានប្រសិទ្ធិភាព

៣.១ ការកំនត់ និងការព្យាករណ៍ពីមុខសញ្ញាគ្រោះថ្នាក់

ការកំណត់ និងការព្យាករណ៍ជាមុននូវមុខសញ្ញាគ្រោះថ្នាក់ ប្រាកដជានឹងអាចកាត់បន្ថយការ បាត់បង់អាយុជីវិតមនុស្ស សត្ត និងវិនាសកម្មទ្រព្យសម្បត្តិ។ វាជាទិន្នន័យមូលដ្ឋានសំរាប់ការផ្សព្វផ្សាយ និងផ្តល់ពត៌មានជាមុនពីមុខសញ្ញាគ្រោះថ្នាក់ និងឥទ្ធិពលអាក្រក់ក៏រិតណាមួយ ដែលអាចកើតមាននិងបង្ករការគំរាមកំហែងដល់ប្រជាជន ឬសហគមន៏ ដែលរស់នៅតំបន់ប្រឈមមុខ។ ការកំណត់ និងព្យាករណ៍ជាមុននូវមុខសញ្ញាគ្រោះថ្នាក់តម្រូវឱ្យមានបណ្តាញ ស្ថានីយសង្កេត ចំណេះដឹង និងបច្ចេកទេសផ្នែកជលសាស្ត្រ និងឧតុនិយម។ ទិន្នន័យជលសាស្ត្រ និងអាកាសធាតុ ត្រូវបញ្ជូនយ៉ាងរហ័សទៅ កាន់មជ្ឈមណ្ឌលឧតុនិយមនិងជលសាស្ត្រ ដើម្បីធ្វើការវិភាគ និងបកស្រាយវាឱ្យបានត្រឹមត្រូវ និងទាន់ពេល។

៣.២ ការគណនា ឬរៀបចំពត៌មានសំរាប់ធ្វើការប្រកាសឱ្យដឹងមុន

ក្រោយពីធ្វើការកំណត់ និងធ្វើការព្យាករណ៍លើមុខសញ្ញាគ្រោះថ្នាក់ដោយរួចហើយ មជ្ឈមណ្ឌលឧតុនិយម និង ជលសាស្ត្រ ត្រូវធ្វើការវិភាគពត៌មានឱ្យសមស្របដើម្បីផ្តល់ និងផ្សព្វផ្សាយ ជូនភ្នាក់ងារដែលមានសមត្ថកិច្ច គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ មន្ទីរធនធានទឹក និងឧតុនិយមថ្នាក់ខេត្ត-ស្រុក និងបណ្តាស្ថាប័នដទៃទៀតដែលពាក់ព័ន្ធ ព្រមទាំង អង្គការជាតិ-អន្តរជាតិ អង្គការថ្នាក់តំបន់ និងភ្នាក់ងារអង្គការសហប្រជាជាតិ ដើម្បីបង្កើនការយកចិត្តទុកដាក់ និងត្រៀម លក្ខណៈឆ្លើយតប និងបន្តផ្សព្វផ្សាយដល់ប្រជាជន និងសហគមន៏ដែលកំពុងប្រឈមមុខនឹងមុខសញ្ញាដែលអាចកើតឡើង។ ព័ត៌មានប្រកាសឱ្យដឹងមានប្រសិទ្ធិភាពត្រូវមានធាតុសំខាន់ៗដូចតទៅ:

- **ទីកន្លែងជ្រាក់លាក់**
  - អាទិភាពចម្បង គឺកន្លែងងាយរងគ្រោះបំផុត និងទីកន្លែងដែលមានប្រជាពលរដ្ឋងាយជួប គ្រោះภัយរស់នៅ។
- **ទិន្នន័យពីមុខសញ្ញារគ្រោះថ្នាក់**
  - ពេលនៃការកំនត់ និងកាលវេលាដែលមាន មុខសញ្ញាគ្រោះថ្នាក់មកដល់
  - នៅពេលណាមុខសញ្ញាគ្រោះថ្នាក់នឹងអាចកើតឡើង
  - រយៈពេលប៉ុន្មានដែលមុខសញ្ញាគ្រោះថ្នាក់ស្ថិតនៅ
  - មុខសញ្ញាគ្រោះថ្នាក់នោះចេញពីណា ហើយឆ្ពោះទៅណា
  - ថាមពល និង ល្បឿននៃមុខសញ្ញាគ្រោះថ្នាក់
- **គ្រោះថ្នាក់ផ្សេងៗទាក់ទងនឹងមុខសញ្ញារគ្រោះថ្នាក់**
  - ប៉ាន់ស្មានតំបន់ ដែលអាចនឹងកើតមាន
  - ចំនួនប្រជាពលរដ្ឋ ស្រុក ភូមិដែលអាចនឹងទទួលផលប៉ះពាល់
  - កត្តាផ្សេងៗដែលប៉ះពាល់ដល់សុវត្ថិភាព

- **សកម្មភាពឆ្លើយតបទៅនឹងគ្រោះថ្នាក់ដែលសមស្របនិងចាំបាច់**
  - សកម្មភាព និង វិធានការឆ្លើយតបនេះ អាស្រ័យទៅលើទំហំ ឥទ្ធិពល ល្បឿន និងមានលក្ខណៈសមស្របនឹងកំរិតប្រកាសអាសន្ន ដែលត្រូវផ្តល់ជាមុន។ សហគមន៍ដែលងាយរងគ្រោះ ត្រូវធ្វើសកម្មភាព និងវិធានការបង្ការសមស្រប ដើម្បីឆ្លើយតប។

៣.៣ ការផ្សព្វផ្សាយព័ត៌មានព្យាករណ៍ និងព័ត៌មានប្រកាសឱ្យដឹងមុន

វាមានសារៈសំខាន់ណាស់ ចំពោះការព្យាករណ៍ និងការប្រកាសឱ្យដឹងមុន មុខសញ្ញាគ្រោះថ្នាក់ ផ្សាយបន្តពីប្រភពមួយដែលគួរឱ្យជឿទុកចិត្ត និងមានការអនុញ្ញាត។ ការប្រកាសឱ្យដឹងមុន ធ្វើឡើងផ្អែកលើការព្យាករណ៍ គួរតែបញ្ជូនទៅទីភ្នាក់ងារគ្រប់គ្រងគ្រោះមហន្តរាយក្នុងស្រុកពាក់ព័ន្ធ ដែលអាចធ្វើការសំរេចចិត្ត និងផ្តួចផ្តើមសកម្មភាពដែលបានកំណត់ក្នុងផែនការត្រៀមរៀបចំជាមុន។

ជោគជ័យនៃការកំណត់ និងការព្យាករណ៍មុខសញ្ញាគ្រោះថ្នាក់ នឹងគ្មានប្រសិទ្ធិភាពឡើយ បើការផ្តល់ព័ត៌មានជាមុនមិនត្រូវបានគេផ្សព្វផ្សាយយ៉ាងឆាប់ទាន់ពេល និងទៀតទាត់ និងផ្តល់ដំណឹងដោយសក្តិសិទ្ធទៅដល់សហគមន៍ប្រឈមមុខនឹងគ្រោះภัย។ ដើម្បីបានជាប្រយោជន៍ដល់សហគមន៍ ការប្រកាសឱ្យដឹងមុន ត្រូវផ្សព្វផ្សាយដល់សហគមន៍ឱ្យទាន់ពេល រំលាហើយងាយយល់។ គ្រោះภัย និងគ្រោះថ្នាក់ទាក់ទងនឹងទឹកជំនន់ ត្រូវតែប្រកាសដោយច្បាស់លាស់។ ធាតុសំខាន់ពីរផ្សំឡើងក្នុងប្រតិបត្តិការផ្សព្វផ្សាយព័ត៌មានជាមុន មាន:

- ***បណ្តាញ និង ប្រព័ន្ធទំនាក់ទំនង***

តម្រូវការប្រព័ន្ធដែលអាចទំនាក់ទំនងបានទូលំទូលាយមាន: វិទ្យុ ទូរទស្សន៍ ស៊ីរ៉ែន និង សំភារៈ ផ្តល់ដំណឹង ផ្សេងៗទៀតរបស់សហគមន៍ គឺជាការចាំបាច់ដើម្បីធានាប្រសិទ្ធិភាពនៃការផ្សព្វផ្សាយពត៌មានព្យាករណ៍ និងព័ត៌មាន ប្រកាសភាពអាសន្នដល់សាធារណជន និងអ្នកគ្រប់គ្រងគ្រោះមហន្តរាយ។ ប្រព័ន្ធប្រកាសឱ្យដឹងមុនរបស់សហគមន៍ មូលដ្ឋាន ដូចជា: ស៊ីរ៉ែន និងឧក្សានសព្ទ គឺមានប្រសិទ្ធភាពណាស់។

- ***បង្កើនការយល់ដឹងឱ្យបានទូលំទូលាយ***

ការផ្សព្វផ្សាយពត៌មានមួយដែលល្អ និងមានប្រសិទ្ធិភាព គឺមិនគ្រាន់តែធ្វើឱ្យវាសមកាលសមវេលាប៉ុណ្ណោះទេ តែវានៅត្រូវឱ្យមានភាពងាយយល់និងទទួលយកបានដោយប្រជាពលរដ្ឋគោលដៅនិងអាជ្ញាធរផងដែរ។ ដូចនេះពួកគាត់នេះហើយដែលត្រូវជឿលើការប្រកាសអាសន្នជាមុនហើយធ្វើសកម្មភាពឆ្លើយតប។ ដើម្បីការផ្សព្វផ្សាយព័ត៌មានជាមុន មានប្រសិទ្ធិភាពបណ្តាលក្នុខ័ណ្ឌខាងក្រោមត្រូវលើកយកមកប្រើប្រាស់:

  - ផ្សព្វផ្សាយដល់សហគមន៍ទាន់ពេលវេលា
  - ពត៌មានត្រូវមានលក្ខណៈងាយយល់ សាមញ្ញ និង អាចប្រើប្រាស់បានដោយសហគមន៍
  - ប្រជាជនត្រូវយល់ដឹងពីមុខសញ្ញាគ្រោះថ្នាក់ដែលគេប្រឈមមុខ

- ប្រជាជនអាចយល់ពីការប្រកាសអាសន្ន ហើយអាចប្រែក្លាយពត៌មានឱ្យទៅជាវិធានការ និងសកម្មภาพឆ្លើយតបសមស្រប។ សញ្ញាសំគាល់ ឬសូរសម្លេងដែលគេស្គាល់ដឹងឮជាសាធារណៈ អាចយកមកប្រើប្រាស់ជាសញ្ញាអាសន្ន (ឧ. ស្គរ ជួង ត្រដោក ។ល។)

តួនាទីរបស់អាជ្ញាធរគ្រប់គ្រងគ្រោះមហន្តរាយ គឺត្រូវសហការជាមួយក្រុមឆ្លើយតប និងភ្នាក់ងារដែលទទួលខុសត្រូវ ចំពោះការចេញផ្សាយប្រកាសឱ្យដឹងមុន និងធានាថា ប្រជាជនដែលកំពុងទទួលបានសារប្រកាសឱ្យដឹងមុនបានទទួលទ្យើងទាត់ និងចេះមានវិធានការសមស្របផ្អែកលើព័ត៌មាន។ នៅតាមថ្នាក់ភូមិ ឬថ្នាក់ទាបជាងភូមិ ក្រុមអ្នកស្ម័គ្រចិត្តអាចជួយផ្សព្វផ្សាយព័ត៌មានបានតាមរយៈឧបករណ៍បំពងសំលេង។

៣.៤ ការឆ្លើយតបរបស់សហគមន៍

វាសំខាន់ត្រង់ថា ប្រជាជនដែលរស់នៅក្នុងតំបន់ប្រឈមមុខនឹងមុខសញ្ញាគ្រោះថ្នាក់ មានការយល់ដឹងគ្រប់គ្រាន់អំពីគ្រោះថ្នាក់ដែលពួកគេប្រឈមមានព័ត៌មានគ្រប់គ្រាន់ ច្បាស់លាស់អាចជឿទុកចិត្តបាន និងទទួលបានពត៌មានទ្យើងទាត់ ដើម្បីគេត្រៀមឆ្លើយតបបានទាន់ពេល និងមានប្រសិទ្ធិភាព។ សហគមន៍ដែលអាចឆ្លើយតបបានល្អ និង មានប្រសិទ្ធិภาพ លុះត្រាតែគេអាច :

- ទទួលបានការផ្តល់ព័ត៌មានជាមុន និង
- មុខសញ្ញាគ្រោះថ្នាក់
- ទទួលពត៌មានទាន់ពេលវេលា
- អាចយល់ពីខ្លឹមសារព័ត៌មានគ្រប់គ្រាន់
- ជឿលើព័ត៌មានដែលទទួលបានមុនមានภัย
- ជឿព័ត៌មានពីមុខសញ្ញាគ្រោះថ្នាក់ថាមានពិតមែន
- យល់ដឹងថាសកម្មภาพអ្វី និងពេលណាត្រូវអនុវត្តលើសកម្មภาพទាំងនោះ
- មានលក្ខណៈត្រៀមជានិច្ចចំពោះមុខសញ្ញាគ្រោះថ្នាក់

វ៉ែបសាយសំខាន់ៗសំរាប់ទទួលបានព័ត៌មានព្យាករណ៍ទឹកជំនន់

- http://ffw.mrcmekong.org/ (គណៈកម្មការទន្លេមេគង្គ)
- http://www.hydrologycambodai.50megs.com/ (Hydro-Met, កម្ពុជា)

៣.៥ តួនាទី និងការទទួលខុសត្រូវរបស់ស្ថាប័ន និងភ្នាក់ងារពាក់ព័ន្ធនៅក្នុងប្រព័ន្ធប្រកាសឱ្យដឹងមុន

មណ្ឌលឧត្តុនិយម និងជលសាស្ត្រជាតិ និងទីភ្នាក់ងារពាក់ព័ន្ធនៅក្នុងប្រទេសកម្ពុជា ជាអ្នកទទួលខុសត្រូវ និងជាអ្នកធ្វើការសំរេចចិត្តបឋមក្នុងការប្រមូល ការបង្កើត ផ្សព្វផ្សាយព័ត៌មានយព្យាករណ៍ និងប្រកាសឱ្យដឹងមុន។ និយាយពីមុខសញ្ញាគ្រោះថ្នាក់ដោយទឹកជំនន់ គណៈកម្មការទន្លេមេគង្គ(MRC) តាមរយៈមជ្ឈមណ្ឌលគ្រប់គ្រង និងកាត់បន្ថយទឹកជំនន់ថ្នាក់តំបន់(RFMMC) ជាអ្នកផលិត និងផ្សព្វផ្សាយពត៌មានព្យាករណ៍ថ្នាក់តំបន់ដល់បណ្តាប្រទេសជាសមាជិករបស់គណៈកម្មការនេះ រួមមាន: ប្រទេសឡាវ កម្ពុជា វ៉ៀតណាម និង ប្រទេសថៃ។ ប្រទេសនីមួយៗ តាមរយៈមជ្ឈមណ្ឌលឧត្តុនិយម និងជលសាស្ត្រជាតិ ជាអ្នកផលិតពត៌មានព្យាករណ៍ និងការប្រកាសឱ្យដឹងមុន សំរាប់ប្រទេសរបស់គេនិមួយៗផ្អែកតាមព័ត៌មានដែល ផ្សព្វផ្សាយដោយគណៈកម្មការទន្លេមេគង្គ

ដើម្បីផ្សព្វផ្សាយបន្តដល់ភ្នាក់ងារសមត្ថកិច្ច ដើម្បីផ្តល់ និងផ្សព្វផ្សាយជូនភ្នាក់ងារ ដែលមានសមត្ថកិច្ច ដូចជា: មន្ទីរធនធានទឹក និងឧតុនិយមថ្នាក់ខេត្ត-ស្រុក និងបណ្តាស្ថាប័នដទៃទៀតដែលពាក់ព័ន្ធ ព្រមទាំងអង្គការជាតិ-អន្តរជាតិ អង្គការថ្នាក់តំបន់ និងភ្នាក់ងារអង្គការសហប្រជាជាតិ ដើម្បីបង្កើនការយកចិត្តទុកដាក់ និងត្រៀមលក្ខណៈឆ្លើយតប និង បន្តផ្សព្វផ្សាយដល់ប្រជាជន និងសហគមន៍ដែលកំពុងប្រឈមមុខនឹងមុខសញ្ញាដែលអាច កើតឡើង។

ឧទាហរណ៍: បណ្តាញជាតិសំរាប់ធ្វើការព្យាករណ៍ និងការប្រកាសឱ្យដឹងមុនពីទឹកជំនន់ នៅកម្ពុជា:



ឧទាហរណ៍: គឺបង្ហាញពីតួនាទី និងការទទួលខុសត្រូវរបស់អ្នកពាក់ព័ន្ធ:

ភាគីទទួលខុសត្រូវ	តួនាទី និង ការទទួលខុសត្រូវ
សហគមន៍	▪ យល់ដឹងអំពីមុខសញ្ញា និងផលប៉ះពាល់របស់វា ដែលគាត់ត្រូវ ប្រឈមមុខ ▪ ចាត់វិធានការ និង សកម្មភាពឆ្លើយតបផ្សេងៗដោយខ្លួនឯង ។
អាជ្ញាធរមូលដ្ឋាន	▪ បង្កលក្ខណៈងាយស្រួលដល់ប្រជាជន ដើម្បីអាចទទួលបានការយល់ដឹងពីមុខសញ្ញាបង្ក គ្រោះថ្នាក់ផ្សេងៗ ដែលពួកគាត់ប្រឈមមុខ ។ ▪ ស្វែងយល់ពីដំបូន្មានមុខសញ្ញាគ្រោះថ្នាក់បានទទួល ។
ស្ថាប័នជាតិ (ក្រសួង និង នាយកដ្ឋាន)	▪ ទទួលខុសត្រូវរៀបចំ និង ផ្តល់ការប្រកាសឱ្យដឹងមុន ទៅតាមមធ្យោបាយសមស្រប និង ទាន់ពេលវេលា ។ ▪ ធានាថាការផ្តល់ព័ត៌មាន និង វិធានការការពារ ត្រូវបានណែនាំដល់សហគមន៍ ឬ ប្រជាជន ដែលងាយរងគ្រោះ ។ ▪ ផ្តល់ជំនួយគាំទ្រដល់អាជ្ញាធរមូលដ្ឋាន ដើម្បីឱ្យគេប្រើប្រាស់ព័ត៌មាន និង រៀបចំវិធានការ ឆ្លើយតបទៅនឹងគ្រោះមហន្តរាយ
វិទ្យាស្ថានប្រចាំតំបន់	▪ ផ្តល់ចំណេះដឹងបច្ចេកទេស ប្រឹក្សា និងបទពិសោធន៍ ដើម្បីគាំទ្រដល់ការខិតខំប្រឹងប្រែង របស់ថ្នាក់ជាតិ ចំពោះប្រទេសមានលក្ខណៈភូមិសាស្ត្រនិងបរិស្ថានរួមគ្នា ។ ▪ ផ្តល់ការផ្សារភ្ជាប់សមត្ថភាពទូលំទូលាយរបស់អន្តរជាតិ ទៅនឹងសេចក្តីត្រូវការដាច់ ដោយឡែកៗ របស់សាមីប្រទេសទាំងឡាយ ។
អង្គការអន្តរជាតិ	▪ លើកស្នូយការផ្លាស់ប្តូរទិន្នន័យ និង ចំណេះដឹងក្នុងចំណោមភ្នាក់ងារគ្នាឯង និង រវាង ស្ថាប័នដែលធ្វើការទាក់ទងនឹងការងារគ្រប់គ្រងគ្រោះមហន្តរាយគ្រប់លំដាប់ថ្នាក់ ។ ▪ ផ្តល់ជំនួយគាំទ្រដល់អាជ្ញាធរជាតិ និងអង្គការដែលទទួលខុសត្រូវអនុវត្តការផ្តល់ពត៌មាន ជាមុន ។

ឧទាហរណ៍: ក៏រិត និងសញ្ញានៃការព្យាករណ៍ និងការប្រកាសឱ្យដឹងមុន

ផ្អែកតាមព័ត៌មានព្យាករណ៍ និងព័ត៌មានប្រកាសភាពអាសន្ន ដែលនាយដ្ឋានជលសាស្ត្រនិងការងារទន្លេ និងគណៈកម្មការទន្លេមេគង្គ បានប្រមូលជាច្រើនឆ្នាំមកហើយពីគ្រប់ស្ថានីយ៍ទាំង៧ដែលបានដាក់នៅតាមដងទន្លេមេគង្គ និងទន្លេសាប ។ ប្រទេសកម្ពុជា បានកំណត់ក៏រិតទឹកនិងសញ្ញាសំរាប់ធ្វើការព្យាករណ៍ និងផ្តល់ពត៌មានជាមុននៅតាមស្ថានីយ៍ទាំង ៧ ដូចខាងក្រោម:

<u>រូបភាពទី ១</u>: កំរិតទឹក**<u>ធម្មតា</u>**: ជាដំណាក់កាលឃ្លាំមើលទឹកជំនន់ដែលមានសភាពធម្មតា



កំពស់ទឹកស្ថិតនៅក្រោមកំរិតផ្តល់ពត៌មានជាមុន (មិនមានគ្រោះថ្នាក់ដោយទឹកជំនន់)

<u>រូបភាពទី ២: កំរិតទឹកត្រូវ ការប្រកាសភាពអាសន្ន :</u>



កំពស់ទឹកស្មើ ឬខ្ពស់ជាងកំរិតនៃការប្រកាសអាសន្ន

លក្ខណៈវិនិច្ឆ័យ	ឈ្មោះស្ថានីយ៍						
	ស្ទឹងត្រែង	ក្រចេះ	កំពង់ចាម	ភ្នំពេញ	អ្នកលឿង	កោះខែល	ព្រៃកក្តាម
ប្រកាសជូនដំណឹងជាមុន							
កំរិតទឹកប្រកាសអាសន្ន	(ម៉ែ ត្រ) ១០.៧	ម៉ែ ត្រ ២២	(ម៉ែ ត្រ) ១៥.២	(ម៉ែ ត្រ ១០.៥	(ម៉ែ ត្រ) ៧.៥	(ម៉ែ ត្រ) ៧.៤	(ម៉ែ ត្រ) ៩.៥

សញ្ញាអោយមានការប្រុងប្រយ័ត្ន : កំពស់ទឹកដល់កំរិតប្រកាសអាសន្នតាមស្ថានីយ៍ណាមួយ

រូបភាពទី ៣ : កំរិតទឹកត្រូវលិចតំបន់ណាមួយ



កំរិតទឹកខ្ពស់ជាងកំរិតប្រកាសអាសន្ន

លក្ខណៈវិនិច្ឆ័យ	ឈ្មោះស្ថានីយ៍						
	ស្ទឹងត្រែង	ក្រចេះ	កំពង់ចាម	ភ្នំពេញ	អ្នកលឿង	កោះខែល	ព្រៃកក្តាម
	ប្រកាសជូនដំណឹងជាមុន						
កំពស់ទឹកត្រូវលិច	ម៉ែត្រ ១២	ម៉ែត្រ ២៣	ម៉ែត្រ ១៦.២	ម៉ែត្រ ១២	ម៉ែត្រ ៨	ម៉ែត្រ ៧.៩	១០ ម

សញ្ញាអោយមានការប្រុងប្រយ័ត្ន : កំពស់ទឹកឡើងខ្ពស់ជាង កំរិតប្រកាសអាសន្នតាមស្ថានីយ៍ណាមួយ

(ប្រភពពិតមាន: គណៈកម្មការទន្លេមេគង្គ)

៤. ទម្រង់បញ្ជូនការប្រកាសឱ្យដឹងមុន

- ការប្រជុំប្រជាជនតាមភូមិ ឬ ក្រុម
- ការប្រាប់ផ្ទាល់មាត់ ឬ តាមរូបភាព
- ផ្ទាំងផ្សព្វផ្សាយ ខិត្តប័ណ្ណ ក្តារខៀនព័ត៌មាន - វិទ្យុ - ទូរទស្សន៍ - ភាពយន្ត ... ជាដើម ។

៥. ចំណុចសំខាន់ៗ មុនចេញផ្សព្វផ្សាយពត៌មានព្យាករណ៍ និងពត៌មានប្រកាសភាពអាសន្ន

វាមានសារៈខាន់ណាស់ ដែលភ្នាក់ងារទទួលខុសត្រូវក្នុងការធ្វើការសំរេចចិត្តមុននឹងចេញផ្សាយពត៌មានព្យាករណ៍ និងព័ត៌មានប្រកាសភាពអាសន្នដល់សាធារណៈជន ។ ខាងក្រោមនេះ គឺជាចំណុចសំខាន់ៗមួយចំនួន ដែលត្រូវពិចារណា:

ជំណាក់កាល	កត្តាដែលមានឥទ្ធិពល
១. *ការទទួល*	- កត្តាបច្ចេកទេស: បណ្តាញទំនាក់ទំនងទន់ខ្សោយ ក្នុងការបញ្ជូន និង ទទួលពត៌មាន ជាមុនរបស់សហគមន៏ ឬ ភាពដាច់ស្រយាលនៃតំបន់ដែលងាយរងគ្រោះ - កត្តាបុគ្គល: ការយល់ដឹងកំរិតទាប និងកាយសម្បទាមិនល្អ (ឧ.មនុស្សពិការ ថ្លង់ ខ្វាក់)
២. *ការយល់ដឹង*	- មានបញ្ហាផ្ទៃកភាសា - ពត៌មានប្រើប្រាស់ភាសាបច្ចេកទេសខ្ពស់ពេក - ខ្វះវត្ថុសំអាង សំរាប់ផ្តល់ពត៌មានដូចជាដើមឈើ អាគារ ស្ពាន ។ល។ -បកស្រាយខុសពីភាពគ្រោះថ្នាក់ដែលអាចកើតឡើង (ប៉ាន់ស្មានលើស ខ្វះ)
៣. *ការជឿ*	- ភាពជឿជាក់ និងភាពស្របច្បាប់នៃប្រភពព័ត៌មាន - ភាពទុកចិត្តរបស់សាធារណជន - ភាពខុសគ្នារវាងខ្លឹមសារនៃការផ្តល់ពត៌ជាមុន និង ការសង្កេតផ្ទាល់ខ្លួននៅមូលដ្ឋាន
៤. *ការសំរេចចិត្ត និង វិធានការ ឬ សកម្មភាព*	- ភាពមិនយល់ លើការណែនាំពីសុវត្ថិភាពបុគ្គល (ច្រកភៀសខ្លួន ទីទួលសុវត្ថិភាព ការតាំង លំនៅដ្ឋាន ឱ្យមានសុវត្ថិភាព...) - ភាពមិនយល់ដឹងពីវិធានការគ្រប់គ្រងគ្រោះមហន្តរាយរបស់អាជ្ញាធរ - ការអនុវត្តយន្តការទប់ស្កាត់ ត្រៀមបង្ការនិងកាត់បន្ថយគ្រោះមហន្តរាយ មិនសមស្រប ។

មេរៀនទី ៥: ការឆ្លើយតបគ្រោះអាសន្ន និងការស្តារឡើងវិញ

ការឆ្លើយតបគ្រោះអាសន្ន គឺការផ្តល់នូវជំនួយ ឬអន្តរាគមន៍ក្នុងអំឡុងពេល ឬពេលបន្ទាន់ ក្រោយមានគ្រោះមហន្តរាយ ដើម្បីការពារជីវិត និងសេចក្តីត្រូវការជាមូលដ្ឋានគ្រប់គ្រាន់របស់ប្រជាជន ដែលរងឥទ្ធិពល។ វាអាច ភ្លាមៗ រយៈពេលខ្លី ឬការពន្យារយៈពេល។

I. ការឆ្លើយតប សង្គ្រោះបន្ទាន់

ប្រសិទ្ធិភាពនៃការឆ្លើយតប សង្គ្រោះបន្ទាន់ គឺស្ថិតនៅលើផ្នែកសំខាន់ៗដូចតទៅនេះ :

- **ការសហការប្រកដោយប្រសិទ្ធភាព**

ការសហការទូលំទូលាយក្នុងចំណោមភ្នាក់ងារទាំងអស់ដែលចូលរួមក្នុងសកម្មភាពឆ្លើយតប ជាកត្តាដែលធ្វើអោយជោគជ័យនៃប្រតិបត្តិការឆ្លើយតបគ្រោះអាសន្នណាមួយ ការអនុវត្តតួនាទី ការទទួលខុសត្រូវបានល្អ និងការបញ្ជៀសបាននូវភាពជាន់គ្នាក្នុងការអនុវត្តតួនាទី និងការទទួលខុសត្រូវ និងការប្រើប្រាស់ធនធាន ដែលមានស្រាប់ប្រកបដោយ ប្រសិទ្ធិភាព។ ដាក់ពង្រាយភ្នាក់ងារ ឬស្ថាប័នសំរបសំរួលស៊ីចង្វាក់គ្នា ជាកត្តាធានាបាននូវជោគជ័យក្នុងការឆ្លើយតបគ្រោះ អាសន្ន។

- **ការគ្រប់គ្រងតស្តុកាមានប្រសិទ្ធភាព**

ចំពោះស្ថានការគ្រោះអាសន្នធំៗ ត្រូវកំនត់ធនធានដែលត្រូវការឱ្យបានឆាប់រហ័សពោលគឺ ក្រុមឆ្លើយតប សំភារៈ និងរបស់ប្រើប្រាស់ព្រមទាំងកៀរគរ និងដឹកជញ្ជូនទៅកន្លែងត្រឹមត្រូវឱ្យ និងទាន់ពេល។ ប្រការពីរយ៉ាង ធ្វើវាឱ្យកើតឡើងគឺ :

- **ការចាំន់ប្រមាណពេលវេលា និងបញ្ជីដាក់ពង្រាយ:** បញ្ជីអាទិភាពមួយនៃធនធានសំភារៈសំខាន់បំផុតធ្វើនៅមុនព្រឹត្តិការណ៍។
- **ការសំរបសំរួលដល់ការធ្វើចលនា:** តំរូវការសេវាកម្មដឹកជញ្ជូន និងការសំរបសំរួលចរន្តដឹកជញ្ជូនធនធាននៅក្នុង និងនៅជុំវិញតំបន់រងគ្រោះប្រើបញ្ជីអាទិភាព ការរាយការណ៍ជាបន្តអំពីចលនាធនធានដែលបានដឹកជញ្ជូនចេញ និងចូលតំបន់រងគ្រោះ ការតាមដានផលប៉ះពាល់មុខសញ្ញាគ្រោះថ្នាក់ ឧទាហរណ៍ទឹកជំនន់លើប្រព័ន្ធ ដឹកជញ្ជូន និងការដោះស្រាយផ្លូវ ឬបញ្ជូនទៅដល់គោលដៅ។

- **ក៏រិតការឆ្លើយតបរបស់សហគមន៍**

សហគមន៍យល់ដឹងអំពីមុខសញ្ញាគ្រោះថ្នាក់ដែលពួកគេប្រឈមមុខ ឧទាហរណ៍ទឹកជំនន់ រាំងស្ងួត ខ្យល់ព្យុះ ជំងឺរាតត្បាតនានា ។ល។ និងវិធាការដែលត្រូវធ្វើបានកាន់តែច្រើន ធ្វើឱ្យឥទ្ធិពលការឆ្លើយតបគ្រោះអាសន្នកាន់តែមានប្រសិទ្ធិភាព។

ការឆ្លើយតបនឹងមុខសញ្ញាគ្រោះថ្នាក់ណាមួយ ឧទាហរណ៍ទឹកជំនន់ ត្រូវធ្វើឡើងដោយកំនត់តួនាទី និងការទទួលខុសត្រូវយ៉ាងច្បាស់លាស់ ដូចបានចែងក្នុងផែនការកាត់បន្ថយគ្រោះภัยនៃគ្រោះមហន្តរាយ ឬផែនការត្រៀមរៀបចំសម្រាប់ គ្រោះមហន្តរាយ និងមានការយល់ដោយអ្នកអនុវត្តសំខាន់ៗដែលនឹងធ្វើវិធានការ ដែលបានកំណត់ឡើងក្នុងពេលគ្រោះអាសន្ន។

ការគ្រប់គ្រងគ្រោះអាសន្ន តំរូវឱ្យមានការសំរបសំរួល និងការសហការគ្នារវាងអ្នកអនុវត្តថ្នាក់ជាតិ ថ្នាក់ខេត្ត ថ្នាក់ស្រុក និងថ្នាក់ឃុំ។ ព័ត៌មានជាមូលដ្ឋានសំខាន់ក្នុងការធ្វើការសំរេចចិត្តលើទំហំឆ្លើយតប និងការដាក់ពង្រាយធនធាន។ ជាញឹកញាប់ប្រព័ន្ធឆ្លើយតបបរាជ័យដោយសារតែកង្វះការយល់ដឹងរវាងអ្នកពាក់ព័ន្ធផ្សេងៗគ្នា និងការសហការរវាង ភ្នាក់ងារឆ្លើយតបធំៗ ដូចជាយោធានិងប៉ូលីស មន្ទីរគ្រប់គ្រងព័ត៌មាននិង គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយមូលដ្ឋាន។

រឿងសំខាន់បំផុត ត្រូវទទួលស្គាល់នៅក្រោមដំណាក់កាលឆ្លើយតប គឺថាការផ្តល់ជំនួយ (ហិរញ្ញវត្ថុ សំភារៈ) ត្រូវតែផ្ទាកនៅពេលណាមួយសមស្រប ដើម្បីបញ្ជៀសអោយបាននូវការពឹងផ្អែកទាំងស្រុងរបស់សាធារណៈជនលើការគាំទ្រពីខាងក្រៅ។

សំណួរដែលត្រូវសួរគឺ :

- តើគួរតែបន្តសកម្មភាពឆ្លើយតបអ្វីខ្លះ?
- តើនរណាគួរតែសំរបសំរួលសកម្មភាពរបស់អង្គការមិនមែនរដ្ឋាភិបាលដែលបន្តធ្វើការងារនៅក្នុងពេលនេះ?
- តើត្រូវមានដំណោះស្រាយអ្វីដើម្បីធ្វើការងារបន្ត?
- តើកម្មវិធីរយៈពេលខ្លីបណ្តោះអាសន្នអាចក្លាយជាការស្តារ និង កសាងឡើងវិញយ៉ាងដូចម្តេច?

សកម្មភាពសំខាន់ៗនៃការឆ្លើយតបទៅនឹងមុខសញ្ញាគ្រោះថ្នាក់ មានពិពិណនានៅខាងក្រោម :

១. ការតាមដានមុខសញ្ញាគ្រោះថ្នាក់

កំឡុងពេលឆ្លើយតបនឹងមុខសញ្ញាគ្រោះថ្នាក់ ស្ថានការណ៍អាសន្ន និងច្របូកច្របល់កើតមាន។ នេះអាចដោះស្រាយបានដោយការបង្កើតប្រព័ន្ធតាមដានការកើតឡើងនៃមុខសញ្ញាគ្រោះថ្នាក់ និងឥទ្ធិពលរបស់វាអោយបានគ្រប់គ្រាន់នៅតាមមូលដ្ឋាន។ ការតាមដានមុខសញ្ញាគ្រោះថ្នាក់ ឧទាហរណ៍: គ្រោះទឹកជំនន់ ធ្វើឡើងចាប់តាំងពីពេលព័ត៌មានទឹកជំនន់សំរាប់ អ្នកគ្រប់គ្រងគ្រោះមហន្តរាយនៅតាមមូលដ្ឋាន ផ្តល់ឧបករណ៍ឱ្យពួកគេ ត្រួតពិនិត្យលើប្រតិបត្តិការគ្រោះអាសន្នឱ្យទាន់ពេលវេលា។ សកម្មភាពធ្វើទាន់ពេលវេលាមានដូចជា ការប្រកាសភាពអាសន្នទឹកជំនន់ ការជំលៀសប្រជាពលរដ្ឋដែលងាយ រងគ្រោះទៅកាន់តំបន់សុវត្ថិភាព ការដាក់ពង្រាយក្រុមស្វែងរក និងសង្គ្រោះ ពឹងផ្អែកលើព័ត៌មានទាន់ហេតុការណ៍អំពីកំរិតទឹក ចុងក្រោយបំផុតនៅតាមទន្លេ ជាចំណុចពិសេសមួយ។

ការតាមដានមុខសញ្ញាគ្រោះថ្នាក់ នៅពេលមានភាពអាសន្ន ជាធម្មតាធ្វើឡើងដោយភ្នាក់ងារដែលទទួលខុសត្រូវខាងការព្យាករណ៍និងប្រកាសភាពអាសន្ន។ ក្នុងករណីបណ្តាប្រទេសដែលស្ថិតនៅតាមអាងទន្លេ មន្ទីរឧតុនិយមជលសាស្ត្រ ក្នុងមូលដ្ឋាននឹងធ្វើជាភ្នាក់ងារដឹកនាំ។ តែទោះជាយ៉ាងណាក៏ដោយ ការតាមដានបន្តត្រូវតែមានក្នុងកំឡុងពេលវិបត្តិដែលអាចលើសពីសមត្ថភាពរបស់មន្ទីរផងដែរ។ នៅក្នុងកាលៈទេសៈបែបនេះគណៈកម្មាធិការ ឬក្រុមឃ្លាំមើលមុខសញ្ញាគ្រោះថ្នាក់មូលដ្ឋាន ក៏អាចឃ្លាំមើលការកើតឡើង និងឥទ្ធិពលរបស់វាគ្រប់ពេលវេលាក្នុងរយៈពេល ២៤ម៉ោង។ ចំណែកភ្នាក់ងារ ឬអាជ្ញាធរមូលដ្ឋានត្រូវធ្វើការផ្សព្វផ្សាយព័ត៌មាន ប្រកាសភាពអាសន្នអោយបានត្រឹមត្រូវ និងទៀងទាត់ឱ្យសាធារណៈជន បានដឹង។

២. ការព្យាករណ៍ និងការប្រកាសឱ្យដឹងមុន

ដូចបាននិយាយថា ជាផ្នែកនៃវិធានការត្រៀមរៀបចំការប្រកាសឱ្យដឹងមុន ត្រូវតែមានលក្ខណៈត្រឹមត្រូវងាយយល់ និងអាចជឿទុកចិត្តបានដោយសហគមន៍និងមន្ត្រីដែលនឹងអនុវត្តសកម្មភាពឆ្លើយតប។ ព័ត៌មានត្រូវផ្អែកលើស្ថានភាពពិតតាមពេលវេលា (ព័ត៌មានផ្តល់ឱ្យតាមរយៈការតាមដាន និងការបញ្ជូនពីភ្នាក់ងារប្រចាំការ)។

តួនាទីរបស់គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយ គឺត្រូវសហការជាមួយក្រុមឆ្លើយតប និងភ្នាក់ងារដែលទទួលខុសត្រូវចំពោះការចេញផ្សាយប្រកាសភាពអាសន្ន និងធានាថា ប្រជាជនដែលកំពុងទទួលបានសារប្រកាសភាពអាសន្នបានទៀងទាត់ និងចេះមានវិធានការសមស្របផ្អែកលើព័ត៌មាន។ នៅតាមថ្នាក់ភូមិ ក្រុមអ្នកស្ម័គ្រចិត្តអាចជួយផ្សព្វផ្សាយព័ត៌មានបានតាមរយៈឧបករណ៍បំពងសំលេង។

៣. ប្រតិបត្តិការជំលៀស

ផែនការត្រៀមរៀបចំល្អមួយត្រូវមានកំណត់ ទីតាំងជំលៀស ផ្លូវ និងជំរកមានសុវត្ថិភាព មានប្រយោជន៍ដើម្បី ជំលៀសប្រជាជនដែលរងគ្រោះចេញពីតំបន់លិចទឹកទៅកាន់តំបន់ សុវត្ថិភាព។ ផែនទីមានប្រយោជន៍ខ្លាំងបំផុត សំរាប់សកម្មភាពនេះ។ ពេលវេលាគឺជាកត្តាសំខាន់ក្នុងកំឡុងពេលជំលៀសប្រជាជនទៅកន្លែងសុវត្ថិភាព។ អាជ្ញាធរមូលដ្ឋានគឺជាចៅក្រមល្អបំផុត កំនត់ពេលវេលាត្រឹមត្រូវសំរាប់ការជំលៀសផ្អែកលើការប្រកាសភាពអាសន្នមុន និងស្ថានភាពទឹកជន់ចុងក្រោយបំផុត។ ប្រសិនបើការសំរេចចិត្តជំលៀសមិនធ្វើទាន់ពេលវេលាទេ ការបាត់បង់ជីវិត និងទ្រព្យសម្បត្តិអាចខ្ពស់។

> ***ការអំពាវនាវជំលៀស***
>
> - *ប្រសិនបើតេឱ្យជំលៀស ត្រូវធ្វើតាមភ្លាម។*
> - *ការជំលៀសងាយស្រួល និងសុវត្ថិភាពជាងនៅមុនពេលទឹកជន់ឡើងកាន់តែជ្រៅ សំរាប់យាន្តធម្មតាបើកាត។*
> - *ស្តាប់វិទ្យុអំពីការណែនាំឱ្យជំលៀស។*
> - *ទៅតាមផ្លូវដែលស្នើឱ្យជំលៀស ផ្លូវកាត់អាចបិទ។*
> - *ចាកចេញឱ្យបានមុន ជៀសវាងការជាប់គាំងដោយទឹកជន់។*
>
> *FEMA, 1993*

ប្រសិនបើការជំលៀសតំរូវឱ្យមានទ្រង់ទ្រាយធំ ប្រតិបត្តិការជាធម្មតាត្រូវធ្វើឡើងដោយបុគ្គលិក ដែលទទួលបានការបណ្តុះបណ្តាល ដូចជាភ្នាក់ងារ ជាអង្គការកាកបាទក្រហមជាតិ កងកំលាំងយោធា និងប៉ូលីសមូលដ្ឋាន សហការជាមួយអាជ្ញាធរគ្រប់គ្រងគ្រោះមហន្តរាយមូលដ្ឋាន។ គ្រួសារនីមួយៗ នៅពេលបានដឹងអំពីគ្រោះថ្នាក់ជាយូរមកហើយ អាចរៀបចំជំលៀសដោយខ្លួនឯងទៅកាន់កន្លែងដែលពួកគេត្រូវទៅ (ជំរកសុវត្ថិភាព ផ្ទះសាច់ញាតិ)។

៤. តំបន់សុវត្ថិភាព និងការគ្រប់គ្រងជំរកបណ្តោះអាសន្ន

ដើម្បីផ្តល់ទីសុវត្ថិភាពដល់ប្រជាជនរងគ្រោះដោយសារ មុខសញ្ញាគ្រោះថ្នាក់ ដែលស្ថិតនៅក្នុងស្ថានភាពមិនមានសុវត្ថិភាពគ្រប់គ្រាន់ដូចជា គ្មានផ្ទះសម្បែង និងប្រញាប់ប្រញាល់មុនការកំនត់រកតំបន់ដ៏ខ្ពស់ ដែលមានសុវត្ថិភាពសំរាប់ការស្នាក់នៅជាបណ្តោះអាសន្នក្នុងកំឡុងពេលនៃការកើតឡើងនៃមុខសញ្ញាគ្រោះថ្នាក់ ត្រូវបានចាត់ទុកថាជាសកម្មភាពមួយសំខាន់បំផុត នៅក្នុងផ្នែកទី១ នៃជំពូកនេះ។ ឧទាហរណ៍: នៅពេលទឹកជន់ឡើងដល់កំពូល ហើយអ្នកដែលងាយរងគ្រោះត្រូវបានជំលៀស ទៅតំបន់សុវត្ថិភាព ការគ្រប់គ្រងតំបន់ទាំងនេះត្រូវមានការយកចិត្តទុកដាក់ខ្លាំងបំផុត។

ជំហានដំបូង ត្រូវធានាឱ្យមានសំភារៈចាំបាច់ ។ អាជ្ញាធរគ្រប់គ្រងគ្រោះមហន្តរាយមូលដ្ឋានរួមជាមួយអង្គការក្រៅរដ្ឋាភិបាល និងក្រុមស្ម័គ្រចិត្តត្រូវតែប្រមែប្រមូលតង់បណ្តោះអាសន្ន ក្រណាត់កៅស៊ូ និងផ្ទះចល័ត ហើយដឹកជញ្ជូនវាទៅតំបន់សុវត្ថិភាព ។ វាក៏មានសំខាន់ផងដែរ ត្រូវបំពាក់បរិក្ខាដែលមានស្តង់ដារ និងមូលដ្ឋានអប្បរមា ដូចជាស្បៀង ទឹកទទួលទាន បរិក្ខារអនាម័យនៅតាមតំបន់សុវត្ថិភាព ។ ប្រព័ន្ធចំរោះទឹកក៏ត្រូវតែគិតគូរនិងបំពាក់នៅតាមទីជំរកបណ្តោះអាសន្ន ។

សន្តិសុខ គឺជាការព្រួយបារម្ភសំខាន់មួយសំរាប់ប្រជាជនដែលបានជំលៀស ជាពិសេស ស្ត្រីងាយរងគ្រោះទៅនឹងការបៀតបៀនលើផ្លូវភេទ ។ អាជ្ញាធរគ្រប់គ្រងគ្រោះមហន្តរាយមូលដ្ឋានត្រូវតែផ្តល់វិធានការសន្តិសុខជាមួយ ជំនួយពីប៉ូលីស យោធា ឬប៉ូលីសឃុំដើម្បីធានាសន្តិសុខនិងសុវត្ថិភាពនៅក្នុងតំបន់សុវត្ថិភាព ។ ការថែទាំកុមារ គឺជាបញ្ហាសំខាន់មួយទៀតនៅឯជំរកបណ្តោះអាសន្ន ដោយសារតែមានករណីស្លាប់ដោយលង់ទឹកត្រូវបានរាយការណ៍ពីគ្រួសារដែលបានជំលៀសទៅកាន់តំបន់សុវត្ថិភាព ។ ការបង្កើតសាលាមត្តេយ្យបណ្តោះអាសន្នដោយមានជំនួយមកពីក្រុមស្ត្រី និងអង្គការក្រៅរដ្ឋាភិបាល គឺជា ជំរើសមួយល្អបំផុតដើម្បីធានាសុវត្ថិភាពកុមារក្មេងៗ ។

៥. ប្រតិបត្តិការស្វែងរក និង សង្គ្រោះ

ក្នុងការអនុវត្តន៍ប្រតិបត្តិការស្វែងរកនិងសង្គ្រោះ វាសំខាន់ត្រង់ថា ក្រុមស្វែងរកនិងសង្គ្រោះត្រូវតែដឹកនាំដោយភ្នាក់ងារដែលមានសមត្ថកិច្ចដែលមានការសំរេចចិត្ត និងការបញ្ជារតែមួយ ។ ក្រុមត្រូវតែកំនត់អាទិភាពលើទីតាំងចំណុចដែលងាយរងគ្រោះខ្លាំងបំផុតនៅក្នុងតំបន់ ហើយប៉ុស្តិ៍សង្គ្រោះត្រូវតែបង្កើតឡើង ។

វាត្រូវតែប្រាកដថា ឧបករណ៍ស្វែងរកនិងសង្គ្រោះ ដូចជា ទូក ខ្សែរពួរ ពោងបណ្តែត និងអាវពោងសង្គ្រោះមានក្នុងដៃគ្រប់ពេល ។ អាជ្ញាធរគ្រប់គ្រងគ្រោះមហន្តរាយមូលដ្ឋានត្រូវធានាថា បញ្ជីធនធាន(បញ្ជីសារពើภัណ្ឌ ធនធាន) មានថ្មីជានិច្ច ហើយឧបករណ៍នៅប្រើការបាន ។

៦. ការថែទាំសុខភាព និង ប្រតិបត្តិការផ្នែកសុខាភិបាល

នៅក្នុងតំបន់ជាច្រើន ការដាក់ពង្រាយនៃក្រុមសង្គ្រោះបឋម ជួនកាលដើរតួមុនគេជាក្រុមស្វែងរកនិង សង្គ្រោះមើលព្យាបាលប្រជាជន និងសត្វពាហនៈមានរបួស ។ ក្រុមស្វែងរកនិងសង្គ្រោះត្រូវមានបុគ្គលិកពេទ្យ ដែលអាចធ្វើការសង្គ្រោះ បឋមបាន ។

ក្នុងកំឡុងពេលនៃការកើតឡើងនៃមុខសញ្ញាគ្រោះថ្នាក់ ការលង់ទឹកគឺជាមូលហេតុសំខាន់នៃការស្លាប់ ។ គ្រប់ជំរកសុវត្ថិភាពត្រូវមានឧបករណ៍សង្គ្រោះបឋម ថ្នាំពេទ្យ និងកន្លែងពេទ្យដើម្បីផ្តល់តំរូវការខាងសុខាភិបាលពិសេសក្នុងអំឡុងពេលគ្រោះអាសន្ន ។ ដូចមានចែងនៅក្នុងជំពូកទី៥នៃឯកសារមេរៀននេះ ក្រុមពិសេសមួយដែលផ្តោតលើបញ្ហាសុខភាព និងអនាម័យអាចបង្កើតឡើងនៅតាមថ្នាក់មូលដ្ឋាន ។ ក្រុមអាចមានតំណាងមកពីមន្ទីរសុខាភិបាល គ្លីនិកមូលដ្ឋាន និងសាខា កាកបាទក្រហម ។

ជាបន្ថែម ក្រុមសុខាភិបាលត្រូវតែផ្តល់ការថែទាំសុខភាព ក៏ដូចជាមើលខុសត្រូវលើផ្នែកទឹក និងអនាម័យ ការបង្ការជំងឺបណ្តាលមកពីទឹក រោគរាតត្បាតនៅក្នុងតំបន់លិចទឹក ។ កិច្ចការរបស់គេមានការផ្តល់បរិក្ខារផ្តត់ផ្ទង់ទឹកស្អាតនៅតាមជំរក សុវត្ថិភាព ការអប់រំសាធារណជនអំពីផលប្រយោជន៍នៃការប្រើប្រាស់ទឹកស្អាត និងការជំរុញឱ្យមន្ទីរពាក់ព័ន្ធ របស់រដ្ឋាភិបាលផ្សេងទៀតរួមចំណែកដល់បញ្ហាសុខភាពនិងអនាម័យ តាមមធ្យោបាយដែលពួកគេអាចធ្វើបាន ។ ក្នុងពេលដំណាលគ្នានេះដែរ ក្រុមសុខាភិបាលត្រូវតែស្វែងរកលទ្ធភាពផ្តល់ការថែទាំខាងចិត្តសាស្ត្រ សង្គមដល់ប្រជាពលរដ្ឋដែលរងគ្រោះដោយទឹកជំនន់ ដើម្បីជួយព្យាបាលภาพตานตึงផ្លូវចិត្តរបស់ពួកគេ ។

៧. ការប៉ាន់ប្រមាណរហ័សអំពីការខូចខាត និងតំរូវការ

ក្នុងការឆ្លើយតបទៅនឹងការកើតឡើង និងការគំរាមកំហែងដោយគ្រោះមុខសញ្ញាគ្រោះថ្នាក់ ភ្នាក់ងាររដ្ឋាភិបាលមូលដ្ឋាននីមួយ១ ដែលមានកិច្ចការជាក់លាក់នៅក្នុងផែនការកាត់បន្ថយគ្រោះภัย ឬផែនការត្រៀមបង្ការគ្រោះមហន្តរាយ មានសិទ្ធិចាត់វិធានការដោះស្រាយជាបន្ទាន់ដើម្បីបំពេញនូវសេចក្ដីត្រូវការបន្ទាន់របស់សហគមន៍ដែលរងគ្រោះ។ នៅពេលដែលស្ថានភាពមុខសញ្ញាគ្រោះថ្នាក់ក្លាយជាបញ្ហាធ្ងន់ធ្ងរ ការប៉ាន់ប្រមាណរហ័សមួយអំពីស្ថានភាពចុងក្រោយត្រូវអនុលោមទៅតាមតំរូវការបន្ទាន់ ដែលមានធ្វើបច្ចុប្បន្នភាពជាញឹកញាប់ថាជាស្ថានភាពវិវត្តន៍។ អាជ្ញាធរគ្រប់គ្រងគ្រោះមហន្តរាយ មូលដ្ឋានត្រូវធានាថាទម្រង់ និងគោលការណ៍ចាំបាច់បានផ្ដល់ទៅឱ្យក្រុមប៉ាន់ប្រមាណរហ័ស និងព័ត៌មានដើម្បីកត់ត្រា និងរាយការណ៍បានត្រឹមត្រូវ អំពីការខូចខាត និងតំរូវការបន្ទាន់។

ក្នុងកំឡុងដំណាក់កាលឆ្លើយតប ការខ្វះការសំរបសំរួល ការសហការ និងការផ្លាស់ប្ដូរព័ត៌មានក្នុងចំណោមភ្នាក់ងារក្រុមឆ្លើយតប និងក្រុមអ្នកស្ម័គ្រចិត្តអាចនាំទៅរកស្ថានភាពធ្ងន់ធ្ងរ។ ហេតុដូច្នេះ សហគមន៍ខ្លះទទួលសំភារៈជំនួយច្រើនពេក រីឯអ្នកផ្សេងទៀតគេមិនយកចិត្តទុកដាក់។ នៅពេលដំណាលគ្នានេះ ព័ត៌មានមិនត្រឹមត្រូវ ឬមិនសព្វគ្រប់អំពីការខូចខាតបានកើតឡើងអាចជាលទ្ធផល មិនអាចជួសជុលហេដ្ឋារចនាសម្ព័ន្ធសំខាន់ៗឱ្យមានប្រសិទ្ធិភាពបាន។ ការប៉ាន់ប្រមាណការខូចខាត និងតំរូវការអាចដោះស្រាយបញ្ហាទាំងនេះបាន ដោយការធ្វើឱ្យព័ត៌មានអំពីការខូចខាត និងតំរូវការពិតជាក់ស្ដែងអាចជឿទុកចិត្តបាននៅក្នុងតំបន់រងគ្រោះដោយសារមុខសញ្ញាគ្រោះថ្នាក់នានា។

ការប៉ាន់ប្រមាណ ត្រូវតែធ្វើឡើងដោយទាំងភ្នាក់ងាររដ្ឋាភិបាល និងភ្នាក់ងារក្រៅរដ្ឋាភិបាលនៅថ្នាក់សហគមន៍ ក្រោមការដឹកនាំរបស់គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយមូលដ្ឋាន ឬភ្នាក់ងារដែលបានជ្រើសតាំងដោយផ្ដោតលើការលើកកំពស់ការប៉ាន់ប្រមាណតាមបែបមានការចូលរួម។ ការប៉ាន់ប្រមាណរហ័សមួយត្រូវចេញជាលទ្ធផលអំពីការបែងចែងសំភារៈសង្គ្រោះ និងការបង្កើតអាទិភាពជួយ។ វាគាំទ្រការប្រើប្រាស់ជាអតិបរមានូវធនធានដែលមានស្រាប់នៅតាមមូលដ្ឋាន។

៨. ការសំរបសំរួល និងការគ្រប់គ្រងជំនួយសង្គ្រោះ

នៅពេលមានការគំរាមកំហែង និងការប៉ះពាល់ដោយមុខសញ្ញាគ្រោះថ្នាក់ដែលកើតឡើង សំភារៈជំនួយសង្គ្រោះរាប់គោនមានន័យថាជាការជួយបន្ទាន់ ឬសហគមន៍រងគ្រោះមកដល់តំបន់ដែលរងគ្រោះ ដែលបានប្រមូលក្បៀសគរដោយភ្នាក់ងារគ្រប់គ្រងគ្រោះមហន្តរាយរដ្ឋាភិបាល និងអង្គការក្រៅរដ្ឋាភិបាល កាកបាទក្រហម និងក្រុមអ្នកស្ម័គ្រចិត្តផ្សេងទៀត។ ការបែងចែកជាធម្មតាធ្វើឡើងតាមរយៈបណ្ដាញដែលមានរបស់ភ្នាក់ងារដែលបានលើកឡើងពីខាងលើ។ ទោះជាយ៉ាងនេះក៏ដោយ ក៏មានករណីដែលជំនួយសង្គ្រោះមិនបានទៅដល់ប្រជាជនដែលរងគ្រោះឱ្យបានគ្រប់គ្រាន់នោះទេ ទាំងបរិមាណ និងពេលវេលា ពីព្រោះតែកង្វះនូវការសហការក្នុងចំណោមអ្នកពាក់ព័ន្ធសំខាន់ៗ។ ដូចនេះការសហការនិងការគ្រាប់គ្រង ប្រតិបត្តិការជំនួយសង្គ្រោះ ក្នុងអំឡុងពេលគ្រោះមហន្តរាយគឺជាស្នូលនៃភាពជោគជ័យរបស់ប្រតិបត្តិការស្តារឡើងវិញ។

អាជ្ញាធរគ្រប់គ្រងគ្រោះមហន្តរាយថ្នាក់មូលដ្ឋានត្រូវតែចាប់យកតួនាទីដឹកនាំមុខគេ ក្នុងការសំរបសំរួលជំនួយសង្គ្រោះ និងធ្វើឱ្យអ្នកពាក់ព័ន្ធទាំងអស់ចូលរួមស្របទៅតាមការប៉ាន់ប្រមាណពីតំរូវការ និងដំណើរការជ្រើសរើសអ្នកទទួលផល។ កិច្ចប្រជុំសំរបសំរួលជាមួយអ្នកពាក់ព័ន្ធទាំងអស់ និងអ្នកដឹកនាំក្រុមបែងចែកជំនួយសង្គ្រោះត្រូវតែធ្វើឡើង យ៉ាងហោចណាស់មួយថ្ងៃម្ដង

ដើម្បីពិនិត្យការបែងចែកជំនួយសង្គ្រោះឡើងវិញ និងកំនត់តំរូវការសំរាប់អនាគត។ អាជ្ញាធរថ្នាក់ជាតិត្រូវតែចូលរួមធានាការគាំទ្រខាងផ្នែកនយោបាយ។ ក៏ត្រូវមានកម្មវិធីមួយចែងច្បាស់លាស់អំពីពេលវេលាដកដំណាក់កាលឆ្លើយតបចេញ (ការបន្តការបែងចែកជំនួយសង្គ្រោះ) និងពេលចាប់ផ្តើមធ្វើដំណើរការស្តារនីតិសម្បទា។

បញ្ជីសារពើภัณฑ์ធនធានដែលបានបង្កើតឡើង បំរើជាឯកសារសំខាន់មួយដល់ការឃ្លាំមើលការសំរបសំរួល និងបែងចែកជំនួយសង្គ្រោះ ព្រោះវាមានព័ត៌មានអំពីកន្លែងស្តុកទុក ចំណុះ និងសំភារៈដែលមាននៅក្នុងតំបន់។ ដើម្បីជៀសវាងការចោទប្រកាន់អំពីការអនុវត្តន៍មិនល្អនៅក្នុងការបែងចែកជំនួយសង្គ្រោះ ប្រព័ន្ធកត់ត្រាត្រឹមត្រូវមួយត្រូវមាននៅនឹងកន្លែង។

ផ្នែកមួយនៃការសំរបសំរួល និងគ្រប់គ្រងជំនួយសង្គ្រោះដែលត្រូវការការប្រុងប្រយ័ត្នខ្ពស់ គឺការដោះស្រាយជាមួយប្រព័ន្ធសារព័ត៌មាន។ នៅពេលដែលឥទ្ធិពលទឹកជន់ន់លើសលប់លើលទ្ធភាពរបស់អាជ្ញាធរមូលដ្ឋាន និងសហគមន៍ គួរតែផ្តល់សញ្ញាចេញទៅឱ្យអ្នកដើរតួខាងក្រៅ។ នេះអាចធ្វើបានតាមរយៈប្រព័ន្ធផ្សព្វផ្សាយផ្សេងៗ ដែលមានមកពីបណ្តាញរដ្ឋផ្លូវការ ដើម្បីប្រកាសជូនដំណឹងអំពាវនាវលើទូរទស្សន៍ជាតិ។ ក្នុងករណីខ្លះត្រូវប្រុងប្រយ័ត្នមិនឱ្យស្ថានភាពស្មុគ្រស្មាញពេក ហើយលើកយកតែការពិតជាក់ស្តែងមកនិយាយដើម្បីសុំជំនួយជាក់លាក់។ ពេលនោះភ្នាក់ងារផ្តល់ជំនួយខាងក្រៅអាចយល់បាន ពីតំរូវការនិងផ្តល់ឱ្យនូវធនធានតាមតំរូវការបាន។

II. ការស្តារ និងការកសាងឡើងវិញ

ដំណាក់កាលស្តារឡើងវិញមានគោលបំណងធ្វើឱ្យមានภาพជាធម្មតាឡើងវិញ និងជួយជនរងគ្រោះអោយអាចវិលត្រឡប់ទៅរកមុខរបរខាងផ្នែកសេដ្ឋកិច្ច និងសង្គម។

វាសំខាន់ត្រង់ថា អ្នកពាក់ព័ន្ធទាំងអស់ រួមទាំងភ្នាក់ងារ និងក្រសួងពាក់ព័ន្ធជាមួយនឹងការបង្កើត និងទិសដៅកម្មវិធីស្តារឡើងវិញយល់ច្បាស់អំពីលក្ខណៈនៃការស្តារឡើងវិញ។ ផ្នែកภาคច្រើននៃការស្តារឡើងវិញ សំដៅលើការស្តារឡើងវិញរយៈពេលខ្លី មធ្យម វែង។ ដូចនេះដំណើរការស្តារឡើងវិញមានภาพចំរុះ និងទូលំទូលាយ ដោយផ្សារภัาប់នឹងដំណើរការអភិវឌ្ឍន៍សេដ្ឋកិច្ច និងសង្គមរយៈពេលវែងរបស់មូលដ្ឋាន។ នៅថ្នាក់ខេត្ត និងថ្នាក់ស្រុក កម្មវិធីស្តារឡើងវិញภาคច្រើន ជាពិសេសកម្មវិធីដែលទាក់ទងនឹងការសាងសង់ធំៗ តែងតែមានតំលៃច្រើន។ ក្នុងដំណាក់កាលដំបូងនៃដំណើរការស្តារឡើងវិញ វាសំខាន់ត្រូវបង្កើតធនធានហិរញ្ញវត្ថុដែលមានដើម្បីអនុវត្តកម្មវិធីទាំងនេះ។ ដូចគ្នានេះការប៉ាន់ប្រមាណតំរូវការធនធាន (ដូចជា ឧបករណ៍ សំភារៈ បុគ្គលិកមានជំនាញ) និងអ្វីដែលមានស្រាប់ហើយ។ វិស័យទាំងនេះមានសារៈសំខាន់សំរាប់កំនត់ ទំហំ និងទ្រង់ទ្រាយនៃកម្មវិធីស្តារឡើងវិញ។ ការប៉ាន់ប្រមាណក្រោយពេលគ្រោះមហន្តរាយអំពីការខូចខាត និងការបាត់បង់ គឺជាគន្លឹះចំពោះវិធានការស្តារឡើងវិញ និងត្រូវអនុវត្តឡើងតាមបែបវិទ្យាសាស្ត្រគ្របដណ្ដប់លើផ្នែកសំខាន់ៗទាក់ទងនឹង វិស័យសង្គម សេដ្ឋកិច្ច បរិដ្ឋាន និងរូបសាស្ត្រ។

ការចូលរួមរបស់សហគមន៍ ក្នុងគ្រប់វិស័យទាំងអស់នៃផែនការស្តារឡើងវិញនិងការអនុវត្តមានសារៈសំខាន់។ វាមានប្រយោជន៍ច្រើនដូចតទៅ:

- ធ្វើឱ្យមានការកំនត់បញ្ហា និងឱកាសបានត្រឹមត្រូវនិងមធ្យោបាយមានប្រសិទ្ធិภาพภาคច្រើនដោះស្រាយស្ថានภาพចាប់តាំងពីការផ្អែកលើនិយមន័យរបស់ប្រជាជនផ្ទាល់អំពីតំរូវការនិងអាទិภาพពិតប្រាកដ។

- ធានាថាសកម្មភាពមានការសំរបសំរួលតាមមធ្យោបាយជាប់ទាក់ទងគ្នានិងត្រូវគ្នាជាមួយគោលដៅ និងសកម្មភាពអភិវឌ្ឍសហគមន៍ការបង្ការជំលោះ និងការកាត់បន្ថយតំលៃអនុវត្តន៍ ។
- អប់រំសហគមន៍អំពីធនធាន និងសមត្ថភាពដែលមាន ។
- កសាងការគាំទ្រ និងភាពជាម្ចាស់របស់ផែនការកាត់បន្ថយគ្រោះภัยនៃគ្រោះមហន្តរាយ ឬផែនការត្រៀមបង្ការ គ្រោះមហន្តរាយ ដូច្នេះត្រូវបង្កើនលទ្ធភាពសំរាប់ធានានិរន្តរភាពនៃការធ្វើអន្តរាគមន៍និងលើកកំពស់ការប្តេជ្ញាចិត្ត ។

ប្រព័ន្ធគាំទ្រការស្តារឡើងវិញដែលត្រូវបានគេប្រើជាទូទៅនៅក្នុងប្រទេសមួយ គឺត្រូវផ្តល់ការគាំទ្រខាងផ្នែកហិរញ្ញវត្ថុជំនួយឥតសំណង និងអ្នកស្ម័គ្រចិត្តដើម្បីកសាងជីវភាពរបស់អ្នករស់រានមានជីវិតឡើងវិញ និងធ្វើអោយជីវភាពរស់នៅជាមូលដ្ឋានរបស់ពួកគេបានល្អប្រសើរ ។ ទម្រង់ជំនួសនៃការគាំទ្រមួយអាចជាការផ្តល់មូលនិធិ និងប្រាក់កំចី ការចែកចាយសំភារៈ សំណង់ និងដីធ្លី និងការចែកគ្រាប់ពូជ និងសំភារៈកសិដ្ឋានចាំបាច់នានា ។

១. ការប៉ាន់ប្រមាណការខូចខាតក្រោយពេលគ្រោះមហន្តរាយ

ការប៉ាន់ប្រមាណការខូចខាតជួយក្នុងការកំនត់កម្មវិធីស្តារឡើងវិញជាក់លាក់ ។ ប្រព័ន្ធការប៉ាន់ប្រមាណមួយដែលបំពាក់ទៅដោយគោលការណ៍ណែនាំ និងបច្ចេកទេសត្រឹមត្រូវត្រូវតែមាននៅតាមថ្នាក់ខេត្ត និងស្រុក ដើម្បីអាចឱ្យក្រុមប៉ាន់ប្រមាណផ្តល់ទិន្នន័យជាមូលដ្ឋានសំរាប់ការបង្កើតកម្មវិធីស្តារឡើងវិញ ។

សំណួរជាគន្លឹះមុនធ្វើការប៉ាន់ប្រមាណ គឺព័ត៌មានទាក់ទងនិងរបៀបវាយតំលៃព័ត៌មាន ។ សំណួរទាំងនេះគឺ :

- តើត្រូវការទិន្នន័យអ្វីខ្លះដើម្បីបង្កើតជាព័ត៌មាន?
- តើទិន្នន័យបានមកពីណា?
- តើទិន្នន័យមាននៅពេលណា?
- តើប្រភពទិន្នន័យគួរឱ្យទុកចិត្តបានដែរឬទេ?
- តើព័ត៌មានត្រូវការមានទំរង់ជាអ្វី?
- តើព័ត៌មានទាក់ទងនឹងគោលដៅដែរឬទេ?
- តើព័ត៌មានត្រឹមត្រូវ ច្បាស់លាស់ និងទាន់ពេលវេលាដែរឬទេ?

ការរៀបចំស្ថាប័នដើម្បីធ្វើការប៉ាន់ប្រមាណមានសារៈសំខាន់ណាស់ ដោយសារវាតំរូវឱ្យមានការចូលរួមរបស់មន្ទីរពាក់ព័ន្ធដែលជាស្ថាប័នរបស់រដ្ឋាភិបាលនៅតាមខេត្តនិងស្រុក ។ ដូចមានអធិប្បាយនៅក្នុងជំពូកទី៥ នៃឯកសារមេរៀននេះ ការកំណត់របស់ក្រុមប៉ាន់ប្រមាណការខូចខាតមានសារៈសំខាន់ និងការបណ្តុះបណ្តាលអំពីការប្រើបច្ចេកទេសប៉ាន់ប្រមាណ និងទម្រង់ស្តង់ដារត្រូវតែមាន ។ ប្រការសំខាន់នៃការប៉ាន់ប្រមាណការខូចខាត ក្រោយពេលការកើតឡើងនៃគ្រោះមហន្តរាយ មានសង្ខេបនៅខាងក្រោម :

- ***ស្តង់ដារទម្រង់ និងនិតិវិធី*** សំរាប់ការប៉ាន់ប្រមាណ និងរាយការណ៍ការខូចខាត ។ វាសំខាន់ត្រូវសំរេចឥទ្ធិពលទាំងមូលលើផ្នែកទាំងអស់ និងធ្វើឱ្យទម្រង់ និងនិតិវិធីមានលក្ខណៈស្តង់ដារត្រូវតែចែករំលែកនៅគ្រប់ក្រិតផ្នែករដ្ឋបាលទាំងអស់ ។
- ***ការបង្កើតជនបម្ពាល*** នៅតាមមន្ទីរពាក់ព័ន្ធនីមួយៗ ។

- ***ការបង្កើតបញ្ជីសារពើភ័ណ្ឌបឋម*** នៃធនធាននៅក្នុងមន្ទីរនីមួយៗ និងធ្វើបច្ចុប្បន្នភាពជារៀងរាល់ឆ្នាំ ។
- ***ប្រព័ន្ធគ្រប់គ្រងទិន្នន័យគ្រោះមហន្តរាយនិងឥទ្ធិពល*** សំរាប់ការវិភាគការខូចខាតងាយស្រួលដើម្បីជំរាបទៅអ្នកសំរេចចិត្ត ។
- ***ការបណ្តុះបណ្តាលបុគ្គលិកសំខាន់ៗ*** ក្នុងការប្រើប្រាស់ទម្រង់ស្តង់ដារ
- ***រយៈពេល*** សំរាប់ការប៉ាន់ប្រមាណការខូចខាត និងសំរាប់ការបង្ហាញការរកឃើញ ។ វាសំខាន់ត្រូវបញ្ចប់ដំណើរការប៉ាន់ប្រមាណ ដើម្បីឱ្យអាជ្ញាធរជាតិនិងខេត្តផ្តួចផ្តើមគំនិតធ្វើកម្មវិធីស្តារឡើងវិញ និងស្តារហេដ្ឋារចនាសម្ព័ន្ធសំខាន់ៗឱ្យបានឆាប់តាមដែលអាចធ្វើទៅបាន ។
- ***ការប៉ាន់ប្រមាណតាមផ្ទះ*** ក៏ត្រូវតែធ្វើឡើងផងដែរ ។
- ***ការផ្តោតលើឥទ្ធិពលរយៈពេលខ្លី និងវែង*** ត្រូវតែមាន ។
- ***ការចាត់ចង់បន្ទាប់បន្សំ និងការចាត់ចង់ទាំងស្រុង*** ដូចជាផលិតកម្មកសិកម្ម និងសេដ្ឋកិច្ចផ្នែកកសិកម្ម ក៏ត្រូវតែធ្វើការវិភាគដើម្បីឱ្យដឹងពីឥទ្ធិពលប៉ះពាល់ទាំងនេះមកលើសុខុមាលភាព ។
- ***ការភ្ជាប់ការទំនាក់ទំនងជាពហុវិស័យ និងឥទ្ធិពល*** ក៏ត្រូវតែគិតគូរដើម្បីប៉ាន់ប្រមាណការភ្ជាប់ការទំនាក់ទំនងការអភិវឌ្ឍទាំងមូល ។

វាសំខាន់ ត្រូវកំនត់មន្ត្រីដែលមានបទពិសោធន៍ពីគ្រោះមហន្តរាយពីអតីតកាល និងចាត់តាំងការទទួលខុសត្រូវដើម្បីប្រមូលព័ត៌មានការខូចខាត ។ ជនបង្គោលបែបនេះ ត្រូវតែទទួលបានការបណ្តុះបណ្តាលអំពីបច្ចេកទេសប៉ាន់ប្រមាណការខូចខាត ។ តួនាទីរបស់ជនបង្គោលមានដូចតទៅ :

- ប្រើវិធីសាស្ត្រដែលត្រូវការសំរាប់ការប៉ាន់ប្រមាណការខូចខាត ។
- បណ្តុះបណ្តាលបុគ្គលិកផ្សេងទៀតនៅក្នុងមន្ទីរអំពីការប្រើប្រាស់វា ។
- បញ្ជាក់និងប្រើប្រាស់វិធីសាស្ត្រ ឱ្យត្រូវទៅនឹងតំរូវការរបស់មន្ទីរ ។
- បង្កើតនិងរក្សាបញ្ជីសារពើភ័ណ្ឌនៃទ្រព្យសម្បត្តិមន្ទីរ និងទិន្នន័យនៃការខូចខាតពីអតីតកាល ។

តួនាទីរបស់អាជ្ញាធរគ្រប់គ្រងគ្រោះមហន្តរាយក្នុងការសំរបសំរួលសកម្មភាពប៉ាន់ប្រមាណការខូចខាត ជួយកំនត់តំរូវការរបស់សហគមន៍សំរាប់ការស្តារឡើងវិញក្រោយពេលគ្រោះមហន្តរាយ ពោលគឺ ផ្ទះ ការថែទាំសុខភាព ការអប់រំ សង្គម សេដ្ឋកិច្ច ។ល។ ស្ថាប័នគ្រប់គ្រងគ្រោះមហន្តរាយទាំងនេះ ក៏ធ្វើផែនការសំរាប់ការស្តារឡើងវិញ ផ្អែកលើការក្សៀវគរធនធានពីខាងក្រៅមានប្រសិទ្ធិភាព ។

២. ការសំអាតបរិស្ថាន

ដោយមានបំណងបង្ការការរាតត្បាតជំងឺ ឬរបួសនានាដែលបណ្តាលមកពីសំណល់បាក់បែក ដំណើរការសំអាតត្រូវធ្វើឡើងជាបន្ទាន់ក្រោយពីគ្រោះមហន្តរាយ ។ ការសំអាតក្រោយពីគ្រោះមហន្តរាយកើតឡើងត្រូវការពេលវេលាច្រើន ការអត់ធ្មត់និងជំនាញ ។ ពេលគ្រួសារនីមួយៗទទួលការសំអាតផ្ទះរបស់គេ សំអាតនៅតាមទីសាធារណៈអាចធ្វើឡើងបាន ដោយក្រុមដែលមាន

ការរៀបចំឡើងបានល្អ ដូចជា (យោធា ប៉ូលីស កាកបាទក្រហម អ្នកស្ម័គ្រចិត្ត) ក្រោមការគ្រប់គ្រងរបស់អាជ្ញាធរគ្រប់គ្រងគ្រោះមហន្តរាយមូលដ្ឋាន។ ការថែទាំត្រូវតែធ្វើឡើងដើម្បីប្រើប្រាស់ឧបករណ៍សមស្រប ដូចជា ឈើវែងដើម្បីយកចេញខ្សែរភ្លើងដែលដួល ស្បែកជើងកវែងដើរក្នុងទឹក ។ល។ សំរាប់ក្រុមសំអាត វាសំខាន់ត្រូវប្រយ័ត្ន គ្រោះថ្នាក់ជាសក្តានុភាពដែលងាយកើតមានក្នុងកំឡុងពេលដំណើរការសំអាតជៀសវាងមានគ្រោះថ្នាក់។ វាមាន :

- ប្រដាប់កាត់ផ្តាច់អគ្គិសនី ឬបន្ទត់អគ្គីភ័យដោយសារតែខ្សែរភ្លើងធ្លាក់
- សត្វមានពីស
- ប៉ះពាល់ទឹកមានមេរោគ
- ប៉ះពាល់សំភារៈដែលមានជាតិគីមីប្រកបដោយគ្រោះថ្នាក់
- ឧប្បត្តិវិហេតុលើផ្លូវ និងតំបន់លិចទឹក

អណ្តូង និងប្រភពទឹកអាចមានមេរោគដោយសារតែទឹកជំនន់ ហើយវាត្រូវបូមចេញ សំលាប់មេរោគជាមួយថ្នាំសំលាប់មេរោគ និងទុកឱ្យមានទឹកតាមធម្មជាតិវិញ និងពិនិត្យសាកមើលសិនមុននឹងបរិភោគ ឬដាំស្រូ។ ប្រសិនបើមានការព្រួយបារម្ភពីសុខភាព ត្រូវទំនាក់ទំនងជាមួយមន្ទីរសុខាភិបាលសាធារណៈមូលដ្ឋាន ហើយសាធារណៈត្រូវតែមានការផ្តល់ឱ្យនូវការទំនាក់ទំនងលំអិតរបស់មន្ទីរពាក់ព័ន្ធ។

១. ការពារផ្លូវថ្នល់ពីទឹកជំនន់(ឧ.ជ្រាវ ខ្សាច់ និងការ ពង្រីងទំនប់ទឹក) ២. ផ្តល់ការបណ្ណាបណ្តាលដល់ទាហាន និងកំនត់តួនាទី និងការទទួលខុសត្រូវរបស់ទាហានដែលប្រចាំការនៅក្នុងតំបន់ប្រឈមនឹងទឹកជំនន់ ៣. ចូលរួមក្នុងកិច្ចប្រជុំប្រចាំឆ្នាំរបស់ PCDM ៤. ចូលរួមកិច្ចប្រជុំទ្វៀតទាត់ជាមួយ DCMD ដើម្បីផ្តល់មតិនិងអនុសាសន៍ ៥. ចូលរួមជាមួយ PCDM ក្នុងការបង្កើតផែនការ ៦. ត្រៀមសំភារៈចាំបាច់ ការងារមធ្យោបាយដឹកជញ្ជូននិងសំភារៈសំរាប់អន្តរាគម	១. ស្វែងរក និងសង្គ្រោះ ២.ជំលៀជនរងគ្រោះទៅ ទីសុវត្ថិភាព ៣.ផ្តល់សេវាសន្តិសុខដល់មន្ទីរផ្សេងៗដែលកំពុងធ្វើការក្នុងតំបន់ រងគ្រោះ ៤. ជួយមន្ទីរផ្សេងទ្វៀត ៥.ប៉ាន់ប្រមាណកាខូចខាតនិង តំរូវការ	១. សហការនិងសំរបសំរួលជាមួយមន្ទីរពាក់ព័ន្ធខេត្តផ្សេង ២. ជួសជុលផ្លូវថ្នល់ និងទំនប់ទឹកដែលខូចខាតឡើងវិញបើចាំបាច់ ៣. ស្តាបស្ងង់ការខូចខាតនិងឥទ្ធិពលទាំងអស់ និងប្រមូល និងចងក្រងទិន្នន័យ

គ្រោះអាសន្ន		
កងរាជអាវុធហត្ថខេត្ត		
១. ចូលរួមក្នុងកិច្ចប្រជុំប្រចាំឆ្នាំរបស់ PCDM ២. ត្រៀមក្រុមសំរាប់អន្តរាគមគ្រោះអាសន្ន ៣.ការពារសាលារៀននិងហេដ្ឋារចនាសម្ព័ន្ធសំខាន់ៗពីទឹកជំនន់ ៤.ដាក់បារាំខ្សាច់ទប់និងតាមដានមើលតំបន់ប្រឈម នឹងទឹកជំនន់ ៥.ជំលៀសជនរងគ្រោះនិងផ្តល់ជំនួយផ្សេងៗតាមការចាំបាច់ ៦. ផ្តល់សន្តិសុខក្នុងទីជំរកបណ្តោះអាសន្ន	១. ដាក់បារាំដីខ្សាច់ ២.ត្រៀមក្រុមសំរាប់ជំលៀសជនរងគ្រោះ ឬសត្វពាហនៈទៅតំបន់សុវត្ថិភាព ៣. ជំលៀសជនរងគ្រោះ ៤. ចែកជំនួយគ្រោះអាសន្ន ៥.ប្រើប្រាស់សំភារៈ និង ឧបករណ៍ដែលមានដើម្បីសង្គ្រោះប្រជាជន និងសត្វពាហនៈ (ស្វែងរក និង សង្គ្រោះ)	១. រក្សាសន្តិសុខ ២. ប៉ាន់ប្រមាណការខូចខាត និងតំរូវការនិងរាយការណ៍ទៅ PCDM ៣. ស្តារ និងស្តារនីតិសម្បទាហេដ្ឋារចនាសម្ព័ន្ធដែលខូចខាតឡើងវិញ ៤. ស្តុបទឹកជំនន់ទុកសំរាប់សកម្មភាពកសិកម្ម
ស្នងការនគរបាលខេត្ត		
១. ចែកចាយព័ត៌មានអំពីវិធានការកាត់បន្ថយ ដល់អ្នករស់នៅក្នុងស្រុក ដូចជា: ក. ហាមប្រាមការដឹកទំនិញលើសចំណុះតាម ទូក ខ. ប្រើពោងសង្គ្រោះជីវិត គ. ផ្តល់ការប្រកាសអាសន្ន ការណែនាំដល់ អ្នកធ្វើដំណើរ	១. ជួយប្រជាជនក្នុងតំបន់រងគ្រោះ ២. ប្រមូលទិន្នន័យនៃការខូចខាត និងការស្លាប់ ៣. ដាក់បារាំដីខ្សាច់និងការពារទំនប់ទឹក ៤. ជំលៀសជនរងគ្រោះ ទ្រព្យសម្បត្តិ និងសត្វពាហនៈទៅតំបន់ សុវត្ថិភាព ៥. អប់រំប្រជាជនពីសុខភាពនិង អនាម័យ ៦. ផ្តល់សន្តិសុខនៅក្នុងតំបន់ សុវត្ថិភាព ៧. ជួយចែកជំនួយសង្គ្រោះភាព អាសន្ន	១. ផ្តល់សន្តិសុខក្នុងតំបន់ សុវត្ថិភាព ២. សហការជាមួយ PCDM ៣.ប្រមូលព័ត៌មាននៃការខូចខាត និងតំរូវការសំរាប់ស្តារ ឡើងវិញ
មន្ទីរវប្បធម៌ និង វិចិត្រសិល្ប:ខេត្ត		
១.រៀបចំតំបន់សុវត្ថិភាពដោយណែនាំពី PCDM ២. ជួយ PCDM ជំលៀសជនរងគ្រោះទៅកន្លែងសុវត្ថិភាព ៣.ត្រួតពិនិត្យនិងការពារតំបន់ប្រឈមនឹងទឹកជំនន់(តំបន់ប្រវត្តិសាស្ត្រនិងវប្បធម៌) ៤. ហាមការដឹកកកាយខុសច្បាប់នៅក្នុងតំបន់ សុវត្ថិភាព (តំបន់ប្រវត្តិសាស្ត្រនិងវប្បធម៌) ដើម្បី រកវត្ថុបុរាណ	១. ដឹកជនរងគ្រោះទៅទីសុវត្ថិភាព ២. ជួយដាក់បារាំដីខ្សាច់និងការពារ ទំនប់ទឹក ឬផ្លូវថ្នល់	១. ប្រមូលទិន្នន័យអំពីជនរងគ្រោះដែលកំពុងរស់នៅក្នុងតំបន់ សុវត្ថិភាព ២. ការពារតំបន់ប្រវត្តិសាស្ត្រដែលបានចុះបញ្ជី

មន្ទីរហិរញ្ញវត្ថុខេត្ត		
១. ចូលរួមកិច្ចប្រជុំជាមួយ PCDM ២. ចែករំលែកគំនិតអំពីការបង្ការគ្រោះមហន្តរាយ ៣.ចូលរួមយ៉ាងសកម្មក្នុងសកម្មភាពរៃអង្គាសថវិកា	១. ចូលរួមក្នុងសកម្មភាពស្វែងរកនិងជ្រោះដោយសហការជាមួយមន្ទីរពាក់ព័ន្ធខេត្ត និងអង្គការ ២. ចែកជំនួយសង្គ្រោះភាពអាសន្ន ៣. រៀបចំនិងដាក់ចារដីខ្សាច់ ៤. ចូលរួមក្នុងសកម្មភាពរៃអង្គាសថវិកា ៥. ក្បៀងគរធនធានមនុស្សនៅក្នុងមន្ទីរសំរាប់ប្រតិបត្តិការស្វែងរក និងសង្គ្រោះ	១. ចូលរួមប្រមូលទិន្នន័យនៃការខូចខាត ២. ចូលរួមយ៉ាងសកម្មនៅក្នុងសកម្មភាពស្តារឡើងវិញនិងការស្តារនីតិសម្បទាឡើងវិញ
មន្ទីរសាធារណការ និង ដឹកជញ្ជូនខេត្ត		
១. ការពារផ្លូវថ្នល់និងស្ពាន ២.ត្រៀមរថយន្តធំដឹកជញ្ជូនដីនិងខ្សាច់សំរាប់ត្រៀមធ្វើចារដីខ្សាច់ ៣. ហ៊ុមព័ទ្ធតំបន់ការពារ ៤. បង្កើតយុទ្ធសាស្ត្រត្រៀមបង្ការទឹកជំនន់យ៉ាងហោចណាស់ឱ្យបានមួយខែមុន ។	១. ចែកជំនួយសង្គ្រោះ ២. ផ្តល់ការដឹកជញ្ជូនដល់បុគ្គលិកសុខាភិបាលទៅតំបន់សុវត្ថិភាព ៣. ជួសជុលផ្លូវថ្នល់និងស្ពាន	១. បង្កើតផែនការស្តារនីតិសម្បទាហេដ្ឋារចនាសម្ព័ន្ធ រួមទាំងផ្លូវថ្នល់ ស្ពាន និង ផ្លូវជាតិ
មន្ទីរអភិវឌ្ឍន៍ជនបទខេត្ត		
១. ផ្តល់ការបណ្តុះបណ្តាលអំពីការធ្វើផែនការទាក់ទងនឹងជំនួយសង្គ្រោះភាពអាសន្ននៅតាមសហគមន៍ ២. សង់បង្គន់ និងអណ្តូងទឹកក្នុងតំបន់សុវត្ថិភាព ៣. រៀបចំវគ្គបណ្តុះបណ្តាលអំពីការសង្គ្រោះបឋម សំរាប់អ្នកភូមិ ៤. រៀបចំវគ្គបណ្តុះបណ្តាលសំរាប់សហគមន៍អំពី ការថែទាំសុខភាពនិងអនាម័យ	១. ចូលរួមជាមួយ PCDM ២. ប្រមូលព័ត៌មានទឹកជំនន់ និងការខូចខាត និងរាយការណ៍ទៅអ្នកពាក់ព័ន្ធ ៣.ផ្តល់សេវាកម្មដឹកជញ្ជូន និង ប្រេង ៤. ធ្វើសំណើសុំនិងដាក់ទៅម្ហូ ស ជំនួយ ៥. ផ្តល់ស្បៀងដល់ប្រជាជន	១. ស្តារ និងជួសជុលអណ្តូងទឹកឡើងវិញ ២. រៀបចំវគ្គបណ្តុះបណ្តាលអំពីសង្គ្រោះបឋមសំរាប់អ្នកភូមិ ៣.រៀបចំវគ្គបណ្តុះបណ្តាលសំរាប់សហគមន៍ស្តីពីការថែទាំ សុខភាពនិងអនាម័យ ៤.ស្តារ និងជួសជុលហេដ្ឋារចនាសម្ព័ន្ធដែលខូចខាតទាំងអស់ឡើងវិញ រួមទាំងផ្លូវថ្នល់ ស្ពាន និងទ្វារទឹក
មន្ទីរពាណិជ្ជកម្មខេត្ត		
១. តាមដានមើលអង្ករនិងប្រេងឥន្ធនៈ:មាន	១. រក្សាកំនត់ហេតុ និងគ្រប់គ្រងការប្រើ	

ក្នុងស្តុក ២. ផ្តល់ជំនួយដល់អភិបាលខេត្តសំរាប់ការគ្រប់គ្រងស្បៀងនិងប្រេងឥន្ធនៈ	អង្ករពីខាងក្រៅ និងប្រេងមកពីរោងម៉ាស៊ីនឯកជន និងពីស្ថានីយ៍ប្រេង ២. ផ្តល់ជំនួយនិងការស្នើសុំទៅអភិបាលខេត្តពីការចែកទំនិញ (ស្បៀង និងប្រេង)	
មន្ទីរព័ត៌មានខេត្ត		
១. គ្រប់គ្រងព័ត៌មាន ២. ផ្សព្វផ្សាយព័ត៌មានដល់សាធារណជនតាមរយៈ ប្រព័ន្ធផ្សព្វផ្សាយ ដូចជា វិទ្យុ និងទូរទស្សន៍	១. គ្រប់គ្រងព័ត៌មាន ២. ផ្សព្វផ្សាយព័ត៌មានដល់សាធារណៈជនតាមរយៈប្រព័ន្ធផ្សព្វផ្សាយដូចជា វិទ្យុ និងទូរទស្សន៍	១. គ្រប់គ្រងព័ត៌មាន ២. ផ្សព្វផ្សាយព័ត៌មានដល់សាធារណៈជនតាមរយៈប្រព័ន្ធផ្សព្វផ្សាយដូចជាវិទ្យុ និងទូរទស្សន៍
មន្ទីរបរិស្ថានខេត្ត		
១. ចែកចាយព័ត៌មានដល់សាធារណៈជនអំពីការ គ្រប់គ្រងការបំពុលទឹកទឹក និងការសំណល់ ២. សហការជាមួយអាជ្ញាធរមូលដ្ឋាន និងអង្គការ ដើម្បីចាក់ដីបំពេញជាថ្មី ៣.បញ្ជូនកាកសំណល់ទៅតំបន់ឆ្ងាយដាច់ស្រយាលពីតំបន់លំនៅដ្ឋាន ។	១. លើកកំពស់ការយល់ដឹងអំពីការបោះចោល និងគ្រប់គ្រងកាកសំណល់ ២. ជំរុញឱ្យក្រុមហ៊ុនឯកជនដឹកកាកសំណល់ទៅចាក់បំពេញដី	១. លើកកំពស់ការយល់ដឹងជាសាធារណៈអំពីការបោះចោល និងការគ្រប់គ្រងកាកសំណល់ ២. ផ្តល់ឱ្យវាទអាជ្ញាធរមូលដ្ឋាន និងអង្គការអំពីការគ្រប់គ្រងកាកសំណល់ ៣. តាមដានការអនុវត្តន៍ការគ្រប់គ្រងកាកសំណល់នៅតាមផ្ទះនិងផ្តល់អនុសាសន៍ ។

ប្រភពពិតមាន : កម្មវិធីត្រៀមបង្ការទឹកជំនន់ខេត្តព្រៃវែង ឆ្នាំ២០០៦

៧. សំណួរសំរាប់ការពិចារណា

- តើឯកសារយោងរបស់ស្ថាប័ន គឺជាអ្វី? ហេតុអ្វីបានជាគេចាត់ទុកថាវាមានសារៈសំខាន់?
- ដើម្បីត្រៀមរៀបបង្ការទឹកជំនន់ តើក្រុមគ្រប់គ្រងគ្រោះមហន្តរាយខេត្ត និងមន្ទីរពាក់ពន្ធ ត្រូវមានតួនាទី ភារកិច្ច និងការទទួលខុសត្រូវអ្វីខ្លះ?
- តើអ្នកដឹងថាមានការប្រឈមមុខសំខាន់ៗអ្វីខ្លះ នៅក្នុងដំណាក់កាលឆ្លើយតបបន្ទាន់នៃគ្រោះទឹកជំនន់ ដើម្បីធានាថាតួនាទី ភារកិច្ច និងការទទួលខុសត្រូវ ត្រូវបានរៀបចំតាមលំនាំនៃឯកសារយោងមកខាងលើ?
- តើស្ថាប័នគ្រប់គ្រងគ្រោះមហន្តរាយណាមួយ ដែលគួរបង្កើតឱ្យមានឯកសារយោងសំរាប់ការកាត់បន្ថយគ្រោះទឹកជំនន់?

មេរៀនទី ២: ទម្រង់គំរូ និងផែនការកាត់បន្ថយគ្រោះภัយ នៃគ្រោះមហន្តរាយថ្នាក់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

អ្នកធ្វើផែនការថ្នាក់ខេត្ត និងថ្នាក់ស្រុក ត្រូវប្រុងប្រយ័ត្នពិនិត្យមើលឱ្យបានច្បាស់លាស់ទម្រង់ដូចតទៅស្តីពីការធ្វើផែនការកាត់បន្ថយគ្រោះภัយនៃគ្រោះមហន្តរាយ និងបង្កើតផែនការផ្ទាល់ខ្លួនរបស់គេ ដោយការប្រើប្រាស់តាម និងធ្វើ ទៅតាមទំរង់នេះ។

I. គោលបំណងរួម

សិក្ខាកាម ឬអ្នកចូលរួមទាំងអស់ អាចនឹងយល់ដឹងបានទូលំទូលាយ និងចេះពីរបៀបរៀបចំផែនការត្រៀមបង្ការគ្រោះមហន្តរាយមួយដែលមានលក្ខណៈពិស្តារ និងពេញលេញ សំរាប់យកទៅអនុវត្តនៅតាមបណ្តាខេត្ត និងស្រុក របស់ខ្លួន។

II. ខ្លឹមសារមេរៀន

១. ព័ត៌មាន/និន្នន័យសំខាន់ៗសំរាប់រៀបចំផែនការត្រៀមបង្ការគ្រោះមហន្តរាយ

១.១ មាតិកា

១.២ អារម្ភកថា

បន្ទាប់ពីទំព័រមាតិកា គឺ**អារម្ភកថា**។ អារម្ភកថា មិនគួរសរសេរវែងពេកទេ យ៉ាងច្រើនត្រឹមមួយទំព័រ។ អារម្ភកថាត្រូវបង្ហាញអំពីសារៈប្រយោជន៍របស់ផែនការ ការថ្លែងអំណរគុណចំពោះអ្នកដែលបានចូលរួមកសាងផែនការ និងសេចក្តីសង្ឃឹមដែលនឹងទទួលបានការគាំទ្រពីអ្នកពាក់ព័ន្ធ។ នៅចុងបញ្ចប់នៃអារម្ភកថានេះ អភិបាលខេត្ត/រាជធានី ឬស្រុក/ក្រុង ត្រូវចុះហត្ថលេខា ឈ្មោះ មុខងាររបស់ខ្លួន និងកាលបរិច្ឆេទ។ អារម្ភកថាត្រូវរក្សាមួយទំព័រដាច់ដោយឡែក។

១.៣ ក្រុមការងារ

បន្ទាប់ពីអារម្ភកថា គឺ**សមាសភាពក្រុមការងារ**។ ចំណុចនេះ អ្នករៀបចំត្រូវសរសេរផ្តើមសេចក្តីបន្តិច (ប្រហែល ៣-៤ បន្ទាត់) ទាក់ទិននឹងសមាសភាពស្ថាប័នឬអង្គភាពពាក់ពន្ធ័នានា ដែលបានជួយជ្រោមជ្រែង គាំទ្រ និងផ្តល់ជា បច្ចេកទេសផ្សេងៗជាដើម ដែលបានធ្វើឱ្យផែនការនេះកើតចេញជារូបរាងឡើង។ បន្ទាប់មក កំណត់ដោយ ការបែងចែកសមាសភាព ០៣ប្រភេទ:

- ទី១: **សមាសភាពក្រុមការងារ**: ត្រូវបង់លេខរៀង ឈ្មោះ និង មុខងាររបស់អ្នកទាំងនោះ។ សមាសភាពក្រុមការងារដែលត្រូវដាក់នៅក្នុងចំណុចទី១នេះ គឺជាអ្នកជំនាញដែលបានចូលរួមនិងពាក់ពន្ធ័ដោយផ្ទាល់ក្នុងដំណើរការចុះណែនាំ និងផ្តល់បច្ចេកទេសផ្សេងៗ នៅក្នុងសិក្ខាសាលាកន្លងមក ទាក់ទងនឹងការកសាងផែនការនេះ។

- ទី២: **ពិនិត្យ និងផ្តល់បច្ចេកទេស**: គួរដាក់ឈ្មោះថ្នាក់ដឹកនាំ ឬប្រធានគំរោងទាំងឡាយដែលបានផ្តួចផ្តើម ផ្តល់ការណែនាំ ផ្តល់ឱវាទដល់អ្នកជំនាញដើម្បីកសាងផែនការ (អ្នកទាំងនោះអាចជា: អភិបាលខេត្ត អភិបាលស្រុក ប្រធានអង្គការ-ស្ថាប័ន ជាដើម)។

- ទី៣: **ស្ថាប័នរួមចំណែកសំខាន់ៗ:** គួរដាក់មន្ទីរ/វិស័យនិងអង្គភាពទាំងអស់ ដែលជាសមាជិកគណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយខេត្ត ឬស្រុក អាស្រ័យលើកំរិត/ប្រភេទរបស់ផែនការ។ ទន្ទឹមនឹងនេះដែរ ចំណុចសមាសភាព ដែលគួរដាក់បន្ថែមទៀតដែរ គឺសមាសភាពរបស់អង្គការជាតិ-អន្តរជាតិនានាដែលបាន ចូលរួមនៅក្នុងសិក្ខាសាលានេះកន្លងមក ដោយរៀបរាប់ពីឈ្មោះអង្គការទាំងនោះ ជាបន្តបន្ទាប់។ នៅចុងបញ្ចប់នៃខ្លឹមសារក្នុងទំព័រនេះ គឺពុំចាំបាច់ មានចុះហត្ថលេខា ឬកាលបរិច្ឆេទណាមួយឡើយ។

១.៤ សេចក្ដីផ្ដើម

បន្ទាប់ពីទំព័រក្រុមការងារ គឺ**សេចក្ដីផ្ដើម**។ នៅក្នុងខ្លឹមសារនៃសេចក្ដីផ្ដើមនេះ គឺមានពិតមានសំខាន់ៗដែលត្រូវសរសេរបំពេញ ដូចខាងក្រោម:

- **ប្រវត្តិគ្រោះមហន្តរាយ**

អ្នករៀបចំត្រូវសរសេររៀបរាប់ពីប្រវត្តិនៃគ្រោះមហន្តរាយចម្បងៗនានា ដែលបានកើតឡើង និងបានបង្កជាផលប៉ះពាល់របស់វាកន្លងមកនៅក្នុងខេត្ត ឬស្រុកគោលដៅនៃគំរោងរបស់អ្នករួមមាន: ចំនួន ជីវិតមនុស្ស (ស្លាប់ របួស គ្មានទីជំរក) សត្វ ទ្រព្យសម្បត្តិ ផ្ទះសម្បែង ផលដំណាំ កសិកម្ម និងចំនួនភូមិ ឃុំ ស្រុកនានា ហេដ្ឋារចនាសម្ព័ន្ធ ផ្សេងៗទៀតដែលទទួលរងការប៉ះពាល់ និងខូចខាតជាដើម។ល។

- **គោលបំណង**

អ្នករៀបចំ ត្រូវសរសេរនិងកំណត់ឱ្យបានច្បាស់លាស់ពីគោលបំណង និង រយៈពេលរបស់ផែនការ។

- **ការរៀបចំផែនការ និង សារៈសំខាន់**
  - *តើហេតុអ្វីបានជាត្រូវមានផែនការត្រៀមបង្ការគ្រោះមហន្តរាយ?*
  - *តើផែនការត្រៀមបង្ការគ្រោះមហន្តរាយអាចជួយយើងបានអ្វីខ្លះ?*
  - *តើនរណាជាអ្នករៀបចំផែនការ?*
  - *តើផែនការនេះកើតឡើងយ៉ាងដូចម្ដេច?*
  - *តើនរណាជាអ្នកអនុវត្តផែនការ?*

- **ដំណើរការរៀបចំផែនការ**

អ្នករៀបចំ ត្រូវសរសេររៀបរាប់ដោយសង្ខេបបំផុតស្ដីពីដំណើរការ (ជំហាន ឬ ដំណាក់កាលនានានៃការរៀបចំ ផែនការ) រាប់តាំងពីការចាប់ផ្ដើម រហូតដល់ផែនការនេះត្រូវបានអនុម័ត និងប្រកាសដាក់ឱ្យប្រើប្រាស់ជាផ្លូវការ នៅក្នុងសិក្ខាសាលាចុងក្រោយ បង្ហួសនៃដំណើរការនេះ។

- **ការកែសំរួល និងធ្វើបច្ចុប្បន្នភាពលើផែនការ**
  - ស្ថាប័នអ្នកអនុវត្ត: គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយខេត្ត ឬ ស្រុក

- ស្ថាប័នទទួលខុសត្រូវលើការកែសំរួល: គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយខេត្ត ឬស្រុកក្រោមជំនួយ បច្ចេកទេសពី.....
- ផែនការសំរាប់អនុវត្តរយៈពេល.....ឆ្នាំ: ២០០... ដល់ ២០១.....
- កាលបរិច្ឆេទនៃការកែសំរួល: ខែ..... ឆ្នាំ ២០១.....

១.៥ ទិន្នន័យទូទៅរបស់ខេត្ត ឬ ស្រុក

ក. ទីតាំងភូមិសាស្ត្រ និង ទំហំផ្ទៃដី

- **ភូមិសាស្ត្ររបស់ខេត្ត ឬស្រុក:** ត្រូវសរសេររៀបរាប់ពីទីតាំងរបស់ខេត្ត/ស្រុកនោះវាស្ថិតនៅទិសខាងណានៃផ្ទៃប្រទេស, រាជធានីភ្នំពេញ ឬទីរួមខេត្ត ដែលមានព្រំប្រទល់ខាងកើត, ខាងលិច, ខាងត្បូង និងខាងជើងជាប់នឹង..... មានចម្ងាយប៉ុន្មានគ.ម ពីចំនុចប្រៀបធៀបខាងលើមានផ្លូវជាតិណាខ្លះ មានទន្លេ-ស្ទឹងសំខាន់ៗណាខ្លះឆ្លងកាត់ជាដើម។
- **ចំនួនក្រុង ស្រុក ឃុំ និងភូមិ:** ត្រូវបំពេញពិតមានពីចំនួនក្រុង/ស្រុក, ឃុំ និងភូមិទាំងអស់ដែលមាន នៅក្នុងខេត្ត ឬស្រុកដូចមានតារាងគំរូខាងក្រោម:

ល.រ	ឈ្មោះក្រុង ឬ ស្រុក	ចំនួនឃុំ/សង្កាត់	ចំនួនភូមិ
១			
២			
៣			
៤			
៥			

សរុប:			

- **ចំនួនផ្ទៃដី និង ប្រភេទដី:** ត្រូវសរសេររៀបរាប់ពីចំនួនផ្ទៃដីសរុបទូទាំងខេត្តឬស្រុក/ក្រុងមានប៉ុន្មានហិកតា។ ក្នុងនោះផ្ទៃដីចែកចេញជាប៉ុន្មានហិកតា សំរាប់ធ្វើកសិកម្ម, ស្រូវប្រាំង, ស្រូវវស្សា, ផ្ទៃដីចំការ, ដីព្រៃ, ផ្ទៃដីព្រៃក បឹងបួរ-ទន្លេ, ដីសំណង់សាធារណៈ, ដីលំនៅដ្ឋាន ជាដើម។ បន្ទាប់មកត្រូវបំពេញព័ត៌មានដោយលើកយកតែផ្ទៃដីសំរាប់បង្កបង្កើនផលមួយមុខ ប៉ុណ្ណោះមកលំអិតជាតួលេខនៅតាមបណ្តាក្រុង/ស្រុក ឬ ឃុំ នីមួយៗ ដូចមានក្នុងតារាងគំរូខាងក្រោម:

ល.រ	***ឈ្មោះក្រុង/ស្រុក ឬ ឃុំ***	***ដីស្រែ***			
		ស្រែវស្សា		**ស្រែប្រាំង**	
		ពឹងទឹកភ្លៀង (ហ.ត)	បញ្ជូលទឹកបង្ត្រាប់ (ហ.ត)	បញ្ជូលទឹកទាំងស្រុង (ហ.ត)	ស្រូវស្រាល (ហ.ត)
១					
២					
៣					
៤					

សរុប					

ខ. ទិន្នន័យប្រជាសាស្ត្រ

ល.រ	**ឈ្មោះស្រុក/ក្រុង ឬ ឃុំ**	**ចំនួនគ្រួសារ**	**ចំនួនមនុស្ស**	**ប្រុស**	**ស្រី**
១					
២					
៣					
៤					

សរុប:					

- ***ចំនួនប្រជាពលរដ្ឋ:***
- ***មុខរបរសំខាន់ៗរបស់ប្រជាពលរដ្ឋ:*** អ្នករៀបចំផែនការ ត្រូវសរសេររៀបរាប់អំពីមុខរបរសំខាន់ៗជាងគេ ដែលប្រជាពលរដ្ឋ ភាគច្រើនក្នុងខេត្ត ឬស្រុក/ក្រុង បានប្រកបរបរចិញ្ចឹមជីវិតរបស់ពួកគេ។ តមកទៀត ត្រូវសរសេរ រៀបរាប់ពីមុខរបរ និងការងារបន្ទាប់បន្សំដទៃទៀតផងដែរ ជាមួយនឹងហេតុផលផ្សេងៗ ដែលបណ្តាលឱ្យប្រជាពលរដ្ឋទៅប្រកបមុខរបរបន្ទាប់បន្សំខាងលើ។ ជាចុងក្រោយ ពិតមានស្តីពីប្រភេទមុខរបរនីមួយៗ(គិតជា%)គួរបំពេញបន្ថែមទៀត នៅក្នុងតារាងគំរូជាឧទាហរណ៍ខាងក្រោមនេះ:

ប្រភេទមុខរបរ	**ភាគរយ (%)**
កសិកម្ម	--- %
លក់ដូរ	--- %
ចិញ្ចឹមសត្វ	--- %

ឡើងត្នោត	--- %
ដាំដំណាំ	--- %
តម្បាញ	--- %
គ្រួសារធ្វើចំណាកស្រុក (ប្រចាំថ្ងៃ)	--- %
គ្រួសារធ្វើចំណាកស្រុក យូរអង្វែង (រយៈពេល៦ខែឡើង)	--- %

- ***ក៏វិតវប្បធម៌:***

ល.រ	ប្រភេទសិស្ស	សរុប (នាក់)	សិស្សស្រី	សិស្សប្រុស
១	មហាវិទ្យាល័យ			
២	វិទ្យាល័យ			
៣	អនុវិទ្យាល័យ			
៤	បឋមសិក្សា			
៥	មត្តេយ្យសិក្សា			

គ. ប្រវត្តិគ្រោះមហន្តរាយ

- ***តារាងវិភាគពីប្រភេទគ្រោះមហន្តរាយតាមឆ្នាំ*** (តារាង ឧទាហរណ៍)

ល.រ	ប្រភេទមុខសញ្ញា	២000	២00១	២00២	២00៣	២00៤	២00៥	---	---
១	ទឹកជំនន់	x xx		x x		x			
២	រាំងស្ងួត				x x		x		
៣	ខ្យល់ព្យុះ	x					x x		
៤	ជំងឺមនុស្ស (រាតត្បាត)		x x		x				
៥	អគ្គិភ័យ							x x	
៦	គ្រោះថ្នាក់ចរាចរ				x x				
៧	សត្វល្អិតបំផ្លាញដំណាំ		x x			x			
៨	រន្ទះបាញ់					x		x xx	
---	.....								
---	.....								

<u>កំណត់សំគាល់</u>: x = តិចតួច/ស្រាល, xx = មធ្យម, xxx = ធំ ឬ ធ្ងន់ធ្ងរ

- ***តារាងតួលេខពីផលប៉ះពាល់ដោយគ្រោះមហន្តរាយតាមឆ្នាំ***

លរ	ប្រភេទនៃផលប៉ះពាល់	២000	២00១	២00២	២00៣	--	--	--	សរុប
១	ចំនួនមនុស្សស្លាប់ (នាក់)								
២	ចំនួនគ្រួសារការប៉ះពាល់								
៣	ចំនួនប្រជាជនរងការប៉ះពាល់								
៤	ចំនួនឃុំរងការប៉ះពាល់								
៥	ចំនួនភូមិរងការប៉ះពាល់								
៦	ចំនួនផ្ទះរងការខូចខាត								
៧	ចំនួនផ្ទះរងការខូចខាតដោយអគ្គីភ័យ								
៨	ចំនួនផ្ទះរងការខូចខាតដោយខ្យល់ព្យុះ								
៩	ចំនួនស្ពានរងការខូចខាត								
១0	ប្រវែងផ្លូវលំរងការខូចខាត								
១១	ស្រូវវស្សារងការខូចខាត(ហត)								
១២	ស្រូវប្រាំងរងការខូចខាត(ហត)								
១៣	ដំណាំអនុផលរងការខូចខាត(ហត)								
១៤	ចំនួនសត្វពាហនៈងាប់								
១៥	ចំនួនសាលារៀនរងការខូចខាត								
១6	ចំនួនអណ្តូងទឹករងការប៉ះពាល់								
--									

ឃ. ធនធានសំខាន់ៗ

- ***សាលារៀន វត្ត និង ទូលសុវត្ថិភាព***

ស្រុក/ក្រុង ឬ ឃុំ/សង្កាត់	មតេយ្យសិក្សា			បឋមសិក្សា			មធ្យមសិក្សា			ចំនួន វត្ត	ទូល សុវត្ថិភាព
	ចំនួនខ្នង	គ្រូប្រុស	គ្រូស្រី	ចំនួនខ្នង	គ្រូប្រុស	គ្រូស្រី	ចំនួនខ្នង	គ្រូប្រុស	គ្រូស្រី		
១ ---											
២ ---											
៣ ---											
៤ ---											

<u>**សរុប**</u>											

- ***ប្រពន្ធ័ធារាសាស្ត្រ***

ល.រ	ស្រុក/ក្រុង ឃុំ/សង្កាត់	ព្រៃក	ប្រឡាយ	ភ្លឺភ្លោះ	អូរ	អាង	ស្ទឹង	ទន្លេ	បឹង(ធំ)
១									
២									
៣									
៤									
--									
--									
<u>សរុប</u>									

- ***មណ្ឌលសុខភាព និង មន្ទីរពេទ្យ***

ល.រ	ស្រុក/ក្រុង ឃុំ/សង្កាត់	មណ្ឌល សុខភាព	*បុគ្គលិក*	ស្រុក ប្រតិបត្តិ	*បុគ្គលិក*	មន្ទីរពេទ្យ បង្អែក	*បុគ្គលិក*
១							
២							
៣							
៤							
--							
--							
<u>សរុប</u>							

- ***មធ្យោបាយដឹកជញ្ជូន***

ល.រ	ស្រុក/ក្រុង ឃុំ/សង្កាត់	ម៉ូតូ	ត្រាក់ទ័រ	គោយន្ត ភ្ជួរស្រែ	គោយន្ត កែផ្នែ	រទេះ គោ/សេះ	កង់	ទូកអ៊ុំ/ ចែវ	ទូកម៉ាស៊ីន /កាណូត
១									
២									
៣									
៤									
--									
<u>សរុប</u>									

- ***ប្រពន្ធ័ទំនាក់ទំនង***

លេខ.រ	ឈ្មោះ	តួនាទី/មុខងារ/អង្គភាព	ទូរស័ព្ទទំនាក់ទំនង
១			
២			
៣			
៤			
--			

១.៦ ផែនការសកម្មភាពសំរាប់ការកាត់បន្ថយគ្រោះภัยនៃគ្រោះមហន្តរាយ

អ្នករៀបចំផែនការត្រូវពិនិត្យមើលឱ្យបានច្បាស់លាស់ពីខ្លឹមសារសកម្មភាពអាទិភាពនានាដែលបានលើក និងកំណត់នៅក្នុងក្របខណ្ឌការងារយូរហ្គោដែលមានចំនួន០៥ចំណុច និងនៅក្នុងផែនការសកម្មភាពជាតិនៃយុទ្ធសាស្ត្រសំរាប់ការកាត់បន្ថយគ្រោះภัยនៃគ្រោះមហន្តរាយមានចំនួន ០៦ចំណុច ដើម្បីធ្វើយ៉ាងណាឱ្យផែនការបានឆ្លើយតបទៅនឹងប្របខណ្ឌការងារទាំងពីរខាងលើ។ ចំពោះខ្លឹមសាររួមនៃក្របខណ្ឌការងារ និងផែនការសកម្មភាពជាតិនៃយុទ្ធសាស្ត្រសំរាប់ការ កាត់បន្ថយគ្រោះภัยនៃគ្រោះមហន្តរាយ គឺមាននៅក្នុងស្យៀភៅផែនការយុទ្ធសាស្ត្រដែលបានរៀបចំឡើងដោយ NCDM ។

១.៧ យន្តការស្ថាប័ន និង ការគ្រប់គ្រងគ្រោះមហន្តរាយ

ក. សមាសភាព

- អភិបាលខេត្ត ឬស្រុក ជាប្រធាន
- អភិបាលរងខេត្ត ឬអភិបាលរងស្រុក ជាអនុប្រធាន
- ប្រធានមន្ទីរ អង្គភាព ឬការិយាល័យ ជាសមាជិក
- នាយខុទ្ទកាល័យខេត្ត ឬប្រធានមន្ទីរសាលាស្រុក ជាលេខាអចិន្ត្រៃយ៍ និងមានជំនួយការមួយចំនួនទៀត សំរាប់ជួយការងារតាមការចាំបាច់ ។

ខ. រចនាសម្ព័ន្ធគណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយខេត្ត ឬ ស្រុក

(សូមមើល រចនាសម្ព័ន្ធទាំងពីរ នៅក្នុងផ្នែកទី២) ។

គ. ក្រុមប្រតិបត្តិការ និង តួនាទី/ការទទួលខុសត្រូវ

(សូមមើល សមាសភាពរបស់ក្រុមប្រតិបត្តិការទាំង ០៤ និងតួនាទី/ការទទួលខុសត្រូវនីមួយៗ នៅក្នុងផ្នែកទី២) ។

១.៨ ផែនការសកម្មភាពរបស់មន្ទីរ-អង្គភាព ឬការិយាល័យជុំវិញខេត្ត/ស្រុក

អ្នករៀបចំត្រូវលើកទឹកចិត្តដល់គ្រប់មន្ទីរ-អង្គភាព ឬការិយាល័យជុំវិញខេត្តឬស្រុក ដើម្បីចូលរួមក្នុងការកសាងផែនការរបស់ពួកគេរៀងៗខ្លួន។ ការរៀបចំផែនការគ្រោះមហាមន្ត្រាយត្រូវធានាថាវាពាក់ព័ន្ធយ៉ាងពិតប្រាកដជាមួយនឹងការងារស្នូលរបស់មន្ទីរ-អង្គភាព ឬការិយាល័យនីមួយៗ។ ខាងក្រោមនេះ គឺជាតារាងគំរូនៃផែនការត្រៀមបង្ការគ្រោះ ទឹកជំនន់:

មន្ទីរ/អង្គភាព/ការិយាល័យ :..... (អ្នកតំណាង/ជនបង្គោល:..... ទូរស័ព្ទ: .....)

លេខ	ផែនការសកម្មភាពលំអិត	កត្តាវាស់វែង	អ្នកអនុវត្ត និង អង្គភាពពាក់ព័ន្ធ	ធនធានតម្រូវការ និង ថវិកាប៉ាន់ស្មាន	អាទិភាព និង ពេលវេលាអនុវត្ត			
					ខ្ពស់	មធ្យម	ទាប	រយៈពេល
I. ការងារត្រៀមបន្ទាន់គ្រោះទឹកជំនន់ (មុនទឹកជំនន់)								
១. ការពង្រឹងសមត្ថភាព និងបណ្តុះបណ្តាល ដល់សមាជិកគណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយខេត្ត-ស្រុក ឃុំ និង ភូមិ:								
១.១								
១.២								
២. ការផ្សព្វផ្សាយ និង បង្កើនការយល់ដឹងពីផលប៉ះពាល់ និង វិធានការត្រៀមបង្ការ ឆ្លើយតប ទៅនឹងមុខសញ្ញាបង្ករគ្រោះមហន្តរាយនានា ជាពិសេសទឹកជំនន់ ដល់ប្រជាជនដែលកំពុងរស់នៅក្នុងតំបន់ងាយរងគ្រោះតាមដងទន្លេ មេគង្គ និង ទន្លេនានាក្នុងស្រុក :								
២.១								
២.២								
៣. ប្រពន្ធ័ផ្តល់ពត៌មានជាមុនពីគ្រោះទឹកជំនន់ និង ឧបករណ៍វាស់ស្ទង់កំពស់ទឹកជំនន់ដែលបានរៀបចំនៅតាមភូមិ-ឃុំ ជាគោលដៅ :								
៣.១								
៣.២								
៤. ការស្តុក និងការគ្រប់គ្រងឃ្លាំងស្តុកសំភារ: និង ជំនួយសង្គ្រោះ:								
៤.១								
៥. យុទ្ធសាស្ត្រ សង្គ្រោះ ជំលៀស និង ស្រាវជ្រាវរុករកជនរងគ្រោះ ត្រូវបានរៀបចំ និង កំណត់ :								
៥.១								
៥.២								

៦. ការរៀបចំ និង គ្រប់គ្រងទីទួលសុវត្ថិភាព មុនពេលមានគ្រោះទឹកជំនន់ :								
៦.១								
៦.២								
៧. ការរៀបចំ និង គ្រប់គ្រងប្រពន្ធ័ផ្តល់ពិតមាន :								
៧.១								
៧.២								
II. ប្រតិបត្តិការឆ្លើយតប និង សង្គ្រោះបន្ទាន់ (ក្នុងពេលទឹកជំនន់)								
១. ត្រួតពិនិត្យមុខសញ្ញាបង្ករគ្រោះមហន្តរាយ និងគ្រោះថ្នាក់ដែលអាចកើតឡើង (ត្រួតពិនិត្យមើលស្ថានភាព):								
១.១								
១.២								
២. ការព្យាករណ៍ ការផ្តល់ពិតមានជាមុនពីគ្រោះមហន្តរាយទឹកជំនន់ និង ការផ្សព្វផ្សាយពិតមានព្យាករណ៍, ប្រកាសអាសន្នដល់សហគមន៍ :								
២.១								
២.២								
៣. យុទ្ធសាស្ត្រ សង្គ្រោះ ជំលៀស និង ស្រាវជ្រាវរកជនរងគ្រោះនៅរដូវទឹកជំនន់ (កក្កដា ដល់ វិច្ឆិកា) :								
៣.១								
៤. ការគ្រប់គ្រងប្រជាពលរដ្ឋដែលបានជម្លៀស មកស្នាក់នៅលើទីទួលសុវត្ថិភាពនៅរដូវទឹកជំនន់ :								
៤.១								
៥. កម្មវិធី ផ្នែកសេវាសុខភាព អនាម័យ និង ទឹកស្អាត :								
៥.១								

៦. ការវាយតំលៃ និង ការប៉ាន់ប្រមាណពីផលប៉ះពាល់ និង សេចក្ដីត្រូវការរបស់ជនរងគ្រោះ								
៦.១								
៧. ប្រតិបត្តិការឆ្លើយតបជំនួយសង្គ្រោះបន្ទាន់ :								
៧.១								
III. ការស្តារ និង ជួសជុលឡើងវិញ (ក្រោយទឹកជំនន់)								
១. ការវាយតំលៃ និង ការប៉ាន់ប្រមាណការខូចខាត និងសេចក្ដីត្រូវការ ដើម្បីធ្វើការស្តារ និង ជួសជុលឡើងវិញ :								
.១.១								
២. ការរៀបចំផែនការ និង យុទ្ធសាស្ត្រស្តារ, ជួសជុលឡើងវិញ ផ្អែកលើលទ្ធផលវាយតំលៃក្នុងចំណុច (៧.១):								
.២.១								
៣. ការអនុវត្តន៍គំរោងផែនការ និង យុទ្ធសាស្ត្រស្តារ-ជួសជុលឡើងវិញ ក្រោយទឹកជំនន់ :								
៣.១								

ថ្ងៃទី.....ខែ.....ឆ្នាំ ២០១....

ប្រធាន:.....

ហត្ថលេខា និង ត្រា

ឈ្មោះ.....

១.៩ ឯកសារភ្ជាប់/ឧបសម្ព័ន្ធផ្សេងៗ

- ផែនទីរដ្ឋបាល ផែនទីសេដ្ឋកិច្ច ផែនទីគ្រោះមហន្តរាយនានា ដូចជា: ទឹកជំនន់ រាំងស្ងួត ខ្យល់ព្យុះ សត្វល្អិត បំផ្លាញដំណាំ... ។
- អនុក្រឹត្យ, ដីការ និង សេចក្ដីណែនាំផ្សេងៗ ស្ដីពីការបង្កើតគណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយនានា (ថ្នាក់ខេត្ត ស្រុក និង ឃុំ ជាដើម) ។
- បញ្ជីរាយឈ្មោះអង្គការជាតិ អង្គការក្រៅរដ្ឋាភិបាលនានា ដែលកំពុងបំពេញការងារនៅក្នុងខេត្ត ស្រុក និងឃុំ គោលដៅ
- បញ្ជីវត្តមានរបស់អ្នកចូលរួមក្នុងសិក្ខាសាលារៀបចំផែនការ
- តារាងប្រៀបធៀបកំរិតភាពក្រីក្ររបស់ប្រជាពលរដ្ឋ ។ល។
- ផ្សេងៗ.....

III. ឯកសារយោង

- កម្មវិធីត្រៀមបង្ការគ្រោះមហន្តរាយខេត្ត-ស្រុក: ២០០៩-២០១១ ក្រោមគំរោង MRC/ADPC/GTZ ចោះពុម្ព ផ្សាយក្នុងខែមិថុនា ២០០៩ ។

មេរៀនទី ៣: ការធ្វើសមាហរណកម្មផែនការកាត់បន្ថយគ្រោះภัយនៃគ្រោះមហន្តរាយទៅក្នុងផែនការអភិវឌ្ឍថ្នាក់ជាតិ រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

I. ទិដ្ឋភាពរួម

ផែនការកាត់បន្ថយគ្រោះภัយនៃគ្រោះមហន្តរាយ ភ្ជាប់ទំនាក់ទំនងជាមួយផែនការអភិវឌ្ឍនៅគ្រប់ថ្នាក់ រួមមាន ថ្នាក់ជាតិ ខេត្ត ស្រុក និងថ្នាក់ឃុំ តាមរយៈកិច្ចសហប្រតិបត្តិការពហុវិស័យ និង ការគាំទ្រផ្នែកហិរញ្ញវត្ថុដែលខ្លួនស្វែងរកពី ថវិកាអភិវឌ្ឍ។ នៅពេលមានមុខសញ្ញាគ្រោះថ្នាក់កើតឡើង វាបង្កការផលប៉ះពាល់លើការអភិវឌ្ឍន៍ ជាពិសេសផ្នែកកសិកម្ម ផ្ទះ សម្បែង និងហេដ្ឋារចនាសម្ព័ន្ធ សុខភាព ការអប់រំ និង ការអភិវឌ្ឍនសំរាប់ស្ត្រី។ ដូច្នេះ វាជាការចាំបាច់ដែលតំរូវ អោយមានការរៀបចំ និងបញ្ជាបផែនការនេះ ជាមួយផែនការអភិវឌ្ឍន៍នៅថ្នាក់ខេត្ត-ក្រុង ហើយនៅកំរិតពហុវិស័យ វាត្រូវតែភ្ជាប់ការទំនាក់ទំនងផ្ទៃក្នុងជាមួយនឹងផែនការកាត់បន្ថយគ្រោះមហន្តរាយទាំងមូល និងភ្ជាប់ការទំនាក់ទំនងខាងក្រៅ ជាមួយផែនការអភិវឌ្ឍទាំងនៅថ្នាក់មូលដ្ឋាន និងនៅថ្នាក់ជាតិ។

ជំពូកនេះនឹងជួយអ្នកធ្វើផែនការកាត់បន្ថយគ្រោះภัយនៃគ្រោះមហន្តរាយ ឱ្យយល់ពីការភ្ជាប់ទំនាក់ទំនងរវាងផែនការកាត់បន្ថយគ្រោះภัយនៃគ្រោះមហន្តរាយ និងផែនការអភិវឌ្ឍ និងពីរបៀបដែលផែនការទាំងពីរនេះអាចបន្សីគ្នាបាន។ នៅទីបញ្ចប់ការប្រឈមមុខជាចំបងនៃដំណើរការសមាហរណកម្មនេះ ត្រូវបានលើកឡើងដើម្បីឱ្យអ្នកធ្វើផែនការបានដឹងច្បាស់ និងអាចយកឈ្នះលើវាបាន។

II. គោលបំណង

- លើកឡើងពីសារៈសំខាន់នៃការធ្វើសមាហរណកម្មផែនការ កាត់បន្ថយគ្រោះภัយនៃគ្រោះមហន្តរាយទៅក្នុងផែនការអភិវឌ្ឍន៍នៅគ្រប់កំរិត។
- ស្វែងយល់ពីទំនាក់ទំនង រវាងកាត់បន្ថយគ្រោះภัយនៃគ្រោះមហន្តរាយ និងការអភិវឌ្ឍន៍។
- ស្វែងយល់ពីការប្រឈមមុខជាចំបង នៃការធ្វើសមាហរណកម្មផែនការកាត់បន្ថយគ្រោះภัយនៃគ្រោះមហន្តរាយទៅក្នុងផែនការផ្សេងៗដទៃទៀត។
- យល់ពីវិធីសហការល្អប្រសើរ នៅក្នុងភ្នាក់ងារនានា របស់ខេត្ត-ស្រុក ដែលនាំទៅដល់ការភ្ជាប់ការទំនាក់ទំនងផែនការកាត់បន្ថយគ្រោះภัយនៃគ្រោះមហន្តរាយជាមួយផែនការផ្សេងៗទៀត។

III. គោលគំនិតសំខាន់ៗ

- ផែនការខុសៗគ្នាមាននៅគ្រប់កំរិតទាំងអស់របស់ប្រទេស ចាប់ពីថ្នាក់ជាតិ ខេត្ត ស្រុក និង ឃុំ។ អាស្រ័យលើទំហំ វិសាលភាពនិងពេលវេលានៃផែនការនីមួយៗ គោលបំណង និងវិធីនៃផែនការ គឺមានភាពខុសគ្នា។ ការដែលសំខាន់ គឺអ្នកធ្វើផែនការមូលដ្ឋាន មានការយល់ដឹងល្អពីផែនការអភិវឌ្ឍ និងផែនការកាត់បន្ថយគ្រោះภัយនៃគ្រោះមហន្តរាយ

នៅគ្រប់ក្រិត គោលបំណង និងវិស្តីផែនការ និងកំណត់ពីការជាប់ទាក់ទងដែលអាចបង្កើតបានរវាង ផែនការកាត់បន្ថយគ្រោះภัยនៃគ្រោះមហន្តរាយ និងផែនការអភិវឌ្ឍ ខេត្ត ឬ ស្រុក ។

- សារៈសំខាន់នៃការធ្វើសមាហរណកម្មការកាត់បន្ថយគ្រោះមហន្តរាយ ទៅក្នុងវិស្តីផែនការទ្សេងទាត់ (របស់ផ្នែក អភិវឌ្ឍ) មិនត្រឹមតែនៅថ្នាក់ខេត្ត និងថ្នាក់ស្រុកនោះទេ ប៉ុន្តែនៅថ្នាក់ជាតិក៏គួរឱ្យអ្នកពាក់ព័ន្ធបានយល់ដឹងផងដែរ ។ លទ្ធភាពនៃធនធានថវិកាបន្ថែមតាមរយៈការភ្ជាប់ទំនាក់ទំនងគួរតែបានលើកឡើង ដើម្បីធានាពីនិរន្តរភាព នៃការអនុវត្តន៍ផែនការកាត់បន្ថយគ្រោះภัยនៃគ្រោះមហន្តរាយ ។
- សមាហរណកម្មនៃផែនការ កាត់បន្ថយគ្រោះภัยនៃគ្រោះមហន្តរាយជាមួយផែនការកាត់បន្ថយគ្រោះមហន្តរាយ និងការអភិវឌ្ឍន៍ថ្នាក់មូលដ្ឋានតំរូវឱ្យអ្នកធ្វើផែនការកាត់បន្ថយគ្រោះภัยនៃគ្រោះមហន្តរាយ អាចចេះដឹងបាន អំពីនីតិវិធីធ្វើផែនការអភិវឌ្ឍ កំណត់ពេលវេលា និង យន្តការថវិកានៅតាមតំបន់របស់គេ ។
- សមាហរណកម្មក៏អំពាវនាវឱ្យមានប្រព័ន្ធសំរបសំរួលល្អប្រសើរជាច្រើន ដើម្បីឱ្យផែនការកាត់បន្ថយគ្រោះภัยនៃគ្រោះមហន្តរាយមានការគាំទ្រទាំងពីអាជ្ញាធរគ្រប់គ្រងគ្រោះមហន្តរាយនិងការអភិវឌ្ឍ និងមានថវិកាគ្រប់គ្រាន់ ។
- ដំណើរការធ្វើសមាហរណកម្ម នឹងបង្ហាញពីប្រសិទ្ធភាព ព្រោះស្ថាប័នគ្រប់គ្រងគ្រោះមហន្តរាយ និងស្ថាប័នផ្នែកអភិវឌ្ឍអាចអនុវត្តគំរោងរួមគ្នាបាន ។ ដំណើរការនេះធ្វើឱ្យសកម្មភាពត្រួតស៊ីគ្នាមានជាអប្បរមា ជំរុញការបង្កើតកម្មវិធីបន្ថែម និង លើកកំពស់ការរួមកំលាំងគ្នារវាងវិស័យទាំងពីរ ។
- ប្រសិនបើយើង ធ្វើមិនដឹងមិនញ្ញចំពោះស្ថាប័នដែលធ្វើការផ្នែកការគ្រប់គ្រងគ្រោះមហន្តរាយនៅថ្នាក់ខេត្ត-ស្រុក នោះផែនការអភិវឌ្ឍ នឹងនាំមកនូវភាពអសមត្ថភាព ដើម្បីព្យាករណ៍ទុកនូវធនធានមនុស្ស និង ធនធានហិរញ្ញវត្ថុដែលត្រូវការក្នុងកំឡុងពេលគ្រោះអាសន្ន ។ វាទំនងជាថា កង្វះភាពយល់ដឹងបែបនេះនឹងត្រូវចំណាយច្រើន និងធ្វើឱ្យផែនការអភិវឌ្ឍ និងការប៉ាន់ប្រមាណហិរញ្ញវត្ថុបរាជ័យ ។ ដូច្នេះការធ្វើសមាហរណកម្មក្លាយជាដំណើរការមួយសំរាប់អ្នកធ្វើផែនការ នៅក្នុងវិស័យទាំងពីរ ។

ផែនការ	***គោលបំណងនៃផែនការ***
ផែនការកាត់បន្ថយគ្រោះภัย នៃគ្រោះមហន្តរាយ	• *ប្រមូលធនធាន និង កំណត់វិធានការជាក់លាក់ ដើម្បីត្រៀមបង្ការ ឆ្លើយតប និង ស្តារឡើងវិញពី គ្រោះមហន្តរាយដែលខេត្ត-ស្រុក អាចនឹងប្រឈមមុខ ។*
ផែនការអភិវឌ្ឍខេត្ត-ស្រុក	• *កំណត់វិស័យអភិវឌ្ឍ និង ធនធានសក្តានុភាព ដើម្បីអនុវត្តកិច្ចការនៅថ្នាក់ខេត្ត និង ស្រុក ។*
ផែនការមន្ទីរខេត្ត-ស្រុក	• *ចំណាត់ធនធានសំរាប់ប្រតិបត្តិការជាប្រចាំ និងសំរាប់ការខិតខំប្រឹងប្រែងថ្មីៗ*
ផែនការពិសេសផ្សេងទៀតនៅថ្នាក់ ខេត្ត និង ស្រុក	• *ធានាថាសកម្មភាពថ្មី ដែលបានបង្កើតឡើងត្រូវបានអនុវត្ត ដោយមានធនធានគ្រប់គ្រាន់ (មនុស្ស សំភារៈ ហិរញ្ញវត្ថុ)*

IV. ឧបសគ្គចំៗនៃការធ្វើសមាហារណកម្ម

ការបញ្ចូលគ្នានៃផែនការកាត់បន្ថយគ្រោះภัយនៃគ្រោះមហន្តរាយ ជាមួយការអភិវឌ្ឍ គឺមិនទាន់ក្លាយជាដំណើរការល្អ នៅឡើយទេ នៅក្នុងការធ្វើសមាហារណកម្មនៅបណ្តារប្រទេសកំពុងអភិវឌ្ឍ។ ការដែលខ្វះការយល់ដឹងពីគ្នា និងកិច្ចសហការនៃស្ថាប័ន ឬអ្នកអនុវត្តវិស័យទាំងពីរនេះជាឧបសគ្គចំបង។ ខាងក្រោមនេះគឺជាការប្រឈម ដែលអ្នកធ្វើផែនការ និងអ្នកអនុវត្តការងារគ្រប់គ្រងគ្រោះមហន្តរាយ អាចប្រឈមក្នុងពេលធ្វើសមាហារណកម្មផែនការទាំងពីរនេះ ហើយក៏មើលឃើញជាផែនការកាត់បន្ថយគ្រោះภัយនៃគ្រោះមហន្តរាយត្រូវបានអនុវត្តមានប្រសិទ្ធភាព។

- **ចំណេះដឹងអំពីនីតិវិធីធ្វើផែនការអភិវឌ្ឍ និងការតាមដានរបស់វា:** វាតំរូវឱ្យ អ្នកធ្វើផែនការកាត់បន្ថយគ្រោះภัយនៃគ្រោះមហន្តរាយនិងអ្នកអនុវត្តការគ្រប់គ្រងគ្រោះមហន្តរាយដឹងច្បាស់ពីនីតិវិធីធ្វើផែនការអភិវឌ្ឍនៅក្នុងតំបន់របស់ពួកគេ និងអាចវាស់ស្ទង់វាបាន។ ការណ៍នេះ នឹងតំរូវឱ្យមានការពិចារណាអំពី :
    - តើប្រព័ន្ធផែនការអភិវឌ្ឍមានដំណើរការយ៉ាងដូចម្តេចនៅថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ និង មូលដ្ឋាន ។
    - តើអ្វីខ្លះជាពេលវេលាជាក់លាក់ សំរាប់ធ្វើផែនការអភិវឌ្ឍ និងស្នើឱ្យមានសំណើសកម្មภาពអភិវឌ្ឍដែលទាក់ទង (ពីស្ថាប័នធ្វើផែនការថ្នាក់មូលដ្ឋាន) ដើម្បីបានបញ្ចូលទៅក្នុងផែនការ។
    - តើនរណាជាអ្នកតាមមើល និងតើអ្វីជាកំរិតនៃអំណាចក្នុងការធ្វើផែនការអភិវឌ្ឍ។

ចំណេះដឹងអំពីនីតិវិធីទាំងនេះ នឹងអាចធ្វើឱ្យអ្នកធ្វើផែនការកាត់បន្ថយគ្រោះภัយនៃគ្រោះមហន្តរាយមានគំនិតល្អប្រសើរថា នៅពេលណាត្រូវតាមរកកិច្ចខិតខំប្រឹងប្រែងធ្វើសមាហារណកម្ម និងលើកផែនការកាត់បន្ថយគ្រោះภัយនៃគ្រោះមហន្តរាយ ដើម្បីឱ្យស៊ីគ្នាជាមួយនឹងវដ្តផែនការអភិវឌ្ឍ។

- **ការយល់ដឹងពីយន្តការថវិកាជាផ្លូវការ:** វាជាការសំខាន់ ដែលអ្នកធ្វើផែនការ និងអ្នកអនុវត្តការងារគ្រប់គ្រង គ្រោះមហន្តរាយ ដឹងពីយន្តការដែលបានយកមកចំណាត់ថវិកាសំរាប់ផែនការនៅតាមតំបន់។ ការណ៍នេះនឹងវាស់ក៏រិត អ្នកធ្វើផែនការត្រៀមបង្ការគ្រោះទឹកជំនន់ ដើម្បីដាក់ជូនផែនការកាត់បន្ថយគ្រោះภัយនៃគ្រោះមហន្តរាយ សំរាប់ការធ្វើសមាហារណកម្ម និងចំណាត់ធនធានបានទាន់ពេលវេលា។

- **ការសហការជាពហុវិស័យ**
    - ផ្តល់ និងចងក្រងទុកជាឯកសារនូវក្របខ័ណ្ឌសហការ និងសំរបសំរួលតែមួយ។ វានឹងធានាពីภาពស៊ីគ្នាការសហការ ការទំនាក់ទំនង និង ការកំណត់ច្បាស់លាស់នូវការទទួលខុសត្រូវនៅតាមវិស័យនានា។
    - ចាត់តាំងជនបង្គោលសំរាប់ការធ្វើសមាហារណកម្ម។
    - លើកឡើងនូវគំរោង គោលគំនិត របៀបវារៈការងារដើម្បីសំរបសំរួលការចូលរួម និងការអនុវត្តន៍នៅគ្រប់វិស័យ។ វាអាចនាំអោយមន្ទីរពាក់ព័ន្ធ និង អ្នកពាក់ព័ន្ធជាច្រើន ធ្វើការសហការ និង ជួយបង្កើតយន្តការ និងលើកកម្មវិធី ដែលអាចធ្វើការរួមគ្នាបាន។ ត្រូវផ្តល់ការថែទាំ ជាពិសេស ចំពោះការសហការគ្រប់វិស័យ និងគ្រប់ក៏រិត។

- ធានាការចូលរួមរបស់សហគមន៍ នៅក្នុងការធ្វើផែនការកាត់បន្ថយគ្រោះภัយនៃគ្រោះមហន្តរាយ ដោយមានការយល់ដឹងពិសេសចំពោះក្រុមដែលងាយរងគ្រោះ វានឹងស្តែងឱ្យឃើញនូវតំរូវការរបស់សហគមន៍ បង្កើតภาពជាម្ចាស់ និងការទាមទារមកលើអាជ្ញាធរ ដើម្បីធ្វើការងារក្នុងសក្តណៈបែបសហការគ្នា ។
- គាំទ្រការទទួលខុសត្រូវតាមបែបវិមជ្ឈការ និងសហវិមជ្ឈការក្នុងរចនាសម្ព័ន ដើម្បីធានាថាគោលនយោបាយត្រូវបានអនុវត្ត និងមានภาពบต់ปืนក្នុងយុទ្ធវិធីស្របតាមការផ្លាស់ប្តូរនៅពេលអនាគត ។

V. ឯកសារពិគ្រោះ

- ADPC ការបញ្ជាបការកាត់បន្ថយគ្រោះภัយនៃគ្រោះមហន្តរាយទៅក្នុងគោលនយោបាយការធ្វើផែនការ និងការអនុវត្តន៍នៅអាស៊ី
- Osbahr, Henny. Viner, David & Wakhungu, Judi. ទំនាក់ទំនងលំនាំផ្លាស់ប្តូរអាកាសធាតុ និងការគ្រប់គ្រងគ្រោះមហន្តរាយ : ការសិក្សានៅប្រទេស Kenya

ឯកសារបណ្តុះបណ្តាល

ផ្នែកទី ៦

ការចាត់ប្រមាណការខូចខាត និងសេចក្តីត្រូវការ

មេរៀនទី ១: ដំណើរការនៃការប៉ាន់ប្រមាណការខូចខាត និងសេចក្ដីត្រូវការ

I. គោលបំណង

សិក្ខាកាម ឬអ្នកចូលរួមទាំងអស់ អាចនឹងបានយល់ដឹងទូលំទូលាយពីនិតិវិធីនៃការប៉ាន់ប្រមាណលើការខូចខាតលើផ្នែកអាយុជីវិត, ការរងរបួស, ទ្រព្យសម្បត្ដិ ជាដើម សំរាប់រៀបចំជាផែនការ និងអនុវត្ដមានប្រសិទ្ធិភាព ទាំងផ្នែកជំនួយសង្គ្រោះ និងការស្ដារឡើងវិញ ក្រោយពីគ្រោះមហន្ដរាយបានកើតឡើង:

- ធម្មជាតិ និង វិសាលភាពនៃគ្រោះមហន្ដរាយ
- ការខូចខាត និង ការគំរាមកំហែងផ្សេងៗ
- តម្រូវការរបស់ប្រជាពលរដ្ឋ
- ធនធានដែលមាន និង សមត្ថភាពរបស់មូលដ្ឋានសំរាប់ធ្វើការឆ្លើយតប
- ជំរើសផ្សេងៗទាក់ទិនជំនួយសង្គ្រោះ, រយៈពេលយូរអង្វែងសំរាប់ស្ដារឡើងវិញ និងការអភិវឌ្ឍន៍
- តម្រូវការផ្សេងៗទៀតលើការជួយជ្រោមជ្រែងពីខាងអន្ដរជាតិ
- .....

II. ខ្លឹមសារមេរៀន

១. ទស្សនទានពីការប៉ាន់ប្រមាណការខូចខាត និង សេចក្ដីត្រូវការ

ការប៉ាន់ប្រមាណការខូចខាត គឺជាដំណើរការប្រមូលទិន្នន័យ ស្ថិតិ និងវិភាគនូវផលប៉ះពាល់អវិជ្ជមាន ពីគ្រោះមហន្ដរាយ ទោលើជីវិតមនុស្ស សេដ្ឋកិច្ច និងបរិស្ថាន និងកំណត់អត្ដសញ្ញាណ ភាពអាក្រក់ហួសហេតុ និងទំហំនៃគ្រោះមហន្ដរាយ ផលប៉ះពាល់អវិជ្ជមាន លើជីវិតមនុស្ស សេដ្ឋកិច្ច និងបរិស្ថានក្នុងតំបន់ ដែលឆាប់ទទួលគ្រោះមហន្ដរាយ។ ដោយហេតុនោះហើយទើបលើកឡើងនូវអំណាចជ្រើសរើស សម្រាប់ការស្ដារធ្វើឱ្យប្រសើរឡើងវិញ។

២. ដំណើរការប៉ាន់ប្រមាណលើការខូចខាត និង សេចក្ដីត្រូវការ

២.១ ការបង្កើតក្រុមប៉ាន់ប្រមាណ (Formation of the Assessment Team)



២.២ ជំហានៃការប៉ាន់ប្រមាណ (Steps of Assessment)

តើអ្វីខ្លះជាជំហានសំខាន់នៃការប៉ាន់ប្រមាណ?

ក. **ការរៀបចំ** (Preparation)



- ការចាត់ចែងប៉ាន់ប្រមាណ (Organizing Assessment Team)
- ឯកសារពាក់ពន្ធ័ (Relevant documents)
- ថវិកា (Budget)
- សំភារ: (Materials)
- មធ្យោបាយដឹកជញ្ជូន(Means of transportation)
- ទំនាក់ទំនងជាមួយតំបន់គោលដៅ (Communication with targeted area)

ខ. **ការចុះពិនិត្យតំបន់គោលដៅ** (Visiting targeted area)



- ចុះពិនិត្យសហគមន៍រងគ្រោះ
- ចាត់ចែងកិច្ចប្រជុំ
- សំភាសន៍
- អង្កេត, សង្កេត និង តាមដានសភាពការណ៍

គ. **ការវិភាគ** (Analysis)



- ប្រមូលទិន្នន័យ និង ព័ត៌មាន
- តម្រូវការផ្សេងៗ
- សមត្ថភាពនៅនឹងកន្លែង
- ធ្វើការសន្និដ្ឋាន និង វាយតំលៃ



ឃ. **ការសរសេររបាយការណ៍** (Writing report)

- កំណត់អ្នកដែលត្រូវដាក់ជូនរបាយការណ៍
- ជ្រើសរើសទំរង់របាយការណ៍
- ចាប់ផ្តើមសរសេររបាយការណ៍

ង. **ការដាក់ជូនរបាយការណ៍** (Submitting report)



- កំណត់អ្នកដែលត្រូវដាក់ជូនរបាយការណ៍
- រៀបចំលិខិតអម
- ត្រួតពិនិត្យមើលឯកសារដែលត្រូវជូនភ្ជាប់
- អ្នកណាខ្លះដែលត្រូវចំលងជូនជ្រាប
- ដាក់ជូនរបាយការណ៍

២.៣ វដ្ដនៃការរៀបចំនិងអនុវត្ដលើការប៉ាន់ប្រមាណពីការខូចខាត និងសេចក្ដីត្រូវការ



៣. ការប៉ាន់ប្រមាណការខូចខាត និងតម្រូវការតាមផ្នែក

៣.១ ការប៉ាន់ប្រមាណសង្គ្រោះបន្ទាន់អំពីសុខភាព

ការប៉ាន់ប្រមាណរហ័សអំពីសុខភាព

- ការប៉ាន់ប្រមាណរហ័សផ្នែកសុខភាព គឺជាការប្រមូលទិន្នន័យនិងពិតមាន ឱ្យបានចំទិសដៅ និងកម្មវត្ថុ ដើម្បីធ្វើការឆ្លើយតបសង្គ្រោះបន្ទាន់ ដល់ជនរងគ្រោះបណ្ដាលមកពីគ្រោះមហន្ដរាយ អំពីការខូចខាត និងសេចក្ដី ត្រូវការជាមូលដ្ឋាន។ ការប៉ាន់ប្រមាណរហ័ស គប្បីត្រូវធ្វើភ្លាមៗក្នុងខណៈពេលដែលគ្រោះមហន្ដរាយ បានកើតឡើង និងភ្លាមៗបន្ទាប់មក។
- វិធីដែលប្រសើរបំផុត គឺត្រូវរៀបចំឱ្យមានការវាយតំលៃរហ័សរួមគ្នាជាមួយបណ្ដាភ្នាក់ងារពាក់ពន្ធ័ដែលទទួលខុសត្រូវចំពោះការឆ្លើយតប និងសង្គ្រោះបន្ទាន់។
- ជំងឺឆ្លងក្នុងអំឡុងពេលទឹកជំនន់ និងការជំលៀសដោយគ្មានផែនការ ការវាយតំលៃ គប្បីធ្វើយ៉ាងយឺត បំផុតពី ០២ ទៅ ០៤ថ្ងៃ។
- ក្នុងករណីដែលគេគិតថាអាចមានគ្រោះទ្ធ្ភិក្សកើតឡើង ជាធម្មតាវាកើតឡើងដោយមានល្បឿនយឺត ដូចនេះការប៉ាន់ប្រមាណអាចតម្រូវឱ្យមានពេលវេលាវែងជាមូលដ្ឋាន។

- រូបមន្តសំខាន់ៗ ០៤យ៉ាងក្នុងការប្រមូលទិន្នន័យ:
  - ត្រួតពិនិត្យមើលសារឡើងវិញនូវអ្វីជាប្រភពពិតមានដែលមានស្រាប់
  - ពិនិត្យមើលដោយផ្ទាល់លើតំបន់គ្រោះថ្នាក់
  - សំភាសន៍ជាមួយមនុស្សសំខាន់ៗ
  - ត្រួតពិនិត្យតាមដានដើម្បីប៉ាន់ប្រមាណរហ័ស

ផលប៉ះពាល់ភ្លាមៗនៃគ្រោះមហន្តរាយដោយធម្មជាតិ

- **គោលបំណងនៃការប៉ាន់ប្រមាណ:**

ការប៉ាន់ប្រមាណគប្បីធ្វើភ្លាមៗតាមដែលអាចធ្វើទៅបានបន្ទាប់ពីព្រឹត្តិការណ៍បានកើតឡើង ដើម្បីកំណត់រកនូវ:

- ប្រភេទនៃការសង្គ្រោះបន្ទាន់ និងឆ្លើយតប
- ផលប៉ះពាល់លើសុខភាព
- ផលប៉ះពាល់ភ្លាមៗលើសេវាកម្មសុខភាព
- ការខូចខាតលើវិស័យដទៃទៀតទាក់ទងនឹងប្រតិបត្តិការផ្នែកសុខាភិបាល

<u>ដំណាក់កាលទី១ (ថ្ងៃទី ១):</u>

- ការឆ្លើយតបភ្លាមៗចំពោះតំបន់ដែលទទួលរងផលប៉ះពាល់ជាបឋម គឺត្រូវធ្វើដោយសហគមន៍ខ្លួនឯងផ្ទាល់
- នេះមានន័យថា វិធានការផ្នែកវេជ្ជសាស្ត្រត្រូវបានយកមកអនុវត្តដោយពុំចាំបាច់មានពិតមានគ្រប់គ្រាន់
- ធនធានទនៅមូលដ្ឋានត្រូវបានប្រើប្រាស់ដោយឥតព្រាងទុក

<u>ដំណាក់កាលទី២ (ថ្ងៃទី ២):</u>

ក្នុងដំណាក់កាលនេះការប៉ាន់ប្រមាណរហ័ស គួរផ្តោតលើ:

- សេចក្តីត្រូវការនៃការឆ្លើយតបភ្លាមៗផ្នែកសុខភាពនៅក្នុងតំបន់រងគ្រោះ
- កង្វះខាតប្រភពធានសំរាប់សេវាកម្មសុខភាពបឋម
- សេចក្តីត្រូវការបំពេញបន្ថែម ដូចជា: សេវាកម្មសុខភាព ជំរក ស្បៀងអាហារ ទឹកស្អាត
- តម្រូវការប្រភពធនធានបន្ថែមពីថ្នាក់ជាតិ និង អន្តរជាតិ (ដើម្បីផ្តល់បន្ថែមនូវសេវាសុខាភិបាលចាំបាច់ និង បង្កើនបរិមាណស្តុកថ្នាំពេទ្យ ក៏ដូចជា គ្រឿងបរិក្ខារ និង ឧបករណ៍ពេទ្យ ផងដែរ ។

<u>ដំណាក់កាលទី៣ (ថ្ងៃទី ៣-៥):</u>

ក្នុងដំណាក់កាលនេះ ការកសាងឡើងវិញនូវ សុខភាពបឋម ការសង្គ្រោះ និង ជំរក គឺជាបញ្ហាអាទិភាព។ ដូចនេះ ការវាយតំលៃរហ័សគួរផ្តោតការយកចិត្តទុកដាក់ខ្លាំងលើ:

- បរិស្ថានសុខភាព, សន្តិសុខ, សុវត្ថិភាពស្បៀង និង សេវាសុខភាពសាធារណៈ
- ការការពារ ជាពិសេសចំពោះជំរករបស់ប្រជាជនដែលងាយរងគ្រោះ
- ស្តារ និងធ្វើឱ្យមានដំណើរការឡើងវិញនូវប្រពន្ធ័សេវាសកម្មសុខភាពបឋម

ដំណាក់កាលទី៤ (បន្ទាប់ពីថ្ងៃទី ៥):

បន្ទាប់ពីរយៈពេល០៥ថ្ងៃ ផែនការឆ្លើយតបសង្គ្រោះបន្ទាន់ គប្បីធ្វើឱ្យបានពេញលេញ។ ប្រតិបត្តិការ ឆ្លើយតប និងស្តារឡើងវិញគ្រប់ផ្នែកគប្បីមាននៅនឹងកន្លែង ហើយចាប់តាំងពីពេលនេះ ការវាយតំលៃសុខភាព ត្រូវផ្តោតការយកចិត្តទុកដាក់លើ:

- ផ្នែកលើប្រពន្ធ័ត្រួតពិនិត្យ ដែលបានបង្កើតឡើង។
- ដាក់បញ្ចូលពិតមាន អំពីការត្រួតពិនិត្យទៅលើជំងឺ និង អំពីប្រពន្ធ័ថែទាំសុខភាព។
- ការផ្តោតទៅលើនិន្នការសុខភាពដោយហេតុថា វាជាប់ពាក់ពន្ធ័ទៅនឹងការឆ្លើយតប និងប្រតិបត្តិការស្តារឡើងវិញ។
- ការរួមវិភាគទាន ចំពោះការប្រើប្រាស់ឱ្យមានប្រសិទ្ធិភាពខ្ពស់ តាមធានធានជាតិ និងអន្តរជាតិ។

ការអនុវត្តន៍ ការប៉ាន់ប្រមាណ:

ចំពោះពិតមានដែលប្រមូលបានចាំបាច់ត្រូវបញ្ជាក់:

- ចំនួនប្រជាជន (ភេទ, អាយុ)
- ឈ្មោះតំបន់ដែលងាយរងគ្រោះធ្ងន់ធ្ងរ
- ការខូចខាត ចំពោះប្រពន្ធ័សុខាភិបាល ផលប៉ះពាល់ និង មិនប៉ះពាល់
- ពិតមានទាំងនេះ ត្រូវមានលក្ខណៈងាយស្រួលដល់ការអង្កេតពិនិត្យបន្តទៀត

ការប៉ាន់ប្រមាណផលប៉ះពាល់ទៅលើផ្នែកសុខភាព:

- ***របួស:***
  - ការរញ្ជួយដី បង្ករបួសច្រើន។
  - គ្រោះទឹកជំនន់ របួសតិចតួច តែស្លាប់ច្រើន។
  - ប្រភេទរបួសស្នាម (ដូចជា: ការដាច់ រហែក បាក់ រលាក)។
  - កន្លែងរបួស (ដូចជា: ដៃ ជើង ក្បាល)។

វិធីសាស្ត្រ និងការប្រមូលពិតមាន:

ពេលណា	ទីកន្លែង ឬប្រភពផ្តល់ព័ត៌មាន
ក្នុងដំណាក់កាលក្រោយមានផលប៉ះពាល់ភ្លាមៗ	មន្ទីរពេទ្យ (ទិន្នន័យអ្នកប្រើប្រាស់បន្ទប់ និងតួលេខអ្នកសំរាកពេទ្យ, គិតទាំងពេទ្យចល័ត) ទាំងនេះជាប្រភពពិតមានល្អបំផុត។
ដំណាក់កាលបន្ទាន់	➢ ឱសថស្ថាន ➢ មណ្ឌលសុខភាពសហគមន៍ ➢ មណ្ឌលជំលៀស ➢ មន្ត្រី និងថ្នាក់ដឹងនាំមូលដ្ឋាន ➢ អង្គការក្រៅរដ្ឋាភិបាល និង អង្គការសហគមន៍

- ***ការណីមនុស្សស្លាប់:***

ជាពិតមានស្តីពីមរណភាព ជាតួលេខ ទិន្នន័យដទៃទៀតត្រូវបានប្រមូលបន្ទាប់ពីការឆ្លើយតប និងសង្គ្រោះ បន្ទាប់ដែលអាចជួយយើងក្នុងការត្រៀមជាមុនសំរាប់ពេលអនាគត។ កត្តាទាំងនោះ រួមមាន:

- អត្រាស្លាប់ទក់ទិននឹងអាយុភេទ
- ឧប្បត្តិហេតុបណ្តាលឱ្យស្លាប់
- កត្តាគ្រោះថ្នាក់បណ្តាលឱ្យស្លាប់

- ***ការប៉ាន់ប្រមាណផលប៉ះពាល់លើសេវាសុខភាព:***

សេវាសុខភាព

ការប៉ាន់ប្រមាណរហស័គប្បីត្រូវមានព័ត៌មាន:

- ទំហំនៃការខូចខាត
- ទីតាំងសេវា ដែលកំពុងដំណើរការ
- ទីតាំងដែលមិនខូខាត
- ចំនួនទីកន្លែង និងប្រភេទមណ្ឌលផ្តល់សេវា
- ស្ថានភាពរចនាសម្ព័ន្ធ នៃមណ្ឌលថែទាំសុខភាពក្រោយពេលកើតហេតុការណ៍
- សមត្ថភាពក្នុងពេលបច្ចុប្បន្ន នៃមណ្ឌលសុខភាព
- ការអាក់ខានក្នុងការងារទំនាក់ទំនង និងបណ្តាញផ្គត់ផ្គង់នានា
- ចំនួនរបួស និងស្លាប់របស់បុគ្គលិក
- ដំណើរការនៃអគ្គិសនី និងការផ្គត់ផ្គង់ (មាន ឬ គ្មាន)
- កង្វះខាតក្នុងការចាត់ចែង ស្តីពីបុគ្គលិកសំខាន់ៗ
- កង្វះខាតធ្ងន់ធ្ងរ ស្តីពី សំភារៈ ការផ្គត់ផ្គង់សំខាន់ៗ និង ថ្នាំពេទ្យ

បរិស្ថានសុខភាព

ការប៉ាន់ប្រមាណអំពីស្ថានភាព នៃសេវាទាក់ទងនឹងសុខភាព រួមមាន:

- ការផ្គត់ផ្គង់ទឹក
- បញ្ហាអនាម័យ (ប្រពន្ធ័បង្ហូរទឹកសំអុយ)
- ការគ្រប់គ្រងជំងឺ ដែលចំលងដោយភ្នាក់ងារចំលងជំងឺ
- បញ្ហាជំរក
- បញ្ហាដឹកជញ្ជូន

ការប៉ាន់ប្រមាណអំពីផលប៉ះពាល់នៃផ្នែកនានានឹងសុខភាព :

- ស្បៀងអាហារ

- ជំរក និង ផ្ទះសំបែង
- ការដឹកជញ្ជូន និងការងារទំនាក់ទំនង

<u>បញ្ជាក់:</u> បន្ទាប់ពីមានគ្រោះមហន្តរាយដែលមានផលប៉ះពាក់ភ្លាមៗ ការវាយតំលៃអំពីស្ថានភាព អាហារូបត្ថម្ភ ពុំមែនជាចំនុចអាទិភាពទេ។

៣.២ ការប៉ាន់ប្រមាណអំពីទឹក និងអនាម័យ

ទិដ្ឋភាពទូទៅ

- តើមានប្រជាជនប៉ុន្មាននាក់ដែលបានទទួលរងការប៉ះពាល់ (ដោយសារព្រឹត្តិការណ៍អ្វីមួយឬច្រើន) និងថាតើព្រឹត្តិការណ៍ទាំងនោះបណ្តាលមកពីអ្វី? តើប្រជាជនរស់នៅកន្លែងណាខ្លះ? តើប្រជាជនត្រូវបានចាត់ចែងដូចម្តេច? តើពួកគេមានជំរកស្នាក់នៅសមរម្យ ឬជានិច្ចកាលផ្លាស់ប្តូរពីកន្លែងមួយ ទៅកន្លែងមួយទៀត?
- តើមានការកើតឡើងនូវជំងឺអ្វីខ្លះដែលទាក់ទងនឹង ទឹក និង អនាម័យ ក្នុងពេលបច្ចុប្បន្ន និងអនាគត?
- តើនរណាខ្លះកំពុងធ្វើការផ្នែកទឹក និង អនាម័យ ហើយមានតួនាទីអ្វីខ្លះ?

សំណួរផ្សេងៗទាក់ទងនឹងការទប់ស្កាត់ការរីករាលដាលនៃរោគនានា

- <u>ទឹក</u>
  - តើទឹក និងការប្រើប្រាស់ទឹកទទួលផលប៉ះពាល់ដូចម្តេចក្នុងស្ថានភាពគ្រោះអាសន្ន?
  - តើអ្វីខ្លះជាប្រភពទឹកស្អាតបច្ចុប្បន្ន? តើប្រភពទឹកអ្វីខ្លះប្រើប្រាស់សំរាប់ងូត បោកគក់សំលៀកបំពាក់ និងប្រើប្រាស់នៅក្នុងគ្រួសារ?
  - តើបរិមាណទឹកប៉ុន្មានសំរាប់មនុស្សម្នាក់ក្នុង១ថ្ងៃ? ហើយតើមនុស្សគ្រប់ក្រុមទាំងអស់(បុរស-ស្ត្រី-កូនក្មេង ដោយមិនគិតពីឋានៈក្នុងសង្គម) អាចមានលទ្ធភាពស្មើគ្នាក្នុងការប្រើប្រាស់ទឹកដែរឬទេ? តើពួកគេត្រូវចំណាយពេលប៉ុន្មានដើម្បីអាចយកទឹកមកប្រើប្រាស់បាន? (សន្ទស្សន៍តាមផ្នែក: ១៥លីត្រ/ ថ្ងៃ)។
  - តើមានប្រភពទឹកចំនួនប៉ុន្មាន? តើវាគ្រប់គ្រាន់សំរាប់សេចក្តីត្រូវការរយៈពេលខ្លី និងវែង ដែរឬទេ? (សន្ទស្សន៍តាមផ្នែក: ០.១២៥លីត្រ/១នាទី, ហើយយ៉ាងតិចបំផុតក៏អាចឱ្យប្រជាជនចំនួន ២៥០នាក់ ប្រើប្រាស់ គ្រប់គ្រាន់ពីប្រភពនីមួយៗ)។
  - តើចំងាយពីប្រភពទឹកទៅកន្លែងប្រជាជនរស់នៅមានប្រវែងប៉ុន្មាន? (សន្ទស្សន៍តាមផ្នែក: ៥០០ម៉ែត្រ ពីប្រភព ទៅជំរកស្នាក់នៅ)។
  - តើបរិមាណទឹកដែលមានស្រាប់អាចគ្រប់គ្រាន់ដែរឬទេ? តើអ្វីខ្លះដែលជះឥទ្ធិពលដល់ការផ្គត់ផ្គង់ទឹក? តើការផ្គត់ផ្គង់ទឹកមានរយៈពេលប៉ុន្មាន?
  - តើនរណាខ្លះត្រូវចូលរួមគ្រប់គ្រង និងថែរក្សាប្រភពទឹក?

- តើប្រភពទឹកមានភាពក្រខ្វក់ដែរឬទេ? តើប្រភពទឹកអាចនឹងប្រឈមមុខនឹងភាពក្រខ្វក់ដែរឬទេ? (អតិសុខុមប្រាណ និង ជាតិគីមី-ជាតិវិទ្យុសកម្ម) ប្រសិនបើមាន, តើអ្វីដែលបង្កឱ្យមានភាពក្រខ្វក់? (សន្ទស្សន៍តាមផ្នែក: អត្រាបាក់តេរីតូចជាង ១០ក្នុងទឹក ១00មីលីលីត្រ នៅកន្លែងមានប្រភពទឹក)។ តើសត្វពាហនៈមានទឹកផឹកដែរទេ? តើសត្វពាហនៈផឹកទឹកនៅឯប្រភពទឹករួមជាមួយមនុស្សដែរឬទេ?
- តើការធ្វើប្រព្រឹត្តិកម្មទឹកចាំបាច់ដែរឬទេ? តើការធ្វើប្រព្រឹត្តិកម្មទឹកអាចប្រព្រឹត្តទៅបានដែរឬទេ? តើប្រភេទនៃប្រព្រឹត្តិកម្មអ្វីដែលចាំបាច់?
- តើការសំលាប់មេរោគចាំបាច់ដែរឬទេ ប្រសិនបើទឹកមិនមានភាពក្រខ្វក់ទេនោះ? បើសិនជាចាំបាច់ តើហេតុអ្វី? (ក្លរីនកំចាត់មេរោគពី 0.២-១.៥មីលីក្រាម/លីត្រ និងកំហាប់ ៥ NTU, TDs មិនលើសពី១000មីលីក្រាម/លីត្រទឹក)។
- តើអ្វីដែលជាប្រភពទឹកល្អ? នៅឯណា?
- តើមានឧបសគ្គអ្វីផ្នែកច្បាប់អ្វីខ្លះចំពោះការប្រើប្រាស់ធនធានទឹកដែលមាន?
- តើប្រជាជនអាចផ្លាស់ប្តូរទីលំនៅបានដែរឬទេ? ប្រសិនបើពុំមានប្រភពទឹកគ្រប់គ្រាន់? តើអ្នកណាជាអ្នកមានសិទ្ធិសំរេច?
- តើបញ្ហាអនាម័យសំខាន់ទាក់ទងនឹងការផ្គត់ផ្គង់ទឹកមានអ្វីខ្លះ? តើប្រជាជនប្រើមធ្យោបាយអ្វីខ្លះ ក្នុងការដឹកជញ្ជូនទឹក និងស្តុកទឹកសំរាប់ប្រើប្រាស់ក្នុងគ្រួសារ? តើប្រជាជនមានឧបករណ៍សំរាប់ដាក់ទឹក ដែលមានទំហំ និងប្រភេទត្រឹមត្រូវគ្រប់គ្រាន់ឬទេ? (ស្តង់ដារអឃ្ជរមាបានកំណត់ថា សំរាប់គ្រួសារនីមួយៗត្រូវប្រដាប់ស្តុកទឹកចំណុះ ២0លីត្រ មួយ)។

- <u>**អនាម័យ**</u>

ការកសំណាល់រាវ

- តើការប៉ាន់ស្មានមានប្រជាជនប៉ុន្មាននាក់ ហើយមានរបាយប្រជាជនដូចម្តេចដែរនៅក្នុងតំបន់នេះ? (សន្ទស្សន៍តាមផ្នែក: ជាអតិបរមាមានប្រជាជន ២0នាក់ ប្រើប្រាស់បង្គន់មួយ)។
- តើទំនៀមទំលាប់នៃការបន្ទោបង់ មានការផ្លាស់ប្តូរនៅពេលមានគ្រោះអាសន្នដែរឬទេ? តើការបន្ទោបង់ដែលអនុវត្តនាពេលបច្ចុប្បន្ននេះ អាចជាការគំរាមកំហែងដល់សុខភាពដែរឬទេ? ប្រសិនបើមានការគំរាមកំហែង តើគំរាមកំហែងដូចម្តេច? (សន្ទស្សន៍តាមផ្នែក: បង្គន់អនាម័យ ស្ថិតនៅចំងាយជាង៣0ម៉ែត្រពីប្រភពទឹកក្នុងដី)។
- តើមានជំនឿ និងទំនៀមទំលាប់ដូចម្តេចខ្លះនាពេលបច្ចុប្បន្ននេះទាក់ទងទៅនឹងការបន្ទោបង់ ជាពិសេសទំលាប់ និងតរិយាបថរបស់ស្ត្រីចំពោះការបន្ទោបង់របស់កុមារ? តើសំភារៈអ្វីខ្លះ ឬទឹកដូចម្តេចខ្លះដែលគេប្រើប្រាស់ក្រោយពេលបន្ទោរបង់? តើមានសំភារៈ និងទឹកដែរឬទេ?

- តើមានមូលដ្ឋានសំភារៈសំរាប់ប្រើប្រាស់ដែរឬទេ? ប្រសិនបើមាន តើមូលដ្ឋានសំភារៈទាំងនោះកំពុងត្រូវបានគេប្រើប្រាស់ហើយឬនៅ? តើមានមូលដ្ឋានសំភារៈគ្រប់គ្រាន់ឬទេ តើមូលដ្ឋានសំភារៈទាំងនោះមានប្រតិបត្តិការល្អដែរឬទេ? តើមាននរណាខ្លះជាអ្នកសំអាត និង ថែទាំមូលដ្ឋានសំភារៈទាំងនោះ?
- តើគ្រប់ក្រុមទាំងអស់មានលទ្ធភាពប្រើប្រាស់មូលដ្ឋានសំភារៈទាំងនោះស្មើៗគ្នាដែរឬទេ? (សន្ទស្សន៍តាមផ្នែក: បង្គន់អនាម័យមានចំងាយមិនលើសពី ៥០ម៉ែត្រ ពីលំនៅដ្ឋាន ឬដើរក្នុងរយៈពេលមិនលើស ពី ១នាទី) ។ តើមូលដ្ឋានសំភារៈទាំងនោះអាចពង្រីក ឬកែសំរួលបានទេ?
- តើស្ត្រីធ្វើដូចម្តេចពេលមានរដូវ? តើមានសំភារៈ ឬមូលដ្ឋានសំភារៈសំរាប់ដោះស្រាយបញ្ហាពេលមានរដូវដែរឬទេ?
- តើមានសំភារៈអ្វីខ្លះសំរាប់លាងសំអាតដៃបន្ទាប់ពីបន្ទោរបង់រួច? តើមានសាប៊ូ និងទឹកដែរឬទេ?
- តើទាំងបុរស និងស្ត្រីបានត្រៀមលក្ខណៈប្រើប្រាស់: វាលបន្ទោរបង់ បង្គន់អនាម័យសាធារណៈ ឬបង្គន់អនាម័យសំរាប់គ្រួសារដែរឬទេ?
- តើមានកន្លែង ឬដី គ្រប់គ្រាន់សំរាប់វាលបន្ទោរបង់ បង្គន់អនាម័យ(នៅពេលមានទឹកជំនន់) ដែរឬទេ?
- តើកំរិតទឹកក្រោមដីមានកំពស់ប៉ុន្មាន?(សន្ទស្សន៍តាមផ្នែក: បាតរណ្តៅបង្គន់អនាម័យ ស្ថិតនៅជាង ១ម៉ែត្រកន្លះ លើផ្ទៃទឹក) ។
- តើមានសំភារៈអ្វីខ្លះនៅមូលដ្ឋានសំរាប់ការសាងសង់បង្គន់អនាម័យ?
- តើមានប្រជាជនដែលចេះពីរបៀបសាងសង់បង្គន់អនាម័យដែរឬទេ?
- តើភ្លៀងចាប់ផ្តើមធ្លាក់នៅពេលណា?

ការបោះចោលកាកសំណល់រឹង

- តើកាកសំណល់រឹងចោទជាបញ្ហាដែរឬទេ?
- តើប្រជាជនបោះចោលកាកសំណល់ដោយរបៀបណា? (សន្ទស្សន៍តាមផ្នែក: ធុងសំរាមមានចំងាយ ១៥ម៉ែត្រ ពីលំនៅដ្ឋាន ឬចំងាយ ១00ម៉ែត្រ ពីរណ្តៅសំរាមសាធារណៈ) ។
- តើកាកសំណល់រឹងមានប្រភេទដូចម្តេច និងមានបរិមាណប៉ុន្មាន?
- តើកាកសំណល់រឹងត្រូវបានបោះចោលត្រឹមត្រូវតាមកន្លែង ឬបានប្រមូលទៅចាក់ចោលខុសកន្លែង? (សន្ទស្សន៍តាមផ្នែក: ធុងសំរាមមានចំណុះ១00លីត្រ ចំនួន១សំរាប់ប្រជាជន១0គ្រួសារ ដែលដាក់នៅចំងាយ 0៥ម៉ែត្រ ពីលំនៅដ្ឋានដែលបោះសំរាមខុសច្បាប់) ។
- តើមូលដ្ឋានសំភារៈផ្នែកពេទ្យ និងសកម្មភាពសុខាភិបាល មានកាកសំណល់នេះដែរឬទេ? តើកាកសំណល់ទាំងនេះបោះចោលដោយរបៀបណា? តើនរណាជាអ្នកទទួលខុសត្រូវ?
- តើមានតម្រូវការអោយកប់សាកសពមនុស្ស និងសត្វដែរឬទេ?

ប្រព័ន្ធបង្ហូរទឹក

- ○ តើទឹកដែលនៅនឹង ឬទឹកហូរអាចបង្កឱ្យមានគ្រោះថ្នាក់ដល់សុខភាពរបស់ប្រជាជន តាមរយៈការផ្តល់ ទឹក ទឹកនៃ្ហងរស់នៅរបស់ភ្ជាក់ងារចំលង និងបង្កើតកូនចៅ តាមរយៈការធ្វើឱ្យប្រភពទឹកមានភាព ក្រខ្វក់ ឬធ្វើឱ្យមានទឹកជំនន់ដែរឬទេ?
- ○ តើតម្រូវការបង្កើតឱ្យមានប្រពន្ធ័បង្ហូរទឹកជាទ្រង់ទ្រាយតូចនៅជុំវិញបង្គន់អនាម័យ និងផ្ទះ ដែរឬទេ?

៣.៣ ការប៉ាន់ប្រមាណអំពីស្បៀង និងអាហារូបត្ថម្ភ

ទិដ្ឋភាពទូទៅ

- តើមានប្រជាជនប៉ុន្មាននាក់ដែលបានទទួលរងការប៉ះពាល់ (ពីអ្វីមួយ) និងបណ្តាលមកពីហេតុអ្វី? តើប្រជាជនរស់នៅកន្លែងណា? តើប្រជាជនត្រូវបែងចែកដូចម្តេច? តើប្រជាជនទាំងនោះមានលំនៅដ្ឋានត្រឹមត្រូវ ឬក៏ចល័តពីកន្លែងមួយទៅកន្លែងមួយ?
- តើបច្ចុប្បន្ននេះអ្វីជាការគំរាមកំហែងចំពោះសន្តិសុខស្បៀង និង អាហារូបត្ថម្ភ?

សន្តិសុខស្បៀង

- ហេតុអ្វីស្បៀងសំខាន់ៗដែលប្រើប្រាស់ជាទូទៅក្នុងតំបន់នេះមានអ្វីខ្លះ?
- តើបរិមាណស្បៀងមានការប្រែប្រួលទៅតាមរដូវដូចម្តេចខ្លះ? តាមធម្មតាការដាច់ស្បៀងកើតមាននៅពេលណា ហើយស្បៀងដែលមានច្រើនបំផុតនៅពេលណា ក្នុងមួយឆ្នាំ?ៗ? តើមានកត្តាសំខាន់ៗអ្វីខ្លះដែលធ្វើឱ្យប៉ះពាល់ដល់សន្តិសុខស្បៀងរបស់គ្រួសារ?
- តើបរិមាណស្បៀងធម្មតានៅក្នុងពេលឥឡូវនេះ មានការប្រែប្រួលឬទេ?
  - ○ តើស្បៀងសំខាន់ៗមានការប្រែប្រួលដូចម្តេច? (បរិមាណ គុណភាព រយៈពេល តំលៃ)
  - ○ តើមានកត្តាអ្វីខ្លះដែលមានឥទ្ធិពលលើវត្តមានរបស់ស្បៀង?
- តើតាមធម្មតាស្បៀងចេញមកពីប្រភពណា? ឧទាហរណ៍: ផលិតកម្ម ការដាំដុះ ការទិញដូរ ។ល។

លទ្ធភាពទទួលបានស្បៀង

- តើមានក្រុមសំខាន់ៗណាខ្លះស្ថិតក្នុងតំបន់ដែលទទួលរងផលប៉ះពាល់?
  - ○ កំណត់អំពីក្រុមគ្រួសារ ទៅតាមមធ្យោបាយដែលពួកគេទទួលបានស្បៀង, ឧទាហរណ៍: ការចិញ្ចឹមសត្វ ជំនួញ កសិកម្ម និង នេសាទ ។ល។
  - ○ តើក្រុមនីមួយៗរកបានស្បៀងដោយរបៀបណាមុនពេលមានវិបត្តិ?
  - ○ តើឥឡូវនេះក្រុមនីមួយៗរកស្បៀងបានដោយរបៀបណា?
  - ○ តើគេត្រូវធ្វើដូចម្តេចនៅពេលមានការខ្វះខាតស្បៀង?
  - ○ តើបញ្ហាយេនឌ័រអ្វីខ្លះដែលមានទំនាក់ទំនងនឹងលទ្ធភាពទទួលបានស្បៀងនៅក្នុងក្រុមខុសគ្នានេះ?

- តើអ្វីជាប្រពន្ធ័ទីផ្សារ(ស្បៀង) នៅក្នុងតំបន់នេះ? សូមបញ្ជាក់ពីទីតាំងភាពមមាញឹក, ទំនិញសំខាន់ៗ (បញ្ជាក់ពីទំនិញនៅក្នុងមូលដ្ឋាន ឬទំនិញនាំចូល) លក្ខណៈពិសេសរបស់ពណិជ្ជករ លទ្ធភាពក្នុងនោះ រួមមាន ក្រុមក្រីក្រទន់ខ្សោយ (ឧទាហរណ៍: ស្ត្រី) ចំងាយពីទីផ្សារទៅកន្លែងប្រជាជនរងគ្រោះរស់នៅ គោលនយោបាយគ្រប់គ្រងពាណិជ្ជកម្ម និងទីផ្សារទំនិញក្នុងស្រុក/នាំចូល ។ល។
- តើកត្តានៅក្នុងចំណុចលេខ៦ ខាងលើនេះ មានឥទ្ធិពលដូចម្តេចខ្លះទៅលើទីផ្សារស្បៀងនាពេលបច្ចុប្បន្ន? សូមរៀបរាប់ពីតំលៃបច្ចុប្បន្ន និងតំលៃធម្មតា(បញ្ជាក់ពីពេលវេលា និងទីកន្លែង) កន្លែងប្រភពស្បៀង នីមួយៗ?
- តើមានលក្ខខណ្ឌពាណិជ្ជកម្មស្បៀងសំខាន់ៗអ្វីខ្លះសំរាប់ប្រជាជនដែលទទួលរងផលប៉ះពាល់? តើអាចធ្វើការថ្លឹងថ្លែងពីតំលៃនៃស្បៀងសំខាន់ៗរបស់ខ្លួន ដូចជា: ធញ្ញជាតិ បើប្រៀបធៀបទៅនឹងតំលៃលក់នៅ តាមប្រភពទំនិញសំខាន់ៗទាំងនោះ ឧទាហរណ៍: សត្វពាហនៈ (ឧ. គោមួយក្បាល ត្រូវការស្រូវសាលីតែ ១០០គីឡូក្រាម ប៉ុណ្ណោះនៅពេលឥឡូវនេះ បើប្រៀបធៀបនឹងឆ្នាំមុនក្នុងពេលនេះ មានចំនួន ៣០០គីឡូក្រាម) បានដែរឬទេ?
- តើអំណាចទិញរបស់ប្រជាជន (ពួកគេមានប្រាក់សំរាប់ទិញស្បៀង) ដែលទទួលរងផលប៉ះពាល់មានការប្រែប្រួលដូចម្តេចដែរ? ហើយបណ្តាលមកពីមូលហេតុអ្វី? (សូមបញ្ជាក់ទាំងឥទ្ធិពលនៃការងារ និងអតិផរណា) ។ ក្រុម និងបុគ្គលណាខ្លះ ដែលទទួលរងផលប៉ះពាល់ច្រើន/ច្រើនបំផុត និង តិច/តិចបំផុត? តើមានផលប៉ះពាល់ខុសៗគ្នា ដោយផ្អែកលើយេនឌ័រដែរឬទេ?
- តើយុទ្ធសាស្ត្រទាំងនេះ គ្រួសារប្រើប្រាស់ដើម្បីធ្វើឱ្យមានធិរន្តរភាពស្បៀងដែរឬទេ? តើមានវិសមភាពយេនឌ័រនៅក្នុងយុទ្ធសាស្ត្រស្បៀង និងជោគជ័យ ព្រមទាំងនិន្តរភាពរបស់ស្បៀងដែរឬទេ?

អាហារូបត្ថម្ភ

- តើមានព័ត៌មានអ្វីខ្លះដែលទាក់ទងនឹងស្ថានភាពអាហារូបត្ថម្ភនាពេលបច្ចុប្បន្ន? (ឧទាហរណ៍: ការអង្កេតអាហារូបត្ថម្ភនាពេលថ្មីៗនេះ ទិន្នន័យអង្កេតអាហារូបត្ថម្ភដែលទទួលបានពីគ្លីនិកគាំពារមាតា និងទារក/SFCs/TFCsសន្តិសុខស្បៀង និងពិតមានដំបូង) ។ សូមដកស្រង់ដោយផ្ទាល់នូវទិន្នន័យ សង្ខេប រួចបញ្ចូលបន្ថែម ឬបញ្ជូនទិន្នន័យ ។
- តើមានវិសមភាពយេនឌ័រចំពោះលទ្ធភាពទទួលបាន និងការប្រើប្រាស់ស្បៀងដែរឬទេ? តើការវិភាគទិន្នន័យបានបង្ហាញពីវិសមភាពអាហារូបត្ថម្ភតាមយេនឌ័រដែរឬទេ?
- តើមានព័ត៌មានអ្វីខ្លះ ដែលទាក់ទងនឹងស្ថានភាពអាហារូបត្ថម្ភនៅក្នុងតំបន់នេះ មុនពេលកើតមានវិបត្តិ? តើមានបញ្ហាអាហារូបត្ថម្ភដែរឬទេ? តើបញ្ហាណាខ្លះដែលមានលក្ខណៈធ្ងន់ធ្ងរនាពេលបច្ចុប្បន្ននេះ? (ដូចជា: កង្វះខាតមីក្រូសារធាតុ និង បុព្វហេតុចំបង) ស្ថានភាពប្រែប្រួលនៃអាហារូបត្ថម្ភ ទៅតាមរដូវ និងសុខភាព?
- តើរចនាសម្ព័ន្ធផ្លូវការ និងមិនផ្លូវការ នៅក្នុងមូលដ្ឋានអ្វីខ្លះ ដែលត្រូវបង្កើតឡើងតាមរយៈអន្តរាគមន៍អាចត្រូវបានប្រើប្រាស់?
- តើគេបានធ្វើអ្វីខ្លះហើយក្នុងការដោះស្រាយស្ថានភាពបច្ចុប្បន្ននេះ?

បញ្ហាផ្សេងៗ (សួរសំណួរទាំងនេះដោយផ្អែកលើកាលៈទេសៈ)

- តើគ្រួសារមានឧបករណ៍ចំអិនអាហារដែរឬទេ?
- តើតាមធម្មតាគេប្រើប្រាស់ប្រេងឥន្ធនៈប្រភេទណាសំរាប់ចំអិនអាហារ? តើការផ្គត់ផ្គង់ប្រេងឥន្ធនៈធ្វើឡើងដោយរបៀបណា?
- តើទំនៀមទំលាប់ចិញ្ចឹមទារកនៅក្នុងចំនោមសហគមន៍ ដែលទទួលផលប៉ះពាល់មានអ្វីខ្លះ? (ក្នុងនោះមានទាំងសេចក្តីលំអិតអំពីការបំបៅកូនដោយទឹកដោះ ទំនៀមទំលាប់ផ្តាច់ដោះការតបចំណី)។

III. ទំរង់របាយការណ៍ផ្សេងៗសំរាប់ប្រើប្រាស់ក្នុងការវាយតំលៃលើការខូចខាតនិងសេចក្តីត្រូវការ

- ឧបសម្ព័ន្ធ ១: របាយការណ៍ ស្តីពីតាមដានត្រួតពិនិត្យស្ថានភាពគ្រោះภัយ
- ឧបសម្ព័ន្ធ ២: របាយការណ៍ បន្ទាន់
- ឧបសម្ព័ន្ធ ៣: របាយការណ៍ ដំបូង
- ឧបសម្ព័ន្ធ ៤: របាយការណ៍ស្តីពីការខូចខាតនិងសេចក្តីត្រូវការនៅថ្នាក់ខេត្ត
- ឧបសម្ព័ន្ធ ៥: របាយការណ៍បស្តីពីការខូចខាតនិងសេចក្តីត្រូវការនៅថ្នាក់ស្រុក
- ឧបសម្ព័ន្ធ ៦: របាយការណ៍ខេត្តលំអិត ស្តីពីការខូចខាតនិងសេចក្តីត្រូវការទាក់ទងនឹងស្បៀងនិងកសិកម្ម
- ឧបសម្ព័ន្ធ ៧: របាយការណ៍ជាតិ ស្តីពីការខូចខាតនិងសេចក្តីត្រូវការសំរាប់ឆ្លើយតប
- ឧបសម្ព័ន្ធ ៨: របាយការណ៍ជាតិលំអិត ស្តីពីការខូចខាតនិងសេចក្តីត្រូវការទាក់ទងនឹងស្បៀងនិងកសិកម្ម

IV. ឯកសារយោង

- ឯកសារផ្សព្វផ្សាយ ស្តីពីការវាយតំលៃគ្រោះមហន្តរាយ ការខូចខាត និង តំរូវការ របស់គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ(NCDM), ហ្ណុមពិន្ធ ក្នុងខែកញ្ញា ឆ្នាំ២០០៣។

របាយការណ៍តាមដានត្រួតពិនិត្យគ្រោះภัយ

Risk Monitoring Report (RMR)

កាលបរិច្ឆេទនៃរបាយការណ៍: ថ្ងៃ 5 / ខែ 8 / ឆ្នាំ 2003

ឈ្មោះខេត្ត: _____ លេខកូដ _____

ភាពអាសន្ន/គ្រោះមហន្តរាយ ដែលអាចកើតមាន (សូមពិនិត្យ)		ទីតាំងដែលអាចកើត	
		ឈ្មោះឃុំ	ឈ្មោះស្រុក
គ្រោះទឹកជំនន់	☐		
ខ្យល់ព្យុះ	☐		
បាក់ស្រុតដី	☐		
គ្រោះរាំងស្ងួត	☐		
គ្រោះអគ្គីភ័យ	☐		
គ្រោះមហន្តរាយផ្សេងៗ	☐		

អាចមានឥទ្ធិពលបង្ករឱ្យ ប្រជាជន		ឈ្មោះឃុំ	ឈ្មោះស្រុក
ស្លាប់	☐		
របួស	☐		
មានជំងឺ	☐		
ខ្វះខាតស្បៀង	☐		
ខ្វះអាហារូបត្ថម្ភ	☐		
ខ្វះខាតជំរករស់នៅ	☐		

កសិកម្ម: ប្រភេទដាក់លាក់ដែលអាចទទួលការប៉ះពាល់		ឈ្មោះឃុំ	ឈ្មោះស្រុក
ស្រូវ	☐		
ពោត	☐		
ឈើហូបផ្លែ	☐		
បន្លែ	☐		
សត្វពាហនៈ	☐		
សត្វចិញ្ចឹម	☐		
ផល ឬ របរនេសាទ	☐		
ផ្សេងៗ	☐		

សេវាកម្មជាចម្បងនិងធ្យាបាយសំរបសំរួលផ្សេងៗ ដែលអាចប៉ះពាល់

		ឈ្មោះឃុំ	ឈ្មោះស្រុក
សាលារៀន	☐		
មណ្ឌលសុខភាព	☐		
មន្ទីរពេទ្យ	☐		
វត្ត	☐		
ប្រភពទឹក	☐		
ផ្សេងៗ	☐		

សេវាសំខាន់

		ឈ្មោះឃុំ	ឈ្មោះស្រុក
អាគាររដ្ឋាភិបាល	☐		
ផ្ទះវិទ្ធល់	☐		
លូទឹក	☐		
ស្ពាន	☐		
សេរ៉ាទំនាក់ទំនង	☐		
ថាមពលអគ្គិសនី	☐		
ផ្សេងៗ	☐		

សកម្មភាពស្នើឡើងដើម្បីធ្វើការកាត់បន្ថយគ្រោះภัយ ឬឥទ្ធិពលដែលអាចកើតមាន

-
-
-
-
-

<u>គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយខេត្ត</u>

ប្រធាន

<u>កំណត់ពន្យល់</u>

១. របាយការណ៍ពិនិត្យតាមដានហានិภัយ (RMR) ត្រូវធ្វើដាក់ជូនតែមួយដងគត់ទៅឱ្យ NCDM ដោយ PCDM

២. គោលបំណងនៃរបាយការពិនិត្យតាមដានស្ថានភាពហានិภัយ គឺដើម្បីរាយការណ៍ថា ភាពអាសន្ន/គ្រោះមហន្តរាយណាមួយអាចនឹងកើតឡើង ដោយសារតែមាន ការកើនឡើងនូវសក្តានុភូតុនៃមុខសញ្ញាបង្ករគ្រោះមហន្តរាយ (ទឹកជំនន់ ការរាំងស្ងួត អគ្គីภัយ ការបាក់ស្រុតដី ។ល។) ដែលអាចប៉ះពាល់ដល់ប្រជាជន ជីវភាពរស់នៅ ទ្រព្យសម្បត្តិ និងបរិស្ថាន ។

៣. លេខកូដខេត្តរៀបតាមលំដាប់អក្សរឡាតាំង ឧ. ខេត្តបន្ទាយមានជ័យ KH01ខេត្តកំពង់ចាម លេខកូដ KH03 ។ ល ។

គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ

របាយការណ៍បន្ទាន់

Flash SOS Report

កាលបរិច្ឆេទនៃរបាយការណ៍: ថ្ងៃ / ខែ / ឆ្នាំ

ឈ្មោះស្រុក: លេខកូដ

ឈ្មោះខេត្ត: លេខកូដ

១.ស្ថានភាព

កាលបរិច្ឆេទ និងម៉ោងពេល នៃគ្រោះអាសន្ន: ថ្ងៃ / ខែ / ឆ្នាំ

បុព្វហេតុបង្កឱ្យមានគ្រោះអាសន្ន		**តំបន់ដែលរងគ្រោះ** ឃុំ	ស្រុក
ទឹកជំនន់	☐		
ខ្យល់ព្យុះ	☐		
ការបាក់ស្រុតដី	☐		
គ្រោះរាំងស្ងួត	☐		
អគ្គីភ័យ	☐		
ផ្សេងៗ	☐		

២. ការប៉ាន់ប្រមាណលើឥទ្ធិពលក្នុងតំបន់ជួប

	ចំនួនដែលបានជួប
ស្លាប់	
របួស	
បាត់ខ្លួន	
ជំរកបណ្តោះអាសន្នត្រូវការ	
សំភារៈប្រើប្រាស់ក្នុងគ្រួសារត្រូវការ	
ស្បៀងអាហារត្រូវការ	
ការផ្គត់ផ្គង់ទឹកស្អាតត្រូវការ	
សេវាអនាម័យត្រូវការ	

៣. ការប៉ាន់ប្រមាណក្នុងតំបន់ជួប អំពីសេចក្តីត្រូវការចំនួយពីខាងក្រៅ (ក្នុងសណ្ឋា ✓)

	ជាអាទិភាពឬទេ?			
ការរុករក និងសង្គ្រោះ	បាទ ☐	ទេ ☐	ភ្លាមៗ ☐	ក្រោយ ☐
ការជម្លៀស	បាទ ☐	ទេ ☐	ភ្លាមៗ ☐	ក្រោយ ☐
ការព្យាបាល និងថែទាំសុខភាព	បាទ ☐	ទេ ☐	ភ្លាមៗ ☐	ក្រោយ ☐
ជំរកបណ្តោះអាសន្ន	បាទ ☐	ទេ ☐	ភ្លាមៗ ☐	ក្រោយ ☐

សំភារៈប្រើប្រាស់ក្នុងគ្រួសារ	បាទ ☐	ទេ ☐	កំរិតខ្ពស់ ☐	កំរិតទាប ☐
ស្បៀងអាហារ	បាទ ☐	ទេ ☐	កំរិតខ្ពស់ ☐	កំរិតទាប ☐
ទឹក	បាទ ☐	ទេ ☐	កំរិតខ្ពស់ ☐	កំរិតទាប ☐
